ក្រសួងអប់រំ យុវជន និងកីឡា
Misnistry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ឥរិយាបថគ្រូបង្រៀនបឋមសិក្សា ចំពោះអធិការកិច្ច លើការបង្រៀន និងរៀន ក្នុងខេត្តកំពង់ធំ

ដោយ/**By**

**នៅ ចាន់មករា**

**NEOU CHANMAKARA**

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ ជំនាន់ទី៧**

**ឯកទេសៈ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៨ - ២០២០**

ក្រសួងអប់រំ យុវជន និងកីឡា

Misnistry of Education, Youth and Sport

វិទ្ ... ប់រំ

National Institute of Education

# និក្ខេបបទ

## ឥរិយាបថគ្រូបង្រៀនបឋមសិក្សា ចំពោះអធិការកិច្ច លើការបង្រៀន និងរៀន ក្នុងខេត្តកំពង់ធំ

ដោយ/By

**នៅ ចាន់មករា / NEOU CHANMAKARA**

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ ជំនាន់ទី៧

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៨ ◆ ២០២០

គ្រូដឹកនាំបង្គោល៖ បណ្ឌិត អាន វ៉ប្រាថ

គ្រូដឹកនាំរង៖ លោក លឹម វ៉ាន់

# **សេចក្តីប្រកាសអះអាងរបស់បេក្ខជន**

ខ្ញុំបាទសូមធ្វើការបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា "**ឥរិយាបថគ្រូបង្រៀនបឋមសិក្សាចំពោះអធិការកិច្ចលើការបង្រៀន និងរៀននៅក្នុងខេត្តកំពង់ធំ**" សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុងប្រាកដមែន។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាបានសិក្សាស្រាវជ្រាវចងក្រងដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន។

ថ្ងៃ.........................ខែ.........ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី...... ខែ........... ឆ្នាំ២០២០

**ហត្ថលេខា**

**នៅ ចាន់មករា**

# លិខិតបញ្ជាក់

**បណ្ឌិត អាន វ៉ុប្រាជ** ជាគ្រូដឹកនាំបង្គោល

**លោក លឹម វ៉ាន់** ជាគ្រូដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **នៅ ចាន់មករា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**ឥរិយាបថគ្រូបង្រៀនបឋមសិក្សា ចំពោះអធិការកិច្ចលើការបង្រៀន និងរៀន នៅក្នុងខេត្តកំពង់ធំ** " ពិតប្រាកដមែន។

ថ្ងៃ.......................ខែ...............ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី...... ខែ ...... ឆ្នាំ២០២០

.................................. ..................................

**បណ្ឌិត អាន វ៉ុប្រាជ** **លោក លឹម វ៉ាន់**

គ្រូឧទ្ទេស អនុប្រធានដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ

វិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានជាតិអប់រំ

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៥៣០៧ អយក.ឧទន

(ការសម្ងាត់)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។

-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារសារណា** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯ.ឧបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | អនុប្រធាន |
| ៣- ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៤-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោកបណ្ឌិត | នូវ វីរៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោកបណ្ឌិត | អាន វុទ្ធប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកស្រី | នូ ចន្នី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារសារណា របស់និស្សិតពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ច័ន្ទ ៣ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០២០
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ -ឯកសារ វជអ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **នៅ ចាន់មករា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៃវិទ្យាស្ថានជាតិអប់រំ ឆ្នាំសិក្សា ២០១៨ - ២០២០ ពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានបញ្ចប់ការស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដោយជោគជ័យ។ ជាមួយលទ្ធផលដ៏ត្រចេះត្រចង់នេះ មិនអាចកាត់ផ្តាច់បានពីការខិតខំប្រឹងប្រែង និងការជួយជ្រោមជ្រែងគាំទ្រ និងយកចិត្តទុកដាក់ពីលោកឪពុក អ្នកម្តាយ លោកគ្រូ/អ្នកគ្រូ បងប្អូនប្រុសស្រី មិត្តភក្តិបានឡើយ។

ជាបឋមខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះ **លោកឪពុក នៅ ប៊ុនណា អ្នកម្តាយ ស្រី ប៉ូលីន** ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ទំនុកបំរុងដល់រូបកូនឱ្យបានទទួលការសិក្សារហូតរូបកូនមានថ្ងៃនេះ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់អ៊ំស្រី ប្អូនប្រុស ប្អូនស្រីជាទីស្រឡាញ់ដែលតែងតែគាំទ្រ ផ្តល់កម្លាំងចិត្ត និងទំនុកបំរុងដល់រូបខ្ញុំដើម្បីមានលទ្ធភាពក្នុងការបន្តការសិក្សារហូតពេលនេះ។

ខ្ញុំបាទក៏សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **លោកបណ្ឌិត អាន វ៉ូប្រាវ** ជាគ្រូដឹកនាំបង្គោលលើការសរសេរនិក្ខេបបទ ដែលតែងតែចំណាយពេលវេលាដ៏មានតម្លៃដើម្បីជួយពន្យល់ណែនាំបង្ហាញផ្លូវ កែលម្អជាច្រើនលើកច្រើនសារ ធ្វើឱ្យការសិក្សាស្រាវជ្រាវរបស់ខ្ញុំទទួលបានជោគជ័យ និងបញ្ចប់ប្រកបដោយភាពរលូន។ ខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់ **លោក លឹម វ៉ាន់** ជាគ្រូដឹកនាំរង ដែលបានជួយសម្រួលក្នុងការសរសេរនិក្ខេបបទដល់រូបខ្ញុំបាទ។

ខ្ញុំបាទសូមថ្លែងអំណរគុណដល់ ឯកឧត្តមនាយក លោកនាយករង លោក/លោកស្រី សាស្ត្រាចារ្យនៃវិទ្យាស្ថានជាតិអប់រំ និងថ្នាក់ដឹកនាំក្រសួងអប់រំយុវជន និងកីឡា ដែលបានប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តក្នុងការបង្រៀនដល់ក្រុមនិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ គ្រប់គ្រងអប់រំជំនាន់ទី៧។ ខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់លោកគ្រូ/អ្នកគ្រូ រាមច្បង និងមិត្តរួមជំនាន់ទាំងអស់ ដែលបានផ្តល់កម្លាំងចិត្ត និងចែករំលែកចំណេះដឹង

ឯកសារនានាដល់រូបខ្ញុំ ហើយក៏សូមអរគុណចំពោះរាមច្បងនៅក្នុងការិយាល័យអធិការកិច្ចដែលបានខិតខំប្រឹងប្រែងជួយពិនិត្យ និងកែលម្អអក្ខរាវិរុទ្ធលើការសរសេរនិក្ខេបបទនេះ។

ខ្ញុំបាទសូមថ្លែងអំណរគុណដល់មន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ធំ ការិយាល័យអធិការកិច្ច លោកនាយក លោកស្រីនាយិកា លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សនៅតាមសាលាគោលដៅទាំងអស់ ដែលបានអនុញ្ញាត និងចូលរួមសហការធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។

ជាទីបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធពរជ័យ ជូនចំពោះឯកឧត្តម លោក/លោកស្រីសាស្ត្រាចារ្យ លោកលោកស្រី នាងកញ្ញា រាមច្បង និងមិត្តរួមជំនាន់ទាំងអស់ សូមមានសុខភាពល្អបរិបូណ៌ កម្លាំងពលំមាំមួនប្រកបការងារទទួលបានជោគជ័យគ្រប់ភារកិច្ច ព្រមទាំងទទួលបាននូវព្រះពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និង ពលៈកុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ !

# មូលន័យសង្ខេប

ការអប់រំបានដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្សប្រកបដោយចំណេះដឹង ជំនាញមានសមត្ថភាពខ្ពស់ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច និងកសាងសង្គមជាតិឱ្យបានរឹងមាំ។ ដើម្បីឱ្យការអប់រំមួយមានការរីកចម្រើន និងមានគុណភាពគេចាំបាច់ត្រូវគិតគូរទៅលើការធ្វើអធិការកិច្ច។ ក្នុងនយោបាយចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចក្នុងផែនការយុទ្ធសាស្ត្ររបស់ក្រសួងអប់រំ យុវជន និងកីឡា បានចាត់ទុកការងារអធិការកិច្ច ជាកិច្ចការសំខាន់មួយដើម្បីត្រួតពិនិត្យឡើងវិញ នូវការអនុវត្តការងាររបស់សាលារៀន និងបានរួមចំណែកក្នុងការពង្រឹងគុណភាពអប់រំនៅតាមសាលារៀន។ អធិការកិច្ចបានរួមចំណែកក្នុងកែលម្អសាលារៀនតាមរយៈការផ្តល់អនុសាសន៍ទៅដល់នាយក/នាយិកា និងគ្រូបង្រៀន ប៉ុន្តែទាំងក្នុងរបាយការណ៍វឌ្ឍនភាពនៃការិយាល័យអធិការកិច្ច ក៏ដូចក្នុងរបាយការណ៍សាលារៀនតាមកាលកំណត់ក្តី មិនបានបង្ហាញពីប្រតិកម្មរបស់នាយក និងគ្រូបង្រៀន ក៏ដូចអ្នកពាក់ព័ន្ធនានាមកលើការងារអធិការកិច្ចឡើយ ថាពួកគាត់យល់ស្របទទួលស្គាល់ ប្រឆាំង ឬមិនយកចិត្តទុកដាក់លើកិច្ចការដែលក្រុមអធិការបានធ្វើនោះទេ។ ការមិនបានបង្ហាញនេះ មិនមានន័យថាគ្រូបង្រៀនពេញចិត្តចំពោះការងារអធិការកិច្ចឡើយ ព្រោះភាពជាក់ស្តែងគ្រូបង្រៀនតែងបង្ហាញការយល់ឃើញផ្សេងៗគ្នាចំពោះអធិការកិច្ច។ ដោយសារបែបនេះហើយ ទើបមានការសិក្សាស្រាវជ្រាវលើប្រធានបទ ឥរិយាបថគ្រូបង្រៀនបឋមសិក្សា ចំពោះអធិការកិច្ចលើការបង្រៀន និងរៀន នៅខេត្តកំពង់ធំ ក្នុងគោលបំណងស្វែងយល់ពី ឥរិយាបថគ្រូបង្រៀនសាលាបឋមសិក្សា ចំពោះអធិការកិច្ចលើការបង្រៀន និងរៀន និងស្វែងរកភាពខុសគ្នានៃឥរិយាបថគ្រូបង្រៀនបឋមសិក្សា ចំពោះអធិការកិច្ចលើការបង្រៀន និងរៀនដោយផ្អែកលើទីតាំងសាលារៀន និងបទពិសោធន៍លើការបង្រៀន។ សំណួរស្រាវជ្រាវនៃប្រធានបទនេះមានពីរគឺ (១) តើគ្រូបង្រៀនបឋមសិក្សា មានឥរិយាបថវិជ្ជមាន ឬអវិជ្ជមានចំពោះអធិការកិច្ច លើការបង្រៀន និងរៀន? និង (២) តើឥរិយាបថរបស់គ្រូបង្រៀន ចំពោះអធិការកិច្ចមានភាពខុសគ្នាឬទេ បើផ្អែកលើទីតាំងសាលារៀន និងបទពិសោធន៍លើការបង្រៀន?

ការស្រាវជ្រាវនេះបានធ្វើឡើងនៅតាមសាលារៀនបឋមសិក្សាចំនួន១៣ នៅក្នុងក្រុង/ស្រុកចំនួន០៣ ដោយបានប្រើប្រាស់កម្រងសំណួរបែបបរិមាណវិស័យ ចំនួនបីប្រភេទសម្រាប់ គ្រូបង្រៀន នាយក/នាយិកា និងសិស្សពីថ្នាក់ទី៤ ដល់ទី៦។ ការប្រមូលទិន្នន័យធ្វើឡើងក្នុងរយៈពេល ០៤សប្តាហ៍ ចាប់ពីថ្ងៃទី១៧ ខែកក្កដា ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ មានគ្រូបង្រៀន៩៤នាក់ នាយក/នាយិកា១៣នាក់ និងសិស្ស១៧៤នាក់បានចូលរួមបំពេញកម្រងសំណួរ។ ការវិភាគទិន្នន័យធ្វើឡើងដោយការគណនា ប្រេកង់ ភាគរយ និងតម្លៃមធ្យម (Mean)។

លទ្ធផលនៃការស្រាវជ្រាវបានបង្ហាញថាគ្រូបង្រៀនភាគច្រើនមានឥរិយាបថវិជ្ជមានចំពោះដំណើរការអធិការកិច្ច ទាំងមូលលើការបង្រៀន និងរៀនមានមធ្យមភាគពិន្ទុ 4.18។ ក្នុងដំណាក់កាលទាំងបីនៃដំណើរការអធិការកិច្ចលើការបង្រៀន និងរៀន គ្រូបង្រៀនមានការពេញចិត្ត លើដំណាក់កាលទី២ ″អំឡុងពេលអធិការកិច្ច″ ទៅលើសកម្មភាពអធិការក្នុងពេលអធិការកិច្ចថ្នាក់រៀន និងពេលសម្ភាស ច្រើនជាងដំណាក់កាលទី១″មុនពេលអធិការកិច្ច″ និងដំណាក់កាលទី២″ក្រោយពេលអធិការកិច្ច″។ លទ្ធផលនេះ មានន័យថាគ្រូបង្រៀនភាគច្រើន មានការចូលរួមសហការជាមួយក្រុមអធិការកិច្ច និងយកចិត្តទុកដាក់លើសកម្មភាពបង្រៀន និងរៀន ច្រើនក្នុងពេលក្រុមអធិការមានវត្តមាននៅក្នុងសាលារៀន។ បើធៀបនឹង ទីតាំងសាលារៀន គ្រូបង្រៀននៅតំបន់ជនបទ មានឥរិយាបថវិជ្ជមាន កម្រិតខ្ពស់ជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជន គ្រប់ដំណាក់កាលនៃអធិការកិច្ចលើមធ្យមភាគពិន្ទុ 4.32 ធៀបនឹង 4.06។ បើធៀបទៅនឹង រយៈពេលបំពេញការងារជាគ្រូបង្រៀន ឃើញថាគ្រូបង្រៀនមានបទពិសោធន៍តិចជាងមួយឆ្នាំមានឥរិយាបថវិជ្ជមានខ្ពស់ជាងគេនៅគ្រប់ដំណាក់កាលនៃការធ្វើអធិការកិច្ចមានមធ្យមភាគរួម4.30។ ចំណែកឯគ្រូបង្រៀនមានបទពិសោធន៍បង្រៀនលើសពី១០ឆ្នាំមានឥរិយាបថវិជ្ជមានកម្រិតទាបជាងគេ មានមធ្យមភាគ 4.05។

# Abstract

Education has played an important role in the development of human resources with knowledge, skills and high ability to develop the economy and build a strong society. In order to make improvement of standards and quality of education, it is necessary to consider inspections. In the rectangular policy of the Royal Government of Cambodia, as well as in the strategy plan of the Ministry of Education, Youth and Sports, inspection work is considered an important task to review the performance of schools and contribute to improving the quality of education in schools. Inspections have contributed to the improvement of the school by making recommendations to principals and teachers, but neither the inspectors 'progress report nor the school inspection report does reflect the principal or teachers' reaction, whether they agree, accepte, oppose or do not pay attention to the inspection. Not showing this, it doesn't mean teachers are satisfied with the inspection because in reality, teachers often express different views on inspection. Due to this, a research study was conducted on the topic of primary school teachers' attitudes towards inspection on teaching and learning in Kampong Thom province in order to understand the attitudes of primary school teachers towards inspection on teaching and learning and to find differences of attitudes. based on school location and teaching experience. There are two research questions on this topic: (1) Do primary school teachers have a positive or negative attitude towards teaching and learning inspections? And (2) do teachers' attitudes toward inspection differ based on school location and teaching experience?

The research was conducted in 13 primary schools in 3 cities / districts, using three quantitative questionnaires for teachers, principals and students from 4th to 6th grade. Data collection was conducted in 4 weeks from July 17 to August 10, 2020. 94 teachers, 13 principals and 174 students completed the questionnaire. Data analysis was performed by calculating frequency, percentage and mean.

The results showed that most of the teachers had positive attitude towards the whole inspection process on teaching and learning with an average score of 4.18. In all three phases of the teaching and learning inspection process, teachers were more satisfied with the second phase “during inspection” on inspector activities during classroom inspections and interviews than in the first phase, “pre-inspection” and Second, "after-inspection." This result means that most teachers are involved with the inspection team and pay more attention to teaching and learning activities while the inspectors are present in the school. Compared to school locations, teachers in rural areas had a higher positive attitude than teachers in urban areas at all stages of the inspection, with an average

score of 4.32 compared to 4.06. Based on teaching experience, teachers with less than a year of experience had the highest positive attitude toward inspection, with an overall average of 4.30. And teachers with more than 10 years of teaching experience had the lowest level of positive attitude, with an average score of 4.05.

# មាតិកា


**ជំពូកទី១ សេចក្តីផ្តើម** ........ 1

១.១ សាវតារ ........ 1

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ 3

១.៣ គោលបំណងនៃការស្រាវជ្រាវ ........ 6

១.៤ សំណួរនៃការស្រាវជ្រាវ ........ 7

១.៥ សម្មតិកម្មនៃការស្រាវជ្រាវ ........ 7

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ 7

១.៧ ដែនកំណត់នៃការស្រាវជ្រាវ ........ 8

១.៨ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ 8

**ជំពូកទី២ រំលឹកទ្រឹស្តី** ........ 10

២.១ សាវតារនៃអធិការកិច្ចនៅកម្ពុជា ........ 10

២.១.១ ដើមកំណើតអធិការកិច្ចក្នុងបរិបទពិភពលោក ........ 10

២.១.២ ការសិក្សានៅក្រោមសម័យអាណាព្យាបាលបារាំង ........ 10

២.១.៣ អធិការកិច្ចចាប់ពីឆ្នាំ១៩៤៥ ដល់១៩៧៥ ........ 11

២.១.៤ អធិការកិច្ចកម្ពុជាបច្ចុប្បន្ន ........ 12

២.២ ការងារអធិការកិច្ចលើការបង្រៀន និងរៀនកម្រិតបឋមសិក្សានៅកម្ពុជា ........ 19

២.២.១ និយមន័យ អធិការកិច្ច ........ 19

២.២.២ គោលបំណងអធិការកិច្ច ........ 22

២.២.៣ ភារកិច្ចសំខាន់ៗរបស់អធិការបឋមសិក្សា ........ 26

២.២.៤ វិធីសាស្ត្រអធិការកិច្ច ........ 28

២.២.៥ ដំណើរការអធិការកិច្ច ........ 34

២.៣ ឥរិយាបថ Attitude ........ 36

២.៣.១ និយមន័យ ........ 36

២.៣.២ ភាពផ្សេងៗនៃឥរិយាបថ ........ 38

**ជំពូកទី៣ វិធីសាស្ត្រស្រាវជ្រាវ** ........ 46

៣.១ ព័ត៌មានទូទៅពីគម្រោងស្រាវជ្រាវ ........ 46

៣.២ ទីកន្លែងសិក្សាស្រាវជ្រាវ ........ 46

៣.៣ ក្រុមគោលដៅ ........ 48

៣.៤ ទំហំសំណាក ........ 49

៣.៥ ឧបករណ៍ស្រាវជ្រាវ ........ 51

៣.៥.១ កម្រងសំណួរសម្រាប់គ្រូបង្រៀន ........ 52

៣.៥.២ កម្រងសំណួរសម្រាប់នាយកសាលា ........ 55

៣.៥.៣ កម្រងសំណួរសម្រាប់សិស្ស ........ 57

៣.៦ វិធីសាស្ត្រប្រមូលទិន្នន័យ ........ 58

៣.៧ ដំណើរការក្នុងការប្រមូលទិន្នន័យ ........ 58

៣.៧.១ ព័ត៌មានទូទៅរបស់គ្រូបង្រៀន ........ 60

៣.៧.២ ព័ត៌មានទូទៅអំពីនាយក/នាយិកា ........ 62

៣.៧.៣ ព័ត៌មានទូទៅអំពីសិស្ស ........ 65

៣.៨ ការវិភាគទិន្នន័យ ........ 67

៣.៩ ក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ ....70

៣.១០ ព្រំដែននៃការសិក្សាស្រាវជ្រាវ ....70

**ជំពូកទី៤ លទ្ធផល និងការពិភាក្សា** ....72

៤.១- លទ្ធផល ....73

៤.១.១ ឥរិយាបថគ្រូបង្រៀនបឋមសិក្សា ចំពោះអធិការកិច្ចលើការបង្រៀន និងរៀន ....73

៤.១.១.១ ឥរិយាបថគ្រូបង្រៀន មុនពេលអធិការកិច្ចលើការបង្រៀន និងរៀន ....73

៤.១.១.២ ឥរិយាបថគ្រូបង្រៀន អំឡុងពេលអធិការកិច្ចលើការបង្រៀន និងរៀន ....87

៤.១.១.៣ ឥរិយាបថគ្រូបង្រៀន ក្រោយពេលអធិការកិច្ចលើការបង្រៀន និងរៀន ....100

៤.១.២ ឥរិយាបថគ្រូបង្រៀនបឋមសិក្សា ចំពោះអធិការកិច្ច ផ្អែកលើទីតាំងសាលារៀន ....111

៤.១.២.១ ឥរិយាបថគ្រូបង្រៀននៅតំបន់ជនបទ និងតំបន់ទីប្រជុំជន មុនពេលអធិការកិច្ច ....113

៤.១.២.២ ឥរិយាបថគ្រូបង្រៀននៅតំបន់ជនបទ និងតំបន់ទីប្រជុំជន អំឡុងពេលអធិការកិច្ច ....125

៤.១.២.៣ ឥរិយាបថគ្រូបង្រៀននៅតំបន់ជនបទ និងតំបន់ទីប្រជុំជន ក្រោយពេលអធិការកិច្ច ....135

៤.១.៣ ឥរិយាបថគ្រូបង្រៀនបឋមសិក្សា ចំពោះអធិការកិច្ច ផ្អែកលើបទពិសោធន៍ការងារ ....147

៤.១.៣.១ ឥរិយាបថគ្រូបង្រៀន មុនពេលអធិការកិច្ច ផ្អែកលើបទពិសោធន៍ការងារ ....148

៤.១.៣.២ ឥរិយាបថគ្រូបង្រៀន អំឡុងពេលអធិការកិច្ចផ្អែកលើបទពិសោធន៍ការងារ ....155

៤.១.៣.៣ ឥរិយាបថគ្រូបង្រៀន ក្រោយពេលអធិការកិច្ចផ្អែកលើបទពិសោធន៍ការងារ ....164

៤.២ ការពិភាក្សា ....173

៤.២.១ ការពិភាក្សា ....173

៤.២.២ ការផ្ទៀតផ្ទាត់សម្មតិកម្ម ....179

៤.២.៣ ដែនកំណត់នៃការស្រាវជ្រាវ ....179

**ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងសំណូមពរ** 181

៥.១ សេចក្តីសន្និដ្ឋាន 181

៥.២ សំណូមពរ 184

៥.៣ អនុសាសន៍សម្រាប់ការសិក្សាស្រាវជ្រាវបន្ត 186

**ឯកសារយោង** 187

**បញ្ជីតារាង** 191

**បញ្ជីរូបភាព** 196

**ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធទី១៖ លិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងការសិក្សាស្រាវជ្រាវ

ឧបសម្ព័ន្ធទី២៖ កម្រងសំណួរសម្រាប់គ្រូបង្រៀន នាយក/នាយិកា និងសិស្ស

ឧបសម្ព័ន្ធទី៣៖ កម្រងសំណួរដែលបានបំពេញដោយគ្រូបង្រៀន នាយក/នាយិកា និងសិស្ស

# ជំពូកទី១

# សេចក្តីផ្តើម

# ជំពូកទី១ សេចក្តីផ្តើម

## ១.១ សាវតារ

ការអប់រំបានដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្ស និងជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ប្រទេសនីមួយៗជានិច្ចកាលត្រូវការធនធានមនុស្សដែលមានចំណេះដឹង និងជំនាញប្រកបដោយសមត្ថភាពខ្ពស់ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចក៏ដូចជាកសាងសង្គមជាតិឱ្យបានរឹងមាំ។ ការអប់រំមានតាមគ្រប់រូបភាពទាំងក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ ជាមធ្យោបាយស័ក្តិសិទ្ធិក្នុងការធានាសិទ្ធិសេរីភាព និងសុភមង្គលបុគ្គល គ្រួសារ និងសង្គមដើម្បីឆ្លើយតបនឹងទីផ្សារការងារក្នុងបរិបទថ្មី។ ការអប់រំ មានតាំងពីចាប់កំណើតរហូតដល់វ័យជរា ដើម្បីអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងគុណសម្បទាឱ្យក្លាយជាពលរដ្ឋល្អ និងចេះរស់ជាមួយគ្នាប្រកបដោយសុខុមនៅក្នុងសង្គម(រាជរដ្ឋាភិបាលកម្ពុជា, ២០១៩, ទំព័រ២)។

ការអប់រំប្រកបដោយគុណភាពជាកត្តាសំខាន់បំផុត។ ដើម្បីឲ្យការអប់រំមួយមានការរីកចម្រើន និងមានគុណភាពគេចាំបាច់ត្រូវគិតគូរទៅលើការធ្វើអធិការកិច្ច (Machumu, 2012, ទំព័រ១)។ រាជរដ្ឋាភិបាលកម្ពុជាក្នុងអាណត្តិទី៦ បានដាក់ចេញយុទ្ធសាស្រ្តដំណាក់កាលទី៤ ដោយចាត់ទុកការអភិវឌ្ឍធនធានមនុស្សជាអាទិភាពទី១ ហើយបានចាត់ទុកការធ្វើអធិការកិច្ចជាកិច្ចការសំខាន់ដែលចាំបាច់ធ្វើការពង្រឹង ដើម្បីអភិវឌ្ឍធនធានមនុស្ស។ នៅក្នុងមុំទី១ស្តីពី " ការពង្រឹងគុណភាពអប់រំ វិទ្យាសាស្រ្ត និងបច្ចេកវិទ្យា " នៃយុទ្ធសាស្រ្តចតុកោណ ផ្តោតទៅអាទិភាព៧គឺៈ (១) ការយកចិត្តទុកដាក់លើគ្រូបង្រៀន (២) ការពង្រីកវិសាលភាពសាលារៀនគ្រប់កម្រិត (៣) ការពង្រឹងអធិការកិច្ចគ្រប់ជ្រុងជ្រោយលើការគ្រប់គ្រងសាលារៀន (៤) ការជំរុញការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ (៥) ការអប់រំបំណិនឱ្យស្របតាមទីផ្សារការងារ (៦) ការអភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅគោលគ្រប់ជ្រុងជ្រោយ និង(៧) ការត្រៀមប្រកួតកីឡាស៊ីហ្គេមឆ្នាំ

២០២៣ (រាជរដ្ឋាភិបាលកម្ពុជា, ២០១៨, ទំព័រ២១-២៣)។ ក្រសួងអប់រំ យុវជន និងកីឡា ជាស្ថាប័នស្នូលលើការអភិវឌ្ឍធនធានមនុស្សបានចាត់ទុកអធិការកិច្ចសាលារៀន ជាផ្នែកមួយត្រូវអនុវត្តចាំបាច់ក្នុងការកំណែទម្រង់វិស័យអប់រំ។ ជាក់ស្តែង ក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩ - ២០២៣, ទំព័រ១១-១៣ បានដាក់ចេញនូវសសរស្តម្ភ៥នៃការទម្រង់ការគ្រប់គ្រងអប់រំរួមមានៈ (១)ផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន និងផែនការសកម្មភាពអភិវឌ្ឍបុគ្គលិកអប់រំដោយគ្រោងថវិកាច្បាស់លាស់ (២) ការពិនិត្យតាមដាន និងអធិការកិច្ចសាលារៀន (៣) វង្វាយតម្លៃតម្លៃលទ្ធផលសិក្សា (៤) ការពិនិត្យឡើងវិញកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងកែលម្អហេដ្ឋារចនាសម្ព័ន្ធសាលារៀន (៥)កំណែទម្រង់ឧត្តមសិក្សា។ ក្នុងក្របខណ្ឌសសរស្តម្ភទាំង៥ ក្រសួងអប់រំ យុវជន និងកីឡាក្នុងឆ្នាំ២០១៨ បានអនុវត្តកម្មវិធីកំណែទម្រង់១៥ចំណុច ក្នុងនោះចំណុចទី៥ បានផ្តោតលើការងារអធិការកិច្ច (ក្រសួងអប់រំយុវជននិងកីឡា, ២០១៩, ទំព័រ៥-១០) ដែលរួមមានៈ (១) ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (២) ការពង្រាយគ្រូបង្រៀន (៣) កំណែទម្រង់មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន (៤) ការលើកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន (៥) ការងារអធិការកិច្ច (៦) វង្វាយតម្លៃលទ្ធផលសិក្សា (៧) កំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (៨) កំណែទម្រង់កម្មវិធីសិក្សា និងសៀវភៅសិក្សាគោល (៩) ការសាងសង់អគារ និងការជួសជុល (១០) ការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា (១១) ការលើកកម្ពស់វិស័យកីឡា (១២) ការអនុវត្តផែនការសកម្មភាពគោលនយោបាយយុវជន (១៣) ការអប់រំបច្ចេកទេស (១៤) ការបង្កើតសាលារៀនជំនាន់ថ្មី និង (១៥) ការរៀបចំគន្លងអាជីព និងការបណ្តុះបណ្តាលនាយកសាលា។

ទាំងក្នុងគោលនយោបាយចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចក្នុងផែនការយុទ្ធសាស្ត្ររបស់ក្រសួងអប់រំ យុវជន និងកីឡា បានចាត់ទុកការងារអធិការកិច្ច ជាកិច្ចការសំខាន់មួយ និងបានផ្តោតការយកចិត្តទុកដាក់លើការងារនេះផងដែរ ដើម្បីត្រួតពិនិត្យឡើងវិញនៃការអនុវត្តការងាររបស់សាលារៀន។ ការធ្វើអធិការកិច្ចសាលារៀន គឺជាយន្តការត្រួតពិនិត្យ និងតាមដាន ថាតើសាលារៀនបានសម្រេចតម្រូវការរបស់ខ្លួន

ត្រឹមកម្រិតណា។ អធិការកិច្ចក៏អាចវាយតម្លៃផងដែរ ថាតើសាលារៀនអាចសម្រេចបានទំនួលខុសត្រូវរបស់ខ្លួនទាក់ទងនឹងគោលការណ៍ទាំងឡាយ ដែលមានចែងក្នុងច្បាប់ស្តីពីការអប់រំបានត្រឹមកម្រិតណា។ អធិការកិច្ចត្រូវធ្វើការវាយតម្លៃថា តើសកម្មភាពអប់រំដែលសាលារៀនកំពុងធ្វើទាក់ទងនឹងវត្ថុបំណង និងកម្មវិធីសិក្សាជាតិសម្រេចបានល្អត្រឹមកម្រិតណាហើយ។ អាចនិយាយបានថា ភារកិច្ចសំខាន់បំផុតរបស់អធិការគឺពិនិត្យមើលថាតើសាលារៀនមានប្រព័ន្ធសម្រាប់ធ្វើស្វ័យវាយតម្លៃ និងយុទ្ធសាស្ត្រស្វ័យកែលម្អហើយឬនៅ? *(ក្រសួងអប់រំយុវជន និងកីឡា, ២០១៥, ទំព័រ៩-១០ )*។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

អធិការកិច្ចសាលារៀន បានរួមចំណែកក្នុងការពង្រឹងគុណភាពអប់រំនៅតាមសាលារៀន ហើយការងារនេះបានអនុវត្តផ្ទាល់ជាមួយនាយកសាលា គ្រូបង្រៀន សិស្ស និងសហគមន៍តាមរយៈការសម្ភាស និងពេលផ្តល់ព័ត៌មានត្រលប់។ ប៉ុន្តែទំនាក់ទំនងរវាងគ្រូបង្រៀន និងមន្ត្រីអធិការ ក្នុងអំឡុងពេលធ្វើអធិការកិច្ចសាលារៀន និងក្រោយពេលធ្វើអធិការកិច្ច មិនទាន់មានការបង្ហាញជាក់ច្បាស់នៅឡើយ ដែលទាមទារមានការឱ្យការស្រាវជ្រាវបន្ថែម។ ជាក់ស្តែងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ២០១៩ របស់ការិយាល័យអធិការកិច្ច នៅក្នុងខេត្តកំពង់ធំ បានលើកឡើងពីវឌ្ឍនភាពមួយចំនួនទាក់ទងការអនុវត្តការងារអធិការកិច្ចដូចជា ការចុះអធិការកិច្ចសាលារៀនផ្តោតសំខាន់តែលើការងារផ្នែករដ្ឋបាលនិងផ្នែកបច្ចេកទេស ហើយការចុះអធិការកិច្ចបានត្រួតពិនិត្យតាមដានការអនុវត្តការងារសាលារៀន ដោយសង្កត់ធ្ងន់លើការងារអប់រំ៤ចំណុចៈ (១) ការងារដឹកនាំនិងគ្រប់គ្រង (២) ការបង្រៀន និងរៀន (៣) លទ្ធផលការសិក្សារបស់សិស្ស និង (៤) ស្វ័យវង្វាយតម្លៃសាលារៀន ដើម្បីរកឱ្យឃើញនូវចំណុចខ្លាំង ចំណុចកែលម្អ និងបញ្ហាប្រឈម។ ក្រោយពីចុះអធិការកិច្ចសាលារៀន មន្ត្រីអធិការបានប្រជុំគ្រូបង្រៀន និងផ្តល់អនុសាសន៍លើចំណុចខ្វះខាតដែលត្រូវកែតម្រូវដល់នាយកសាលា និងគ្រូបង្រៀនក្នុងករណីដែលអធិការកិច្ចបានរកឃើញលើការអនុវត្តការងារទាំង៤ចំណុច

របស់សាលារៀននីមួយៗ។ ក្នុងនោះក៏មានបញ្ហាប្រឈមមួយចំនួនដូចជា៖ ក្រុមDTMT[1]ក្រុង/ស្រុកបានធ្វើការអធិការកិច្ចផ្ទៃក្នុងជាមួយសាលារៀនបានតិចតួច ហើយការិយាល័យអប់រំក្រុង/ស្រុក ពុំបានចុះដោយសារថវិកាវិភាគរបស់ក្រុង/ស្រុកមិនទាន់ដំណើរការបានក្នុងការអភិវឌ្ឍសាលារៀន។ សហគមន៍នៅតាមតំបន់ខ្លះមិនទាន់យល់ដឹងច្បាស់ពីកិច្ចសហការល្អជាមួយសាលារៀន និងសហការដើម្បីអភិវឌ្ឍន៍សាលារៀន។ ការិយាល័យអធិការកិច្ចពុំទាន់មានកុំព្យូទ័រលើតុ កុំព្យូទ័រយួរដៃគ្រប់គ្រាន់ ជាហេតុធ្វើឱ្យការធ្វើរបាយការណ៍ចុះអធិការកិច្ចមានការយឺតយ៉ាវក្នុងការផ្តល់ព័ត៌មានត្រឡប់ទៅអ្នកពាក់ព័ន្ធ។ ជារួមក្នុងរបាយការណ៍នេះ បានបង្ហាញពីការរីកចម្រើននៃអនុវត្តការងារអធិការកិច្ចនៅតាមគ្រឹះស្ថានសាធារណៈនានា និងបញ្ហាខ្លះៗដែលប្រឈមទាក់ទងនឹងដំណើរការងារអធិការកិច្ច ប៉ុន្តែរបាយការណ៍នេះមិនបានបង្ហាញពីប្រតិកម្មរបស់នាយក និងគ្រូបង្រៀន ក៏ដូចអ្នកពាក់ព័ន្ធនានាមកលើការងារអធិការកិច្ច ថាពួកគាត់យល់ស្រប ទទួលស្គាល់ ប្រឆាំង ឬមិនយកចិត្តទុកដាក់លើកិច្ចការដែលអធិការបានធ្វើនោះទេ។ ត្រង់ចំណុចនេះ ការិយាល័យអធិការកិច្ចមិនបានឆ្លុះបញ្ចាំងពីសកម្មភាពការងាររបស់ខ្លួន ដោយផ្អែកលើឥរិយាបថគ្រូបង្រៀននៅឡើយទេ។

ទោះបីជាក្នុងរបាយការណ៍អធិការកិច្ចមិនបានបង្ហាញពីឥរិយាបថគ្រូបង្រៀន និងនាយកចំពោះការងារអធិការកិច្ចក៏ដោយ ក្នុងស្ថានភាពជាក់ស្តែងគ្រូបង្រៀនបានបង្ហាញពីឥរិយាបថផ្សេងៗគ្នា ចំពោះការងារអធិការកិច្ច។ បើយោងតាមបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នកស្រាវជ្រាវ ដែលធ្លាប់ធ្វើជាគ្រូបង្រៀនមុខវិជ្ជា រូបវិទ្យា នៅវិទ្យាល័យ ហ៊ុនសែន ភ្នំសន្ទុក រយៈពេល៨ឆ្នាំ ឃើញថានៅពេលដែលមានក្រុមអធិការកិច្ចចុះមកពិនិត្យតាមដានពីដំណើរការសាលារៀនក្នុងឆ្នាំសិក្សា២០១៧-២០១៨ នាយកសាលាបានប្រាប់បុគ្គលិកទាំងអស់ឱ្យប្រុងប្រយ័ត្ន មកបង្រៀនឱ្យទាន់ម៉ោង ចុះហត្ថលេខាលើបញ្ជីវត្តមានឱ្យអស់ និងរៀបចំរដ្ឋបាលគ្រូបង្រៀនឱ្យបានគ្រប់គ្រាន់ដូចជា សៀវភៅពិន្ទុ សៀវភៅវត្តមានសិស្ស កិច្ចតែងការជាដើម។ ជាងនេះទៅទៀត នាយកបានចាត់ចែងឱ្យសិស្សសម្អាតបរិស្ថានសាលារៀនឱ្យស្អាត ស្រោចផ្កា សម្អាតបង្គន់ និង

[1] DTMT: District training monitoring team ក្រុមបំប៉ន និងពិនិត្យតាមដានស្រុក

រំលឹកសិស្សមករៀនឱ្យទាន់ម៉ោង។ ត្រង់ចំណុចនេះបានបង្ហាញថានាយកសាលាមានការយកចិត្តទុកដាក់ច្រើនពីការចុះមកធ្វើអធិការកិច្ចសាលារៀន ប៉ុន្តែគ្រូបង្រៀនមួយចំនួនហាក់មិនបានចាប់អារម្មណ៍ និងមិនបានត្រៀមលក្ខណៈសម្រាប់ការចុះអធិការកិច្ចនោះទេ ព្រោះនៅថ្ងៃចុះអធិការកិច្ច នៅតែមានគ្រូខ្លះមកបង្រៀនមិនទាន់ម៉ោង និងមានគ្រូចំនួនទៀតមិនបានរៀបចំឯកសារផ្ទាល់ខ្លួនឱ្យបានគ្រប់គ្រាន់ឡើយ។ ត្រង់ចំណុចនេះបានបង្ហាញថា គ្រូបង្រៀនមួយចំនួនមានសកម្មភាពខុសគ្នាក្នុងការត្រៀមលក្ខណៈសម្រាប់ការចុះធ្វើអធិការកិច្ចពីខាងក្រៅ។

ម្យ៉ាងទៀតតាមការរយៈបទពិសោធជាមន្ត្រីអធិការអប់រំរយៈពេលពីរខែកន្លងមក អ្នកស្រាវជ្រាវបានមើលឃើញពីឥរិយាបថផ្សេងគ្នារបស់គ្រូបង្រៀន និងនាយកលើការកិច្ចការអធិការកិច្ច។ ជាក់ស្តែង នៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០ មានការចុះអធិការកិច្ចតាមកាលកំណត់នៅសាលាបឋមសិក្សា ប្រម៉ាត់ដី យោងតាមលិខិតឧទ្ទេសនាមលេខ ០៧៩ អយក.កធ.បប។ ក្រោយពេលធ្វើអធិការកិច្ចសាលារៀន ក្រុមអធិការបានប្រជុំជាមួយនាយកសាលា គ្រូបង្រៀន និងសហគមន៍ ដើម្បីផ្តល់ព័ត៌មានត្រឡប់លើលទ្ធផលអធិការកិច្ច អំពីអ្វីជាចំណុចល្អ និងអ្វីជាចំណុចខ្សោយដែលសាលារៀនត្រូវកែលម្អ។ បន្ទាប់ពីបានស្តាប់លទ្ធផលរួចមក នាយកសាលា បានទទួលស្គាល់នូវបញ្ហាដែលសាលារៀនអនុវត្តមានការខ្វះខាត និងទទួលយកអនុសាសន៍ដែលក្រុមអធិការកិច្ចបានផ្តល់ឱ្យ គាត់បាននិយាយ *"ខ្ញុំសូមអរគុណដល់ក្រុមអធិការកិច្ចដែលបានផ្តល់អនុសាសន៍ដើម្បីកែលម្អនូវអ្វីដែលបានរកឃើញនៅសាលារៀនយើងខ្ញុំ ការចុះអធិការកិច្ចនេះគឺចុះមកជួយ មិនមែនចុះមកចាប់កំហុសទេ ហើយបានរកឃើញបញ្ហាច្រើនជាងអ្វីដែលពួកខ្ញុំបានដឹងទៅទៀត ខ្ញុំនឹងខិតខំអនុវត្តតាមអនុសាសន៍ដែលក្រុមអធិការកិច្ចបានផ្តល់ឱ្យ "*។ ប៉ុន្តែគ្រូបង្រៀនហាក់សម្តែងការមិនពេញចេញនូវអ្វីដែលបានរកឃើញនោះទេ ក្នុងនោះគ្រូម្នាក់គាត់បានមានមតិថា " *ក្រុមមន្ត្រីអធិការអប់រំចុះមកអធិការកិច្ចសាលារៀនយើងខ្ញុំ តែមួយថ្ងៃ ចៃដន្យជាពេលដែលពួកខ្ញុំមានធុរៈ ហើយមកបង្រៀនយឺតពេល ហើយក្រុមអធិការកិច្ចបានវិនិច្ឆ័យថាគ្រូនៅសាលារៀននេះមិនគោរពពេលវេលា"* ហើយគ្រូមួយចំនួនទៀតបានព្យាយាមលើកឡើងពីមូលហេតុ

ផ្សេងៗដែលធ្វើឱ្យការបង្រៀនរបស់គាត់មានភាពខ្វះចន្លោះ ដូចជា "*ខ្ញុំជាគ្រូបង្រៀនថ្នាក់ទី៤ ហើយខ្ញុំជាគណនេយ្យរបស់សាលារៀន រាល់កិច្ចបញ្ជីការទាក់ទងនឹងការប្រើប្រាស់ជាមួយកុំព្យូទ័រ ខ្ញុំជាអ្នកធ្វើ ដោយសារនាយកគាត់មិនចេះកុំព្យូទ័រទេ ដូចនេះការបង្រៀនរបស់ខ្ញុំមានភាពធូកល្វែងខ្លះ ជាពិសេសនៅពេលថ្នាក់ស្រុកថ្នាក់ខេត្តប្រញាប់ឯកសារសាលារៀនផ្សេងៗ*"។ ត្រង់ចំណុចនេះស្តែងថា ទាំងនាយកសាលា ទាំងគ្រូបង្រៀនយល់ឃើញផ្សេងគ្នាពីអ្វីដែលក្រុមអធិការកិច្ចបានរកឃើញ និងគ្រូបង្រៀនបានបកស្រាយពីមូលហេតុខាងក្រៅដែលគាត់បានអនុវត្តការងារបង្រៀនខ្វះចន្លោះ ទោះបីគាត់ទទួលស្គាល់លើបញ្ហានោះក៏ដោយ។

សរុបមកដោយមើលឃើញពីឥរិយាបថផ្សេងគ្នាមួយចំនួន របស់គ្រូបង្រៀនលើការងារអធិការកិច្ច និងដោយសារអ្នកស្រាវជ្រាវមិនទាន់បានរកឃើញការស្រាវជ្រាវជាក់លាក់ណាមួយ ដែលបង្ហាញអំពីឥរិយាបថរបស់គ្រូបង្រៀនចំពោះអធិការកិច្ចនៅឡើយ ទើបបានជាអ្នកស្រាវជ្រាវ លើកយកប្រធានបទ " ឥរិយាបថរបស់គ្រូបង្រៀនបឋមសិក្សា ចំពោះការងារអធិការកិច្ច លើការបង្រៀន និងរៀននៅក្នុងខេត្តកំពង់ធំ" មកធ្វើការសិក្សាស្រាវជ្រាវ។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានគោលបំណងសំខាន់ដូចខាងក្រោម៖

១. ស្វែងយល់ពីឥរិយាបថរបស់គ្រូបង្រៀនបឋមសិក្សា ចំពោះការងារអធិការកិច្ចសាលារៀន លើការបង្រៀននិងរៀន

២. កំណត់ពីឥរិយាបថផ្សេងគ្នារវាងគ្រូបង្រៀន ចំពោះអធិការកិច្ចលើការបង្រៀន និងរៀនដោយផ្អែកលើ៖

ក. ទីតាំងសាលារៀន

ខ. បទពិសោធន៍លើការបង្រៀន

## ១.៤ សំណួរនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបនឹងប្រធានបទខាងលើគឺ ឥរិយាបថរបស់គ្រូបង្រៀនបឋមសិក្សា ចំពោះការងារអធិការកិច្ចនោះ មានសំណួរសំខាន់ៗដូចខាងក្រោម៖

១. តើគ្រូបង្រៀនបឋមសិក្សា មានឥរិយាបថវិជ្ជមាន ឬអវិជ្ជមានចំពោះអធិការកិច្ច លើការបង្រៀន និងរៀន?

២. តើឥរិយាបថរបស់គ្រូបង្រៀន ចំពោះអធិការកិច្ចមានភាពខុសគ្នាឬទេ ? ដោយផ្អែកលើ៖

ក. ទីតាំងសាលារៀន

ខ. បទពិសោធន៍លើការបង្រៀន

## ១.៥ សម្មតិកម្មនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវ លើប្រធានបទខាងលើនឹងត្រូវស្រាយបញ្ជាក់ដោយប្រើសម្មតិកម្មបីគឺ៖

១. គ្រូបង្រៀននៅបឋមសិក្សា មានឥរិយាបថវិជ្ជមាន ចំពោះអធិការកិច្ចលើការបង្រៀន និងរៀន

២. គ្រូបង្រៀននៅសាលាតំបន់ជនបទ មានឥរិយាបថវិជ្ជមានចំពោះអធិការកិច្ច លើការបង្រៀន និងរៀន ខ្ពស់ជាងគ្រូបង្រៀននៅសាលាតំបន់ទីប្រជុំជន

៣. គ្រូបង្រៀនដែលមានបទពិសោធន៍តិចជាងមួយឆ្នាំ មានឥរិយាបថវិជ្ជមានចំពោះអធិការកិច្ច លើការបង្រៀន និងរៀន ខ្ពស់ជាងគ្រូបង្រៀនដែលមានបទពិសោធន៍យូរឆ្នាំ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

លទ្ធផលនៃការស្រាវជ្រាវនេះអាចត្រូវបានប្រើប្រាស់ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃអធិការកិច្ច ព្រោះមកដល់ពេលឥឡូវនេះ អ្នកស្រាវជ្រាវមិនបានឃើញមានការស្រាវជ្រាវណាមួយបង្ហាញអំពីឥរិយាបថរបស់គ្រូបង្រៀនបឋមសិក្សា ចំពោះអធិការកិច្ចលើការបង្រៀន និងរៀននៅឡើយទេ។ ការស្រាវជ្រាវនេះអាចផ្តល់ឱកាសឱ្យអធិការអប់រំអាចធ្វើការវាយតម្លៃពីការងារ របស់ពួកគេ ដោយផ្អែកលើឥរិយាបថរបស់គ្រូបង្រៀន

ចំពោះការងារអធិការកិច្ច។ ការស្រាវជ្រាវនេះ ក៏មានសារៈសំខាន់សម្រាប់នាយកដ្ឋានជានាគុណភាពអប់រំ ក៏ដូចវិទ្យាស្ថានជាតិអប់រំ ដែលជាអ្នកបណ្តុះបណ្តាលអធិការអប់រំ ក្នុងការពង្រឹងសមត្ថភាពអធិការអប់រំបន្ថែម ជាពិសេសការស្រាវជ្រាវនេះ បានបង្ហាញពីសំណូមពររបស់គ្រូបង្រៀន អំពីការងារអធិការកិច្ច ដែលអាចជាមូលដ្ឋានដើម្បីធ្វើឱ្យការងារអធិការកិច្ចកាន់តែមានប្រសិទ្ធភាព និងមានការទទួលស្គាល់ជាងមុន។

## ១.៧ ដែនកំណត់នៃការស្រាវជ្រាវ

ដើម្បីឱ្យការសិក្សាស្រាវជ្រាវនេះប្រព្រឹត្តទៅបានដោយរលូន និងវិភាគបានគ្រប់ជ្រុងជ្រោយទៅលើប្រធានបទ "**ឥរិយាបថគ្រូបង្រៀនបឋមសិក្សា ចំពោះអធិការកិច្ចលើការបង្រៀន និងរៀននៅក្នុងខេត្តកំពង់ធំ**" អ្នកស្រាវជ្រាវផ្តោតតែលើសាលារៀននៅកម្រិតបឋមសិក្សា នៅក្នុងក្រុងស្ទឹងសែន ស្រុកកំពង់ស្វាយ និងស្រុកប្រាសាទសំបូរ នៃខេត្តកំពង់ធំតែប៉ុណ្ណោះ ហើយសាលាបឋមសិក្សាទាំងអស់នោះ ធ្លាប់បានទទួលការធ្វើអធិការកិច្ចតាមកាលកំណត់យ៉ាងតិចម្តង(អធិការកិច្ចជាប្រព័ន្ធ) ក្នុងរយៈពេលពីរឆ្នាំសិក្សាចុងក្រោយ គឺឆ្នាំសិក្សា២០១៨~២០១៩ និងឆ្នាំសិក្សា២០១៩~២០២០។ ម្យ៉ាងទៀតការសិក្សាលើប្រធានបទនេះ គឺសិក្សាទៅលើឥរិយាបថគ្រូបង្រៀនបឋមសិក្សា ចំពោះអធិការកិច្ចផ្ទៃក្រៅ(អធិការកិច្ចតាមកាលកំណត់) ដែលធ្វើឡើងដោយការិយាល័យអធិការកិច្ច នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំប៉ុណ្ណោះ ហើយផ្តោតតែលើការបង្រៀន និងរៀន ដោយមិនបានសិក្សាលើផ្នែកបីផ្សេងទៀត(ការដឹកនាំគ្រប់គ្រង លទ្ធផលសិក្សារបស់សិស្ស និងស្វ័យវាយតម្លៃ) របស់ការងារអធិការកិច្ចនោះទេ។

## ១.៨ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ ត្រូវបានបែងចែកជា៥ជំពូកធំៗដូចខាងក្រោម៖

**១. ជំពូកទី១ សេចក្តីផ្តើម៖** ជំពូកនេះបង្ហាញពីសាវតារនៃការអប់រំនៅកម្ពុជា គោលបំណងនៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ លំនាំនៃការស្រាវជ្រាវ និងសារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**២. ជំពូកទី២ រំលឹកទ្រឹស្តី៖** ជំពូកនេះបង្ហាញពីការសិក្សាទៅលើទ្រឹស្តី និងបទបញ្ញត្តិនានា ដែលពាក់ព័ន្ធទៅនឹងចំណុច ដែលបានចោទសួរនៅក្នុងចំណោទបញ្ហាដូចជា៖ សាវតារអធិការកិច្ចនៅក្នុងប្រទេសកម្ពុជា ការងារអធិការកិច្ចលើការបង្រៀន និងរៀនកម្រិតបឋមសិក្សានៅកម្ពុជា ដែលក្នុងនោះមានការបកស្រាយពីនិយមន័យនៃអធិការកិច្ច គោលបំណងនៃអធិការកិច្ច តួនាទីនៃអធិការកិច្ច វិធីសាស្ត្រអធិការកិច្ច ដំណើរការអធិការកិច្ច និងនិយមន័យនៃពាក្យឥរិយាបថ(Attitude)។

**៣. ជំពូកទី៣ វិធីសាស្ត្រស្រាវជ្រាវ៖** ជំពូកនេះរៀបរាប់អំពីវិធីសាស្ត្រស្រាវជ្រាវ ដែលអ្នកស្រាវជ្រាវបានយកមកប្រើប្រាស់។ នៅក្នុងជំពូកនេះអ្នកស្រាវជ្រាវ បង្ហាញពីរបៀបនៃការសិក្សា ការប្រមូលសំណាក ការប្រមូលព័ត៌មាន ការវិភាគព័ត៌មាន ការប្រើប្រាស់ឧបករណ៍ស្ថិតិ ការប្រើប្រាស់រូបមន្តសម្រាប់ធ្វើការគណនា និងការជ្រើសរើសវិធីសាស្ត្រប្រមូលទិន្នន័យ។

**៤. ជំពូកទី៤ លទ្ធផលនិងការពិភាក្សា៖** ក្នុងជំពូកនេះ បានលើកឡើងពីលក្ខណៈជាក់ស្តែង ដែលយើងបានធ្វើការស្រាវជ្រាវ ហើយចំណុចដែលត្រូវលើកឡើង បានឆ្លើយតបទៅនឹងចំណោទបញ្ហា និងវត្ថុបំណងនៃប្រធានបទ។ ការបកស្រាយយ៉ាងលម្អិតទៅលើគោលបំណងនៃការស្រាវជ្រាវ ដោយយោងទៅលើលទ្ធផលនៃការស្រាវជ្រាវទ្រឹស្តី ឬខ្លឹមសារដែលមាននៅក្នុងកម្រងសំណួរ។

**៥. ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងសំណូមពរ៖** ជំពូកនេះអ្នកស្រាវជ្រាវត្រូវធ្វើការសង្ខេបការសិក្សាស្រាវជ្រាវ រួចទាញជាសេចក្តីសន្និដ្ឋានលើចំណុចដែលបានវិភាគ និងផ្តល់យោបល់ឬសំណូមពរទៅលើចំណុចដែលត្រូវកែលម្អ។

# ជំពូកទី២
# រំលឹកទ្រឹស្ដី

# ជំពូកទី២ រំលឹកទ្រឹស្តី

## ២.១ សាវតារនៃអធិការកិច្ចនៅកម្ពុជា

### ២.១.១ ដើមកំណើតអធិការកិច្ចក្នុងបរិបទពិភពលោក

យោងតាម Wilcox (2000) អធិការកិច្ចអាចជាវិធីសាស្ត្រដ៏ចាស់បំផុតនៃការពិនិត្យកែលម្អគ្រូបង្រៀន និងសាលារៀន។ អធិការកិច្ចក្នុងប្រទេសជាច្រើន មានប្រភពពីការវិវត្តនៃការអប់រំសាធារណៈក្នុងសតវត្សទី១៩។ អធិការកិច្ចសាលារៀនជាប្រព័ន្ធមួយរបស់រាជរដ្ឋាភិបាល ដើម្បីត្រួតពិនិត្យមើលគុណភាពអប់រំ។ អធិការកិច្ចសាលារៀនមានប្រភពមកពីប្រទេសបារាំងក្រោមរបបណាប៉ូឡេអុងនៅចុងសតវត្សទី១៨ និងត្រូវបានយកទៅអនុវត្តបន្តនៅក្នុងតំបន់អឺរ៉ុបនៅសតវត្សទី១៩ (Grauwe, 2007)។ ឧទាហរណ៍ក្នុងប្រទេសអង់គ្លេស អធិការកិច្ចលើកដំបូងត្រូវបានបង្កើតឡើងនៅឆ្នាំ១៨៣៩ និងត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ដោយម្ចាស់ក្សត្រីយ៍របស់ចក្រភពអង់គ្លេស ដើម្បីពង្រឹងគណនេយ្យភាពក្នុងប្រព័ន្ធអប់រំ ក្នុងគោលបំណងផ្តល់សេវាអប់រំឱ្យកាន់តែប្រសើរឡើងទៅដល់កូនៗរបស់អ្នកបង់ពន្ធតែប៉ុណ្ណោះ (Neav,1987)។

### ២.១.២ ការសិក្សានៅក្រោមសម័យអាណាព្យាបាលបារាំង

បើយោងតាម ក្រសួងអប់រំយុវជន និងកីឡា (២០១៥) អធិការកិច្ចសាលារៀនត្រូវបានគេឃើញមាននៅប្រទេសកម្ពុជាតាំងពីសម័យអាណាព្យាបាលបារាំងមកម្ល៉េះ(១៨៦៣~១៩៤៥)។ " *នៅឆ្នាំ១៩៣៥ដើម្បីជួយពង្រឹងគុណភាពអប់រំ លោកមានីពូដ៍[2] (Manipoud) ដែលជាព្រះរាជប្រតិភូរបស់ព្រះមហាក្សត្របានតែងតាំងលោក* ***អ៊ុំ ឈាងស៊ុន***[3] *ជាកូឈ្មួយទទួលបន្ទុកអធិការកិច្ចសាលាវត្តនៅភូមិភាគខាងត្បូងក្នុងនោះមានខេត្តកំពត កណ្តាល កំពង់ស្ពឺ ព្រៃវែង ស្វាយរៀង ស្ទឹងត្រែង តាកែវនិងរាជធានីភ្នំពេញ។ លោក* ***ចៃត្រ ឆែម***[4] *ទទួល*

[2] មានីពូដ៍ ជាព្រះរាជប្រតិភូរបស់ព្រះមហាក្សត្រ ជាអ្នកនិពន្ធសៀវភៅ បឋម វិជ្ជា ខេមរភាសា:កុមារឋាន រួមជាមួយ ខិម ប៉ែន និងឈិម សុទ្ធ

[3] អ៊ុំ ឈាងស៊ុន(០១ មិថុនា ឆ្នាំ១៩០០_១៩៦៣) អតីតនាយករដ្ឋមន្ត្រីកម្ពុជា ឆ្នាំ១៩៥១ និងឆ្នាំ១៩៥៦

[4] ចៃត្រ ឆែម( ១៩០៤_១៩៧២) អធិការបឋមសិក្សា បារាំងខ្មែរ ជាអ្នកនិពន្ធសៀវភៅ វិធីរៀនមើល និងសរសេរអក្សរខ្មែរសម្រាប់ថ្នាក់កុមារដ្ឋាន, កម្រងអត្ថបទរៀនជាភាសាបារាំងសម្រាប់ថ្នាក់អាទិកដ្ឋាន

*បន្ទុកជាកូឈួយទទួលបន្ទុកអធិការកិច្ចសាលាវត្តភូមិភាគខាងជើងដែលក្នុងនោះមានខេត្តបាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ ក្រចេះ ពោធិ៍សាត់ និងសៀមរាប ព្រមទាំងតែងតាំង លោក **ខិម ប៉ែន**[5] ជាលេខាធិការ។ មិនត្រឹមតែប៉ុណ្ណោះ ក្រៅពីលោកទាំងបី នៅមានគ្រូជាច្រើនទៀតបម្រើការសិក្សាកែប្រែក្នុងឋានៈជាអធិការរង មាន១៦នាក់ និងនាយកសាលាអនុវត្ត ១៤នាក់។*

នៅសម័យនេះផងដែរនាយកក្រសួងសិក្សាធិការ ត្រូវបានដឹកនាំដោយជនជាតិបារាំងម្នាក់ ដោយស្ថិតនៅក្រោមឱវាទរបស់លោករ៉េស៊ីដង់ជាន់ខ្ពស់។ ចំណែកការសិក្សាវិញត្រូវអនុវត្តតាមបញ្ជាពីអគ្គនាយកសិក្សាសារជាណៈនៅក្រុងហាណូយ។ នៅតាមបណ្តាខេត្តធំៗនៃ ព្រះរាជាណាចក្រកម្ពុជាមានបុគ្គលិកសិក្សាបារាំងម្នាក់មានតួនាទីជាអធិការបឋមសិក្សា ហើយក្នុងមួយឆ្នាំៗ លោកអធិការនេះតែងតែធ្វើទស្សនាចរទៅធ្វើអធិការកិច្ចនៅសាលាសិក្សាជាន់ដំបូងនៅតាមទីរួមស្រុក។ រីឯសាលាវត្តវិញគាត់មិនមានសិទ្ធិធ្វើអធិការកិច្ចទេ ពីព្រោះសាលាវត្ត និងសាលាអនុវត្តនៅតាមខេត្តស្ថិតនៅក្រោមការគ្រប់គ្រងផ្សេង គឺតាមរយៈលោកម៉ានីពូជ៏។

### ២.១.៣ អធិការកិច្ចចាប់ពីឆ្នាំ១៩៤៥ ដល់១៩៧៥

ចាប់ពីឆ្នាំ១៩៤៥ដល់ឆ្នាំ១៩៧៥ ទីស្តីការក្រសួងអប់រំជាតិ និងវិចិត្រសិល្បៈ ត្រូវបានដឹកនាំដោយឥស្សរជនខ្មែរសុទ្ធសាធ។ យោងតាម ក្រសួងអប់រំយុវជន និងកីឡា (២០១៥) នៅឆ្នាំ១៩៤៧ នាយកដ្ឋានមួយត្រូវបានបង្កើតដែលត្រូវចែកចេញជាក្រុមសេវាកម្មពីរគឺ ក្រុមទី១ជាអធិការដ្ឋាននៃការសិក្សាសាលាវត្តមានលោក **អ៊ុំ ឈាងស៊ុន** ជាអធិការនាយក និងក្រុមទី២ ជាអធិការដ្ឋាននៃការសិក្សាបារាំងខ្មែរ មានលោក **ចៃត្រ ឆែម** ជាអធិការនាយក។ នៅឆ្នាំ១៩៤៩ក្រុមទាំងពីរខាងលើបានរួមបញ្ចូលគ្នាបង្កើតជាអធិការដ្ឋានបឋមសិក្សា ដែលមានអធិការនាយកម្នាក់ និងមានអធិការរងពីរនាក់ជាជំនួយការទទួលបន្ទុកអធិការកិច្ចសាលាវត្ត និងអធិការកិច្ចសាលាសាធារណៈព្រមទាំងត្រួតពិនិត្យសាលាឯកជន។ នៅគ្រប់ខេត្តមានបង្កើតតំបន់អធិការកិច្ចសាលារៀនហើយតំបន់អធិការកិច្ចនីមួយៗ មានគ្រូក្រោមឱវាទច្រើនជាង១០០នាក់។ ក្នុង

[5] ខិម ប៉ែន ជាអ្នកនិពន្ធ សៀវភៅ បឋម វិជ្ជា ខេមរភាសា:កុមារឋាន រួមជាមួយ មានីពូជ៏ និងឈឹម សុទ្ធ

នោះអធិការបឋមសិក្សាមានតួនាទីសំខាន់បីគឺ៖ (១) តំណាងអាជ្ញាធរមានសមត្ថកិច្ចតំណាងឱ្យក្រសួង (បឋម មធ្យម ការិយាល័យ) (២) ជាអ្នកបច្ចេកទេសបឋមសិក្សាពិនិត្យលើគ្រប់មុខវិជ្ជាភាសា វិទ្យាសាស្ត្រសង្គម គណិត (៣) ជាគ្រូឧទ្ទេសពេលជួបបញ្ហានីមួយៗមានការប្រជុំគរុកោសល្យត្រង់ៗ និងជាសម្ងាត់។ ភាគច្រើននៃការធ្វើអធិការកិច្ចគឺឱ្យដំបូន្មានទៅលើការបង្រៀនភាសាបារាំង ដំបូន្មានគរុកោសល្យ និយ័តភាព និងការមកបង្រៀនមិនទៀងទាត់។ ចំពោះអធិការមធ្យមសិក្សា គឺជាអធិការឯកទេសដែលក្នុងនោះអធិការគណិតវិទ្យាទៅមើលគណិតវិទ្យា អធិការអក្សរសាស្ត្រខ្មែរទៅមើលអក្សរសាស្ត្រខ្មែរ ប៉ុន្តែពុំសូវបានទៅមើលទេ ដូចជាលោក **កែវ ចែម អ៊ឹម រុន។**

នៅឆ្នាំ១៩៦៩~១៩៧០ ទូទាំងប្រទេសមាន១៩៨តំបន់អធិការកិច្ច។ រហូតមកដល់ឆ្នាំ១៩៩៤ ដើម្បីរួមចំណែកដល់ការពង្រឹងគុណភាពអប់រំក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតក្របខណ្ឌអធិការក្នុងការត្រួតពិនិត្យតាមដានលើការដឹកនាំ និងគ្រប់គ្រង ការបង្រៀន និងរៀន នៅតាមរាជធានីខេត្ត។ ក្នុងនោះក្រសួងអប់រំ យុវជន និងកីឡាបានបណ្តុះបណ្តាលអធិការបឋមសិក្សា ០៦ជំនាន់ បានចំនួន២៣០នាក់ និងអធិការមធ្យមសិក្សា០៤ជំនាន់ មានចំនួន៧៣នាក់។

### ២.១.៤ អធិការកិច្ចកម្ពុជាបច្ចុប្បន្ន

បើយោងតាម វិទ្យាស្ថានជាតិអប់រំ (២០១៧) អធិការកិច្ចសាលារៀនដែលជាមធ្យោបាយសម្រាប់ធ្វើឱ្យការអប់រំ និងគុណភាពអប់រំមានការប្រសើរឡើងនោះ ជាការពិតត្រូវបានគេយកចិត្តទុកដាក់រាប់រយឆ្នាំមកហើយ។ បើប្រៀបធៀបពីភាពខុសគ្នានាពេលបច្ចុប្បន្នទៅនឹងកាលពី៣០ឆ្នាំមុន គឺថាការចុះពិនិត្យតាមដានការវាយតម្លៃ និងការធានាគុណភាពអប់រំ គឺជាបញ្ញត្តិអន្តរជាតិមួយដោយសារវិមជ្ឈការនៅក្នុងប្រព័ន្ធអប់រំ និងការផ្តោតទៅលើស្តង់ដាដែលបានលើកឡើង។ នេះគឺជាផ្នែកមួយនៃនិន្នាការពិភពលោក ដែលកំពុងអនុវត្តអស់រយៈពេលជាច្រើនឆ្នាំមកហើយ។

ការធ្វើអធិការកិច្ចសាលារៀន ត្រូវបានចាត់ទុកជាមធ្យោបាយដ៏សំខាន់ដែលប្រទេសជាច្រើនដូចជា កម្ពុជា និងស៊ុយអ៊ែតជាដើមយកមកពិនិត្យតាមដានគុណភាពអប់រំបាន។ ហេតុផលមួយទៀតការធ្វើអធិការកិច្ចសាលារៀន គឺដើម្បីកឱ្យឃើញនូវអ្វីៗដែលបានកើតឡើងនៅក្នុងសាលារៀនទាំងមូល ឧទាហរណ៍ដូចជា គុណភាពនៃការបង្រៀន គុណភាពនៃការដឹកនាំនិងគ្រប់គ្រង អត្រាសិស្សបោះបង់ការសិក្សា និងលទ្ធផលសិក្សាសិស្សជាដើម។ មកដល់សម័យបច្ចុប្បន្នដោយសារបរិបទប្រទេសកម្ពុជាយើងមានការរីកចម្រើន ហើយដោយសារតែក្រសួងអប់រំ បានធ្វើកំណែទម្រង់ជាច្រើនចំណុចផងនោះ ការងារអធិការកិច្ចនៅតាមសាលារៀនក៏មានការផ្លាស់ប្តូរយ៉ាងច្រើន ពីអធិការកិច្ចតាមមុខវិជ្ជា មកជាអធិការកិច្ចជាប្រព័ន្ធវិញ ដោយធ្វើអធិការកិច្ចទៅលើប្រព័ន្ធទាំងមូលរបស់សាលារៀនដូចជា៖ (១)ការដឹកនាំនិងគ្រប់គ្រង (២) ការបង្រៀននិងរៀន (៣) លទ្ធផលសិក្សារបស់សិស្ស (៤) ស្វ័យវាយតម្លៃសាលារៀន។ ដើម្បីឱ្យការងារអធិការកិច្ចថ្មីទទួលបានជោគជ័យក្រសួងអប់រំយុវជន និងកីឡាបានចាប់ផ្តើមជ្រើសរើស និងបណ្តុះបណ្តាលអធិការអប់រំនៅវិទ្យាស្ថានជាតិអប់រំ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ បាន៤ជំនាន់ សរុបចំនួន១៩៧នាក់ និងកំពុងបណ្តុះបណ្តាលជំនាន់ទី៥ ចំនួន៤៩នាក់បន្ថែមទៀត (នាយកដ្ឋានធានាគុណភាពអប់រំ, ២០២០ខ)។ ក្រសួងអប់រំបានរៀបចំបែងចែកតំបន់អធិការកិច្ចចំនួន៨តំបន់[6] (ក្រសួងអប់រំយុវជន និងកីឡា, ២០១៧ខ)។ តំបន់អធិការអប់រំទាំងនោះរួមមាន៖ តំបន់រាជធានីភ្នំពេញ តំបន់តាកែវ តំបន់ព្រះសីហនុ តំបន់បាត់ដំបង តំបន់សៀមរាប តំបន់កំពង់ចាម តំបន់ព្រៃវែង និងតំបន់ស្ទឹងត្រែង។

[6] តំបន់រាជធានីភ្នំពេញ(រាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តកំពង់ឆ្នាំង) តំបន់តាកែវ(ខេត្តតាកែវ ខេត្តកំពត និងខេត្តកែប) តំបន់ព្រះសីហនុ (ខេត្តព្រះសីហនុ ខេត្តកំពង់ស្ពឺ និងខេត្តកោះកុង) តំបន់បាត់ដំបង(ខេត្តបាត់ដំបង ខេត្តពោធិសាត់ និងខេត្តប៉ៃលិន) តំបន់សៀមរាប(ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ) តំបន់កំពង់ចាម(ខេត្តកំពង់ចាម ខេត្តកំពង់ធំ និងខេត្តព្រះវិហារ) តំបន់ព្រៃវែង(ខេត្តព្រៃវែង ខេត្តស្វាយរៀង និងខេត្តត្បូងឃ្មុំ) និងតំបន់ស្ទឹងត្រែង(ខេត្តស្ទឹងត្រែង ខេត្តក្រចេះ ខេត្តមណ្ឌលគីរី និងខេត្តរតនគីរី)

| អធិការកិច្ចតាមមុខវិជ្ជា | អធិការកិច្ចជាប្រព័ន្ធ |
|---|---|
| ជាដំណើរការដែលផ្តោតលើដំណើរការបង្រៀនរបស់គ្រូនៅក្នុងបរិបទថ្នាក់រៀន(កម្មវិធីសិក្សា កិច្ចតែងការ សម្ភារឧបទេស ការប្រើប្រាស់ក្តារខៀន ការគ្រប់គ្រងពេលវេលា) | ជាដំណើរការដែលផ្តោតលើអ្នករៀន ធ្វើយ៉ាងណាដើម្បីកែលម្អគុណភាពអប់រំ និងកែលម្អលទ្ធផលសិក្សារបស់សិស្ស |
| មិនបានធ្វើឱ្យការអប់រំមានភាពប្រសើរឡើងគ្រប់ជ្រុងជ្រោយ | បានផ្តោតលើតួនាទីគ្រូបង្រៀន នាយកសាលា សិស្ស និងសហគមន៍ |
| ផ្តោតលើគ្រូបង្រៀន(ឯកទេសនៃមុខវិជ្ជានីមួយៗ) | ពិនិត្យមើលប្រព័ន្ធសាលារៀនទាំងមូល |
| ជួយគ្រូបានតិចតួច | ជួយគ្រូបានច្រើនគ្នា |
| ត្រូវការធនធានមនុស្សច្រើន ព្រោះតម្រូវឱ្យមានអធិការគ្រប់មុខវិជ្ជា | កំណត់ចំនួនមនុស្សច្បាស់លាស់(ក្រសួងជ្រើសរើសអធិការអប់រំថ្មី៥០០នាក់ |
| ចំណាយថវិកាច្រើន (អធិការគ្រប់មុខវិជ្ជា/សាលា) | ចំណាយថវិកាតិច(អធិការអប់រំ២នាក់/សាលា) |
| ពិបាកក្នុងបណ្តុះបណ្តាល | ងាយស្រួលក្នុងការបណ្តុះបណ្តាល |
| មានបែងចែកអធិការបឋម និងអធិការមធ្យមសិក្សា | គ្មានការបែងចែក គឺមានតែ អធិការអប់រំ |

***តារាង 1៖*** *ការប្រៀបធៀបរវាងអធិការកិច្ចតាមមុខវិជ្ជា និងអធិការកិច្ចជាប្រព័ន្ធ*

ប្រភព៖ a. ឯកសារបំប៉ននាយក នាយិកាសាលារៀន ស្តីពី អធិការកិច្ចអប់រំជាប្រព័ន្ធ

b. ការពិភាក្សាក្រុមអធិការកិច្ចក្រុម១ ជំនាន់ទី៤ ឆ្នាំសិក្សា២០១៩ ២០២០

អធិការកិច្ចសម័យបច្ចុប្បន្ន ចែកជា២ប្រភេទធំៗគឺអធិការកិច្ចផ្ទៃក្នុង និងអធិការកិច្ចផ្ទៃក្រៅ។

| **អធិការកិច្ចផ្ទៃក្នុង** | **អធិការកិច្ចផ្ទៃក្រៅ** |
|---|---|
| • ដឹកនាំដោយនាយកសាលារៀន<br>• ជាការផ្តួចផ្តើមដោយខ្លួនឯង ឬតម្រូវតាមច្បាប់<br>• ប្រឈមនឹងភាពមិនច្បាស់លាស់នៃលទ្ធផល (រាក់ពេក) មិនហ្មត់ចត់គ្រប់គ្រាន់<br>• អាស្រ័យលើសមត្ថភាពនាយកសាលា<br>• មានការចូលរួមពីថ្នាក់ការិយាល័យអប់រំស្រុក | • វដ្តនៃអធិការកិច្ចពី៣ឆ្នាំ ទៅ៦ឆ្នាំ<br>• លក្ខណៈវិនិច្ឆ័យរួម ការវិនិច្ឆ័យមានលក្ខណៈប្រាកដ<br>• បង្ហាញពីរូបភាពថ្នាក់ជាតិនៃគុណភាពអប់រំ<br>• ជំរុញការរីកចម្រើន<br>• ត្រូវការក្រុមអធិការកិច្ចដែលមានជំនាញ<br>• មានតម្លៃខ្ពស់<br>• អាចមានលក្ខណៈបត់បែនគ្រប់គ្រាន់<br>(វិទ្យាស្ថានជាតិអប់រំ, ២០១៧ ទំព័រ១៦) |

***តារាង 2៖** ការប្រៀបធៀបរវាងអធិការកិច្ចផ្ទៃក្នុង និងអធិការកិច្ចផ្ទៃក្រៅ*

- អធិការកិច្ចផ្ទៃក្នុង ឬស្វ័យវាយតម្លៃ គឺផ្អែកលើការធ្វើស្វ័យវាយតម្លៃរបស់សាលារៀន ដែលអនុវត្តដោយនាយកសាលារៀន គ្រូបង្រៀន និងសិស្សានុសិស្ស។ កិច្ចការនេះក៏ត្រូវផ្តោតផងដែរលើការងារទាក់ទងនឹងគុណភាពផ្ទៃក្នុងនៅកម្រិតសាលារៀន ដោយប្រើប្រាស់ធនធានផ្ទៃក្នុង ឬធនធានមូលដ្ឋាន។ ការធ្វើអធិការកិច្ចផ្ទៃក្នុងត្រូវរៀបចំ និងអនុវត្តជាប្រចាំ ប៉ុន្តែពុំសូវមានលក្ខណៈផ្លូវការដូចអធិការកិច្ចពីខាងក្រៅទេ ហើយចំពោះការធ្វើការកែលម្អអ្វីមួយក៏ត្រូវធ្វើឡើងជាប្រចាំផងដែរក្នុងកំឡុងឆ្នាំសិក្សា។

- អធិការកិច្ចផ្ទៃក្រៅ គឺជាការធ្វើអធិការកិច្ចក្នុងរយៈពេលខ្លីណាមួយដោយអ្នកមកពីខាងក្រៅសាលារៀន។ ការធ្វើអធិការកិច្ចនេះ គឺជាការសាកសួរដើម្បីរកឱ្យឃើញនូវផ្នែកទាំងឡាយណា ដែលសាលារៀនបំពេញបានល្អ ឬមិនទាន់បានល្អ រួចរិះរកវិធានការណ៍ ឬផ្តល់អនុសាសន៍ ដើម្បីស្វែងរកតម្រូវការនានា

សម្រាប់កែលម្អចំណុចមិនទាន់បានល្អទាំងនោះ។

| | គុណសម្បត្តិ | គុណវិបត្តិ |
|---|---|---|
| **អធិការកិច្ចផ្ទៃក្នុង** | • នាយកសាលាជាអ្នកធ្វើ គាត់មានភាពស្និទ្ធស្នាលជាមួយសាលារៀន<br>• គ្រូបង្រៀន សិស្ស មានឆន្ទៈក្នុងការនិយាយ<br>• ចំណាយលុយតិច | • ចាប់អារម្មណ៍តែលើចំណុចមួយដើម្បីឈានដល់ការសន្និដ្ឋានជាវិជ្ជមាន<br>• អាចមិនជំនាញ ឬមិនបានបណ្តុះបណ្តាល<br>• ចំណាយពេលច្រើន |
| **អធិការកិច្ចផ្ទៃក្រៅ** | • អាចច្បាស់លាស់ព្រោះមិនមែនជាផ្នែកនៃសាលារៀន<br>• មានកម្រិតជំនាញ និងបទពិសោធ<br>• គ្រូបង្រៀន និងសិស្សហ៊ាននិយាយប្រាប់អ្នកខាងក្រៅជាងអ្នកខាងក្នុង<br>• មានឱកាសរកឃើញពីលទ្ធផលវិជ្ជមាន និងគួរឱ្យជឿជាក់ | • មិនបានយល់ពីវប្បធម៌ ឬកិច្ចការសាលារៀនកំពុងព្យាយាមធ្វើ។<br>• អ្នកចូលរួមសកម្មភាពនានារបស់សាលាដោយផ្ទាល់អាចមិនចង់និយាយដោយបើកចំហរ និងមិនចង់សហការ<br>• អាចមានការយល់ច្រលំនូវអ្វីដែលសាលា ត្រូវការ និងផ្តល់អ្វីតាមតម្រូវការសាលា<br>• ត្រូវការចំណាយច្រើន។ |

***តារាង 3៖*** *គុណសម្បត្តិ និងគុណវិបត្តិនៃអធិការកិច្ចផ្ទៃក្នុង/ផ្ទៃក្រៅ*

អធិការផ្ទៃក្រៅត្រូវបែងចែកពីរផ្នែកទៀតគឺ អធិការកិច្ចតាមកាលកំណត់ និងអធិការកិច្ចតាមប្រធានបទ។

○ អធិការកិច្ចតាមកាលកំណត់ គឺជាការពិនិត្យ និងវាយតម្លៃសាលារៀនទាំងអស់ជាប្រព័ន្ធ ដើម្បីធានាថាពួកគេបានគោរពតាមច្បាប់ និងបទបញ្ញត្តិដែលទាក់ទងនឹងភារកិច្ចរបស់ខ្លួន។ ការវាយតម្លៃគឺត្រូវផ្អែក

លើការបកស្រាយ បទប្បញ្ញត្តិរបស់ជាតិ។ លទ្ធផលដែលបានមកនឹងបង្ហាញពីកិច្ចការណាខ្លះដែលមានដំណើរការល្អ និងកិច្ចការណាខ្លះទៀតដែលត្រូវការកែលម្អ។ អធិការកិច្ចតាមកាលកំណត់នឹងត្រូវអនុវត្តដោយមន្ទីរអប់រំ យុវជន និងកីឡាទាំង២៥រាជធានី/ខេត្ត និងក្រុមអធិការរបស់ពួកគេ។ (វិទ្យាស្ថានជាតិអប់រំ, ២០១៧) អធិការកិច្ចតាមកាលកំណត់អនុវត្តលើផ្នែកសំខាន់ៗចំនួនបួនគឺៈ (១) ការដឹកនាំ និងគ្រប់គ្រង (២) ការបង្រៀន និងរៀន (៣) លទ្ធផលសិក្សារបស់សិស្ស និង(៤) គុណភាពការងារស្វ័យវាយតម្លៃសាលារៀន។ អធិការកិច្ចតាមការកំណត់ គឺជាអធិការកិច្ចផ្តោតលើហានិភ័យ ហើយថ្នាក់ខេត្តជាអ្នករៀបចំផែនការអធិការកិច្ច និងជ្រើសរើសសាលារៀន ដោយសហការជាមួយនាយកដ្ឋានធានាគុណភាពអប់រំ។ ជាទូទៅការធ្វើអធិការកិច្ចសាលារៀនមួយ ចំណាយពេលពី១ ឬ២ថ្ងៃ ដោយមានអធិការពីររូប។

○ អធិការកិច្ចតាមប្រធានបទ គឺជាការពិនិត្យ និងវាយតម្លៃជាលក្ខណៈប្រព័ន្ធលើគុណភាពរបស់កិច្ចការណាមួយដែលបានកំណត់។ ការវាយតម្លៃត្រូវផ្អែកលើការបកស្រាយទៅតាមគោលបំណងថ្នាក់ជាតិ និងគោលការណ៍ណែនាំគាំទ្រដោយលទ្ធផលស្រាវជ្រាវ និងការអនុវត្តល្អបំផុត។ លទ្ធផលដែលបានមកនឹងបង្ហាញអំពីកិច្ចការណាខ្លះដែលមានដំណើរការល្អ និងកិច្ចការណាខ្លះទៀតដែលត្រូវការកែលម្អ (អធិការដ្ឋានអប់រំ ស៊ុយអែត ក្របខណ្ឌធានាគុណភាពអប់រំ)។ យោងតាម វិទ្យាស្ថានជាតិអប់រំ (២០១៧) អធិការកិច្ចតាមប្រធានបទ គឺផ្តោតទៅលើករណីពិសេស ឬបញ្ហាណាមួយ ដែលកើតមាននៅសាលារៀនមួយដូចជាៈ ការគ្រប់គ្រងគ្រូបង្រៀន ការអនុវត្តកម្មវិធីសិក្សារបស់សាលារៀន ការពង្រឹងសមត្ថភាពគ្រូ និងវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស។ ឧទាហរណ៍ៈ អត្រាការបោះបង់សិក្សាធៀបនឹងសាលាដទៃទៀតនូវមូលហេតុដែលខុសគ្នារវាងមូលហេតុដទៃទៀតនៅក្នុងប្រទេសកម្ពុជា។ អាចជាប្រធានបទមួយ ដែលសាលារៀនជួយដល់សិស្សពិការ ឬមួយក៏របៀបដែលនាយកសាលារៀន ដើរតួនាទីជាអ្នកដឹកនាំអប់រំ និងគរុកោសល្យ។ មុខវិជ្ជាមួយក្នុងសាលារៀនក្នុងកម្រិតថ្នាក់ជាក់លាក់ណាមួយ ក៏អាចជាប្រធានបទសំខាន់សម្រាប់អធិការកិច្ចតាមប្រធានបទដែរ។ នាយកដ្ឋានធានាគុណភាពអប់រំ(នា.ធគអ) ជាអ្នកទទួលខុសត្រូវលើការអធិការកិច្ចតាមប្រធានបទ។

*រូបភាព 1៖ រចនាសម្ព័ន្ធអធិការកិច្ចជាប្រព័ន្ធ*

**អធិការកិច្ចជាប្រព័ន្ធ**

| **អធិការកិច្ចផ្ទៃក្នុង** | | **អធិការកិច្ចផ្ទៃក្រៅ** | |
|---|---|---|---|
| ស្វ័យវាយតម្លៃ | ក្រុមសាលាកុមារមេត្រី | តាមកាលកំណត់ | តាមប្រធានបទ |
| នាយកសាសា | ក្រុមDTMT | POE[7] | EQAD[8] |
| គ្រូបង្រៀន | DOE[9] | | |
| សិស្សានុសិស្ស | សាលាកម្រង | | |

សរុបមកប្រព័ន្ធអធិការកិច្ចនៅកម្ពុជាចែកចេញជាពីរប្រភេទ គឺអធិការកិច្ចផ្ទៃក្នុង ដែលធ្វើដោយនាយកសាលា ប្រធានក្រុមបច្ចេកទេស និងមន្ត្រីការិយាល័យអប់រំក្រុង/ស្រុក និងអធិការកិច្ចផ្ទៃក្រៅធ្វើឡើងដោយការិយាល័យអធិការកិច្ចនៃមន្ទីរអប់រំរាជធានី/ខេត្ត និងនាយកដ្ឋានធានាគុណភាពអប់រំ។ ចំណែកឯអធិការកិច្ចតាមកាលកំណត់ ធ្វើឡើងដើម្បីពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តរបស់សាលារៀន លើផ្នែកសំខាន់ទាំងបួន។ បញ្ហាដែលបានរកឃើញតាមរយៈការធ្វើអធិការកិច្ចតាមកាលកំណត់ និងក្លាយជាប្រភពព័ត៌មានសំខាន់សម្រាប់អធិការកិច្ចតាមប្រធានបទ។ ជាក់ស្តែងតាមរបាយការណ៍បូកសរុបលទ្ធផលអធិការកិច្ចតាមកាលកំណត់ឆ្នាំ២០១៨ របស់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី/ខេត្ត បានរកឃើញថាសាលាបឋមសិក្សា ៣៥១ ត្រូវជា ៤១.៦% ជួបបញ្ហាខ្វះសៀវភៅសិក្សាគោល (នាយកដ្ឋានធានាគុណភាពអប់រំ, ២០២០a)។ នៅឆ្នាំ២០១៩ ប្រធានបទ ˝ ការគ្រប់គ្រង និងប្រើប្រាស់សៀវភៅសិក្សាគោលនៅបឋមសិក្សា២០១៩˝ ត្រូវ

7 មន្ទីរអប់រំ យុវជន និងកីឡា

8 នាយកដ្ឋានធានាគុណភាពអប់រំ

9 ការិយាល័យអប់រំ យុវជន និងកីឡា

បានលើកមកធ្វើជាប្រធានបទនៃអធិការកិច្ចតាមប្រធានបទ។

ផ្នែកខាងលើបានបង្ហាញពីប្រវត្តិនៃអធិការកិច្ចនៅកម្ពុជា និងប្រភេទនៃអធិការកិច្ចដែលប្រទេសកម្ពុជាបានកំពុងនឹងអនុវត្ត។ តើអធិការកិច្ចមានអត្ថន័យដូចម្តេច? តើអធិការកិច្ចត្រូវបានធ្វើឡើងក្នុងគោលបំណងអ្វី?

## ២.២ ការងារអធិការកិច្ចលើការបង្រៀន និងរៀនកម្រិតបឋមសិក្សានៅកម្ពុជា

### ២.២.១ និយមន័យ អធិការកិច្ច

ពាក្យថា អធិការកិច្ចជារឿយៗគឺសំដៅលើការត្រួតពិនិត្យ ដែលជាពាក្យមានន័យអវិជ្ជមាន ប៉ុន្តែអធិការកិច្ចជាឧបករណ៍មួយសម្រាប់អនុវត្ត និងកែលម្អផងដែរ។ ការត្រួតពិនិត្យតាមដាន និងវាយតម្លៃបានផ្តល់ព័ត៌មានយ៉ាងសំខាន់ដែលអាចប្រើប្រាស់សម្រាប់ណែនាំ និងផ្តល់យោបល់ផងដែរ (Matthew, 2012; ក្រសួងអប់រំយុវជន និងកីឡា, ២០១៥)។ វាមានភាពស្រដៀងគ្នានឹងលោក Hornby (1995)ដែលថាអធិការកិច្ចគឺជាការពិនិត្យមើលអ្វីមួយ ឬនរណាម្នាក់ក្នុងគោលបំណងរកឱ្យឃើញពីវត្តមានអ្វីមួយ ពិនិត្យមើលអង្គភាពផ្លូវការមួយដើម្បីឱ្យប្រាកដថាតួនាទីផ្សេងៗត្រូវបានអនុវត្តដោយត្រឹមត្រូវ។ អធិការកិច្ចជាដំណើរនៃការតាមដាន ការបង្កើតឡើងវិញ ការអភិវឌ្ឍនៃតួនាទីរបស់អង្គភាពមួយក្នុងគោលបំណងការពារកុំឱ្យមានគម្លាតវត្ថុបំណងដែលអង្គភាពនោះបានរៀបចំ (Başaran,1988) ហើយបើតាម វិទ្យាស្ថានជាតិអប់រំ (២០១៧) អធិការ គឺជាអ្នកជំនាញក្នុងការរកឱ្យឃើញនូវហេតុវិនិច្ឆ័យផ្សេងៗក្នុងវិស័យអប់រំ ។

បើយោងតាម Wilcox (2000) ការងារអធិការកិច្ចគឺជាដំណើរពិនិត្យតាមដានរបស់ភ្នាក់ងារពីខាងក្រៅទៅលើគុណភាព និងការបំពេញការងាររបស់សាលារៀន។ វាត្រូវបានអនុវត្តយ៉ាងទូលំទូលាយក្នុងប្រព័ន្ធអប់រំទូទាំងពិភពលោក។ ប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រទេសជាច្រើនបានកែសម្រួលប្រព័ន្ធអធិការកិច្ចក្នុងវិស័យអប់រំ ដើម្បីសម្របទៅតាមតម្រូវការដែលសាលារៀនត្រូវមានតម្លាភាព គណនេយ្យភាព ជាតុចេញ និងការសម្រេចបានស្តង់ដា។

តាមរយៈលោក Dodd (1968) អធិការកិច្ច ជាដំណើរការជាក់លាក់មួយក្នុងការផ្តល់នូវដំបូន្មានសម្រាប់ការកែលម្អលើសិក្សានៅក្នុងសាលារៀន ដែលរាល់ការផ្តល់ដំបូន្មាននោះត្រូវបញ្ជាក់ដោយរបាយការណ៍។ អធិការកិច្ចជាធាតុមួយនៃដំណើរការរដ្ឋបាល និងរដ្ឋបាលសាលារៀន។ អធិការកិច្ចត្រូវបានគេប្រើសម្រាប់រកឱ្យឃើញពីកម្រិតដែលអាចជឿទុកចិត្តបាននៃគោលដៅនៃការអប់រំដែលបានកំណត់ទុក (Bursalioglu,2002)។ ការធ្វើអធិការកិច្ចបានជួយឱ្យការប្រើប្រាស់ធនធានរបស់អង្គភាពប្រកបដោយប្រសិទ្ធភាព និងទទួលបានប្រយោជន៍ច្រើនដូចជា៖ និរន្តរភាព និងវឌ្ឍនភាពរបស់អង្គភាព (Basar, 1998)។ អធិការកិច្ច គឺការធ្វើការជាមួយបុគ្គល ឬក្រុម។ ប្រសិនបើប្រព័ន្ធមួយគ្មានការធ្វើអធិការកិច្ច វានឹងក្លាយទៅជាការងារឯកការ គ្មានរបៀបរៀបរយ គ្មានស្ថិរភាព និងបាត់បង់អានុភាព (Aydin ,2005)។ អធិការកិច្ច និងការប្រឹក្សាយោបល់ counseling ដែលបង្កើតដោយអធិការនៅតាមសាលារៀនរដ្ឋ និងឯកជនមានគោលបំណងធ្វើឱ្យអង្គភាពបំពេញការងារប្រកបដោយប្រសិទ្ធភាព និងផលិតភាព (Memisoglu & Ekinci, 2013) ។ បើយោងតាមកិច្ចប្រជុំគណៈកម្មការដឹកនាំកម្មវិធីនៅទីក្រុងស្តុកហូម ប្រទេសស៊ុយអែត ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣ បានឱ្យនិយមន័យថា ការងារអធិការកិច្ច ត្រូវតែចូលរួមផ្តល់វិភាគទានដល់ការអភិវឌ្ឍ និងអនុវត្តជាប្រចាំ ដើម្បីឱ្យប្រព័ន្ធស្វ័យវាយតម្លៃមានប្រសិទ្ធភាពនៅគ្រប់សាលារៀនទាំងអស់។

ចំណែកឯ លោក សុភា (២០១២) ទំព័រ២៧ បានលើកឡើងបន្តពី Hargreaves(1995) និងបានកត់សម្គាល់ឃើញថា ការចុះអធិការកិច្ចជាមធ្យោបាយដ៏មានឥទ្ធិពលមួយនៅក្នុងការចុះពិនិត្យតាមដានលើប្រព័ន្ធអប់រំដើម្បីឱ្យដឹងថាការអនុវត្តបាននឹងកំពុងប្រព្រឹត្តទៅតាមស្តង់ដា និងកម្រិតនៃការអនុវត្តការងារទៅតាមដំណាក់កាលនីមួយៗ និងបញ្ជាក់ពីភាពអសកម្មឬអន់ថយ។ លើសពីនេះទៀតនៅក្នុងការសិក្សារបស់ McGlynn & Stalker's(1995) ក៏បានបញ្ជាក់ផងដែរថា ការចុះអធិការកិច្ចគឺត្រូវបានគេប្រើប្រាស់ដើម្បីកំណត់ពីទិដ្ឋភាព និងការអភិវឌ្ឍនៅតាមសាលានីមួយៗដើម្បីបញ្ជាក់ពីកាអនុវត្តជាក់ស្តែង និងការអភិវឌ្ឍ។ បន្ថែមលើសពីនេះទៀត គេបានកំណត់បញ្ហាដែលរកឃើញពីការចុះអធិការកិច្ចគឺដើម្បីពិនិត្យទៅលើសេចក្តី

ណែនាំរបស់រដ្ឋ របស់ក្រសួងចំពោះផែនការអភិវឌ្ឍសាលារៀន និងផ្តល់ជាមូលដ្ឋានសម្រាប់ការវាយតម្លៃនៅកម្រិតថ្នាក់ជាតិស្តីពីការងារអប់រំ( Zachariah Wanzare, Kenneth L.Ward,2000 )។

ជារួមក្នុងលក្ខខណ្ឌណាក៏ដោយ អធិការកិច្ចសាលារៀន គឺជាសកម្មភាពត្រួតពិនិត្យតាមដាន និងវាយតម្លៃការបំពេញការងាររបស់សាលារៀនមួយ ដើម្បីប្រាកដថាសាលារៀននោះបានអនុវត្តបានត្រឹមត្រូវទៅតាមគោលដៅដែលបានកំណត់ទុក។ វាត្រូវធ្វើឡើងដោយអ្នកមកពីខាងក្រៅ ក្នុងការជួយឱ្យអង្គភាពប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងមានការអភិវឌ្ឍ។

| | **ការពិនិត្យតាមដាន** | **វាយតម្លៃ** |
|---|---|---|
| និយមន័យ | • ការពិនិត្យតាមដាន គឺជាប្រតិបត្តិការក្នុងការគ្រប់គ្រងប្រចាំថ្ងៃ ដើម្បីធ្វើការវាយតម្លៃភាពរីកចម្រើន ធៀបទៅនឹងកម្មវត្ថុដែលបានកំណត់។<br>• ការពិនិត្យតាមដានមានរូបភាព ជាការតាមដានធាតុចូល ការតាមដានដំណើរការការងារ ឬសកម្មភាព ការតាមដានទិន្នន័យ ឬសមិទ្ធផល។ ការពិនិត្យតាមដាន នឹងនាំទៅរកការកែលម្អធាតុចូល ការកែតម្រូវដំណើរការការងារ ឬសកម្មភាពទាំងនោះ ប្រសិនបើចាំបាច់។ គោលបំណងនៃការពិនិត្យតាមដានគឺគាំទ្រប្រសិទ្ធភាពនៃការគ្រប់គ្រងតាមរយៈរបាយការណ៍ នៃការបំពេញការងារពិតជាក់ស្តែង ធៀបទៅនឹងចំណុចដៅដែលបានរំពឹងទុក ។ (ក្រសួងអប់រំយុវជននិងកីឡា, ២០១៧ក) | • ការវាយតម្លៃ គឺជាដំណើរការជាប្រព័ន្ធដោយប្រើប្រាស់សូចនាករ ឬលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃ (ភាពពាក់ព័ន្ធ ប្រសិទ្ធភាព ប្រសិទ្ធផល ផលប៉ះពាល់ និងនិរន្តភាព) ទៅលើការងារដែលបានអនុវត្ត។ ធាតុចូល សកម្មភាព ធាតុចេញ ផលសម្រេច និងផលប៉ះពាល់របស់កម្មវិធី គម្រោងអន្តរាគមន៍ សកម្មភាព គឺជាកម្មវត្ថុនៃការវាយតម្លៃ។ ការវាយតម្លៃ គឺជាឧបករណ៍សម្រាប់ធ្វើការសម្រេចចិត្ត ដែលស្ថិតនៅក្នុងខួបនៃដំណើរការ ការកសាងផែនការ ការអនុវត្តផែនការ និងការវាស់វែងការបំពេញការងារ។ (ក្រសួងអប់រំយុវជន និងកីឡា, ២០១៧ក) |

| | | |
|---|---|---|
| | | • ការវាយតម្លៃ គឺជាការប៉ាន់ប្រមាណជាប្រព័ន្ធ និងផ្តោតលើគោលបំណងអំពីគម្រោងកម្មវិធី និងគោលនយោបាយដែលកំពុងអនុវត្តឬចប់ទៅហើយ។ |
| គោលបំណង | • រកចំណុចខ្លាំង និងចំណុចខ្សោយ<br>• ជួយកែលម្អទាន់ពេលវេលា<br>• ជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាព | • ធ្វើចំណាត់ថ្នាក់លើលទ្ធផលចុងក្រោយ<br>• ផ្តល់សញ្ញាបត្រ និងការទទួលស្គាល់<br>• កែប្រែការអនុវត្តសកម្មភាពថ្មី |

***តារាង 4៖*** *ភាពខុសគ្នារវាងការពិនិត្យតាមដាន និងវាយតម្លៃ*

ចំណុចខាងលើ បានបកស្រាយពីនិយមន័យមួយចំនួននៃពាក្យ "អធិការកិច្ច"។ តើអធិការកិច្ចសាលារៀននៅកម្ពុជា ត្រូវបានធ្វើឡើងក្នុងគោលបំណងអ្វី? ហើយអធិការត្រូវមានភារកិច្ចសំខាន់ៗអ្វីខ្លះ? ខាងក្រោមនេះ យើងនឹងបកស្រាយអំពីគោលបំណងនៃអធិការកិច្ច និងភារកិច្ចរបស់អធិការ។

### ២.២.២ គោលបំណងអធិការកិច្ច

ការធ្វើអធិការកិច្ចសាលារៀន គឺជាយន្តការត្រួតពិនិត្យ និងតាមដាន ថាតើសាលារៀនបានសម្រេចតម្រូវការរបស់ខ្លួនត្រឹមកម្រិតណា។ អធិការកិច្ចក៏អាចវាយតម្លៃផងដែរ ថាតើសាលារៀនអាចសម្រេចបានទំនួលខុសត្រូវរបស់ខ្លួនទាក់ទងនឹងគោលការណ៍ទាំងឡាយ ដែលមានចែងក្នុងច្បាប់ស្តីពីការអប់រំបានត្រឹមកម្រិតណា។ អធិការកិច្ចត្រូវធ្វើការវាយតម្លៃថា តើសកម្មភាពអប់រំដែលសាលារៀនកំពុងធ្វើទាក់ទងនឹងវត្ថុបំណង និងកម្មវិធីសិក្សាជាតិសម្រេចបានល្អត្រឹមកម្រិតណាហើយ។ អាចនិយាយបានថា ភារកិច្ចសំខាន់បំផុតរបស់អធិការគឺពិនិត្យមើលថាតើសាលារៀនមានប្រព័ន្ធសម្រាប់ធ្វើស្វ័យវាយតម្លៃ និងយុទ្ធសាស្ត្រស្វ័យវាយកែលម្អហើយឬនៅ (ក្រសួងអប់រំយុវជននិងកីឡា, ២០១៥)។ ជាសង្ខេបរួមគោលបំណងរួមរបស់អធិការកិច្ច គឺកែលម្អអ្នកសិក្សាទាំងអស់តាមរយៈការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្ត និងពង្រឹងសមត្ថភាព

ធ្វើស្វ័យវាយតម្លៃ។ អធិការកិច្ចក៏ត្រូវវាយតម្លៃសាលារៀនផងដែរ ដើម្បីបង្ហាញអំពីចំណេះដឹង និងស្ថានភាពជាក់ស្តែងរបស់ប្រទេស។

គោលបំណងនៃការធ្វើអធិការកិច្ច គឺដើម្បីទទួលបាននូវការអនុវត្តដែលកាន់តែប្រសើរឡើងនៅក្នុងសាលារៀនដែលបានពិនិត្យជាមួយនឹងការផ្តោតលើលទ្ធផលសិក្សារបស់សិស្ស និងសុខុមាលភាពសង្គម ហើយយកចំណេះដឹងទាំងនោះទៅផ្សព្វផ្សាយដល់សាលារៀនដទៃទៀតនៅក្នុងប្រទេស និងជូនក្រសួងអប់រំ យុវជន និងកីឡា។

*រូបភាព 2៖ គោលបំណងនៃអធិការកិច្ច*




បើយោងតាម របាយការណ៍សាលារៀន អធិការកិច្ចតាមកាលកំណត់ របស់នាយកដ្ឋានជានាគុណភាពអប់រំ អធិការកិច្ចតាមសាលារៀន មានគោលបំណងពិនិត្យ និងតាមដានកម្រិតដែលសាលារៀននានាអាចបំពេញបានទៅតាមលក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋាន គោលបំណងថ្នាក់ជាតិ និងកម្មវិធីសិក្សាជាតិ។ អធិការកិច្ចបែបនេះក៏ធ្វើការវាយតម្លៃផងដែរ ថាតើសកម្មភាពអប់រំ និងសាលារៀនកំពុងដំណើរការ

ទៅតាមកត្តានាំឱ្យមានជោគជ័យ ដែលរកឃើញដោយការស្រាវជ្រាវបែបទំនើប យ៉ាងដូចម្ដេចខ្លះ? គោលបំណងមួយទៀត គឺដើម្បីពិនិត្យមើលថា តើសាលារៀនមានប្រព័ន្ធស្វ័យវាយតម្លៃ និងយុទ្ធសាស្ត្រសម្រាប់កែលម្អដែរឬទេ? របាយការណ៍បូកសរុប និងទិន្នន័យរួម ដែលទទួលបានពីការធ្វើអធិការកិច្ចនេះ គឺជាប្រភពព័ត៌មានដ៏មានប្រយោជន៍សម្រាប់រៀបចំគោលនយោបាយអប់រំ និងកំណត់ពីអាទិភាពអប់រំជាតិ។

យោងតាមលោក Machumu (2012) អធិការកិច្ចសាលារៀនគឺបង្កើតឡើងស្របតាមផ្លូវច្បាប់ដើម្បីត្រួតពិនិត្យមើលសាលារៀន និងពិនិត្យឱ្យឃើញច្បាស់ថាសាលារៀនបានអនុវត្តតាមតួនាទី គោរពតាមផ្លូវច្បាប់ អនុវត្តតាមកម្មវិធីសិក្សា ជាពិសេសអនុវត្តតាមគោលនយោបាយស្តង់ដា។ អធិការកិច្ចសាលារៀនមានការទាក់ទងទៅនឹងគណនេយ្យភាពគ្រូបង្រៀន និងគោលដៅនៃការអប់រំ ដើម្បីពង្រឹងគុណភាពអប់រំ។ ហើយអធិការកិច្ចជាសកម្មភាពអប់រំត្រូវបានអនុវត្តសម្រាប់គោលបំណងដូចខាងក្រោម៖

(១) ដើម្បីធ្វើឱ្យប្រាកដថាស្តង់ដារអប្បបរមាត្រូវបានប្រកាន់ខ្ជាប់។ ចេតនានៃធ្វើការនេះ គឺដើម្បីផ្តល់ឱកាសអប់រំស្មើៗគ្នាសម្រាប់កុមារទាំងអស់

(២) ផ្តល់នូវវេទិកាមួយ តាមរយៈការផ្តល់ដំបូន្មាន និងការកែលម្អសម្រាប់ជាប្រយោជន៍នៃការធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃការបង្រៀននៅក្នុងសាលាតាមរយៈការកែលម្អកន្លែងអប់រំ

(៣) ធ្វើឱ្យប្រាកដថា ការចំណាយថវិកាក្នុងការដំណើរការសាលារៀនប្រកបដោយភាពត្រឹមត្រូវ និងប៉ិនប្រសប់

(៤) ដើម្បីឱ្យការប្រើប្រាស់ធនធានមនុស្ស និងសម្ភារូបវ័ន្តបានត្រឹមត្រូវ ដូចជា៖ កន្លែងទំនេរ ទំហំថ្នាក់រៀន ស្ថានភាពនៃទីកន្លែង ភាពខ្លាំងរបស់បុគ្គលិក វិធីសាស្ត្របង្រៀន

(៥) ជំរុញនិងផ្តល់ការណែនាំ ពីការអនុវត្តការអប់រំដែលគួរឱ្យចង់បាន ខណៈពេលដែលមានការអនុវត្តការអប់រំអវិជ្ជមាននានា

(៦) ដើម្បីផ្តល់ជាមូលដ្ឋាន និងអាចផ្ទៀតផ្ទាត់បាន ទៅលើសកម្មភាពសិក្សាមួយចំនួន ដែលផ្តួចផ្តើម

ដោយគ្រូបង្រៀន នាយកសាលា អធិការ និងរាជរដ្ឋាភិបាល (Ojelabi,1981)។

ចំណែកឯលោក Su (1974) បានបង្ហាញពីគោលបំណងរបស់អធិការកិច្ចសាលារៀនផងដែរ ដូចជាៈ

(១) ផ្តល់ភាពសហការក្នុងទំនាក់ទំនងគ្រូ-សិស្ស

(២) ផ្តល់ការសហការ និងទំនាក់ទំនងរវាងអធិការ និងគ្រូបង្រៀន

(៣) ផ្តល់ផែនការ និងនិរន្តរភាពនៃអធិការកិច្ច

(៤) ផ្តល់ការវាយតម្លៃ

(៥) បង្កើតការស្រាវជ្រាវ ស៊ើបអង្កេត និងធ្វើការកែតម្រូវ។

យោងលើក្របខណ្ឌការងារ និងការរៀបចំចាត់ចែងនៃការចុះអធិការកិច្ចរបស់ Ofsted Inspection នៅឆ្នាំ២០០៩ បានកំណត់នូវចំណុចអាទិភាពមួយចំនួននៃគោលបំណងក្នុងការចុះអធិការកិច្ចគឺៈ

(១) ជំរុញឱ្យមានការអភិវឌ្ឍ គឺក្រុមអធិការត្រូវផ្តល់ជាអនុសាសន៍ជាក់លាក់ដោយផ្អែកទៅលើការវិភាគពិភាក្សាលើចំណុចខ្លាំង និងចំណុចខ្សោយរបស់សាលារៀន

(២) ធ្វើការវាយតម្លៃទៅលើសមិទ្ធផល និងពង្រីកការអភិវឌ្ឍចំពោះកុមារ សិស្សានុសិស្សឱ្យកាន់តែប្រសើរឡើងព្រមទាំងពិនិត្យទៅលើភាពអសកម្ម ឬហានិភ័យផងដែរ

(៣) ធ្វើការវាយតម្លៃទៅលើការបង្រៀន និងរៀននៅតាមថ្នាក់រៀននីមួយៗ

(៤) វាយតម្លៃចំពោះភាពជោគជ័យរបស់សាលារៀនដែលបានជំរុញឱ្យមានឱកាសស្មើភាពគ្នាក្នុងការទទួលបាននូវសេវាអប់រំដោយមិនរើសអើង

(៥) ពិនិត្យទៅលើបែបបទសុវត្ថិភាពរបស់កុមារ

(៦) ជំរុញឱ្យមានការចូលរួម និងបន្តចុះអធិការជាប្រចាំ

(៧) ជំរុញឱ្យមានការចូលរួម ធ្វើការវិភាគ វាយតម្លៃ និងយកមកពិចារណាតាមរយៈទស្សនៈរបស់មាតាបិតាសិស្ស និងអាណាព្យាបាល

(៨) ធ្វើការវាយតម្លៃពីប្រសិទ្ធភាពនៃដំណើរការរបស់សាលារៀននៅក្នុងភាពជាដៃគូ ក្នុងគោលបំណងជំរុញប្រសិទ្ធផលនៃការសិក្សារបស់កុមារឱ្យកាន់តែប្រសើរឡើង។

អធិការកិច្ចសាលារៀនត្រូវបានធ្វើឡើងនៅតាមសាលារៀននានាដោយមន្ត្រីអប់រំដែលជាអ្នកមកពីខាងក្រៅសាលារៀន ក្រោមការចាត់តាំងពីមន្ទីរអប់រំយុវជន និងកីឡា រាជធានី/ខេត្ត និងក្រសួងអប់រំយុវជន និងកីឡា។ គេច្រើនហៅមន្ត្រីនោះថា អធិការ។ តើអធិការត្រូវមានតួនាទីអ្វីខ្លះក្នុងវិស័យអប់រំ ?

### ២.២.៣ ភារកិច្ចសំខាន់ៗរបស់អធិការបឋមសិក្សា

អធិការបឋមសិក្សាមានភារកិច្ចសំខាន់ៗ ៤ គឺ ៖

(១) ណែនាំការអនុវត្តគោលនយោបាយ ការណែនាំផ្សេងៗ កម្មវិធីសិក្សា និងសៀវភៅសិក្សា

(២) ជួយបណ្តុះបណ្តាល និងរិះគ្រឹតការគ្រូបង្រៀនតាមការចាំបាច់

(៣) ធ្វើអធិការកិច្ចវាយតម្លៃគ្រូបង្រៀន និងនាយកសាលារៀនព្រមទាំងផ្តល់យោបល់ក្នុងរបាយការណ៍អធិការកិច្ចទៅលើបញ្ហាផ្សេងៗពាក់ព័ន្ធដល់ការងារបុគ្គលិក

(៤) ធ្វើទំនាក់ទំនងជាមួយសហគមន៍ អាជ្ញាធរ អង្គភាព ស្ថាប័ន និងមជ្ឈដ្ឋាននានាដើម្បីលើកកម្ពស់គុណភាពអប់រំ។

- អធិការបឋមសិក្សាត្រូវចាត់តាំងឱ្យបម្រើការងារនៅការិយាល័យអធិការកិច្ច នៃនាយកដ្ឋានបឋមសិក្សា និងមត្តេយ្យសិក្សាក្រោមការដឹកនាំផ្ទាល់របស់ប្រធាននាយកដ្ឋានបឋម និងមត្តេយ្យសិក្សា។ ចំណែកឯអធិការនៅតាមរាជធានី ខេត្ត ត្រូវប្រមូលផ្តុំនៅការិយាល័យអធិការកិច្ចនៃមន្ទីរអប់រំយុវជន និងកីឡា ក្រោមការដឹកនាំផ្ទាល់របស់ប្រធានមន្ទីរ។ (ក្រសួងអប់រំយុវជន និងកីឡា, ២០១៥, ទំព័រ៣)។

បើយោងតាម ក្រសួងអប់រំយុវជន និងកីឡា (២០១៥) អធិការមានតួនាទីជាមន្ត្រីគ្រប់គ្រងអប់រំ និងជាសេនាធិការរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលត្រូវបានតែងតាំងឱ្យបំពេញភារកិច្ចនៅថ្នាក់ក្រសួង

(នាយកដ្ឋានធានាគុណភាពអប់រំ) និងការិយាល័យអធិការកិច្ចនៅថ្នាក់រាជធានី ខេត្តតាមការចាំបាច់ និងតម្រូវការ។ អធិការត្រូវមានមនសិការ និងស្មារតីទទួលខុសត្រូវខ្ពស់ចំពោះមុខក្រសួង និងចំពោះមុខរាជធានីខេត្តដោយខិតខំធ្វើឱ្យឃើញច្បាស់ពីការរួមចំណែករបស់ខ្លួនក្នុងការលើកកម្ពស់គុណភាពអប់រំតាមរយៈការងារអធិការកិច្ច។ ទន្ទឹមនឹងនេះ អធិការដើរតួសំខាន់បួនដូចខាងក្រោម៖

(១) តំណាងអាជ្ញាធរមានសមត្ថកិច្ច តំណាងឱ្យក្រសួងអប់រំ យុវជន និងកីឡា

(២) ជាអ្នកបច្ចេកទេសត្រួតពិនិត្យលើគ្រប់មុខវិជ្ជាទាំងផ្នែកភាសា ផ្នែកវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម

(៣) ជាគ្រូឧទ្ទេសពេលជួបបញ្ហានីមួយៗ មានការប្រជុំគរុកោសល្យត្រង់ៗ និងជាសម្ងាត់

(៤) ធ្វើអធិការកិច្ចលើប្រព័ន្ធសាលារៀនទាំងមូល។

ក្រៅពីតួនាទីខាងលើ អធិការនៅមានភារកិច្ច៥ជាមូលដ្ឋានទៀតគឺ៖ (១) ជាអ្នកណែនាំអនុវត្តគោលនយោបាយអប់រំ (២) ជាអ្នកវាយតម្លៃ (៣) ជាអ្នកធ្វើអធិការកិច្ច (៤) ជាទីប្រឹក្សាគរុកោសល្យ និង (៥) ជាអ្នកផ្តល់ការវិនិច្ឆ័យផ្សេងៗតាមផ្លូវច្បាប់។

យោងតាមប្រកាសលេខ ៦៤៩ អយក.ប្រក (ក្រសួងអប់រំយុវជន និងកីឡា, ២០១៧ខ) បានបែងចែកតួនាទី និងភារកិច្ចរបស់តំបន់អធិការកិច្ចអប់រំ មានដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវ វិភាគ និងវាយតម្លៃគុណភាព និងប្រសិទ្ធភាពវិស័យអប់រំ
- ពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សា និងការប្រើប្រាស់សម្ភារសិក្សានានា នៅគ្រប់គ្រឹះស្ថានសាធារណៈ និងឯកជន
- ពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្ត ឬបំពេញលក្ខខណ្ឌស្តង់ដាជាតិអប់រំរបស់គ្រឹះស្ថានសិក្សានានា
- ពិនិត្យតាមដាន និងលើកសំណើដោះស្រាយករណីមិនប្រក្រតីនានាដែលពាក់ព័ន្ធទៅនឹងបច្ចេកទេសអប់រំ

- លើកសំណើគម្រោងថវិកាកម្មវិធីអំពីការងារអធិការកិច្ចតាមការកំណត់ និងតេស្តវង្វាយតម្លៃ ដើម្បីដាក់បញ្ចូលក្នុងកញ្ចប់ថវិកាកម្មវិធីរបស់អង្គភាពថវិការាជធានី ខេត្ត
- សម្របសម្រួល និងរៀបចំផែនការសម្រាប់ធ្វើអធិការកិច្ចតាមកាលកំណត់ និងតាមវដ្តអធិការកិច្ចអប់រំនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- សហការជាមួយអង្គភាពពាក់ព័ន្ធដើម្បីពិនិត្យលើកសំណើ និងដោះស្រាយការងារបច្ចេកទេសអប់រំ
- ធ្វើរបាយការណ៍ស្តីពី សកម្មភាពការងារអធិការកិច្ចតាមកាលកំណត់ជូនថ្នាក់ដឹកនាំតាមឋានានុក្រម
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការចាំបាច់។

ដើម្បីឱ្យការធ្វើអធិការកិច្ចសាលារៀនមួយទទួលបានជោគជ័យ និងទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ តើអធិការប្រើប្រាស់មានវិធីសាស្ត្រអ្វីខ្លះ ក្នុងការធ្វើអធិការកិច្ច? ហើយអ្នកណាខ្លះដែលត្រូវចូលរួមក្នុងសកម្មភាពអធិការកិច្ចសាលារៀននេះ?

### ២.២.៤ វិធីសាស្ត្រអធិការកិច្ច

ការចុះអធិការកិច្ចទាមទារឱ្យអធិការមានចំណេះដឹង ជំនាញអធិការ និងវិធីសាស្ត្រក្នុងការប្រមូលព័ត៌មានដើម្បីឱ្យបានព័ត៌មានជាក់លាក់ និងលម្អិតសម្រាប់ជួយកែលម្អសាលារៀន ក៏ដូចជាលើកកម្ពស់គុណភាពអប់រំ (វិទ្យាស្ថានជាតិអប់រំ, ២០១៧,ទំព័រទី៧២)។ វិធីសាស្ត្រដែលអធិការប្រើក្នុងការប្រមូលព័ត៌មានគឺត្រីកោណព័ត៌មាន(វិធីជ្រុងបី)ដែលរួមមាន៖

#### ២.២.៤.១ ការសម្ភាស

មានប្រភេទសំណួរច្រើនសម្រាប់សួរនាយកសាលា គ្រូបង្រៀន សិស្ស និងសហគមន៍ដូចខាងក្រោមគឺ

- សំណួរបិទ

- សំណួរបើក

**ចំពោះនាយកសាលា៖** សំណួរបិទអាចត្រូវប្រើមុន និងបន្ទាប់មកប្រើសំណួរបើក។ ឧទាហរណ៍៖

- តើការបង្រៀនសម្របតាមតម្រូវការសិស្សដែរឬទេ តើនាយកសាលាធ្វើដូចម្តេចដើម្បីប្រាកដថា ការបង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស?
- ចូរប្រាប់ពីរបៀបបង្រៀនរបស់គ្រូក្នុងការជួយសិស្សខ្សោយក្នុងថ្នាក់របស់គាត់

ការសម្ភាសនេះអាចផ្តល់ព័ត៌មានឱ្យអធិការបន្ថែមទៀត៖ ចម្លើយនៃសំណួរចុងក្រោយខាងលើអាចបង្ហាញថានាយកសាលាមានការយល់ឃើញមិនច្បាស់លាស់ពីការបង្រៀននៅក្នុងថ្នាក់ អធិការអាចប្រើព័ត៌មាននេះ ដើម្បីតាមដានផ្នែកដែលត្រូវវាយតម្លៃដូចជាភាពជាអ្នកដឹកនាំ និងគ្រប់គ្រងស្វ័យវាយតម្លៃសាលារៀន។

**ចំពោះគ្រូ៖** សំណួរបិទអាចត្រូវប្រើមុន និងបន្ទាប់មកប្រើសំណួរបើក។ ឧទាហរណ៍៖

- តើការបង្រៀនរបស់អ្នកសម្របនឹងតម្រូវការរបស់សិស្សដែរឬទេ? ចូរលើកឧទាហរណ៍ខ្លះមកបញ្ជាក់។
- ចូរប្រាប់ពីរបៀបដែលអ្នកជួយសិស្សខ្សោយក្នុងថ្នាក់។ ក្នុងករណីនេះព័ត៌មានបន្ថែមអាចជាចម្លើយដែលបង្ហាញថាគ្រូបង្រៀនធ្វើសកម្មភាពខុសៗគ្នា។

អធិការអាចប្រើព័ត៌មាននេះដើម្បីតាមដានផ្នែកដែលត្រូវវាយតម្លៃដូចជាភាពជាអ្នកដឹកនាំ និងគ្រប់គ្រង ស្វ័យវាយតម្លៃសាលារៀន។

**ចំពោះសិស្ស៖** សំណួរបិទអាចជា៖

- ប្រសិនបើអ្នកត្រូវការជំនួយបន្ថែម អ្នកអាចទទួលបានជំនួយនោះដែរឬទេ? តើអ្នកនឹងទទួលបានជំនួយនោះដោយរបៀបណា? គ្រប់មុខវិជ្ជា និងគ្រប់គ្រូដែរឬទេ?

សំណួរបើកអាចជា៖

- ចូររៀបរាប់ពីអ្វីដែលអ្នកគិតថាជាចរិតលក្ខណៈគ្រូបង្រៀនល្អ? សម្រាប់សិស្សអាចបង្ហាញពីព័ត៌មានដែលយើងមិនអាចរំពឹងទុកជាច្រើន។ ព័ត៌មានបន្ថែមទាំងនេះអាចត្រូវបានយកមកប្រើនៅពេលអធិការសម្ភាសនាយកសាលា គ្រូបង្រៀនដើម្បីវាយតម្លៃផ្នែកផ្សេងៗទៀត។

**ចំពោះសហគមន៍៖** សំណួរបើកអាចជា៖

- សូមលោក អ្នកប្រាប់ពីទំនាក់ទំនងរវាងសហគមន៍ និងសាលារៀន (ការគាំទ្រដល់គ្រូបង្រៀនទាំង សម្ភារ និងស្មារតី...)
- តើសាលារៀននេះធ្លាប់កើតមាននូវបាតុភាពមិនប្រក្រតីដែរឬទេ ? ប្រសិនបើមាន តើសហគមន៍ចូលរួមទប់ស្កាត់តាមរូបភាពណាខ្លះ ?

### ២.២.៤.២ ការសង្កេតថ្នាក់រៀន

អធិការត្រូវសង្កេតមេរៀនឱ្យបានគ្រប់ល្មមទៅតាមវ័យសិស្ស ឬថ្នាក់នីមួយៗជាពិសេសថ្នាក់ដែលជាតំណាង។ ដើម្បីសម្រេចវត្ថុបំណងនេះក្នុងរយៈពេល ៥៥% ឬ៦៥%នៃពេលស្ថិតនៅក្នុងសាលារៀន ចាំបាច់ត្រូវតែលៃពេលវេលាសម្រាប់សង្កេតថ្នាក់។ ពេលមើលថ្នាក់ អធិការមិនត្រូវអន្តរាគមន៍អ្វីទាំងអស់ដើម្បីកុំឱ្យរំខានសកម្មភាពបង្រៀនរបស់គ្រូ។ ត្រូវមានឱកាសសម្រាប់សំណេះសំណាលជាមួយគ្រូអំពីការងាររបស់គាត់។ ជួបសម្ភាសសិស្សថាតើសិស្សយល់ឬទេពីអ្វីដែលបានធ្វើ។ មើលសៀវភៅសិស្សវាយតម្លៃពីគុណភាពនៃការងាររបស់ពួកគេ។ អធិការត្រូវកត់សម្គាល់ពីអ្វីដែលព្យួរនៅជញ្ជាំងដែលជាការងាររបស់សិស្ស ដែលអាចបង្ហាញពីស្តង់ដាដែលសិស្សមាន។ អធិការត្រូវចាំបាច់កត់ត្រាអំពីការវាយតម្លៃ អំពីចំណុចខ្វះខាតដែលខ្លួនបានឃើញពេលបង្រៀន និងមិនត្រូវឱ្យអធិការមានលើសពីម្នាក់ទេ ពេលចូលសង្កេតថ្នាក់ (លើកលែងតែពេលបណ្តុះ-បណ្តាលអធិការ)។ ជាធម្មតាត្រូវផ្តល់ព័ត៌មានត្រលប់ (លើកលែងតែករណីពិសេស) ការសំណេះសំណាលត្រូវធ្វើភ្លាមៗ បន្ទាប់ពីធ្វើអធិការកិច្ចសង្កេតថ្នាក់រួច។

អធិការជំនាញអាចមើលឃើញបញ្ហាដោយសារប្រតិកម្មរបស់សិស្សថា តើគ្រូអនុវត្តតាមឬអត់? តើគ្រូបង្រៀនបានកត់ត្រានូវអ្វីដែលសិស្សយល់ឬទេ? តើគ្រូជួយសិស្សខ្សោយឬទេ? តើគ្រូអនុវត្តតាមខ្លឹមសារមេរៀន ឬលំហាត់ដែរឬទេ សន្លឹកកិច្ចការសង្កេតអាចជាជំនួយយ៉ាងល្អបំផុត ប៉ុន្តែវាអាចជាការរំខានដល់គ្រូ និងសិស្សផងដែរ។ ខាងក្រោមនេះជាសកម្មភាពក្នុងថ្នាក់រៀនដែលក្រុមអធិការកិច្ចត្រូវត្រួតពិនិត្យ។

| **បណ្ណសង្កេតថ្នាក់សម្រាប់អធិការកិច្ច** |
| --- |
| **បរិយាកាសសុវត្ថិភាព និងលើកទឹកចិត្តដល់ការរៀនសូត្រ** |
| • គ្រូបង្កើតបរិយាកាសវិជ្ជមាន<br>• គ្រូប្រតិបត្តិចំពោះសិស្សទាំងឡាយដោយការគោរព<br>• គ្រូរក្សាសណ្តាប់ធ្នាប់ក្នុងថ្នាក់រៀនបានល្អ<br>• គ្រូផ្តល់ឱកាសឱ្យសិស្សមានសិទ្ធិឆ្លើយបញ្ចេញយោបល់ប្រកបដោយសមធម៌ |
| **ការសម្របតាមតម្រូវការសិស្ស មានការផ្លាស់ប្តូរកិច្ចការ និងដាក់កិច្ចការពិបាកៗ** |
| • គ្រូកែសម្រួលការបង្រៀនឱ្យស្របតាមតម្រូវការសិស្ស<br>• គ្រូយកចិត្តទុកដាក់ចំពោះសិស្សប្រុស/ស្រី ស្មើគ្នា<br>• គ្រូយកចិត្តទុកដាក់ចំពោះសិស្សរៀនលឿន/យឺត<br>• គ្រូប្រើប្រាស់វិធីសាស្ត្រ ការងារក្រុម ដៃគូ និងបុគ្គល<br>• មានតុល្យភាពរវាងសកម្មភាពរបស់គ្រូ និងសិស្ស<br>• សិស្សប្រុស និងសិស្សស្រីសកម្មដូចគ្នា |
| **រចនាសម្ព័ន្ធរបស់មេរៀន** |
| • គ្រូគ្រប់គ្រងពេលវេលាបានល្អ |

| |
|---|
| •មេរៀនមានរចនាសម្ព័ន្ធច្បាស់លាស់<br>•គ្រូផ្ដល់ការពន្យល់ ពិពណ៌នា និងសង្ខេបច្បាស់លាស់<br>•គ្រូខិតខំឱ្យសិស្សទាំងអស់មានសកម្មភាព និងទទួលបានចំណេះដឹងស្មើៗគ្នា<br>•សិស្សសហការគ្នា និងជួយគ្នាទៅវិញទៅមក<br>•គ្រូពិនិត្យដើម្បីឱ្យដឹងថាសិស្សយល់ ឬមិនយល់<br>•គ្រូផ្ដល់ដំបូន្មានដល់សិស្ស<br>•គ្រូផ្ដល់កិច្ចការផ្ទះដល់សិស្ស |
| **បំណិនក្នុងការបង្រៀន** |
| •គ្រូប្រើប្រាស់វិធីសាស្ត្រផ្សេងគ្នាដូចជា ការងារក្រុម ដៃគូ បុគ្គល<br>•គ្រូប្រើក្ដារខៀន និងសម្ភារឧបទេស<br>•គ្រូប្រើសំណួរសម្បូរបែប |
| **ការងាររដ្ឋបាល** |
| •រដ្ឋបាលគ្រូ (សៀវភៅពិន្ទុសិស្ស សៀវភៅហៅឈ្មោះសិស្ស សៀវភៅកិច្ចតែងការបង្រៀន បំណែងចែកកម្មវិធីសិក្សា សៀវភៅកំណត់ហេតុប្រជុំ សៀវភៅអនុសាសន៍ ....)<br>•រដ្ឋបាលថ្នាក់ (តារាងកិត្តិយស តារាងកម្មវិធីសិក្សា បញ្ជីសារពើភណ្ឌ កាលវិភាគ វេនសម្អាត តារាងចំណាត់ថ្នាក់ប្រចាំខែ តារាងចំណាត់ថ្នាក់ប្រឡងឆមាស តារាងចំណាត់ថ្នាក់ប្រចាំឆមាស បទបញ្ជាផ្ទៃក្នុង) |

***តារាង 5៖** បណ្ណសង្កេតថ្នាក់សម្រាប់អធិការកិច្ចថ្នាក់រៀន*

គោលបំណងនៃការសង្កេតមើលថ្នាក់រៀនគឺដើម្បីទទួលបានព័ត៌មានអំពីអ្វីដែលកើតឡើងជាក់ស្ដែងនៅក្នុងថ្នាក់រៀន។ ការសង្កេតថ្នាក់រៀនត្រូវបានរៀបចំឡើងដោយមានការកំណត់ចំណុច ដែលត្រូវវាយតម្លៃទុកជាមុន ពោលគឺចំណុចដែលគួរទទួលបានព័ត៌មានតាមរយៈការសង្កេតនេះ។ ទោះបីជាការសង្កេតថ្នាក់រៀន

គឺជាផ្នែកមួយដ៏សំខាន់របស់អធិការកិច្ចយ៉ាងណាក៏ដោយ តែវាជាពេលខ្លីនៃការដំណើរការបង្រៀននៅក្នុងថ្នាក់រៀន និងសាលារៀនតែប៉ុណ្ណោះ ហើយកំហុសដែលអាចកើតឡើងដូចជា ថ្នាក់រៀនគ្មានសណ្តាប់ធ្នាប់ អាកប្បកិរិយារបស់គ្រូ និងសិស្សខុសពីធម្មតា ធ្វើឱ្យយើងមិនអាចសន្និដ្ឋានថាថ្នាក់រៀននេះតំណាងឱ្យសាលារៀនទាំងមូលបានទេ។

### ២.២.៤.៣ ការពិនិត្យឯកសារ

អធិការត្រូវពិនិត្យទិន្នន័យដែលមានស្រាប់នៅក្នុងសាលារៀន ដូចជាឯកសារលទ្ធផលការសិក្សារបស់សិស្សតាមឆ្នាំនីមួយៗ ប្លង់អគារសិក្សា ផែនទីសិក្សា ឬផែនទីតាមខ្នងផ្ទះ តារាងស្វ័យវាយតម្លៃសាលារៀន បញ្ជីសារពើភណ្ឌ ( ទ្រព្យសម្បត្តិរដ្ឋ ) ទិន្នន័យបុគ្គលិកគ្រូ សិស្ស ថ្នាក់រៀន អគារសិក្សា របាយការណ៍ប្រជុំបច្ចេកទេស របាយការណ៍ប្រជុំបូកសរុបធមាស របាយការណ៍ថ្នាក់និទស្សន៍ របាយការណ៍អធិការកិច្ចអចិន្ត្រៃយ៍របស់នាយក ផែនការប្រតិបត្តិប្រចាំឆ្នាំ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន របាយការណ៍PRE[10] – PRI[11] ស្ថិតិសិស្សឡើងថ្នាក់ សិស្សត្រួតថ្នាក់ សិស្សបោះបង់ សិស្សឆ្លងភូមិសិក្សា របាយការណ៍ការគ្រប់គ្រងរបស់ក្រុមប្រឹក្សាយុវជន គំរូសៀវភៅលំហាត់ កិច្ចតែងការបង្រៀន ឯកសារបែងចែកតួនាទីនៅក្នុងសាលាជាដើម។

*រូបភាព 3៖ វិធីសាស្ត្រអធិការកិច្ច*




ជារួមក្នុងការចុះធ្វើអធិការកិច្ចសាលារៀន អធិការត្រូវប្រមូលព័ត៌មានឱ្យបានច្បាស់លាស់ និង គ្រប់ជ្រុងជ្រោយ។ វិធីសាស្ត្រដែលអធិការប្រើក្នុងការប្រមូលព័ត៌មានមានបីសំខាន់ៗគឺ ការសម្ភាសជាមួយនាយកសាលា គ្រូបង្រៀន សិស្ស និងសហគមន៍, ការសង្កេតថ្នាក់រៀន និងបរិស្ថានសាលារៀនទាំងមូល, ចុងក្រោយ

[10] តារាងជំរឿនស្ថិតិសាលារៀនចំណោះទូទៅសាធារណៈ ( សម្រាប់មត្តេយ្យសិក្សា )
[11] តារាងជំរឿនស្ថិតិសាលារៀនចំណោះទូទៅសាធារណៈ ( សម្រាប់បឋមសិក្សា )

គឺការពិនិត្យឯកសារនានាក្នុងសាលារៀន រួមទាំងឯកសាររដ្ឋបាលរបស់គ្រូបង្រៀនផងដែរ។

### ២.២.៥ ដំណើរការអធិការកិច្ច

ការធ្វើអធិការកិច្ចសាលារៀនតាមកាលកំណត់ នៅសាលារៀនមួយ ត្រូវចំណាយពេលពី១ ឬ២ថ្ងៃ ដោយមានអធិការពីររូប និងត្រូវបានបែងចែកជាបីដំណាក់កាល។ ខាងក្រោមនេះជាដំណាក់កាលនៃដំណើរការអធិការកិច្ច រួមទាំងសកម្មភាពគោលមួយចំនួនដែលអធិការត្រូវយកចិត្តទុកដាក់។

| ដំណើរការអធិការកិច្ច | សកម្មភាព |
|---|---|
| មុនពេលអធិការកិច្ច | • ផ្តល់ព័ត៌មានដល់សាលារៀនអំពីកិច្ចការអធិការកិច្ច និងកំណត់ពេលវេលា<br>• ពិនិត្យទិដ្ឋភាពទូទៅ និងសកម្មភាពរបស់សាលារៀន (របាយការណ៍សាលារៀន ទិន្នន័យសាលារៀន..)<br>• សរសេររបៀបវារៈសម្រាប់អធិការកិច្ច២ថ្ងៃ និងកែសម្រួលប្រសិនបើចាំបាច់<br>• រៀបចំឧបករណ៍សម្រាប់ការសម្ភាស(នាយក គ្រូ សិស្ស សហគមន៍) និងសង្កេតថ្នាក់រៀន<br>• ពិនិត្យឡើងវិញលិខិតបទដ្ឋានគតិយុត្ត សេចក្តីណែនាំផ្សេងរបស់ក្រសួងអប់រំ យុវជន និងកីឡា (ច្បាប់អប់រំ គោលនយោបាយគ្រូបង្រៀន អនុសញ្ញាស្តីសិទ្ធិកុមារ កម្មវិធីសិក្សាគ្រប់មុខវិជ្ជា គ្រប់កម្រិត...) |
| ក្នុងពេលអធិការកិច្ច | • រៀបចំប្រជុំជាមួយនឹងនាយក និងគណៈគ្រប់គ្រងសាលា<br>• ណែនាំខ្លួន និងគោលបំណងអធិការកិច្ច<br>• កំណត់ពេលវេលា និងរបៀបវារៈដាក់លាក់។ សម្របសម្រួល បើសិនចាំបាច់<br>• ជួបគណៈគ្រប់គ្រងសាលា ប្រធានក្រុមមុខវិជ្ជា គ្រូបង្រៀនឱ្យបានឆាប់តាមដែលអាចធ្វើបាន ព្រមទាំងប្រាប់ពីវត្ថុបំណងនៃការធ្វើអធិការកិច្ច (ការសម្ភាស ការ |

| | |
|---|---|
| | សង្កេតថ្នាក់រៀន ការពិនិត្យមើលឯកសារនានា ស្ថិតិ ទិន្នន័យ)<br>• អនុវត្តដំណើរការអធិការកិច្ចតាមការកំណត់ក្នុងរបៀបវារៈ<br>• ប្រមូលព័ត៌មានឱ្យបានច្រើនក្នុងពេលធ្វើសម្ភាស សង្កេតថ្នាក់ និងការផ្ទៀងផ្ទាត់ការងារ (ផែនការបង្រៀន សម្ភារឧបទេស និងសៀវភៅសិក្សាគោល សៀវភៅគ្រូ សៀវភៅសិស្ស)<br>• ប្រមូលភស្តុតាងគ្រប់គ្រាន់ ដើម្បីផ្តល់អនុសាសន៍អំពីចំណុចដែលត្រូវកែលម្អនៅគ្រប់ផ្នែក ដែលត្រូវវាយតម្លៃដូចជា៖ ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង ការបង្រៀននិងរៀន លទ្ធផលសិក្សារបស់សិស្ស ស្វ័យវាយតម្លៃសាលារៀន។ |
| ក្រោយពេលអធិការកិច្ច | • ពិនិត្យមើលកំណត់ត្រា និងពិភាក្សាចំណុចដែលប្រមូលបានជាមួយសហការី<br>• ធ្វើការសម្រេចចិត្តលើការវិនិច្ឆ័យចុងក្រោយគ្រប់ផ្នែកដែលបានវាយតម្លៃ<br>• ប្រើឯកសារវាយតម្លៃ និងគំរូរបាយការណ៍ដើម្បីណែនាំកិច្ចពិភាក្សាលើអ្វីដែលល្អ និងអ្វីដែលត្រូវកែលម្អ នៅក្នុងផ្នែកវាយតម្លៃផ្សេងៗ<br>• ត្រូវប្រាកដថាអ្នកមានព័ត៌មានគ្រប់គ្រាន់ពីប្រភពជាច្រើន សម្រាប់ធ្វើការវិនិច្ឆ័យ ហើយការវិនិច្ឆ័យត្រូវមានមូលដ្ឋានសមស្រប<br>• ប្រជុំផ្សព្វផ្សាយលទ្ធផលអធិការកិច្ច ជាមួយគណៈគ្រប់គ្រងសាលា គ្រូបង្រៀន សហគមន៍<br>• សរសេររបាយការណ៍ផ្ញើទៅសាលារៀន និងការិយាល័យអប់រំស្រុកក្នុងរយៈពេល ២សប្តាហ៍ក្រោយធ្វើអធិការកិច្ច ធ្វើការទាក់ទងទៅក្រុមពិនិត្យតាមដានបណ្តុះបណ្តាលថ្នាក់ស្រុក ដើម្បីពិភាក្សាលើសកម្មភាពដែលត្រូវធ្វើនៅពេលអនាគត<br>• ណែនាំក្រុមពិនិត្យតាមដានបណ្តុះបណ្តាលថ្នាក់ស្រុកឱ្យរៀបចំផែនការ |

| | |
|---|---|
| | សកម្មភាពសម្រាប់តាមដានសកម្មភាពការអនុវត្តអនុសាសន៍កែលម្អតាមផ្នែកនីមួយៗ។ |

*តារាង ៦៖ ដំណាក់កាលទាំងបីនៃការធ្វើអធិការកិច្ចថ្នាក់រៀន*

ជារួមដំណាក់កាលនីមួយៗនៃដំណើរការអធិការកិច្ច មានសារៈសំខាន់ណាស់ក្នុងការធ្វើឱ្យការចុះធ្វើអធិការកិច្ចនៅសាលារៀនមួយ ទទួលបានព័ត៌មានពេញលេញ និងអាចផ្ដល់ព័ត៌មានត្រឡប់ទៅលើចំណុចអាទិភាពដែលសាលារៀនត្រូវធ្វើការកែលម្អ ដើម្បីបង្កើនលទ្ធផលសិក្សាសិស្សជាបន្តបន្ទាប់។

ដោយសារការស្រាវជ្រាវនេះ មានគោលបំណងសិក្សាអំពី ឥរិយាបថគ្រូបង្រៀនបឋមសិក្សា ចំពោះការងារអធិការកិច្ច លើការបង្រៀន និងរៀន។ ផ្នែកខាងក្រោមនេះ យើងនឹងសិក្សាបន្តទៅលើភាពទូទៅនៃឥរិយាបថ។

## ២.៣ ឥរិយាបថ Attitude

### ២.៣.១ និយមន័យ

ឥរិយាបថគឺជាអាកប្បកិរិយាបង្ហាញពីការចូលចិត្ត ឬមិនចូលចិត្តទៅលើវត្ថុ មនុស្ស ស្ថាប័ន ឬព្រឹត្តការណ៍ណាមួយ (Corsini,1987)។ ឧទាហរណ៍ មនុស្សអាចមានឥរិយាបថផ្សេងគ្នាចំពោះកម្រិតនៃការចូលចិត្តចំពោះពួកគេ និងទិដ្ឋភាពនៃបរិស្ថានជុំវិញពួកគេ។ យោងតាម Nzuve (1999) ឥរិយាបថ គឺជាទំនោរជាប់លាប់មួយនៃអារម្មណ៍ចំពោះវត្ថុដទៃ។

ចំពោះលោក Cowie (1994) និង Mwangi (2002) បានលើកឡើងថា ឥរិយាបថគឺជាវិធីនៃការគិត និងអាកប្បកិរិយា។ ហើយលោក Nzuve (1999) បានកំណត់ធាតុបីនៃឥរិយាបថរួមមាន កត្តាអារម្មណ៍ កត្តាព័ត៌មាន និងកត្តាអាកប្បកិរិយា។ កត្តាអារម្មណ៍គឺជាអារម្មណ៍របស់មនុស្សម្នាក់មានទៅលើវត្ថុណាមួយ ថាតើគាត់ចូលចិត្ត ឬមិនចូលចិត្ត ខ្លាំងឬខ្សោយ។ កត្តាព័ត៌មានគឺកើតឡើងពីជំនឿ និងព័ត៌មានដែលមនុស្ស

ម្នាក់មានអំពីវត្ថុណាមួយ។ ចំណែកឯ កត្តាអាកប្បកិរិយាគឺសំដៅទៅវិធីដាក់លាក់ដែលមនុស្សម្នាក់មានទំនោរទៅលើវត្ថុណាមួយ។

ឥរិយាបថត្រូវបានរៀនតាមរបៀបដូចគ្នានឹងជំនាញ ទម្លាប់ និងការងារផ្សេងៗទៀតដែរ។ ទោះបីជាបុគ្គលមិនអាចជ្រើសរើសអ្វីដែលកើតឡើងចំពោះពួកគេក៏ដោយ ក៏ពួកគេអាចជ្រើសរើសឥរិយាបថរបស់ពួកគេចំពោះស្ថានភាពនីមួយៗបានដែរ (Blair, Jones និង Simpson ,1954)។ តែយ៉ាងណាក៏ដោយក៏លោក Cole (1995)បានបន្ថែមទៀតថា ក្នុងស្ថានភាពការងារមួយឥរិយាបថខ្លះអាចជះឥទ្ធិពលខ្លាំងទៅលើភាពស៊ីចង្វាក់គ្នា វិន័យ និងប្រសិទ្ធភាពនៃការងារ ហើយវាក៏សំខាន់សម្រាប់អ្នកគ្រប់គ្រងអាចធ្វើការផ្លាស់ប្តូរឱ្យមានភាពប្រសើរជាងមុន។ ហើយលោក Day (1991) បានកត់សម្គាល់ថា ឥរិយាបថរបស់គ្រូមួយចំនួនគឺផ្តោតទៅលើភាពគ្រប់គ្រាន់ផ្ទាល់ខ្លួន ការខិតខំប្រឹងប្រែងធ្វើការងារ មនសិការការងារ ការយកចិត្តទុកដាក់ ចំណាប់អារម្មណ៍ និងការពឹងពាក់គ្នាទៅវិញទៅមកក្នុងការអនុវត្តការងាររបស់ពួកគេ។

ឥរិយាបថទទួលបានពីបទពិសោធន៍ និងតាមរយៈការធ្វើត្រាប់តាម (Blair ,1954) ហើយតាមរយៈ Corsini (1987) និង Maina (2003) យល់ថាជំនឿគឺជាមូលដ្ឋាននៃឥរិយាបថ។ ជំនឿធ្វើឱ្យមនុស្សម្នាក់មានឥរិយាបថវិជ្ជមាន ឬអវិជ្ជមានទៅលើវត្ថុមួយ។ ជំនឿតិចតួចធ្វើឱ្យគេគិតអវិជ្ជមាន និងជំនឿខ្លាំងធ្វើឱ្យគិតវិជ្ជមានទៅលើវត្ថុនោះ។

យោងទៅតាម Dennis (1988) ការយល់ដឹងពីទម្រង់ដែលធ្វើឱ្យកើតមានឥរិយាបថគឺជាជំហានដំបូងក្នុងការអនុវត្តឥរិយាបថក្នុងការគ្រប់គ្រងបញ្ហា។ ទម្រង់នៃឥរិយាបថអាចបែងចែកជាបីធាតុសំខាន់គឺ ចំណេះដឹង អារម្មណ៍ និងអាកប្បកិរិយា។ ចំណេះដឹងរបស់ឥរិយាបថ គឺជាការពិតដែលយើងប្រមូលបាន និងបានពិចារណាអំពីវត្ថុ មនុស្ស ឬគំនិត។ អារម្មណ៍នៃឥរិយាបថ គឺសំដៅទៅលើអារម្មណ៍ចំពោះវត្ថុ មនុស្ស ចំណែកឯអាកប្បកិរិយានៃឥរិយាបថគឺទំនោររបស់បុគ្គលម្នាក់ៗដើម្បីធ្វើសកម្មភាពឆ្ពោះទៅវត្ថុឬមនុស្ស។ នៅពេលមនុស្សម្នាក់មានឥរិយាបថត្រឹមត្រូវចំពោះការងារ វានឹងធ្វើឱ្យការងារគាត់ទទួលបានជោគជ័យ

(Mwangi ,2002)។ ស្រដៀងគ្នាដែរ លោក Wenden (1991) បាននិយាយថាឥរិយាបថមានធាតុបីសំខាន់ៗគឺ អារម្មណ៍ ការយល់ដឹង និងអាកប្បកិរិយា។ ឥរិយាបថអារម្មណ៍សំដៅទៅលើអារម្មណ៍ ឬភាពរំជួលចិត្តដែលនរណាម្នាក់មានចំពោះអ្វីមួយថាតើគេចូលចិត្ត ឬមិនចូលចិត្ត។ ចំពោះឥរិយាបថយល់ដឹងគឺ បង្កើតដោយជំនឿជាក់ និងគំនិត ឬការយល់ឃើញអំពីអ្វីមួយ។ រីឯឥរិយាបថបែបអាកប្បកិរិយាវិញសំដៅទៅលើសកម្មភាព ឬជាប្រតិកម្មត្រឡប់របស់នរណាម្នាក់ទៅលើអ្វីមួយ ។

### ២.៣.២ ភាពផ្សេងៗនៃឥរិយាបថ

#### ២.៣.២.១ ឥរិយាបថបែបអារម្មណ៍

Wenden (1991) ឥរិយាបថអារម្មណ៍គឺសំដៅលើអារម្មណ៍ ឬភាពរំជួលចិត្តដែលនរណាម្នាក់មានទៅលើអ្វីមួយ (ចូលចិត្ត ឬមិនចូលចិត្ត ស្រប ឬប្រឆាំង)។ មនុស្សម្នាក់មានឥរិយាបថស្រលាញ់កូនក្មេងដោយសារពួកគេគួរឱ្យខ្លាញ់ និងមនុស្សខ្លះទៀតស្អប់ការជក់បារី ព្រោះវាអាចបំផ្លាញសុខភាពអ្នកជក់ផ្ទាល់ និងអ្នកជុំវិញ។ លោក ប៉ែន ឆោមឆារ៉ែត (២០១៨) បានលើកឡើងថាអារម្មណ៍សំដែងដោយចិត្តរំភើប ចំណូលចិត្ត ស្អប់ ភាពរីករាយ ភាពមិនរីករាយ ធុញថប់។ អារម្មណ៍វិជ្ជមាន និងអារម្មណ៍អវិជ្ជមាន សុទ្ធតែអាចកើតឡើងពីបទពិសោធដែលធ្លាប់ជួបប្រទះជាមួយវត្ថុ ឬរឿងរ៉ាវណាមួយ។ បុគ្គលដែលមានអារម្មណ៍វិជ្ជមានជានិច្ចកាលតែងតែចាត់ទុកខ្លួនឯងជាបុគ្គលដែលមានសេចក្ដីរីករាយ ទំនុកចិត្ត និងសេចក្ដីរំភើប ហើយបុគ្គលដែលមានអារម្មណ៍អវិជ្ជមាន តែងតែចាត់ទុកថា ខ្លួនឯងមានការខុសឆ្គង ខ្លាច និងភិតភ័យ។ ការទទួលបាននូវអារម្មណ៍វិជ្ជមានជំរុញឱ្យបុគ្គលចូលរួមក្នុងបរិស្ថានដែលខ្លួនរស់នៅ និងរួមចំណែកធ្វើសកម្មភាពនានា ដែលនៅក្នុងនោះមានសកម្មភាពជាច្រើន ត្រូវបានកែសម្រួលឱ្យស្របទៅតាម លក្ខណៈបុគ្គល ឬក្រុមរបស់គេ។ បើខ្វះអារម្មណ៍វិជ្ជមានជារឿយៗ បុគ្គលគ្មានទឹកចិត្តចូលរួមនៅក្នុងបរិស្ថានជុំវិញខ្លួនទេ បុគ្គលនោះក៏គ្មានគំនិតកែតម្រូវដើម្បីស្វែងរក និងទទួលបាននូវអ្វីថ្មីគួរជាទីចាប់អារម្មណ៍។ លទ្ធផលនេះបង្ហាញថា ប្រើសិនបើគ្រូបង្រៀន និងនាយកមានអារម្មណ៍ពេញចិត្តនឹងការងារអធិការកិច្ច នោះពួកគាត់នឹងជួយសម្រួល និងចូលរួម

ក្នុងដំណើរការអធិការកិច្ចសាលារៀន។

### ២.៣.២.២ ឥរិយាបថបែបចំណេះដឹង

សមាសធាតុនៃឥរិយាបថបែបចំណេះដឹងត្រូវបានបង្កើតឡើងដោយជំនឿ និងទស្សនៈ ឬគំនិតអំពីអ្វីមួយ (Wenden, 1991)។ តាមយោងតាម iEduNote(2020) ឥរិយាបថបែបចំណេះដឹង គឺផ្តោតទៅលើជំនឿ ការគិត ការសន្មត់ទៅលើវត្ថុ ឬអ្វីមួយ។ លោក សែម ម៉ាក់ (២០១៨) បានដកស្រង់ថា ឥរិយាបថបែបចំណេះដឹងត្រូវបានចាត់ថ្នាក់ជាបួនដំហាន៖ ការផ្សារភ្ជាប់ចំណេះដឹងពីមុន និងចំណេះដឹងថ្មី ការបង្កើតចំណេះដឹងថ្មី ការត្រួតពិនិត្យចំណេះដឹងថ្មី និងការអនុវត្តចំណេះដឹងថ្មីនៅក្នុងស្ថានភាពជាច្រើន។ ការយល់ដឹងនេះ សំដៅលើដំណើរនៃការគិតរបស់ខួរក្បាល ហើយវាកើតមានឡើងនៅពេលមនុស្សទទួលបានព័ត៌មានតាមរយៈបទពិសោធផ្ទាល់(ការចូលរួម និងការចូលពាក់ព័ន្ធ) និងបទពិសោធមិនផ្ទាល់។

### ២.៣.២.៣ ឥរិយាបថបែបអាកប្បកិរិយា

ឥរិយាបថបែបអាកប្បកិរិយាសំដៅលើសកម្មភាព ឬគោលចំណងរបស់នរណាម្នាក់ចំពោះអ្វីមួយ (Wenden, 1991)។ ទិដ្ឋភាពអាកប្បកិរិយានៃឥរិយាបថទាក់ទងទៅនឹងរបៀបដែលមនុស្សប្រព្រឹត្ត និងប្រតិកម្មទៅតាមស្ថានភាពជាក់ស្តែង។ អាកប្បកិរិយា ជាសកម្មភាពដែលបុគ្គលសំដែងចេញតាមរយៈសម្តី ឬមិនមែនជាសម្តី ហើយសកម្មភាពនេះ គេអាចសង្កេតបាន។

ឥរិយាបថបានកំណត់ពីបុគ្គលិកលក្ខណៈរបស់មនុស្ស[12]។ យោងទៅតាម Churchill ឥរិយាបថគឺជារឿងតូចតាចដែលធ្វើឱ្យមានភាពខុសគ្នាខ្លាំង។ ប្រសិនបើចង់ធ្វើឱ្យខ្លួនអ្នកល្អឥតខ្ចោះនោះអ្នកគួរតែមើលឥរិយាបថរបស់អ្នក។ ឥរិយាបថ មានបួនប្រភេទគឺ ឥរិយាបថវិជ្ជមាន ឥរិយាបថអវិជ្ជមាន ឥរិយាបថអព្យាក្រឹត និងឥរិយាបថSikken។

[12] https://stylesatlife.com/articles/types-of-attitudes/ ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០

### ក. ឥរិយាបថវិជ្ជមាន

ចំពោះប្រភេទទី១ មនុស្សម្នាក់ៗត្រូវយល់ថាតើត្រូវមានឥរិយាបថវិជ្ជមានប៉ុនណាដើម្បីឱ្យការងារមានដំណើរការទៅមុខនិងរីកចម្រើន បានន័យថាការរក្សាផ្នត់គំនិតវិជ្ជមាន និងគិតអំពីអ្វីដែលប្រសើរជាងមិនថាកាលៈទេសៈណាក៏ដោយ។ ឥរិយាបថវិជ្ជមានមានគុណប្រយោជន៍ជាច្រើនដែលជះឥទ្ធិពលដល់អាកប្ប-កិរិយាប្រភេទផ្សេងទៀតតាមរបៀបល្អ។ ឧទាហរណ៍ មនុស្សម្នាក់ដែលមានឥរិយាបថ និងផ្នត់គំនិតវិជ្ជមាននឹងស្វែងរកភាពល្អរបស់អ្នកដទៃទោះបីគេធ្វើអាក្រក់ ឬមានអាកប្បកិរិយាអាក្រក់យ៉ាងណាក៏ដោយ។ ប្រសិនបើអ្នកមានឥរិយាបថវិជ្ជមាន អ្នកគួរតែមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

| | | |
|---|---|---|
| ១ | ទំនុកចិត្ត | ភាពច្បាស់លាស់ដែលអ្វីមួយអាចកើតឡើងតាមផ្លូវឬវិធីដែលបានរំពឹងទុក |
| ២ | ចិត្តរីករាយ | អារម្មណ៍ចូលចិត្តធ្វើអ្វីមួយ ទទួលបានអ្វីដែលចូលចិត្ត ធ្វើអ្វីបានសម្រេច |
| ៣ | ភក្ដីភាព | ភាពស្មោះត្រង់ ការពិត |
| ៤ | ការប្ដេជ្ញាចិត្ត | ការព្យាយាមធ្វើអ្វីមួយ ទោះបីជាមានការលំបាកក៏ដោយ |

តាមរយៈការស្រាវជ្រាវរបស់ Machumu (2012) បានរកឃើញថា គ្រូបង្រៀនមានឥរិយាបថវិជ្ជមានចំពោះអធិការកិច្ចសាលារៀន គ្រូបង្រៀនមានជំនឿថាអធិការកិច្ចសាលារៀនមានសារៈសំខាន់ក្នុងការជួយពង្រឹងការរៀនសូត្ររបស់សិស្ស និងបង្កើនវិធីសាស្ត្របង្រៀនរបស់គ្រូផងដែរ។ ប៉ុន្តែគ្រូបង្រៀនយល់ថាអធិការកិច្ចបានធ្វើឱ្យពួកគាត់មានភាពរវល់ច្រើនលើការរៀបចំបែបបទការងារ កិច្ចតែការបង្រៀន រៀបចំសៀវភៅកំណត់ហេតុ និងឯកសាររដ្ឋបាលផ្សេងៗទៀត ម្យ៉ាងទៀតគ្រូបង្រៀនមានការបារម្ភផងដែរទៅលើភាពខ្សោយរបស់ពួកគាត់ត្រូវបានបើកបង្ហាញទៅកាន់នាយកសាលានៅពេលមានអធិការកិច្ច។ ប៉ុន្តែគ្រូបង្រៀនដែលមានអតីតភាពបង្រៀនច្រើនជាង១០ឆ្នាំ មិនពេញចិត្តនឹងអធិការកិច្ចឡើយ គាត់មានមោទនភាពថាគាត់យល់ដឹងពីសាលារៀនច្រើនជាងមន្ត្រីអធិការ ហើយគាត់មិនអើពើចំពោះអធិការកិច្ចឡើយ និងមិនមាន

ការផ្លាស់ប្តូរឡើយ។ ផ្ទុយទៅវិញ គ្រូបង្រៀនដែលសកម្មនឹងការងារមានការគាំទ្រចំពោះការងារអធិការកិច្ច ព្រោះវាជាផ្នែកមួយដើម្បីឱ្យពួកគាត់អាចធ្វើការវាយតម្លៃខ្លួនឯងលើការងារបង្រៀនផ្ទាល់ខ្លួន និងបានចែករំលែកបទពិសោធន៍ជាមួយមន្ត្រីអធិការផងដែរ។ ការធ្វើអធិការកិច្ចជាទៀតទាត់បានជួយក្រើនរំលឹកគ្រូបង្រៀនក្នុងការរៀបចំ និងប្រើប្រាស់ឯកសាររដ្ឋបាល អនុវត្តតាមគោលនយោបាយអប់រំ និងអនុវត្តការបង្រៀនមានប្រសិទ្ធភាព។ លើសពីនេះ ការស្រាវជ្រាវមួយទៀតអំពីឥរិយាបថគ្រូអនុវិទ្យាល័យចំពោះអធិការកិច្ច Harcourt (2018) ទៅលើគ្រូបង្រៀនចំនួន ៥៤០នាក់។ លទ្ធផលបានបង្ហាញថាទាំងលោកគ្រូ អ្នកគ្រូបានបង្ហាញឥរិយាបថវិជ្ជមានចំពោះអធិការកិច្ច ដោយមធ្យមភាគ(Grand mean) 2.71 ខ្ពស់ជាងមធ្យមភាព mean cut off mark ដែលតម្លៃ 2.50។ នេះមានន័យថាគ្រូបង្រៀនមានឆន្ទៈ និងបើកចិត្តទូលាយចំពោះអធិការកិច្ច និងត្រៀមទទួលយកការកែលម្អនានាដូចជា៖ គ្រូបង្រៀនមានអារម្មណ៍ថាអធិការកិច្ចសាលារៀននឹងជួយបន្ថែមនូវអ្វីសម្រាប់បង្កើនការបំពេញការងារ និងអធិការកិច្ចជាទូទៅជាអ្នកកែលម្អជាដើម។

### ខ. ឥរិយាបថអវិជ្ជមាន

ឥរិយាបថអវិជ្ជមាន គឺជាអ្វីដែលមនុស្សគ្រប់រូបគួរតែជៀសវាង។ ជាទូទៅមនុស្សមានឥរិយាបថអវិជ្ជមានមិនអើពើនឹងរឿងល្អៗក្នុងជីវិត ហើយគិតថាតើពួកគេនឹងបរាជ័យ។ ពួកគេច្រើនជាអ្នករត់គេចពីស្ថានភាពលំបាក និងពួកគេចូលចិត្តប្រៀបធៀបខ្លួនពួកគេជាមួយមនុស្សផ្សេងទៀត ហើយរកឃើញចំណុចអាក្រក់នៅក្នុងពួកគេប៉ុណ្ណោះ។ និយាយឱ្យខ្លីគាត់ពិតជាផ្ទុយពីអ្នកដែលមានផ្នត់គំនិតវិជ្ជមាន។ មានផលអាក្រក់មួយចំនួនដែលមនុស្សម្នាក់ដែលមានផ្នត់គំនិតអវិជ្ជមានត្រូវប្រឈមមុខ។

| | | |
|---|---|---|
| ១ | កំហឹង | អារម្មណ៍រិះគន់ ឬចង់ឱ្យនរណាម្នាក់ឈឺចាប់ព្រោះគេបានធ្វើរឿងដែលមិនត្រូវចិត្ត។ មនុស្សដែលឥរិយាបថអវិជ្ជមានតែងមានកំហឹងភាគច្រើន។ |
| ២ | ការសង្ស័យ | អារម្មណ៍សង្ស័យច្រើន នឹងនាំទៅឱ្យគ្មានការរីកចម្រើន និងគ្មានទំនុកចិត្ត។ |
| ៣ | តានតឹងចិត្ត | មនុស្សមានឥរិយាបថអវិជ្ជមាន គឺមនុស្សដែលមានអារម្មណ៍តានតឹងចិត្តច្រើន។ |

| | | |
|---|---|---|
| | | ភាពតានតឹងចិត្តមិនជួយអ្នកក្នុងការកសាងអាជីពរបស់អ្នកទេ វានឹងធ្វើឱ្យអ្នកធាប់ខឹង។ |

តាមរយៈការស្រាវជ្រាវពីបញ្ហាប្រឈមនៃអធិការកិច្ចសាលារៀន នៅក្នុងប្រទេសនីហ្សេរីយ៉ា Matthew (2012) បានរកឃើញថា គ្រូបង្រៀនជាច្រើនបានបង្ហាញពីភាពមិនសហការ នៅពេលដែលមានអធិការកិច្ចសាលារៀន។ គ្រូបង្រៀនគិតថាពួកគាត់មានសមត្ថភាពលើសមន្ត្រីអធិការ ដោយពួកគាត់មានបទពិសោធន៍ការងារច្រើនជាង មានកម្រិតវិជ្ជាជីវៈខ្ពស់ជាង និងមានឋានៈក្នុងសង្គមខ្ពស់ជាង។ គ្រូបង្រៀនតែងតែខកខានក្នុងការប្រគល់របាយការណ៍ក្នុងពេលអធិការកិច្ច និងគ្រូបង្រៀនខ្លះមានសកម្មភាពគេចវេសពីអធិការកិច្ច។ លើសពីនេះសាលារៀនខ្លះ មានការមិនពេញចិត្តចំពោះការងារអធិការកិច្ច និងបានបដិសេធក្នុងការផ្តល់ឯកសារ និងព័ត៌មានសំខាន់ៗដល់អធិការនៅពេលពួកគេមានវត្តមាននៅក្នុងសាលារៀន។ ម្យ៉ាងទៀតគ្រូបង្រៀនបានលើកឡើងថា អធិការបានប្រើពាក្យសម្តីមិនសមរម្យនៅពេលគ្រូមិនបានប្រគល់របាយការណ៍ និងទុកដាក់ឯកសារមិនបានត្រឹមត្រូវ។ លើសពីនេះទៀត ការស្រាវជ្រាវស្រដៀងគ្នាមួយទៀតធ្វើឡើងដោយ Wanjohi (2007) បានរកឃើញថា អធិការកិច្ចសាលារៀនធ្វើឡើងដោយមានភាពផ្តាច់ការ និងផ្តោតសំខាន់លើការស្វែងរកកំហុស ហើយបានជួយពង្រឹងសមត្ថភាពដល់គ្រូ និងនាយកសាលានៅមានកម្រិត និងគ្មានការឯកភាពគ្នា (uniformity)។ លើសពីនេះអធិការកិច្ចសាលារៀន បានលើកទឹកចិត្តតិចតួចដល់គ្រូបង្រៀន និងនាយកសាលា ក្នុងការជំរុញពួកគាត់បង្កើនប្រសិទ្ធភាពក្នុងការបង្រៀន។ ម្យ៉ាងទៀតមន្ត្រីអធិការ ខ្វះខាតបទពិសោធក្នុងផ្តល់អនុសាសន៍ដោយការគោរពចំពោះគ្រូ និងនាយកសាលា។ ការស្រាវជ្រាវនេះ បានរកឃើញផងដែរថា នាយកសាលារៀន យល់ថាអធិការកិច្ចសាលារៀនមានសារៈសំខាន់ក្នុងការពង្រឹងវិន័យបុគ្គលិកបង្រៀន។ នាយកមានឥរិយាបថវិជ្ជមានលើការងារអធិការកិច្ច ច្រើនជាងគ្រូបង្រៀន។ ប៉ុន្តែនាយកមិនបានគិតថាមន្ត្រីអធិការមានចំណេះដឹងជ្រៅជ្រះអំពីការងារគ្រប់គ្រងសាលារៀនឡើយ បើទោះជាពួកគាត់ទទួល

ស្គាល់ថាអធិការកិច្ច បានជួយពង្រឹងការបំពេញតួនាទីការងារគ្រប់គ្រង ដឹកនាំសាលារៀនបានប្រសើរក៏ដោយ។

### គ. ឥរិយាបថអព្យាក្រឹត( Neutral Attitude )

ឥរិយាបថមួយប្រភេទនេះដែលមានលក្ខណៈទូទៅ។ មនុស្សតែងមានទំនោរមិនអើពើនឹងបញ្ហានៅក្នុងជីវិតរបស់ពួកគេ។ ពួកគេរង់ចាំបុគ្គលផ្សេងទៀត ដោះស្រាយបញ្ហារបស់ពួកគេ។ ជាទូទៅពួកគេមានជីវិតខ្ជិលច្រអូស ហើយច្រើនតែគ្មានការយកចិត្តទុកដាក់។ វាហាក់ដូចជាពួកគេមិនអើពើពីអ្វីច្រើននោះទេ។ ពួកគេមិនដែលមានអារម្មណ៍ថាត្រូវការផ្លាស់ប្តូរខ្លួនឯងទេ ពីព្រោះពួកគេអាចរស់នៅតាមរបៀបដែលពួកគេមានរួចហើយ ។

### ឃ. ឥរិយាបថ Sikken

ឥរិយាបថមួយប្រភេទទៀតដែលមានគ្រោះថ្នាក់បំផុត និងខុសពីគេគឺឥរិយាបថ Sikken។ ឥរិយាបថ Sikken មានសមត្ថភាពបំផ្លាញរាល់រូបភាពទាំងអស់ដែលភ្ជាប់ជាមួយរូបភាពវិជ្ជមាន។ ឥរិយាបថប្រភេទនេះច្រើនតែជាឥរិយាបថអវិជ្ជមាន និងមានលក្ខណៈបំផ្លិចបំផ្លាញ។ វាច្រើនតែឆ្លុះបញ្ចាំងពីភាពអវិជ្ជមានរបស់ចិត្ត។ វាចាំបាច់ក្នុងការលះបង់ឥរិយាបថបែបនេះ ដើម្បីភាពប្រសើរឡើងនៃខ្លួនឯង និងមនុស្សនៅជុំវិញអ្នក។ ប៉ុន្តែជារឿយៗពួកគេពិបាកក្នុងការកែលម្អ ពីព្រោះឥរិយាបថត្រូវបានចាក់ឫសជ្រៅនៅក្នុងបុគ្គលិកលក្ខណៈរបស់មនុស្សម្នាក់។ ទោះយ៉ាងណាក៏ដោយជាមួយនឹងពេលវេលា គេអាចផ្លាស់ប្តូរឥរិយាបថនេះបាន។

សរុបជារួមមក ឥរិយាបថគឺសកម្មភាពដែលបង្ហាញពីការចូលចិត្ត ឬមិនចូលចិត្តទៅលើវត្ថុ មនុស្ស ស្ថាប័ន ឬព្រឹត្តិការណ៍ណាមួយ។ ឥរិយាបថរបស់មនុស្សប្រែប្រួលទៅតាម អារម្មណ៍ ចំណេះដឹង និងប្រតិកម្មដែលមនុស្សនោះមានទៅលើវត្ថុ ឬព្រឹត្តិការណ៍ណាមួយដែលបានកើតឡើង។ មនុស្សមានឥរិយាបថវិជ្ជមានច្រើនជាមនុស្សម្នាក់ដែលអាចធ្វើឱ្យការងារមានដំណើរការទៅមុខ និងភាពរីកចម្រើនគ្រប់កាលៈទេសៈ ប្រសើរជាងមនុស្សដែលមានឥរិយាបថអវិជ្ជមាន។

ក្នុងក្របខណ្ឌនៃការស្រាវជ្រាវ អំពីឥរិយាបថគ្រូបង្រៀនបឋមសិក្សាចំពោះការងារអធិការកិច្ច លើការបង្រៀន និងរៀន អ្នកស្រាវជ្រាវផ្តោតតែលើឥរិយាបថបែបអារម្មណ៍ និងឥរិយាបថបែបចំណេះដឹងតែប៉ុណ្ណោះ ដោយមិនសិក្សាអំពីឥរិយាបថបែបអាកប្បកិរិយាទេ ព្រោះដោយសារកត្តាពេលវេលា និងម្យ៉ាងទៀតអ្នកស្រាវជ្រាវមិនអាចមើលឃើញពីសកម្មភាពរបស់គ្រូបង្រៀនចំពោះអធិការកិច្ចបានឡើយ ព្រោះនៅពេលធ្វើការស្រាវជ្រាវនៅតាមសាលារៀនគោលដៅ ជាពេលដែលគ្រូបង្រៀនត្រូវបានធ្វើអធិការកិច្ចរួចមកហើយ។

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣ វិធីសាស្ត្រស្រាវជ្រាវ

## ៣.១ ព័ត៌មានទូទៅពីគម្រោងស្រាវជ្រាវ

ការស្រាវជ្រាវនេះ ត្រូវបានរៀបចំឡើងដោយប្រើទិន្នន័យបែបបរិមាណវិស័យ ដើម្បីយកមកវិភាគស្វែងយល់ពីឥរិយាបថរបស់គ្រូបង្រៀនបឋមសិក្សា ក្នុងដំណើរការនៃការចុះអធិការកិច្ចតាមកាលកំណត់ លើការបង្រៀន និងរៀន។

## ៣.២ ទីកន្លែងសិក្សាស្រាវជ្រាវ

យោងតាមរបាយការណ៍នៃ ការិយាល័យអធិការកិច្ចនៃមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ធំ ឆ្នាំសិក្សា ២០១៨-២០១៩ សាលារៀនសាធារណៈចំនួន ១០១ ត្រូវបានត្រូវបានចុះធ្វើអធិការកិច្ចតាមកាលកំណត់ ក្នុងនោះ សាលាបឋមសិក្សាចំនួន៧០សាលា ត្រូវនឹង **៦៩%៣០.**។ ចំណែកនៅក្នុងឆមាសទី១ ឆ្នាំសិក្សា២០១៩-២០២០ ការិយាល័យអធិការកិច្ច បានចុះធ្វើអធិការកិច្ច សាលារៀនសរុបចំនួន ៥៣ ក្នុងនោះសាលាបឋមសិក្សាចំនួន៤៦សាលា ត្រូវនឹង **៨៦.៧៩%** ក្រៅពីនោះគឺសាលាមធ្យមសិក្សាចំនួន០៧សាលា (អនុវិទ្យាល័យ ចំនួន០៦សាលា វិទ្យាល័យចំនួន០១សាលា) ដែលគិតចាប់ពីថ្ងៃទី ០៣-០៤/១២/២០១៩ រហូតដល់ ១២-១៣/០៣/២០២០។

ក្នុងផែនការប្រតិបត្តិ ប្រចាំឆ្នាំ២០១៩-២០២០ របស់ការិយាល័យអធិការកិច្ចនៃមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ធំ សាលារៀនសាធារណៈចំនួន ១៣៦នៅគ្រប់កម្រិតសិក្សានៅក្នុងខេត្តកំពង់ធំ ត្រូវបានចុះធ្វើអធិការកិច្ចតាមកាលកំណត់ ដែលក្នុងនោះមាន១១៤សាលារៀនជាសាលាបឋមសិក្សា។ ការសិក្សាស្រាវជ្រាវស្តីពី "**ឥរិយាបថគ្រូបង្រៀនបឋមសិក្សា ចំពោះអធិការកិច្ចលើការបង្រៀន និងរៀន នៅក្នុងខេត្តកំពង់ធំ**" បានជ្រើសរើសយកខេត្តកំពង់ធំជាទីតាំងស្រាវជ្រាវ ដែលក្នុងនោះមានក្រុងស្រុក/ចំនួន ០៣ ត្រូវបានជ្រើសរើសរួមមាន ក្រុងស្ទឹងសែន ស្រុកកំពង់ស្វាយ និងស្រុកប្រាសាទសំបូរ។ ចម្ងាយពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ ទៅការិយាល័យអប់រំស្រុកកំពង់ស្វាយ គឺ២០គីឡូម៉ែត្រ និង៣៧គីឡូម៉ែត្រទៅការិយាល័យ

អប់រំស្រុកប្រាសាទសំបូរ ហើយការិយាល័យអប់រំ ក្រុងស្ទឹងសែន មានចម្ងាយ ២គីឡូម៉ែត្រ។

ការស្រាវជ្រាវនេះផងដែរ បានជ្រើសរើសយកតែសាលារៀនបឋមសិក្សា ដែលត្រូវបានចុះអធិការកិច្ច ចាប់ពីឆ្នាំ២០១៨ រហូតដល់ឆ្នាំ២០២០។ ការជ្រើសរើសខេត្តកំពង់ធំ មកស្រាវជ្រាវនេះ ជាការជ្រើសរើស ដោយការកំណត់របស់អ្នកស្រាវជ្រាវចេញពីចំណោមរាជធានី/ខេត្ត ទាំង២៥ នៃព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកលើកត្តាពេលវេលា និងធនធានមានកំណត់។

*រូបភាព 4៖ ផែនទីស្រុកគោលដៅ នៃការប្រមូលទិន្នន័យ*




ប្រភព៖ Google Map

ចំពោះក្រុង/ស្រុកដែលបានជ្រើសរើសចំនួន០៣ នៃក្រុង/ស្រុកទាំងអស់០៩ ក្នុងខេត្តកំពង់ធំ ក៏បាន ប្រើវិធីដូចគ្នាដែរ។ នៅក្នុងក្រុង/ស្រុកទាំងបីនេះ មានសាលាបឋមសិក្សាទាំងអស់ចំនួន ១៤៥សាលារៀន ក្នុង នោះក្រុងស្ទឹងសែនមានសាលាបឋមសិក្សាចំនួន២៨ សាលា, ស្រុកប្រាសាទសំបូរមានសាលាបឋមសិក្សា ចំនួន៤២ សាលា និងស្រុកកំពង់ស្វាយមានសាលាបឋមសិក្សា ចំនួន៧៥ សាលា។ ចំពោះសាលាបឋមសិក្សា ដែលត្រូវបានធ្វើអធិការកិច្ចតាមកាលកំណត់ដោយ ការិយាល័យអធិការកិច្ចនៃមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ធំ មានចំនួន ៤៣សាលារៀន។

| ឆ្នាំសិក្សា | ក្រុងស្ទឹងសែន | ស្រុកកំពង់ស្វាយ | ស្រុកប្រាសាទសំបូរ | សរុប |
|---|---|---|---|---|
| ២០១៨ - ២០១៩ | ០៦ | ០៦ | ០៨ | ២០ |
| ២០១៩ - ២០២០ | ១៣ | ០៧ | ០៣ | ២៣ |
| សរុបរួម | ១៩ | ១៣ | ១១ | ៤៣ |

***តារាង 7៖** សាលាបឋមសិក្សា ដែលត្រូវបានចុះអធិការកិច្ចតាមកាលកំណត់ ពីឆ្នាំ២០១៨ ដល់ ២០២០*

ក្នុងចំណោមសាលាបឋមសិក្សាទាំងអស់ ៤៣សាលា អ្នកសិក្សាស្រាវជ្រាវ ជ្រើសរើសយកតែសាលាបឋមសិក្សាចំនួន១៥ប៉ុណ្ណោះ ក្នុងចំណោមក្រុង/ស្រុក ចំនួន០៣នេះ មានដូចជា(១)ក្រុងស្ទឹងសែន៖ បឋមសិក្សាភូមិក្តី បឋមសិក្សាព្រៃកស្បូវ បឋមសិក្សាអូរកន្ធរត្បូង បឋមសិក្សាបល្លង្គ និងបឋមសិក្សាហ៊ុនសែនត្រពាំងវែង (២)ស្រុកកំពង់ស្វាយ ៖ បឋមសិក្សាព្រះក្រសាំង បឋមសិក្សាបល្លង្គ បឋមសិក្សាភ្លង បឋមសិក្សាឈើទាល និងបឋមសិក្សា មហរ និង(៣)ស្រុកប្រាសាទសំបូរ ៖ បឋមសិក្សាទឹកអណ្តូង បឋមសិក្សាតាំងក្រង បឋមសិក្សាច្រម៉ាស់ បឋមសិក្សាកូនក្អែក និងបឋមសិក្សាព្រៃក្តី។

## ៣.៣ ក្រុមគោលដៅ

ការសិក្សានេះ បានផ្តោតទៅលើគ្រូបង្រៀន ដែលកំពុងបង្រៀនសិស្សនៅថ្នាក់សាលាបឋមសិក្សា (ចាប់ពីថ្នាក់ទី១ដល់ថ្នាក់ទី៦)។ ចំពោះក្រុមគោលដៅគឺ លោកគ្រូ អ្នកគ្រូដែលជាបុគ្គលិកបង្រៀនចំនួន ១១៨នាក់ នាយក/នាយិកាចំនួន ១៥នាក់ និងសិស្សសរុបចំនួន៣១១៨នាក់។

| ក្រុង/ស្រុក | ឈ្មោះសាលា | នាយក/នាយិកា | គ្រូបង្រៀន(នាក់) | សិស្សសរុប |
|---|---|---|---|---|
| ស្ទឹងសែន | បឋមសិក្សា ភូមិក្តី | ០១ | ១០ | ៣៣២ |
| | បឋមសិក្សា ព្រៃកស្បូវ | ០១ | ០៦ | ២២៦ |
| | បឋមសិក្សា អូរកន្ធរត្បូង | ០១ | ១០ | ៣២៧ |
| | បឋមសិក្សា បល្លង្គ | ០១ | ១៦ | ៤៨៦ |

| | | | | |
|---|---|---|---|---|
| | បឋមសិក្សា ហ.ស ត្រពាំងវែង | ០១ | ១៩ | ៤៨៩ |
| កំពង់ស្វាយ | បឋមសិក្សា មហរ | ០១ | ០៦ | ៩៨ |
| | បឋមសិក្សា ព្រះក្រសាំង | ០១ | ០៦ | ១៤៥ |
| | បឋមសិក្សា បល្លង្គ | ០១ | ០៥ | ១៤២ |
| | បឋមសិក្សា ភ្លូង | ០១ | ០៦ | ១២៥ |
| | បឋមសិក្សា ឈើទាល | ០១ | ០៦ | ១៣៩ |
| ប្រាសាទសំបូរ | បឋមសិក្សា ទឹកអណ្ដូង | ០១ | ០៦ | ១៩០ |
| | បឋមកសិក្សា តាំងក្រង | ០១ | ០៦ | ៧៥ |
| | បឋមសិក្សា កូនក្អែក | ០១ | ០៦ | ២០៤ |
| | បឋមសិក្សា ច្រម៉ាស់ | ០១ | ០៧ | ១៣៦ |
| | បឋមសិក្សា ព្រៃក្ដី | ០១ | ០៦ | ១៤៤ |
| សរុប | | ១៥ | ១២១ | ៣២៥៨ |

***តារាង ៩៖*** *ស្ថិតិសិស្ស-គ្រូ សាលាបឋមសិក្សាគោលដៅនៅឆ្នាំសិក្សា ២០១៩-២០២០*

## ៣.៤ ទំហំសំណាក

ភាគសំណាកសម្រាប់ការសិក្សាស្រាវជ្រាវនេះរួមមាន គ្រូបង្រៀនដែលកំពុងបង្រៀននៅថ្នាក់បឋមសិក្សា(ចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី៦) ចំនួន៩៣នាក់ នាយក/នាយិកាចំនួន ១៥នាក់ និងសិស្សចំនួន ៣៤៣នាក់។ ភាគសំណាក គឺស្ថិតនៅតាមសាលាបឋមសិក្សាទាំង១៥ដែលបានជ្រើសរើសក្នុងក្រុងស្ទឹងសែន ស្រុកប្រាសាទសំបូរ និងស្រុកកំពង់ស្វាយ នៃខេត្តកំពង់ធំ។ ការជ្រើសរើសគ្រូបង្រៀន នាយក/នាយិកា និងសិស្សមកធ្វើជាភាគសំណាក ត្រូវធ្វើឡើងដោយប្រើប្រាស់កម្មវិធីអនឡាញ (www.checkmarket.com) ដើម្បីធ្វើការជ្រើសរើសទំហំសំណាកឱ្យមានភាពច្បាស់លាស់។ ចំពោះការជ្រើសរើសទំហំសំណាក Sample

Size for Frequency in a Population (n) គឺប្រើតាមកម្មវិធីសមាមាត្រ (Proportion) ដោយមានការបង្ហាញពីកម្រិតនៃភាពជឿជាក់ (Confidence Levels) រហូតទៅដល់ ៩៥% និងមានកម្រិតលំអៀងត្រឹមតែ ៥% (Margin of error) ប៉ុណ្ណោះ។ ដូចនេះក្នុងចំណោមគ្រូបង្រៀនសរុបដែលបង្រៀនពីថ្នាក់ទី១-៦ នៅក្នុងសាលាទាំង១៥ មានចំនួនសរុប១២១នាក់ (Population) ត្រូវជ្រើសរើសយកតែ ៩៣នាក់មកធ្វើជាទំហំសំណាក និងនាយក/នាយិកានៅសាលាបឋមសិក្សាទាំង១៥ ក៏ត្រូវជ្រើសរើសជាភាគសំណាកក្នុងស្រាវជ្រាវផងដែរ លើសពីនេះ សិស្សចំនួន៣៤៤នាក់ ត្រូវបានជើសរើសចេញពីសិស្សសរុបទាំងអស់ក្នុងចំណោមសិស្ស៣២៥៨នាក់។

| ក្រុង/ស្រុក | ឈ្មោះសាលា | នាយក/នាយិកា | | គ្រូបង្រៀន | | សិស្ស | | ចំនួនសរុប |
|---|---|---|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | |
| ស្ទឹងសែន | បឋមសិក្សា ភូមិក្តី | ១ | ៦.៦៧% | ៨ | ៨% | ៣៥ | ១០% | ៤៤ |
| | បឋមសិក្សា ព្រៃកស្បូវ | ១ | ៦.៦៧% | ៥ | ៥% | ២៤ | ៧% | ៣០ |
| | បឋមសិក្សា អូរកន្ធរត្បូង | ១ | ៦.៦៧% | ៨ | ៨% | ៣៥ | ១០% | ៤៣ |
| | បឋមសិក្សា បល្លង្គ | ១ | ៦.៦៧% | ១២ | ១៤% | ៥១ | ១៥% | ៦៥ |
| | បឋមសិក្សា ហ.ស ត្រពាំងវែង | ១ | ៦.៦៧% | ១៥ | ១៥% | ៥២ | ១៥% | ៦៧ |
| កំពង់ស្វាយ | បឋមសិក្សា មហារ | ១ | ៦.៦៧% | ៥ | ៥% | ១០ | ១៥% | ១៦ |
| | បឋមសិក្សា ព្រះក្រសាំង | ១ | ៦.៦៧% | ៥ | ៥% | ១៥ | ៤% | ២១ |
| | បឋមសិក្សា បល្លង្គ | ១ | ៦.៦៧% | ៤ | ៤% | ១៥ | ៤% | ២០ |
| | បឋមសិក្សា ភ្លង | ១ | ៦.៦៧% | ៥ | ៥% | ១៣ | ៤% | ១៩ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | បឋមសិក្សា ឈើទាល | ១ | ៦.៦៧% | ៥ | ៥% | ១៥ | ៤% | ២០ |
| ប្រាសាទសំបូរ | បឋមសិក្សា ទឹកអណ្ដូង | ១ | ៦.៦៧% | ៥ | ៥% | ២០ | ៦% | ២៦ |
| | បឋមសិក្សា តាំងក្រង | ១ | ៦.៦៧% | ៥ | ៥% | ៨ | ២% | ១៤ |
| | បឋមសិក្សា កូនក្អែក | ១ | ៦.៦៧% | ៥ | ៥% | ២២ | ៦% | ២៧ |
| | បឋមសិក្សា ច្រម៉ាស់ | ១ | ៦.៦៧% | ៣ | ៣% | ១៤ | ៤% | ២០ |
| | បឋមសិក្សា ព្រៃក្ដី | ១ | ៦.៦៧% | ៥ | ៥% | ១៥ | ៤% | ២១ |
| **សរុប** | | ១៥ | ១០០% | ៩៣ | ១០០% | ៣៤៣ | ១០០% | ៤៥១ |

*តារាង ៩៖ ចំនួនសំណាក នាយក/នាយិកា - គ្រូបង្រៀន - សិស្ស នៅតាមសាលាគោលដៅ*

## ៣.៥ ឧបករណ៍ស្រាវជ្រាវ

ចំពោះឧបករណ៍ស្រាវជ្រាវ អ្នកសិក្សាស្រាវជ្រាវ បានរៀបចំបង្កើតកម្រងសំណួរដែលជាលក្ខណៈកម្រិតចម្លើយ ជាសំណួរទម្រង់បិទសម្រាប់សិស្ស និងសម្រាប់នាយក/នាយិកា លោកគ្រូ/អ្នកគ្រូ ជាទម្រង់បើកផងទម្រង់បិទផង ។ កម្រងសំណួរនេះ ត្រូវបានអ្នកស្រាវជ្រាវតាក់តែងឡើងដោយបានគំនិតពីការអានឯកសារ និងនិក្ខេបបទជាច្រើន ដែលរួមទាំងឯកសាររបស់ លោក សុភា (២០១២) និងលោក Wanjohi (2007) ជាដើម។ ផ្នែកខ្លះនៃកម្រងសំណួរ ត្រូវបានអ្នកស្រាវជ្រាវបង្កើតបានតាមរយៈការសាកសួរផ្ទាល់ពីបទពិសោធន៍គ្រូបង្រៀនមួយចំនួន ដែលធ្លាប់បានជួបប្រទះការធ្វើអធិការកិច្ចក្នុងសាលារៀនរបស់ពួកគាត់ ហើយមួយចំនួនទៀតអ្នកស្រាវជ្រាវសំយោគបន្ថែម ក្រោមការចង្អុលបង្ហាញពីលោកសាស្ត្រាចារ្យដឹកនាំ។ មុនដំបូងអ្នកស្រាវជ្រាវ បង្កើតកម្រងសំណួរជាច្រើនប្រភេទ និងផ្នែក ដែលទាក់ទងនឹងឥរិយាបថគ្រូបង្រៀន ចំពោះការងារអធិការកិច្ច បន្ទាប់មកអ្នកស្រាវជ្រាវ សម្រាំងយកសំណួរដែលមានភាពប្រហាក់ប្រហែលគ្នា និងបញ្ចូលជាក្រុមតែមួយ និយាយរួមគឺសង្ខេបកម្រងសំណួរឱ្យខ្លីមានន័យគ្រប់គ្រាន់ និងមានការឯកភាពពីសាស្ត្រាចារ្យដឹកនាំ។

កម្រងសំណួរនេះត្រូវបានអ្នកស្រាវជ្រាវបែងចែកជាបីប្រភេទដើម្បីប្រមូលទិន្នន័យ រួមមាន៖ កម្រងសំណួរសម្រាប់នាយក/នាយិកា ចំនួន១៥ច្បាប់ កម្រងសំណួរសម្រាប់លោកគ្រូ/អ្នកគ្រូបង្រៀននៅបឋមសិក្សាចំនួន៩១ច្បាប់ និងកម្រងសំណួរសម្រាប់សិស្សចំនួន ៣៤៣ច្បាប់។

### *៣.៥.១ កម្រងសំណួរសម្រាប់គ្រូបង្រៀន*

កម្រងសំណួរសម្រាប់គ្រូបង្រៀន មាន៤ ផ្នែក និងមាន ៧២សំណួរ ៖ ផ្នែកទី១ ជាព័ត៌មានទូទៅ និង៣ផ្នែកផ្សេងទៀត សិក្សាអំពីដំណើរការនៃអធិការកិច្ចលើការបង្រៀន និងរៀន ដោយផ្នែកលើឥរិយាបថរបស់គ្រូបង្រៀន (មុនពេលអធិការកិច្ច ក្នុងពេលអធិការកិច្ច និងក្រោយពេលអធិការកិច្ច)។

- **ផ្នែកទី១ ព័ត៌មានផ្ទាល់ខ្លួន** មាន០៨សំណួរ។ អ្នកស្រាវជ្រាវចង់ដឹងពីឈ្មោះសាលារៀន ទីតាំងសាលារៀន ចំនួនថ្នាក់រៀន អំពីកម្រិតវប្បធម៌ កម្រិតវិជ្ជាជីវៈ ភេទ អតីតភាពការងារជាគ្រូបង្រៀន របស់អ្នកបំពេញកម្រងសំណួរ។
- **ផ្នែកទី២ មុនពេលអធិការកិច្ចលើការបង្រៀន និងរៀន** ក្នុងផ្នែកនេះមាន១៧អំណះអំណាង ដែលបែងចែកជា៥កម្រិត គឺមិនយល់ស្របទាល់តែសោះ មិនយល់ស្រប យល់ស្របខ្លះ-មិនយល់ស្របខ្លះ យល់ស្រប និងយល់ស្របទាំងស្រុង ដែលតម្រូវឱ្យលោកគ្រូ/អ្នកគ្រូជ្រើសរើសយកតែមួយគត់សម្រាប់អំណះអំណាងនីមួយៗ។ ការបែងចែក៥កម្រិតនេះ ដើម្បីចៀសវាងអ្នកឆ្លើយមិនឱ្យជ្រើសរើសចម្លើយងាយស្រួលគឺយល់ព្រម ឬមិនយល់យល់ព្រម តែវាបានធ្វើឱ្យអ្នកឆ្លើយតបគិតពិចារណាលើសំណួរទៅតាមកម្រិតតូចៗនៃអំណះអំណាងនេះផងដែរ (McLeod, 2008)។ អ្នកស្រាវជ្រាវកំណត់យកមិនយល់ស្របទាល់តែសោះស្មើនឹង០%នៃកម្រិតយល់ស្រប, មិនយល់ស្របគឺចន្លោះពី១% ដល់២៥% នៃកម្រិតយល់ស្រប, យល់ស្របខ្លះ-មិនយល់ស្របខ្លះ គឺចន្លោះពី២៦% ដល់៥០% នៃកម្រិតយល់ស្រប, យល់ស្រប គឺចន្លោះពី៥១% ដល់៧៥%នៃកម្រិតយល់ស្រប និងយល់ស្របទាំងស្រុងពីចន្លោះ ៧៦% ដល់១០០% (Murray, 2017)។ ក្នុងផ្នែកទី២នេះ អ្នកស្រាវជ្រាវចង់ស្វែងរកឱ្យឃើញពី

ឥរិយាបថមួយចំនួនរបស់គ្រូ មុនពេលមានអធិការកិច្ចថ្នាក់រៀនបានមកដល់ ដូចជាទំនាក់ទំនងរវាងគ្រូបង្រៀន និងអធិការកិច្ច ការទទួលព័ត៌មានអំពីអធិការកិច្ច ការគោរពពេលវេលា និងអារម្មណ៍របស់គ្រូបង្រៀនមុនពេលអធិការកិច្ចថ្នាក់រៀន។

- **ផ្នែកទី៣ ក្នុងពេលអធិការកិច្ចលើការបង្រៀន និងរៀន** មាន២៦អំណះអំណាង និងចែកជា៥កម្រិតយល់ស្របដូចផ្នែកខាងលើដែរ។ ក្នុងផ្នែកនេះ អ្នកស្រាវជ្រាវចង់ស្វែងរកឱ្យឃើញ ពីរបៀបដែលអធិការបានធ្វើនៅពេលសង្កេតថ្នាក់រៀន ដោយផ្អែកតាមការមើលឃើញរបស់គ្រូបង្រៀន និងអាកប្បកិរិយារបស់គ្រូបង្រៀននៅពេលអធិការចុះសង្កេតថ្នាក់រៀន និងរបៀបដែលគ្រូចូលរួមឆ្លើយសំណួរសម្ភាសន៍ពេលអធិការកិច្ច។
- **ផ្នែកទី៤ ក្រោយពេលអធិការកិច្ច** មាន២៣អំណះអំណាង និងចែកជា៥កម្រិតយល់ស្របដូចផ្នែកខាងលើដែរ។ ក្នុងផ្នែកនេះ អ្នកស្រាវជ្រាវចង់រកឱ្យឃើញថា តើលោកគ្រូ/អ្នកគ្រូ យល់ឃើញយ៉ាងណាអំពីអនុសាសន៍ដែលអធិការកិច្ចផ្តល់ឱ្យលើការបង្រៀននិងរៀន។ លើសពីនេះ តើគ្រូបង្រៀនមានការចាប់អារម្មណ៍នឹងរបាយការណ៍អធិការកិច្ចដែរឬទេ? តើរបាយការណ៍អធិការកិច្ចបានជួយគ្រូបង្រៀនក្នុងការបង្កើនប្រសិទ្ធភាពនៃការបង្រៀនដែរឬទេ? និងចុងក្រោយ ជាយោបល់របស់លោកគ្រូ/អ្នកគ្រូអំពីការលំបាកក្នុងពេលអធិការកិច្ច ព្រមទាំងដំណោះស្រាយ រួមទាំងចំណុចដែលលោកគ្រូ/អ្នកគ្រូគិតថាអធិការកិច្ចគួរត្រូវបានកែលម្អមួយចំនួន។

***តារាង 10៖** កម្រងសំណួរសម្រាប់គ្រូបង្រៀន*

| ផ្នែក | លេខរៀងសំណួរ |
| --- | --- |
| ផ្នែកទី១៖ ព័ត៌មានទូទៅ | ១,២,៣,៤,៥,៦,៧,៨ |
| ផ្នែកទី២៖ ឥរិយាបថគ្រូបង្រៀន មុនពេលអធិការកិច្ចលើការបង្រៀន និងរៀន | |
| A. ទំនាក់ទំនងរវាងគ្រូបង្រៀន និងអធិការកិច្ច | ៩,១០,១១,១២,១៣,១៤ |

| | |
|---|---|
| B. ការផ្តល់ព័ត៌មានអធិការកិច្ចទៅដល់គ្រូបង្រៀន | ១៥,១៦,១៧,១៨,១៩,២០ |
| C. ការគោរពពេលវេលានៃក្រុមអធិការកិច្ច | ២១,២២,២៣ |
| D. ការត្រៀមលក្ខណៈរបស់គ្រូមុនពេលអធិការកិច្ច | ២៤,២៥,២៦,២៨ |
| **ផ្នែកទី៣៖ ឥរិយាបថគ្រូបង្រៀន អំឡុងពេលអធិការកិច្ចលើការបង្រៀន និងរៀន** | |
| A. ពេលសង្កេតថ្នាក់ | ២៩,៣០,៣១,៣២,៣៣,៣៤,៣៥ |
| B. ការពិនិត្យការបង្រៀន | ៣៦,៣៧,៣៨,៣៩,៤០,៤១,៤២,៤៣,៤៤,៤៥,៤៦ |
| C. ការសម្ភាសអំពីការរៀន និងរៀន | ៤៧,៤៨,៤៩,៥០,៥១,៥២,៥៣,៥៤,៥៥ |
| **ផ្នែកទី៤៖ ឥរិយាបថគ្រូបង្រៀន ក្រោយពេលអធិការកិច្ចលើការបង្រៀន និងរៀន** | |
| A. ការផ្តល់អនុសាសន៍ | ៥៦,៥៧,៥៨,៥៩,៦០,៦១,៦២,៦៣,៦៤,៦៥,៦៦ |
| B. ការផ្តល់របាយការណ៍ | ៦៧,៦៨,៦៩,៧០,៧១,៧២,៧៣,៧៤,៧៥ |
| មតិយោបល់បន្ថែម | ៧៦,៧៧,៧៨,៧៩ |

អ្នកស្រាវជ្រាវ បានបែកចែងកម្រងសំណួរសម្រាប់គ្រូ ជាផ្នែកៗ ដូចជា មុនពេលអធិការកិច្ច អំឡុងពេលអធិការកិច្ច និងក្រោយពេលអធិការកិច្ច ព្រោះនៅក្នុងជំពូកទី២ រំលឹកទ្រឹស្តីមានការពន្យល់ច្រើនពីដំណាក់កាលទាំងបី នៃដំណើរការអធិការកិច្ច ជាពិសេសក្នុងការអនុវត្តជាក់ស្តែងក្នុងការងារអធិការកិច្ចតាមសាលារៀន ពិតជាមានសកម្មតាមដំណាក់កាលទាំងបីនេះពិតប្រាកដមែន។

### *៣.៥.២ កម្រងសំណួរសម្រាប់នាយកសាលា*

កម្រងសំណួរសម្រាប់នាយកសាលា មាន៤ផ្នែក និងមាន៧០សំណួរ ៖

- **ផ្នែកទី១ ព័ត៌មានផ្ទាល់ខ្លួន** មាន១០សំណួរ។ ក្នុងផ្នែកនេះ អ្នកស្រាវជ្រាវចង់ដឹងឈ្មោះសាលារៀន ទីតាំងសាលារៀន ចំនួនថ្នាក់រៀន ចំនួនសិស្ស អំពីកម្រិតវប្បធម៌ កម្រិតវិជ្ជាជីវៈរបស់នាយក/នាយិកា ភេទ និងអតីតភាពការងារជាគ្រូបង្រៀន និងនាយកសាលារបស់អ្នកបំពេញកម្រងសំណួរ។
- **ផ្នែកទី២ មុនពេលអធិការកិច្ចលើការបង្រៀន និងរៀន** ក្នុងផ្នែកនេះមាន១៥អំណះអំណាង ដែលបែងចែកជា៥កម្រិត គឺមិនយល់ស្របទាល់តែសោះ មិនយល់ស្រប យល់ស្របខ្លះ-មិនយល់ស្របខ្លះ យល់ស្រប និងយល់ស្របទាំងស្រុង ដែលតម្រូវឱ្យនាយក/នាយិកាជ្រើសរើសយកតែមួយគត់សម្រាប់ចំណោមអំណះអំណាងនីមួយៗ។ នៅផ្នែកនេះ អ្នកស្រាវជ្រាវចង់ស្វែងរកពីការយល់មើលឃើញរបស់នាយក/នាយិកា អំពីឥរិយាបថមួយចំនួនរបស់គ្រូបង្រៀនមុនពេលអធិការកិច្ចថ្នាក់រៀនបានចុះមកដូចទំនាក់ទំនងរវាងគ្រូបង្រៀន និងក្រុមអធិការកិច្ច ការផ្តល់ព័ត៌មានពីការចុះអធិការកិច្ច និងការត្រៀមលក្ខណៈរបស់គ្រូបង្រៀនសម្រាប់ការចុះអធិការកិច្ចថ្នាក់រៀនជាដើម។
- **ផ្នែកទី៣ ក្នុងពេលអធិការកិច្ចលើការបង្រៀន និងរៀន** មាន១៨អំណះអំណាង និងចែកជា៥កម្រិតយល់ស្របដូចផ្នែកខាងលើដែរ។ នៅក្នុងផ្នែកនេះ អ្នកស្រាវជ្រាវចង់បញ្ជាក់ឱ្យកាន់តែច្បាស់ពីអ្វីដែលអធិការបានធ្វើនៅពេលក្នុងសង្កេតថ្នាក់រៀន តើគ្រូបង្រៀនបានចូលរួមសកម្មភាពបានកម្រិតណាទាំងពេលបង្រៀន និងពេលឆ្លើយសំណួរសម្ភាសន៍របស់ក្រុមអធិការកិច្ច។
- **ផ្នែកទី៤ ក្រោយពេលអធិការកិច្ច** មាន២២អំណះអំណាង និងចែកជា៥កម្រិតយល់ស្របដូចផ្នែកខាងលើដែរ។ ក្នុងផ្នែកនេះ អ្នកស្រាវជ្រាវចង់រកឱ្យឃើញថា តើលោកនាយក/នាយិកាបានយល់ស្របថាអនុសាសន៍អធិការកិច្ច និងរបាយការណ៍អធិការកិច្ចមានសារៈសំខាន់ចំពោះគ្រូបង្រៀនដែរឬទេ។ តើគ្រូបង្រៀនទទួលស្គាល់ពីអ្វី ដែលអធិការកិច្ចបានរកឃើញ បន្ទាប់ពីបានអធិការកិច្ចថ្នាក់រៀនដែរឬទេ?

*តារាង 11៖ កម្រងសំណួរសម្រាប់នាយក/នាយិកា*

| ផ្នែក | លេខរៀងសំណួរ |
| --- | --- |
| ផ្នែកទី១៖ ព័ត៌មានទូទៅ | ១,២,៣,៤,៥,៦,៧,៨,៩,១០ |
| ផ្នែកទី២៖ ឥរិយាបថគ្រូបង្រៀន មុនពេលអធិការកិច្ចលើការបង្រៀន និងរៀន | |
| A. ទំនាក់ទំនងរវាងគ្រូបង្រៀន និងអធិការកិច្ច | ១១,១២,១៣,១៤,១៥,១៦ |
| B. ការផ្តល់ព័ត៌មានអធិការកិច្ចទៅដល់គ្រូបង្រៀន | ១៧,១៨,១៩ |
| C. ការគោរពពេលវេលានៃក្រុមអធិការកិច្ច | ២០,២១,២២,២៣ |
| D. ការត្រៀមលក្ខណៈរបស់គ្រូមុនពេលអធិការកិច្ច | ២៤,២៥,២៦,២៨ |
| ផ្នែកទី៣៖ ឥរិយាបថគ្រូបង្រៀន អំឡុងពេលអធិការកិច្ចលើការបង្រៀន និងរៀន | |
| A. ពេលសង្កេតថ្នាក់ | ២៩,៣០,៣១,៣២,៣៣,៣៤ |
| B. ការពិនិត្យការបង្រៀន | ៣៥,៣៦,៣៧,៣៨,៣៩,៤០ |
| C. ការសម្ភាសអំពីការរៀន និងរៀន | ៤១,៤២,៤៣,៤៤,៤៥,៤៦,៤៧ |
| ផ្នែកទី៤៖ ឥរិយាបថគ្រូបង្រៀន ក្រោយពេលអធិការកិច្ចលើការបង្រៀន និងរៀន | |
| A. ការផ្តល់អនុសាសន៍ | ៤៨,៤៩,៥០,៥១,៥២,៥៣,៥៤,៥៦,៥៧,៥៨ |
| B. ការផ្តល់របាយការណ៍ | ៥៩,៦០,៦១,៦២,៦៣,៦៤,៦៥,៦៦,៦៧ |
| មតិយោបល់បន្ថែម | ៦៨,៦៩,៧០,៧១ |

កម្រងសំណួរនេះ អ្នកស្រាវជ្រាវបែងចែកជាផ្នែកៗដូចកម្រងសំណួរសម្រាប់គ្រូបង្រៀនដែរ តែមានការកែប្រែខ្លះដើម្បីឆ្លុះបញ្ចាំងពីឥរិយាបថគ្រូបង្រៀនចំពោះអធិការកិច្ច តាមរយៈនាយក/នាយិកាសាលា។ កម្រងសំណួរនេះ បង្កើតឡើងក្នុងគោលបំណងបង្ហាញពីភាពកាន់តែច្បាស់ ក្នុងនាមគាត់ជាគណៈគ្រប់គ្រងសាលា អំពីឥរិយាបថរបស់គ្រូបង្រៀន។ ចំពោះកម្រងសំណួរសម្រាប់គ្រូ និងនាយកសាលា អ្នកស្រាវជ្រាវបង្កើតឡើងជាទម្រង់បិទ និងសំណួរបើក ព្រោះសំណួរបើកជាសំណួរសម្រាប់ពញ្ញាក់អារម្មណ៍អ្នកបំពេញកម្រងសំណួរឱ្យគាត់មានការប្រុងប្រយ័ត្នក្នុងការឆ្លើយសំណួរនីមួយៗ។ ម្យ៉ាងទៀត សំណួរបើកប្រើសម្រាប់បំពេញចន្លោះប្រហោងនៃកម្រងសំណួរបិទ ហើយវាអាចឱ្យអ្នកបំពេញកម្រងសំណួរអាចបញ្ចេញយោបល់អំពីអ្វីដែលមិនមានក្នុងកម្រងសំណួរទម្រង់បិទបានផងដែរ។

*៣.៥.៣ កម្រងសំណួរសម្រាប់សិស្ស*

កម្រងសំណួរសម្រាប់សិស្ស មានពីរផ្នែកដែលចែកចេញជា ៤សំណួរ ៖

- **ផ្នែកទី១ ព័ត៌មានទូទៅ** ក្នុងផ្នែកនេះមាន៤សំណួរ។ អ្នកស្រាវជ្រាវចង់ដឹងឈ្មោះសាលារៀន ភេទ អាយុរបស់សិស្សដែលចូលរួមឆ្លើយសំណួរ និងកម្រិតថ្នាក់រៀនរបស់ពួកគេផងដែរ។
- ***ផ្នែកទី២ ព័ត៌មានអំពីអធិការកិច្ច*** មាន៩សំណួរ។ ក្នុងផ្នែកនេះ អ្នកស្រាវជ្រាវចង់ស្វែងយល់បន្ថែមពីអ្វីដែលសិស្សមើលឃើញពីសកម្មភាពរបស់គ្រូ អំឡុងពេលមានអធិការកិច្ចថ្នាក់រៀន។ តើគ្រូបង្រៀនបានរៀបចំអ្វីខ្លះសម្រាប់អធិការកិច្ច តើការបង្រៀនរបស់គ្រូមានការប្រែប្រួលឬទេពេលមានអធិការសង្កេតថ្នាក់? តើគ្រូបង្រៀនបាននិយាយពីលទ្ធផលអធិការកិច្ចដែរឬទេ?

កម្រងសំណួរសម្រាប់សិស្សនេះ អ្នកស្រាវជ្រាវជ្រើសរើសយកជាទម្រង់បិទសុទ្ធសាធ ព្រោះសិស្សនៅបឋមសិក្សាមានអាយុតិច មិនទាន់មានការយល់ដឹងពីការងារអធិការកិច្ចស៊ីជម្រៅនៅឡើយទេ។ ម្យ៉ាងទៀត សិស្សមិនទាន់អាចវិភាគ និងបានចាប់អារម្មណ៍ពីឥរិយាបថរបស់គ្រូទាក់ទងនឹងការធ្វើអធិការកិច្ចនាពេលកន្លងមកទេ។ ទោះជាបែបនេះក្តី ចម្លើយរបស់សិស្សនៅតែអាចឱ្យអ្នកស្រាវជ្រាវ វិភាគឃើញពី

សកម្មភាពមួយចំនួនរបស់គ្រូបង្រៀននៅពេលមានអធិការកិច្ចការបង្រៀន និងរៀនផងដែរ ព្រោះនៅក្នុងកម្រងសំណួរនេះមានសួរអំពីសកម្មភាពរបស់គ្រូមុនពេល អំឡុងពេល និងក្រោយពេលអធិការកិច្ច។

នៅពេលកម្រងសំណួរសម្រាប់គ្រូ នាយក និងសិស្សត្រូវបានបង្កើតរួចរាល់ អ្នកស្រាវជ្រាវបានយកកម្រងសំណួរនេះទៅសាកល្បងឱ្យលោកគ្រូ/អ្នកគ្រូ ចំនួន៥នាក់ នាយក២នាក់ និងសិស្ស៥នាក់ ដើម្បីប្រាកដថាកម្រងសំណួរនេះ មានភាពងាយស្រួលក្នុងការឆ្លើយ និងបានប្រើប្រាស់ពាក្យពេចន៍សមស្រប។ ជាក់ស្តែងក្រោយពីការសាកល្បង អ្នកស្រាវជ្រាវបានរកឃើញ និងធ្វើការកែប្រែចំណុចមួយចំនួនដូចជា៖ លោកគ្រូ/អ្នកគ្រូពីរនាក់ បានយល់ច្រលំទៅលើកម្រិតយល់ស្របទាំង៥កម្រិត ដែលត្រូវឱ្យគាត់ជ្រើសរើសនៅក្នុងតារាង។ ត្រង់ចំណុចនេះ អ្នកស្រាវជ្រាវបានដាក់ពាក្យពេចន៍ខ្លះ ជាតួលេខ ជាភាគរយដើម្បីធ្វើឱ្យអ្នកឆ្លើយកម្រងសំណួរងាយឆ្លើយ មិនច្រលំ។ ម្យ៉ាងទៀត ពាក្យពេចន៍មួយចំនួនរួមទាំងការអក្ខរាវិរុទ្ធផងដែរ ត្រូវបានកែប្រែផងដែរ បន្ទាប់ពីការធ្វើតេស្តសាកល្បង។

## ៣.៦ វិធីសាស្ត្រប្រមូលទិន្នន័យ

ការសិក្សានេះប្រើប្រាស់វិធីសាស្ត្របរិមាណវិស័យ និងគុណវិស័យ ក្នុងការប្រមូលទិន្នន័យ ។ របៀបប្រមូលទិន្នន័យសម្រាប់បរិមាណវិស័យ គឺបានផ្តល់កម្រងសំណួរ (សំណួរបិទ) ដែលបានរៀបចំទុកជាមុនស្របតាមគោលបំណងនៃការស្រាវជ្រាវដល់នាយក/នាយិកា លោកគ្រូ/អ្នកគ្រូ និងសិស្សឆ្លើយដោយមានការសម្របសម្រួលផ្ទាល់ពីអ្នកស្រាវជ្រាវ។ ចំណែកឯទិន្នន័យសម្រាប់គុណវិស័យវិញ គឺបានផ្តល់កម្រងសំណួរ (សំណួរបើក) ដល់នាយក/នាយិកា លោកគ្រូ/អ្នកគ្រូ និងសិស្សឆ្លើយដោយការសរសេរបន្ថែមនៅលើកម្រងសំណួរផ្ទាល់។

## ៣.៧ ដំណើរការក្នុងការប្រមូលទិន្នន័យ

ការសិក្សាលើប្រធានបទនេះ អ្នកស្រាវជ្រាវបានធ្វើការទាក់ទងសុំការអនុញ្ញាតផ្ទាល់ជាមុនពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង/ស្រុក និងសាលាបឋមសិក្សានានា ជាគោល

ដៅនៃការសិក្សាស្រាវជ្រាវនេះ ។ ជាដំបូងអ្នកសិក្សាស្រាវជ្រាវបានទៅជួបជាមួយនឹងប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ធំ តាមរយៈការិយាល័យ រដ្ឋបាល ដោយភ្ជាប់ទៅជាមួយនូវលិខិត **លេខ១១៥ វជអ.ផក** ស្តីពីការសម្រួលដល់ការស្រាវជ្រាវរបស់និស្សិតឈ្មោះ **នៅ ចាន់មករា** នៅតាមសាលាបឋមសិក្សានានាក្នុងខេត្តកំពង់ធំ ដើម្បីសុំការអនុញ្ញាតប្រថាប់ត្រាលើលិខិតឧទ្ទេសនាមដែលចេញដោយ វិទ្យាស្ថានជាតិអប់រំ និងសុំការអនុញ្ញាតបន្តចុះទៅតាមសាលាគោលដៅ។ បន្ទាប់ពីបានការទទួលស្គាល់ អនុញ្ញាតពីមន្ទីរអប់រំ យុវជន និងកីឡា រួចហើយអ្នកសិក្សាស្រាវជ្រាវបានសុំជួបជាមួយនឹង ប្រធានការិយាល័យអប់រំ យុវជននិងកីឡា ក្រុង/ស្រុកទាំងបី ដើម្បីសុំការអនុញ្ញាតបន្តចុះតាមសាលាដែលបានកំណត់ទុក។ ក្រោយមកទៀត អ្នកស្រាវជ្រាវបានទំនាក់ទំនងតាមទូរសព្ទទៅកាន់នាយក/នាយិកាសាលាគោលដៅ ដើម្បីសុំការអនុញ្ញាត និងកំណត់ពេលវេលាក្នុងការទៅប្រមូលទិន្នន័យ។ នៅពេលទៅដល់សាលារៀនគោលដៅ អ្នកស្រាវជ្រាវ បានជម្រាបអំពីគោលបំណងនៃការចុះធ្វើការសិក្សាស្រាវជ្រាវនេះ ទៅដល់នាយក/នាយិកា រួមទាំងលោកគ្រូ/អ្នកគ្រូ ដើម្បីស្នើសុំជួយសម្រួលក្នុងដំណើរការនេះ។ កម្រងសំណួរត្រូវបានចែកជូន លោកគ្រូ/អ្នកគ្រូ នាយិក/នាយិកា និងសិស្សម្នាក់មួយច្បាប់ ឱ្យចូលរួមបំពេញដោយមានអ្នកស្រាវជ្រាវជាអ្នកសម្របសម្រួលផ្ទាល់។ បន្ទាប់ពីបានបំពេញរួចរាល់ អ្នកសិក្សាស្រាវជ្រាវបានប្រមូលយកកម្រងសំណួរពី នាយក/នាយិកា លោកគ្រូ/អ្នកគ្រូ សិស្សានុសិស្សវិញ និងបានពិនិត្យមើលកម្រងសំណួរដែលបំពេញហើយឡើងវិញ ដើម្បីប្រាកដថាទិន្នន័យទាំងអស់បានបំពេញរួចរាល់ក្នុងការយកមកវិភាគ។ ការសិក្សាស្រាវជ្រាវនេះបានចុះទៅសិក្សាតាមទីកន្លែង ដែលបានកំណត់ជ្រើសរើស ដោយបានប្រើរយៈពេលប្រហែលបួនសប្តាហ៍(០៤)សប្តាហ៍នៃថ្ងៃបង្រៀននៅតាមសាលាដោយគិតចាប់ពីថ្ងៃទី១៧ ខែកក្កដា ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០។

ដោយសារក្នុងស្ថានភាពប្រទេសកម្ពុជាកំពុងប្រឈមមុខ នឹងជំងឺកូវីដ-១៩ (Covid-19) អ្នកស្រាវជ្រាវបានកាត់បន្ថយសាលារៀនគោលដៅចំនួនពីរ គឺសាលាបឋមសិក្សា មហរ នៅស្រុកកំពង់ស្វាយ និងសាលាបឋមសិក្សា ព្រៃក្តី នៅស្រុកប្រាសាទសំបូរ។ អ្នកស្រាវជ្រាវបានស្នើសុំលោកគ្រូ/អ្នកគ្រូ និង

សិស្សានុសិស្សថ្នាក់ទី៤ ដល់ទី៦ ទាំងអស់ដែលបានអញ្ជើញមកសាលារៀនតាមភាពជាក់ស្តែង ដើម្បីបំពេញកម្រងសំណួរតាមប្រភេទដែលបានកំណត់ និងបានរក្សាគម្លាតសុវត្ថិភាពសង្គមតាមការណែនាំរបស់ក្រសួងសុខាភិបាល។ ជាចុងក្រោយ អ្នកស្រាវជ្រាវបានទទួលទិន្នន័យរបស់អ្នកពាក់ព័ន្ធដែលបានបំពេញត្រឹមត្រូវសរុបចំនួន២៨១ច្បាប់ រួមមាន ពីនាយក/នាយិកា ចំនួន១៣ច្បាប់ ពីគ្រូបង្រៀនចំនួន៩៤ច្បាប់ និងសិស្សចំនួន១៧៤ច្បាប់។

### ៣.៧.១ ព័ត៌មានទូទៅរបស់គ្រូបង្រៀន

តាមតារាង 12 បង្ហាញថាក្នុងចំណោមអ្នកចូលរួមបំពេញកម្រងសំណួរ ៩៤នាក់ ភាគច្រើនជាអ្នកគ្រូមានចំនួន ៦៦នាក់ ត្រូវនឹង ៧០% ចំណែកឯ លោកគ្រូមានចំនួន ៣៣នាក់ ស្មើនឹង ៣០%។ លោកគ្រូ/អ្នកគ្រូបង្រៀននៅសាលារៀនស្ថិតក្នុងតំបន់ទីប្រជុំជន ចំនួន៥០នាក់ ស្មើនឹង ៥៣% ក្រៅពីនេះបង្រៀននៅតាមសាលាស្ថិតក្នុងតំបន់ជនបទ។ ក្នុងចំណោមគ្រូបង្រៀន៩៤នាក់ មានលោកគ្រូ/អ្នកគ្រូចំនួន៤៣នាក់ ស្មើនឹង ៤៦% មកពីសាលារៀនដែលមានថ្នាក់រៀន លើសពី១០ថ្នាក់ ហើយគ្រូបង្រៀនចំនួន២៧នាក់ ស្មើនឹង២៩% មកពីសាលារៀនដែលមានថ្នាក់រៀន ចន្លោះពី ៧ដល់១០ថ្នាក់ ក្រៅពីនេះគឺ គ្រូបង្រៀន២៤នាក់ទៀត ស្មើនឹង ២៦% មកពីសាលារៀនដែលមានថ្នាក់រៀន ចន្លោះពី១ ដល់៦ថ្នាក់។ ក្នុងនោះផងដែរ ក្នុងចំណោមគ្រូបង្រៀនថ្នាក់បឋមសិក្សា៩៤នាក់ មាន ៧៩នាក់ ស្មើនឹង ៨៤% ជាគ្រូបង្រៀនមានក្របខ័ណ្ឌរដ្ឋពេញសិទ្ធិ និងគ្រូ១៥នាក់ផ្សេងទៀត ស្មើនឹង ១៦% ជាគ្រូកិច្ចសន្យា។ គ្រូបង្រៀនដែលបានចូលរួមបំពេញកម្រងសំណួរមានកម្រិតវិជ្ជាជីវៈមិនដូចគ្នាទេ គឺគ្រូបឋមសិក្សាមានចំនួន៧៤នាក់ ស្មើនឹង ៧៩% និងគ្រូមូលដ្ឋានមានចំនួន ២០នាក់ ស្មើនឹង ២១%។ ទាក់ទងនឹងកម្រិតវប្បធម៌របស់គ្រូបង្រៀនវិញ លោកគ្រូ/អ្នកគ្រូភាគច្រើន បានបញ្ចប់ការសិក្សាមធ្យមសិក្សាទុតិយភូមិ ដែលមានចំនួន៥០នាក់ ស្មើនឹង ៥៣%។ បន្ទាប់មក គ្រូបង្រៀនដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ មានចំនួន ៣៣នាក់ ស្មើនឹង ៣៥% ក្រៅពីនេះមានគ្រូបង្រៀន១០នាក់ ស្មើនឹង១១% មានសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ហើយមានតែគ្រូបង្រៀន១នាក់ប៉ុណ្ណោះ មានបរិញ្ញាបត្រ

ជាន់ខ្ពស់។ ចំពោះបទពិសោធន៍ការងារជាអាជីពគ្រូបង្រៀនវិញ លោកគ្រូ/អ្នកគ្រូដែលបានបំពេញការងារជាគ្រូបង្រៀនរយៈពេលលើសពី១០ឆ្នាំមានដល់ទៅ ៦២នាក់ ស្មើនឹង ៦៦% ចំណែកគ្រូដែលបំពេញការងារចន្លោះពី ៧ឆ្នាំដល់ ៩ឆ្នាំ មានចំនួន ៨នាក់ ស្មើនឹង ៩% , បទពិសោធន៍ចន្លោះពី៤ឆ្នាំ ដល់ ៦ឆ្នាំមានចំនួន ៨នាក់ ស្មើនឹង ៩% ,ចន្លោះពី១ឆ្នាំដល់ ៣ឆ្នាំមានចំនួន ១០នាក់ ស្មើនឹង ១១% និងតិចជាង១ឆ្នាំមានចំនួន ៦នាក់ ស្មើនឹង ៦%។

| ល.រ | បរិយាយ | | សរុបរួម | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ១ | ទីតាំងសាលារៀន | តំបន់ជនបទ | 44 | 47% |
| | | តំបន់ទីប្រជុំជន | 50 | 53% |
| | | សរុប | 94 | 100% |
| ២ | ចំនួនថ្នាក់រៀន | ពី១ដល់៦ថ្នាក់ | 24 | 26% |
| | | ពី៧ដល់១០ថ្នាក់ | 27 | 29% |
| | | លើសពី១០ថ្នាក់ | 43 | 46% |
| | | សរុប | 94% | 100% |
| ៣ | ភេទ | ប្រុស | 28 | 30% |
| | | ស្រី | 66 | 70% |
| | | សរុប | 94 | 100% |
| ៤ | រយៈពេលបំពេញការងារជាគ្រូបង្រៀន | តិចជាង ១ឆ្នាំ | 6 | 6% |
| | | ពី១ឆ្នាំ ដល់ ៣ឆ្នាំ | 10 | 11% |
| | | ពី៤ឆ្នាំ ដល់ ៦ឆ្នាំ | 8 | 9% |

| | | | | |
|---|---|---|---|---|
| | | ពី៧ឆ្នាំ ដល់ ៩ឆ្នាំ | 8 | 9% |
| | | លើសពី ១០ឆ្នាំ | 62 | 66% |
| | | សរុប | 94 | 100% |
| ៥ | កម្រិតវប្បធម៌ | មធ្យមសិក្សាបឋមភូមិ | 10 | 11% |
| | | មធ្យមសិក្សាទុតិយភូមិ | 50 | 53% |
| | | បរិញ្ញាបត្រ | 33 | 35% |
| | | បរិញ្ញាបត្រជាន់ខ្ពស់ | 1 | 1% |
| | | សរុប | 94 | 100% |
| ៦ | កម្រិតវិជ្ជាជីវៈ | គ្រូបឋមសិក្សា | 74 | 79% |
| | | គ្រូមូលដ្ឋាន | 20 | 21% |
| | | សរុប | 94 | 100% |
| ៧ | ក្របខ័ណ្ឌ | គ្រូក្របខ័ណ្ឌរដ្ឋ | 79 | 84% |
| | | គ្រូកិច្ចសន្យា | 15 | 16% |
| | | សរុប | 94 | 100% |

***តារាង 12៖** ព័ត៌មានទូទៅអំពីគ្រូបង្រៀន ដែលបានចូលរួមបំពេញកម្រងសំណួរ*

### ៣.៧.២ ព័ត៌មានទូទៅអំពីនាយក/នាយិកា

ក្នុងការសិក្សាស្រាវជ្រាវនេះផងដែរ អ្នកស្រាវជ្រាវបានស្នើសុំលោកនាយក និងលោកស្រីនាយិកានៅតាមសាលាបឋមសិក្សាទាំង១៣ ដើម្បីជួយបំពេញកម្រងសំណួរលើប្រធានបទដដែលនេះ។ ជាលទ្ធផលបង្ហាញថា សាលារៀនដែលស្ថិតក្នុងតំបន់ជនបទមាន ៨សាលាស្មើនឹង ៦២% និង៥សាលាទៀត ស្មើនឹង

៣៨%ជាសាលានៅក្នុងតំបន់ទីប្រជុំជន។ ក្នុងនោះផងដែរ សាលារៀនសម្ព័ន្ធ មានចំនួន៩សាលា ស្មើនឹង ៦៩% និងក្រៅពីនេះគឺសាលារៀនបង្គោល មានចំនួន ៤សាលា ស្មើនឹង៣១% ។

***តារាង 13៖*** *ព័ត៌មានទូទៅអំពីនាយក/នាយិកា ដែលបានចូលរួមបំពេញកម្រងសំណួរ*

| ល.រ | បរិយាយ | | សរុបរួម | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ១ | ប្រភេទសាលារៀន | សម្ព័ន្ធ | 9 | 69% |
| | | ឧបសម្ព័ន្ធ | 0 | 0% |
| | | បង្គោល | 4 | 31% |
| | | សរុប | 13 | 100% |
| ២ | ទីតាំងសាលារៀន | តំបន់ជនបទ | 8 | 62% |
| | | តំបន់ទីប្រជុំជន | 5 | 38% |
| | | សរុប | 13 | 100% |
| ៣ | ចំនួនថ្នាក់រៀន | ពី១ដល់៦ថ្នាក់ | 5 | 38% |
| | | ពី៧ដល់១០ថ្នាក់ | 4 | 31% |
| | | លើសពី១០ថ្នាក់ | 4 | 31% |
| | | សរុប | 13 | 100% |
| ៤ | ភេទ | ប្រុស | 10 | 77% |
| | | ស្រី | 3 | 23% |
| | | សរុប | 13 | 100% |

| | | | | |
|---|---|---|---|---|
| ៥ | រយៈពេលបំពេញការងារជាគ្រូបង្រៀន | តិចជាង ១ឆ្នាំ | 0 | 0 |
| | | ពី១ឆ្នាំ ដល់ ៣ឆ្នាំ | 0 | 0 |
| | | ពី៤ឆ្នាំ ដល់ ៦ឆ្នាំ | 0 | 0 |
| | | ពី៧ឆ្នាំ ដល់ ៩ឆ្នាំ | 0 | 0 |
| | | លើសពី ១០ឆ្នាំ | 13 | 100% |
| | | សរុប | 13 | 100% |
| ៦ | រយៈពេលបំពេញការងារជានាយក/នាយិកា | តិចជាង ១ឆ្នាំ | 1 | 8% |
| | | ពី១ឆ្នាំ ដល់ ៣ឆ្នាំ | 2 | 15% |
| | | ពី៤ឆ្នាំ ដល់ ៦ឆ្នាំ | 1 | 8% |
| | | ពី៧ឆ្នាំ ដល់ ៩ឆ្នាំ | 3 | 23% |
| | | លើសពី ១០ឆ្នាំ | 6 | 46% |
| | | សរុប | 13 | 100% |
| ៧ | កម្រិតវប្បធម៌ | មធ្យមសិក្សាបឋមភូមិ | 0 | 0 |
| | | មធ្យមសិក្សាទុតិយភូមិ | 7 | 54% |
| | | បរិញ្ញាបត្រ | 6 | 46% |
| | | បរិញ្ញាបត្រជាន់ខ្ពស់ | 0 | 0 |
| | | សរុប | 13 | 100% |
| ៨ | កម្រិតវិជ្ជាជីវៈ | គ្រូបឋមសិក្សា | 5 | 38% |
| | | គ្រូមូលដ្ឋាន | 8 | 62% |
| | | សរុប | 13 | 100% |

យោងតាមតារាង 13 ឃើញថា ក្នុងចំណោមសាលាបឋមសិក្សាទាំង១៣ មាននាយក១០នាក់ ស្មើនឹង ៧៧% ចំណែកឯនាយិកាមាន៣នាក់ស្មើនឹង ២៧%។ លើសពីនេះមិនថានាយក ឬនាយិកាទាំងអស់ សុទ្ធតែមានបទពិសោធន៍ជាគ្រូបង្រៀន និងមានអតីតភាពបង្រៀនលើសពី១០ឆ្នាំដូចគ្នា ប៉ុន្តែបទពិសោធន៍លើការងារជានាយក/នាយិកាមិនស្មើគ្នាទេ ពោលមានតែ៦នាក់ស្មើនឹង៤៦%ប៉ុណ្ណោះ ដែលមានអតីតភាពជានាយក លើសពី ១០ឆ្នាំ។ ចំពោះកម្រិតសញ្ញាបត្រវិញ នាយក/នាយិកា ៧នាក់ ស្មើនឹង ៤៦% មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និង៤៦%ទៀតបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។ ម្យ៉ាងទៀតទោះបី ជាទីកន្លែងការងារជាសាលាបឋមសិក្សាក្តី ក៏នាយក/នាយិកា ចំនួន៨នាក់ ស្មើនឹង ៦២% មានសញ្ញាបត្រវិជ្ជាជីវៈគ្រូមូលដ្ឋាន និង៥នាក់ផ្សេងទៀត ស្មើនឹង៣៨% ជាគ្រូបឋម។

### ៣.៧.៣ ព័ត៌មានទូទៅអំពីសិស្ស

ការស្រាវជ្រាវនេះផងដែរ មានការចូលរួមពីសិស្សានុសិស្សពីថ្នាក់ទី៤ ដល់ថ្នាក់ទី៦ ដើម្បីចូលរួមបំពេញកម្រងសំណួរ។ ក្រោយពីបានប្រមូលទិន្នន័យរួចរាល់ ដូចបានបង្ហាញក្នុងតារាង14 ឃើញថា៖ ក្នុងចំណោមសិក្សា ១៧៤នាក់ មានសិស្សស្រីចំនួន ៩៩នាក់ ស្មើនឹង ៥៧% និងសិស្សប្រុស ៧៥នាក់ ស្មើនឹង ៤៣%។ សិស្សភាគច្រើនដែលបានបំពេញកម្រងសំណួរ ជាសិស្សរៀនថ្នាក់ទី៦ មានចំនួន ១១៣នាក់ ដែលស្មើនឹង៦៥% នៃភាគសំណាក និងសិស្សថ្នាក់ទី៥ចំនួន ៥០នាក់ ស្មើនឹង២៩% ចំណែកឯសិស្សរៀនថ្នាក់ទី៤មានចំនួនតិចជាងគេ គឺត្រឹម១១នាក់ ស្មើនឹង៦%។ សិស្សទាំងអស់នោះមានអាយុចន្លោះពី ១០ឆ្នាំ ដល់ ១៦ឆ្នាំ ប៉ុន្តែសិស្សដែលបានចូលរួមបំពេញកម្រងសំណួរច្រើនជាងគេមានអាយុ ១៣ឆ្នាំ ចំនួន៥០នាក់ ដែលស្មើនឹង២៩% ។ ចំណែកក្រុមសិស្សដែលមានចំនួនតិចជាងគេគឺ ក្រុមសិស្សអាយុ១០ ឆ្នាំ និង១៦ឆ្នាំ។

| ល.រ | បរិយាយ | | សរុបរួម | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ១ | ថ្នាក់ | ៤ | 11 | 6% |
| | | ៥ | 50 | 29% |
| | | ៦ | 113 | 65% |
| | | សរុប | 174 | 100% |
| ២ | ភេទ | ប្រុស | 75 | 43% |
| | | ស្រី | 99 | 57% |
| | | សរុប | 174 | 100% |
| ៣ | អាយុ | ១០ | 4 | 2% |
| | | ១១ | 36 | 21% |
| | | ១២ | 54 | 31% |
| | | ១៣ | 50 | 29% |
| | | ១៤ | 21 | 12% |
| | | ១៥ | 7 | 4% |
| | | ១៦ | 2 | 1% |
| | | សរុប | 174 | 100% |

***តារាង 14៖*** *ព័ត៌មានទូទៅអំពីសិស្សានុសិស្ស ដែលបានចូលរួមបំពេញកម្រងសំណួរ*

## ៣.៨ ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យដែលទទួលបាន តាមរយៈការបំពេញកម្រងសំណួរ អ្នកស្រាវជ្រាវជ្រាវប្រើប្រាស់កម្មវិធី Mricrosoft Excel version 2016 ដើម្បីបញ្ចូល គណនា វិភាគទិន្នន័យ បង្ហាញតារាង និងតាងក្រាហ្វិក ក្នុងការវិភាគតាមបែបបរិមាណវិស័យ ដែលបង្ហាញពីកម្រិតចម្លើយនៃសកម្មភាពនានាដែលពាក់ព័ន្ធនឹងឥរិយាបថគ្រូបង្រៀនបឋមសិក្សាចំពោះអធិការកិច្ច មានដូចជា ប្រេកង់ ភាគរយ តម្លៃមធ្យម។ ចំណែកសំណួរបើកវិញ ជាសំណួរបែបរៀបរាប់ យើងខ្ញុំវិភាគដោយប្រើប្រាស់កម្មវិធី Mricrosoft Excel version 2016 ដើម្បីរាប់ចំនួនចម្លើយរបស់អ្នកឆ្លើយ។ ដូច្នេះ នៅក្នុងការវិភាគចម្លើយ ចំពោះរាល់សំណួរទាំងអស់ ត្រូវបានធ្វើការវិភាគ គឺអាស្រ័យទៅលើប្រភេទនៃសំណួរ ថាតើវាជាប្រភេទសំណួរបើក ឬសំណួរបិទ បន្ទាប់មកអ្នកស្រាវជ្រាវបានធ្វើការសំយោគរួមតាមផ្នែកដែលពាក់ព័ន្ធតាមក្រោយ។ ចំពោះការវិភាគនេះ អ្នកសិក្សាស្រាវជ្រាវបានវិភាគលើចំណុចសំខាន់មួយចំនួន ដូចជាឥរិយាបថរបស់គ្រូមុនពេលអធិការកិច្ច ក្នុងពេលអធិការកិច្ច និងក្រោយពេលអធិការកិច្ច។ អ្នកស្រាវជ្រាវនឹងធ្វើការបកស្រាយទិន្នន័យដែលប្រមូលបានពីគ្រូបង្រៀន ដោយប្រៀបធៀបជាមួយទិន្នន័យដែលប្រមូលបានពីនាយក/នាយិកា និងសិស្ស។ អ្នកស្រាវជ្រាវធ្វើការវិភាគកម្រងសំណួរទាំងបីប្រភេទ បញ្ចូលគ្នា ព្រោះវាងាយស្រួលក្នុងវិភាគ និងងាយយល់។ ម្យ៉ាងទៀតការវិភាគទិន្នន័យទាំងបីប្រភេទទាំងបីព្រមគ្នាក្នុងពេលតែមួយ ធ្វើឱ្យអ្នកអានងាយតាមដានពីទំនាក់ទំនងរវាងផ្នែកនីមួយៗនៃកម្រងសំណួរ និងអាចឆ្លុះបញ្ចាំងពីឥរិយាបថរបស់គ្រូបង្រៀនបានគ្រប់ជ្រុងជ្រោយដោយមានការចូលរួមឆ្លើយពីសិស្ស និងនាយកសាលា។

ដើម្បីបកស្រាយទៅលើទិន្នន័យដែលប្រមូលបានពីភាគសំណាកទាំងអស់ អ្នកស្រាវជ្រាវប្រើប្រាស់រូបមន្តប្រេកង់ (Frequency) តំណាងឱ្យភាគរយ សម្រាប់បង្ហាញពី ទីតាំងរបស់សាលារៀន ចំនួនថ្នាក់រៀនក្នុងសាលារៀន ភេទ រយៈពេលបំពេញការងារ កម្រិតសញ្ញាបត្រ កម្រិតវិជ្ជាជីវៈ ប្រភេទក្របខណ្ឌ (សម្រាប់គ្រូបង្រៀន និងនាយក/នាយិកា) ព្រមទាំងបង្ហាញពីថ្នាក់ដែលកំពុងរៀន ភេទ អាយុ(សម្រាប់សិស្ស)។ ដាង

នេះ ក្នុងការបកស្រាយផ្នែកផ្សេងទៀត អ្នកស្រាវជ្រាវប្រើប្រាស់ រូបមន្ត Mean ដែលតំណាងឱ្យតម្លៃមធ្យម ដែលប្រើក្នុងការវាយតម្លៃលើឥរិយាបថរបស់លោកគ្រូ អ្នកគ្រូនៅកម្រិតបឋមសិក្សាចំពោះអធិការកិច្ចលើការបង្រៀន និងរៀន ។

តម្លៃមធ្យម (Mean) គឺជាការកំណត់យកចំណុចកណ្តាលនៃទីតាំងដោយយកផលសរុបនៃតម្លៃចែកនឹងចំនួនអាំងឌីកាទ័រ( នីដា, ២០១៨)។

បើយោងតាម SPIEGEL and J.STEPHENS (2008) តម្លៃមធ្យមគណនាតាមរូបមន្ត៖

$$\overline{X} = \frac{X_1 + X_2 + X_3 + \ldots\ldots + X_N}{N} = \frac{\sum_{i=1}^{N} X_i}{N}$$ ដែល $X_1, X_2, X_3, \ldots\ldots, X_N$ ជាទិន្នន័យ

និង $N$ ជាចំនួនទិន្នន័យ

ប្រសិនបើ $X_1, X_2, X_3, \ldots\ldots, X_N$ មានចំនួន $f_1, f_2, f_3, \ldots\ldots, f_N$ ដង នោះតម្លៃមធ្យមគេសរសេរ

$$\overline{X} = \frac{f_1X_1 + f_2X_2 + f_3X_3 + \ldots\ldots + f_NX_N}{f_1 + f_2 + f_3 + \ldots\ldots + f_N} = \frac{\sum_{i=1}^{N} f_iX_i}{\sum_{i=1}^{N} f_i}$$

ការកំណត់ពិន្ទុលើតម្លៃមធ្យម គឺយកតាមលំនាំកម្រិតពិន្ទុរបស់ Wannatawee, Worakham, & Panya (2017) បានសន្មត់យកមធ្យមភាគ និងកម្រិតចង្អុលបង្ហាញដូចខាងក្រោម៖

Mean = 1.00 ដល់ 1.50 ខ្សោយណាស់

Mean =1.51 ដល់ 2.50 ខ្សោយ

Mean = 2.51 ដល់ 3.50 មធ្យម

Mean = 3.51 ដល់ 4.50 ល្អ

Mean = 4.51 ដល់ 5.00 ល្អណាស់

ក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានកំណត់យកកម្រិតយល់ស្រប ល្អ និងល្អណាស់ជាតម្លៃងាកទៅរកឥរិយាបថវិជ្ជមាន និងកម្រិតយល់ស្រប ខ្សោយណាស់ ខ្សោយ មធ្យម ជាតម្លៃងាកទៅរកឥរិយាបថអវិជ្ជមាន។

**ការកំណត់យកពិន្ទុ**

| កម្រិតនៃការយល់ស្រប | ពិន្ទុ |
|---|---|
| មិនយល់ស្របទាល់តែសោះ | 1 |
| មិនយល់ស្រប | 2 |
| មិនច្បាស់( មិនយល់ស្របខ្លះ យល់ស្របខ្លះ ) | 3 |
| យល់ស្រប | 4 |
| យល់ស្របទាំងស្រុង | 5 |

ឧទាហរណ៍៖ ការគណនាតម្លៃមធ្យមតាមសូចនាករនីមួយៗ៖

| ល.រ | បរិយាយ | យល់ស្របខ្លាំង | មិនយល់ស្រប | មិនច្បាស់ | យល់ស្រប | យល់ស្របខ្លាំង | តម្លៃមធ្យម |
|---|---|---|---|---|---|---|---|
| ១ | គ្រូបង្រៀនបានដឹងព័ត៌មាន ពីការចុះអធិការកិច្ចថ្នាក់រៀន | 2 | 2 | 28 | 46 | 16 | 3.77 |
| ២ | គ្រូបង្រៀនចង់ដឹងពីព័ត៌មានអំពីការចុះអធិការកិច្ចថ្នាក់រៀន មុនពេលថ្ងៃចុះអធិការកិច្ច | 2 | 2 | 13 | 34 | 43 | 4.21 |

- តម្លៃមធ្យមនៃសូចនាករទី១៥គឺ

$$\overline{X} = \frac{(2\times1)+(2\times2)+(28\times3)+(46\times4)+(16\times5)}{2+2+28+46+16} = 3.7659 \approx 3.77$$ មានន័យថាការយល់ស្រប

មានកម្រិតល្អ។

- តម្លៃមធ្យមនៃសូចនាករទី១៦គឺ

$$\overline{X} = \frac{(2\times1)+(2\times2)+(13\times3)+(34\times4)+(43\times5)}{2+2+28+46+16} = 4.2127 \approx 4.21$$ មានន័យថាការយល់ស្រប

មានកម្រិតល្អ។

## ៣.៩ ក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ

ក្រមសីលធម៌មានសារៈសំខាន់ណាស់សម្រាប់ការស្រាវជ្រាវ ពីព្រោះរាល់កម្រងសំណួរទាំងទម្រង់បិទ និងទម្រង់បើក គឺអ្នកស្រាវជ្រាវមិនធ្វើឱ្យប៉ះពាល់ដល់អ្នកចូលរួមទេ។ ចំពោះការសិក្សាស្រាវជ្រាវនេះ ដើម្បីរក្សាបាននូវក្រមសីលធម៌ យើងខ្ញុំបានរៀបចំលិខិត ដើម្បីសុំការអនុញ្ញាតពីថ្នាក់ដឹកនាំនៃមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ធំ ដើម្បីបានផ្តល់ដំណឹងបន្តទៅដល់មូលដ្ឋាន និងបានសុំជួបសម្ភាសជាមួយ នាយក/នាយិកា លោកគ្រូ/អ្នកគ្រូ និងសិស្ស ។ នៅគ្រប់ការជួបសម្ភាស ជាមួយនាយក/នាយិកា លោកគ្រូ/អ្នកគ្រូ និងសិស្ស យើងខ្ញុំតែងតែជម្រាបពួកគាត់អំពីក្រមសីលធម៌របស់អ្នកសិក្សាស្រាវជ្រាវ ដែលរក្សានូវការសម្ងាត់នូវរាល់ចម្លើយរបស់ លោកនាយក លោកស្រីនាយិកា លោកគ្រូ អ្នកគ្រូ មិនត្រូវបានបង្ហាញពីឈ្មោះរបស់អ្នកឆ្លើយពិតប្រាកដឡើយ ដើម្បីទាមទារឱ្យបានចម្លើយដែលពិតប្រាកដ។ ព័ត៌មានដែលបានទទួលនឹងមិនត្រូវបានយកទៅប្រើប្រាស់ក្នុងគោលបំណងអ្វីផ្សេងទៀត ក្រៅពីការស្រាវជ្រាវលើប្រធានបទខាងលើនោះទេ។

## ៣.១០ ព្រំដែននៃការសិក្សាស្រាវជ្រាវ

ការសិក្សានេះផ្តោតលើឥរិយាបថគ្រូបង្រៀនបឋមសិក្សា ចំពោះអធិការកិច្ចលើការបង្រៀន និងរៀនភាពដូចគ្នា ឬខុសគ្នារវាងឥរិយាបថគ្រូបង្រៀនដោយផ្អែកលើបទពិសោធន៍ កម្រិតវិជ្ជាជីវៈ និងប្រភេទសាលានៅកម្រិតបឋមសិក្សា ក្នុងក្រុង/ស្រុកចំនួន ០៣ ក្នុងខេត្តកំពង់ធំ តែប៉ុណ្ណោះ។ ក្រុមគោលដៅដែលបានជ្រើស

រើសយកមកសិក្សាគឺមាននាយក/នាយិកា គ្រូបង្រៀនបឋមសិក្សាពីថ្នាក់ទី១ ដល់ទី៦ និងសិស្សថ្នាក់ទី៤ ដល់ទី៦ ។ រាល់កម្រងសំណួរដែលដាក់ជូនអ្នកពាក់ព័ន្ធឆ្លើយ គឺសម្រាប់ការសិក្សាលើគោលបំណងនៃប្រធានបទប៉ុណ្ណោះ។ ព័ត៌មានដែលទទួលបានត្រូវបានរក្សាទុកជាការសម្ងាត់ និងមិនបានយកឈ្មោះ ឬអ្វីដែលបញ្ជាក់ពីអត្តសញ្ញាណរបស់អ្នកចូលរួមទេ ។ ម្យ៉ាងវិញទៀត ចំពោះតំបន់គោលដៅដែលបានជ្រើសរើសយកមកសិក្សាមានលក្ខណៈតូចចង្អៀតនៅឡើយ ដូច្នេះ វាមិនអាចតំណាងឱ្យតំបន់ ឬខេត្តផ្សេងៗទៀតបានទេ ។

# ជំពូកទី៤

# លទ្ធផល និងពិភាក្សា

# ជំពូកទី៤ លទ្ធផល និងការពិភាក្សា

ការស្រាវជ្រាវលើប្រធានបទ "**ឥរិយាបថគ្រូបង្រៀនបឋមសិក្សាចំពោះអធិការកិច្ចលើការបង្រៀន និងរៀននៅក្នុងខេត្តកំពង់ធំ**" ត្រូវបានប្រព្រឹត្តទៅលើសាលាបឋមសិក្សាចំនួន១៣ ក្នុងស្រុកចំនួន២ និងក្រុង១ ក្នុងនោះស្រុកកំពង់ស្វាយមាន៤សាលា, ស្រុកប្រាសាទសំបូរមាន៤សាលា និងក្រុងស្ទឹងសែនមាន៥សាលា។

ក្នុងជំពូកទី៤ នេះអ្នកសិក្សាស្រាវជ្រាវនឹងធ្វើការបង្ហាញពីលទ្ធផលនៃការវិភាគទិន្នន័យ ការបកស្រាយ និងការពិភាក្សានូវអ្វីដែលបានរកឃើញតាមរយៈការបំពេញកម្រងសំណួររបស់ជាតុសំណាក ដែលរួមមាន លោកនាយក/លោកស្រីនាយិកា លោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី១ ដល់ទី៦ និងសិស្សានុសិស្សរៀនថ្នាក់ទី៤ ទី៥ និងទី៦ ទៅលើប្រធានបទ " **ឥរិយាបថគ្រូបង្រៀនបឋមសិក្សាចំពោះអធិការកិច្ចលើការបង្រៀន និងរៀននៅក្នុងខេត្តកំពង់ធំ**"។ រាល់ចំណុចសំខាន់ៗផ្សេងទៀតដែលទាក់ទងនឹងប្រធានបទត្រូវបានលើកយកមកបកស្រាយ និងពិភាក្សានៅក្នុងជំពូកនេះ។ កម្មវិធី Ms. Excel ត្រូវបានប្រើសម្រាប់បញ្ចូលទិន្នន័យ វិភាគ និងសង់តារាង បន្ទាប់មកធ្វើការបកស្រាយ។ ដោយយកទិន្នន័យចេញពីកម្មវិធី Ms. Excel ដើម្បីស្វែងយល់ពីឥរិយាបថគ្រូបង្រៀន ចំពោះការងារអធិការកិច្ចលើការបង្រៀន និងរៀន ទាំងបីដំណាក់កាល គឺដំណាក់កាលមុនពេលអធិការកិច្ច អំឡុងពេលអធិការកិច្ច និងដំណាក់កាលក្រោយពេលអធិការកិច្ច។ នៅក្នុងដំណាក់កាលនៃការវិភាគទិន្នន័យ អ្នកសិក្សាស្រាវជ្រាវបានធ្វើការវិភាគទិន្នន័យដែលប្រមូលបានតាមរយៈការបំពេញកម្រងសំណួររបស់អ្នកចូលរួមទៅតាមផ្នែកតូចៗតាមដំណាក់កាលដូចជា៖ ទំនាក់ទំនងរវាងគ្រូបង្រៀន និងក្រុមអធិការកិច្ច ការផ្តល់ព័ត៌មានអំពីការអធិការកិច្ចទៅដល់គ្រូមុនពេលចុះអធិការកិច្ច ការត្រៀមលក្ខណៈរបស់គ្រូជាមុន ការប្រមូលព័ត៌មានលើការបង្រៀនរបស់គ្រូ រួមទាំងការផ្តល់អនុសាសន៍ និងការផ្តល់របាយការណ៍អធិការកិច្ចផងដែរ។

## ៤.១- លទ្ធផល

### ៤.១.១ ឥរិយាបថគ្រូបង្រៀនបឋមសិក្សា ចំពោះអធិការកិច្ចលើការបង្រៀន និងរៀន

ក្នុងផ្នែកនេះ អ្នកស្រាវជ្រាវ នឹងធ្វើការបកស្រាយទិន្នន័យដែលប្រមូលបានពីគ្រប់ភាគសំណាក ដូចជា លោកគ្រូ/អ្នកគ្រូ នាយក/នាយិកា និងសិស្សានុសិស្ស ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវទី១ " តើគ្រូបង្រៀនបឋមសិក្សា មានឥរិយាបថបែបណាចំពោះអធិការកិច្ចលើការបង្រៀន និងរៀន? "។

#### *៤.១.១.១ ឥរិយាបថគ្រូបង្រៀន មុនពេលអធិការកិច្ចលើការបង្រៀន និងរៀន*

**A. ទំនាក់ទំនងរវាងគ្រូបង្រៀន និងក្រុមអធិការ**

ផ្នែករងនេះ អ្នកស្រាវជ្រាវនឹងបកស្រាយលទ្ធផល ទៅលើឥរិយាបថគ្រូបង្រៀន ទៅលើទំនាក់ទំនងជាមួយក្រុមការងារអធិការកិច្ចដែលទទួលបានពីកម្រងសំណួរសម្ភាសគ្រូបង្រៀន និងនាយក/នាយិកា។ ជាដំបូងយើងនឹងបកស្រាយទៅលើកម្រងសំណួរគ្រូបង្រៀន តាមតារាង15 បានបង្ហាញពីមធ្យមភាគសរុបនៃការទំនាក់ទំនងរវាងគ្រូ និងក្រុមអធិការកិច្ច លើការបង្រៀន និងរៀន គឺគ្រូបង្រៀនយល់ស្របក្នុងកម្រិត"ល្អ" មានមធ្យមភាគពិន្ទុ 4.35។ ក្នុងនោះដែរ សូចនាករទី១២ "ការចុះអធិការកិច្ចបានផ្តល់អត្ថប្រយោជន៍ដល់ការបង្រៀន និងរៀនជាច្រើនគឺជួយជំរុញឱ្យការបង្រៀន និងរៀនឱ្យកាន់តែមានប្រសិទ្ធភាព" និងសូចនាករទី១១ "ក្រុមអធិការបានសម្តែងអាកប្បកិរិយាស្និទ្ធស្នាលជាមួយ លោកគ្រូ/អ្នកគ្រូដោយគ្មានការរើសអើង" គឺទទួលបានការយល់ស្របខ្ពស់ជាងគេ កម្រិត "ល្អ" មានមធ្យមភាគពិន្ទុ 4.50 និង 4.49។ រីឯសូចនាករទី៩ "ក្រុមអធិការបានយល់ច្បាស់ពីតម្រូវការរបស់គ្រូបង្រៀន" ទទួលបានការយល់ស្របទាបជាងគេ គឺស្ថិតនៅកម្រិត "ល្អ" មានមធ្យមភាគពិន្ទុ4.04។

| ល.រ | បរិយាយ | ចំនួន | មធ្យម | លទ្ធផល |
|---|---|---|---|---|
| | **A. ទំនាក់ទំនងរវាងគ្រូបង្រៀន និងអធិការកិច្ច** | | | |
| ១ | ក្រុមអធិការបានយល់ច្បាស់ពីតម្រូវការរបស់គ្រូបង្រៀន | 94 | 4.04 | ល្អ |

| | | | | |
|---|---|---|---|---|
| ២ | ក្រុមអធិការមានអាកប្បកិរិយាសំដែងចេញភាពជាគំរូ និងជាអ្នកអប់រំ | 94 | 4.39 | ល្អ |
| ៣ | ក្រុមអធិការបានសម្តែងអាកប្បកិរិយាស្និទ្ធស្នាលជាមួយ លោកគ្រូ/អ្នកគ្រូដោយគ្មានការរើសអើង | 94 | 4.49 | ល្អ |
| ៤ | ការចុះអធិការកិច្ចបានផ្តល់អត្ថប្រយោជន៍ដល់ការបង្រៀន និងរៀនជាច្រើនគឺជួយជំរុញឱ្យការបង្រៀន និងរៀនឱ្យកាន់តែមានប្រសិទ្ធភាព | 94 | 4.50 | ល្អ |
| ៥ | គ្រូបង្រៀន យល់ថាអធិការមានចំណេះដឹង និងបទពិសោធន៍គ្រប់គ្រាន់លើការបង្រៀន និងរៀន | 94 | 4.32 | ល្អ |
| សរុប | | | 4.35 | ល្អ |

***តារាង 15៖*** *ទំនាក់ទំនងរវាងគ្រូបង្រៀន និងក្រុមអធិការកិច្ច ទទួលបានតាមរយៈកម្រងសំណួរគ្រូបង្រៀន*

សម្រាប់នាយក/នាយិកាវិញ ពួកគាត់យល់ថាទំនាក់ទំនងរវាងគ្រូបង្រៀន និងក្រុមអធិការកិច្ច ស្ថិតក្នុងកម្រិត ″ល្អ″ បើតាមយោងតាមកម្រិតយល់ស្របរបស់នាយក/នាយិកា។ ក្នុងតារាង16 នាយក/នាយិកាយល់ស្របលើទំនាក់ទំនងគ្រូបង្រៀន និងអធិការក្នុងកម្រិត ″ល្អ″ មានមធ្យមភាគពិន្ទុ 4.45។ តាមតារាងដដែលនេះ សូចនាករទី១៣ ″គ្រូបង្រៀនយល់ថាការចុះអធិការកិច្ចបានផ្តល់អត្ថប្រយោជន៍ដល់ការបង្រៀន និងរៀនគឺជួយជំរុញឱ្យការបង្រៀន និងរៀនឱ្យកាន់តែមានប្រសិទ្ធភាព″ បង្ហាញថានាយក/នាយិកាយល់ស្របខ្ពស់ជាងគេកម្រិត ″ល្អណាស់″ ក្នុងមធ្យមភាគពិន្ទុ 4.62។ ចំណែកឯសូចនាករទី១១ ″ គ្រូបង្រៀនបង្ហាញពីទំនាក់ទំនងល្អចំពោះអធិការកិច្ច លើការបង្រៀន និងរៀន″ បានទទួលការយល់ស្របពីនាយក/នាយិកាទាបជាងគេ តែក្នុងកម្រិត ″ល្អ″ លើមធ្យមភាគពិន្ទុ 4.31។

| ល.រ | បរិយាយ | ចំនួន | មធ្យម | លទ្ធផល |
|---|---|---|---|---|
| | **A. ទំនាក់ទំនងរវាងគ្រូបង្រៀន និងអធិការកិច្ច** | | | |
| ១ | គ្រូបង្រៀនបង្ហាញពីទំនាក់ទំនងល្អចំពោះអធិការកិច្ច លើការបង្រៀន និងរៀន | 13 | 4.31 | ល្អ |
| ២ | ក្រុមអធិការមានអាកប្បកិរិយាសំដែងចេញភាពជាគំរូ និងជាអ្នកអប់រំ | 13 | 4.46 | ល្អ |
| ៣ | ក្រុមអធិការបានសម្តែងអាកប្បកិរិយាស្និទ្ធស្នាលជាមួយ គ្រូបង្រៀនដោយគ្មានការរើសអើង | 13 | 4.46 | ល្អ |
| ៤ | គ្រូបង្រៀនយល់ថា ការចុះអធិការកិច្ចបានផ្តល់អត្ថប្រយោជន៍ដល់ការបង្រៀន និងរៀន គឺជួយជំរុញឱ្យការបង្រៀននិងរៀនឱ្យកាន់តែមានប្រសិទ្ធភាព | 13 | 4.62 | ល្អណាស់ |
| ៥ | គ្រូបង្រៀន យល់ថាអធិការមានចំណេះដឹង និងបទពិសោធន៍គ្រប់គ្រាន់លើការបង្រៀន និងរៀន | 13 | 4.38 | ល្អ |
| សរុប | | | 4.45 | ល្អ |

***តារាង 16៖** ទំនាក់ទំនងរវាងគ្រូបង្រៀន និងក្រុមអធិការកិច្ច ទទួលបានតាមរយៈកម្រងសំណួរនាយក*

បើផ្អែកលើកម្រងសំណួរដែលគ្រូបង្រៀនបានសរសេររៀបរាប់ក្នុងសំណួរទី១៤ ″ ជារួមតើទំនាក់ទំនងរវាងគ្រូបង្រៀន និងក្រុមអធិការកិច្ចស្ថិតក្នុងកម្រិតណា?″ គ្រូបង្រៀន៥៣នាក់ក្នុងចំណោម ៩៤នាក់ ស្មើនឹង ៥៦.៤% បានយល់ថាអធិការកិច្ចមានទំនាក់ទំនងល្អជាមួយគ្រូបង្រៀនមុនពេលអធិការកិច្ច ព្រោះអធិការកិច្ចបានផ្តល់ប្រយោជន៍ និងបទពិសោធន៍ដល់ការបង្រៀន និងរៀន។ ជាក់ស្តែងគ្រូបង្រៀនទី៨, ៣១ និងទី៤០ បានលើកឡើងថា ″*អធិការមានបទពិសោធន៍ច្រើនគ្រប់គ្រាន់*″ និង ″*ការចុះមកជួប គឺដើម្បីផ្តល់បទពិសោធន៍*

*ល្អដល់លោកគ្រូ អ្នកគ្រូ"* (គ្រូបង្រៀនទី១៧) ហើយ *"គាត់ជួយពន្យល់ណែនាំបន្ថែមពីការបង្រៀន និងរៀនឱ្យកាន់តែល្អប្រសើរ"* (គ្រូបង្រៀនទី៥៣ និង៥៤)។ លើសពីនេះគ្រូបង្រៀនចំនួន ៣៦នាក់ ស្មើនឹង៣៨.៣% បង្ហាញថាអធិការមានទំនាក់ទំនងល្អជាមួយគ្រូបង្រៀន ព្រោះអធិការកិច្ចបានសហការល្អ គ្មានការរើសអើង មានភាពស្និទស្នាលជាមួយគ្រូ ជាក់ស្តែងគ្រូបង្រៀនទី៣៥បានលើកឡើងថា *"អធិការមានអាកប្បកិរិយាស្និទស្នាល មិនរើសអើង និងផ្តល់ចំណេះដឹងបទពិសោធលើផ្នែកបង្រៀន និងរៀន"* និង *"ក្រុមអធិការកិច្ចរួសរាយរាក់ទាក់ និងសហការជាមួយគ្រូ"* (គ្រូបង្រៀនទី៦៣, ៦៤,និង៦៥) ហើយ *"គាត់គ្មានការរើសអើង មានភាពស្និទ្ធស្នាល"* (គ្រូបង្រៀនទី១៣)។ ផ្ទុយទៅវិញមានតែគ្រូបង្រៀនចំនួន៥នាក់ទេ ដែលឆ្លើយថាកម្រិតទំនាក់ទំនងរវាងក្រុមអធិការកិច្ច និងគ្រូបង្រៀនមិនទាន់ល្អ ព្រោះអធិការកិច្ចចុះមកសាលារៀនម្តងម្កាល (គ្រូបង្រៀនទី២ និងទី១១) និងការធ្វើអធិការកិច្ចមានរយៈពេលខ្លី (គ្រូបង្រៀនទី៥៧ និង៥៩)។ ដូចគ្នាដែរ នាយក/នាយិកាទាំងអស់ បានលើកឡើងថា គ្រូបង្រៀនបានបង្ហាញទំនាក់ទំនងល្អជាមួយអធិការកិច្ច។

សរុបជារួមមក ការទំនាក់ទំនងរវាងគ្រូបង្រៀន និងក្រុមអធិការកិច្ច លោកគ្រូ/អ្នកគ្រូបានបង្ហាញឥរិយាបថវិជ្ជមានទៅលើការប្រាស្រ័យទាក់ទងគ្នារវាងគ្រូបង្រៀន និងក្រុមអធិការ។ ទោះបីជាពួកគាត់ទាំងនោះត្រូវបានចុះអធិការកិច្ច និងត្រូវបានគេពិនិត្យមើលលើការបង្រៀនក៏ដោយ ក៏គ្រូបង្រៀនបានយល់ថាក្រុមអធិការជាអ្នកអប់រំជាអ្នកមានចំណេះដឹង និងបទពិសោធន៍គ្រប់គ្រាន់ ជាពិសេសបានសម្តែងអាកប្បកិរិយាស្និទ្ធស្នាល មិនរើសអើងចំពោះគ្រូ។ ទាំងនេះស្របតាមការយល់ឃើញរបស់នាយក/នាយិកា ដែលបានបង្ហាញថាគ្រូបង្រៀនបង្ហាញពីទំនាក់ទំនងល្អចំពោះអធិការកិច្ច លើការបង្រៀន និងរៀន។

### B. ការផ្តល់ព័ត៌មានអំពីអធិការកិច្ចទៅដល់គ្រូបង្រៀន

មុនពេលអធិការកិច្ច ក្រុមអធិការត្រូវផ្តល់ដំណឹងទៅដល់នាយក/នាយិកា សាលា ដើម្បីបញ្ជូនដំណឹងបន្តទៅគ្រូបង្រៀន ដើម្បីត្រៀមលក្ខណៈសម្រាប់ការអធិការកិច្ចលើការបង្រៀន និងរៀន។

| ល.រ | បរិយាយ | ចំនួន | មធ្យម | លទ្ធផល |
|---|---|---|---|---|
| | B. ការផ្តល់ព័ត៌មាន | | | |
| ១ | គ្រូបង្រៀនបានដឹងព័ត៌មាន ពីការចុះអធិការកិច្ចថ្នាក់រៀន | 94 | 3.77 | ល្អ |
| ២ | គ្រូបង្រៀនចង់ដឹងពីព័ត៌មានអំពីការចុះអធិការកិច្ចថ្នាក់រៀន មុនពេលថ្ងៃចុះអធិការកិច្ច | 94 | 4.21 | ល្អ |
| ៣ | គ្រូបង្រៀនបានយល់ច្បាស់ពីគោលបំណងនៃការចុះអធិការកិច្ចលើការបង្រៀននិងរៀន | 94 | 3.90 | ល្អ |
| ៤ | គ្រូបង្រៀនបានដឹងពីកម្មវិធីនៃការចុះអធិការកិច្ចថ្នាក់រៀន | 94 | 3.40 | មធ្យម |
| ៥ | លោកគ្រូ/អ្នកគ្រូ ដឹងពីអ្វីដែលអធិការត្រូវពិនិត្យនៅអធិការកិច្ចថ្នាក់រៀន | 94 | 3.70 | ល្អ |
| សរុប | | | 3.80 | ល្អ |

***តារាង 17៖*** *ការផ្តល់ព័ត៌មានអំពីការចុះអធិការកិច្ច ទទួលបានតាមរយៈកម្រងសំណួរគ្រូបង្រៀន*

តាមរយៈលទ្ធផល ក្នុងតារាង17 បង្ហាញថា លោកគ្រូ/អ្នកគ្រូបានយល់ស្របចំពោះការផ្តល់ព័ត៌មានរបស់អធិការកិច្ច ក្នុងកម្រិត"ល្អ" លើមធ្យមភាគពិន្ទុ 3.80។ បើយើងមើលជួរដេកទី២ សូចនាករទី២ "គ្រូបង្រៀនចង់ដឹងពីព័ត៌មានអំពីការចុះអធិការកិច្ចថ្នាក់រៀនមុនពេលថ្ងៃចុះអធិការកិច្ច" បានទទួលការយល់ស្របពីលោកគ្រូ/អ្នកគ្រូខ្ពស់ជាងគេក្នុងកម្រិត "ល្អ" មានមធ្យមភាពពិន្ទុ 4.21។ ប៉ុន្តែលើសូចនាករទី៤ "គ្រូបង្រៀនបានដឹងពីកម្មវិធីនៃការចុះអធិការកិច្ចថ្នាក់រៀន "បានទទួលការយល់ស្របទាបជាងគេ ក្នុងកម្រិត "មធ្យម" ក្នុងកម្រិតពិន្ទុ 3.40 ព្រោះគ្រូបង្រៀនមួយចំនួនមិនបានទទួលបានព័ត៌មានគ្រប់គ្រាន់ទេ ដោយពេលចុះមកអធិការមិនបានផ្តល់ព័ត៌មានច្បាស់លាស់ និងខ្លះទៀតនិយាយថាចុះអធិការកិច្ចមិនបានផ្តល់ដំណឹងឱ្យដឹងមុន។

សម្រាប់នាយក/នាយិកា បានយល់ស្របពីការផ្តល់ព័ត៌មានអំពីអធិការកិច្ច លើការបង្រៀន និងរៀន

បានកម្រិត "ល្អ" ក្នុងមធ្យមភាពពិន្ទុ 4.23 ក្នុងតារាង18។ ជាមួយគ្នានេះដែរ ក្នុងសូចនាករទី១ "នាយក/នាយិកាបានផ្តល់ព័ត៌មានពីការចុះអធិការកិច្ចថ្នាក់រៀនទៅដល់គ្រូបង្រៀន" មានការយល់ស្របខ្ពស់ជាងគេកម្រិត "ល្អណាស់" មានមធ្យមភាគពិន្ទុ 4.54។ ចំណែកឯសូចនាករទី២ "គ្រូបង្រៀន ដឹងពីអ្វីដែលអធិការត្រូវពិនិត្យនៅពេលបង្រៀននៅក្នុងថ្នាក់" បានទទួលការយល់ស្របទាបជាងគេ កម្រិត "ល្អ" លើមធ្យមភាគពិន្ទុ 4.23។

| ល.រ | បរិយាយ | ចំនួន | មធ្យម | លទ្ធផល |
|---|---|---|---|---|
| | **B. ការផ្តល់ព័ត៌មាន** | | | |
| ១ | នាយក/នាយិកាបានផ្តល់ព័ត៌មានពីការចុះអធិការកិច្ចថ្នាក់រៀនទៅដល់គ្រូបង្រៀន | 13 | 4.54 | ល្អណាស់ |
| ២ | គ្រូបង្រៀនបានយល់ច្បាស់ពីគោលបំណងនៃការចុះអធិការកិច្ចលើការបង្រៀននិងរៀន | 13 | 4.15 | ល្អ |
| ៣ | គ្រូបង្រៀន ដឹងពីអ្វីដែលអធិការត្រូវពិនិត្យនៅពេលបង្រៀននៅក្នុងថ្នាក់ | 13 | 4.00 | ល្អ |
| សរុប | | | 4.23 | ល្អ |

***តារាង 18៖*** *ការផ្តល់ព័ត៌មានអំពីការចុះអធិការកិច្ច ទទួលបានតាមរយៈកម្រងសំណួរនាយក/នាយិកា*

បើយោងតាមការឆ្លើយរបស់សិស្សដែលបានចូលរួមបំពេញកម្រងសំណួរ បានឆ្លើយថា គ្រូបង្រៀនពួកគេបានដឹងដំណឹងជាមុន ថានឹងមានគេចុះអធិការកិច្ច ព្រោះលើសំណួរ "តើលោកគ្រូ/អ្នកគ្រូរបស់ប្អូនបានដឹងដំណឹងមុនថានឹងមានគេចុះអធិការកិច្ចសាលារៀនដែរឬទេ?" សិស្ស១៥១នាក់ ត្រូវនឹង៨៧%ឆ្លើយថា លោកគ្រូ/អ្នកគ្រូបានដឹងព័ត៌មានជាមុន ហើយមានតែសិស្ស១៥នាក់ ស្មើនឹង៩%ដែលឆ្លើយថាលោកគ្រូ/អ្នកគ្រូ មិនបានដឹងដំណឹងជាមុន ហើយសិស្ស៨នាក់ទៀត ស្មើនឹង ៥% មិនបានចាប់អារម្មណ៍លើបញ្ហានេះទេ។

បើផ្អែកលើសំណួរទី២០ "តើគ្រូបង្រៀន បានទទួលព័ត៌មានគ្រប់គ្រាន់ អំពីអធិការកិច្ចលើការបង្រៀន

និងរៀនរបស់ខ្លួនដែរឬទេ? ចូរបញ្ជាក់" គ្រូបង្រៀន៣៩នាក់ ស្មើនឹង៤១.៤៨% បានទទួលព័ត៌មានគ្រប់គ្រាន់ពីការចុះអធិការកិច្ចលើការបង្រៀនរបស់ខ្លួន ដោយគាត់ទទួលដំណឹងពីនាយក/នាយិកាខ្លះ និងទទួលបានពីក្រុមអធិការផ្ទាល់ខ្លះ។ ឧទាហរណ៍ គ្រូបង្រៀនបានទទួលព័ត៌មានគ្រប់គ្រាន់អំពីអធិការកិច្ចលើការបង្រៀន និងរៀន ព្រោះគាត់បានផ្តល់ដំណឹងជាមុន(គ្រូបង្រៀនទី៣៤, ៣៥ និងទី៤៨) ហើយគ្រូបានទទួលព័ត៌មានអំពីការចុះអធិការកិច្ចពីថ្នាក់ដឹកនាំសាលា(គ្រូបង្រៀនទី៨៣ និងទី៩១)។ រីឯគ្រូបង្រៀន៣៥នាក់ទៀត ស្មើនឹង៣៧.២២% មិនទទួលព័ត៌មានស្តីពីការចុះអធិការកិច្ចបានពេញលេញនៅឡើយទេដោយហេតុថា អធិការកិច្ចជួនកាលត្រូវចុះដោយពុំចាំបាច់ប្រាប់មុន(គ្រូបង្រៀនទី៣១) ហើយគ្រូបង្រៀនទី៥៧, ៥៨, និង៥៩ បានលើកឡើងថា គាត់ទទួលព័ត៌មានមិនបានគ្រប់គ្រាន់អំពីអធិការកិច្ចលើការបង្រៀន និងរៀនឡើយព្រោះជួនពេលកន្លងមកអធិការកិច្ចមិនបានប្រាប់មុន ហើយមិនដឹងថាគាត់ចូលថ្នាក់ណាឱ្យប្រាកដ (គ្រូបង្រៀនទី៨៥)។ ចំណែកចម្លើយរបស់គ្រូបង្រៀន២០នាក់ទៀត មិនពាក់ព័ន្ធនឹងសំណួរខាងលើនោះទេ។

ជារួម គ្រូបង្រៀនមានឥរិយាបថវិជ្ជមាន ចំពោះការផ្តល់ព័ត៌មានអំពីការចុះអធិការកិច្ចលើការបង្រៀន និងរៀន ដោយមានកម្រិតមធ្យមភាគពិន្ទុ 3.80 ។ ចំណុចនេះមានការយល់ស្របប្រហាក់ប្រហែលគ្នាដែរជាមួយនឹងនាយក/នាយិកាសាលា។ អ្វីដែលយើងសង្កេតឃើញក្នុងផ្នែកនេះផងដែរ គឺថានាយក/នាយិកាបានផ្តល់ព័ត៌មានពីការចុះអធិការកិច្ចថ្នាក់រៀនទៅដល់គ្រូបង្រៀន ហើយសិស្សក៏បានឆ្លើយថាគ្រូបង្រៀនរបស់ខ្លួនបានដឹងដំណឹងជាមុនថាមានការចុះអធិការកិច្ចដែរ ប៉ុន្តែលោកគ្រូ/អ្នកគ្រូមួយចំនួនបែរជាបានដឹងព័ត៌មានពីការចុះអធិការកិច្ចថ្នាក់រៀនក្នុងកម្រិតមួយទាបជាងឆ្ងាយ ពីការឆ្លើយរបស់នាយក/នាយិកាទៅវិញ។ លើសពីនេះលោកគ្រូ/អ្នកគ្រូបានដឹងពីកម្មវិធីនៃការចុះអធិការកិច្ចថ្នាក់រៀនរបស់ខ្លួនបានកម្រិតមធ្យម មានន័យថាទោះបីនាយក/នាយិកាបានផ្តល់ព័ត៌មានអំពីការធ្វើអធិការកិច្ចលើការបង្រៀន និងរៀនទៅដល់គ្រូក៏ពិតមែនតែខ្លឹមសារសំខាន់នៃការធ្វើអធិការកិច្ចលើការបង្រៀន គោលបំណងនៃការចុះធ្វើអធិការកិច្ច និងពេលវេលាជាក់ស្តែងនៃការធ្វើអធិការកិច្ចថ្នាក់រៀន គ្រូបង្រៀនមិនបានទទួលគ្រប់ជ្រុងជ្រោយនៅឡើយទេ។

### C. ការគោរពពេលវេលារបស់អធិការកិច្ច

នៅថ្ងៃចុះអធិការកិច្ច តើគ្រូបង្រៀនយល់ឃើញបែបណា ចំពោះការគោរពពេលវេលារបស់ក្រុមអធិការកិច្ច? ក្នុងផ្នែករងនេះ យើងនឹងបកស្រាយសំណួរខាងលើ ដោយផ្អែកលើទិន្នន័យដែលទទួលបានពីគ្រូបង្រៀន និងនាយក/នាយិកា។

| ល.រ | បរិយាយ | ចំនួន | មធ្យម | លទ្ធផល |
|---|---|---|---|---|
| | **C. ការគោរពពេលវេលា** | | | |
| ១ | ក្រុមអធិការកិច្ច បានគោរពពេលវេលាក្នុងការចុះអធិការកិច្ចបានត្រឹមត្រូវ | 94 | 4.49 | ល្អ |
| ២ | គ្រូបង្រៀនដឹងពីពេលវេលានៃការចុះអធិការកិច្ចថ្នាក់រៀន | 94 | 3.97 | ល្អ |
| ៣ | ក្រុមអធិការចុះសង្កេតថ្នាក់រៀនតាមកម្មវិធីអធិការកិច្ចដែលបានកំណត់ | 94 | 4.24 | ល្អ |
| សរុប | | | 4.23 | ល្អ |

***តារាង 19៖*** *ការគោរពពេលវេលារបស់ក្រុមអធិការកិច្ច ទទួលបានពីកម្រងសំណួរគ្រូបង្រៀន*

តាមតារាង19 បង្ហាញថាគ្រូបង្រៀនបានយល់ស្របខ្លាំងកម្រិត ″ល្អ″ ចំពោះការគោរពពេលវេលារបស់ក្រុមអធិការក្នុងការបំពេញការងារអធិការកិច្ចលើការបង្រៀន និងរៀន លើមធ្យមភាគពិន្ទុ 4.23 ។ ក្នុងផ្នែករងនេះ សូចនាករទី១ ‶ក្រុមអធិការកិច្ចបានគោរពពេលវេលាក្នុងការចុះអធិការកិច្ចបានត្រឹមត្រូវ″ មានការយល់ស្របខ្ពស់ជាងគេកម្រិត ″ល្អណាស់″ លើមធ្យមភាគពិន្ទុ 4.94។ ចំណែកឯសូចនាករទី២ ‶គ្រូបង្រៀនដឹងពីពេលវេលានៃការចុះអធិការកិច្ចថ្នាក់រៀន″ មានការយល់ស្របទាបជាងគេកម្រិត ‶ល្អ″ ក្នុងមធ្យមភាគពិន្ទុ 3.97។

ក្នុងចំណោមនាយក/នាយិកាទាំង១៣សាលា ដែលបានចូលរួមបំពេញកម្រងសំណួរស្រាវជ្រាវ ពួកគាត់ភាគច្រើនបានយល់ស្របដូចគ្នានឹងគ្រូបង្រៀនដែរចំពោះការគោរពពេលវេលារបស់ក្រុមអធិការកិច្ចកម្រិត

″ល្អណាស់″ ក្នុងមធ្យមភាគពិន្ទុ 4.54 ដូចបង្ហាញក្នុងតារាង 20។ ជាក់ស្តែងសូចនាករទី១ ″ក្រុមអធិការកិច្ច បានគោរពពេលវេលាក្នុងការចុះអធិការកិច្ចបានត្រឹមត្រូវ″ នាយក/នាយិកាបានយល់ស្របកម្រិត "ល្អណាស់″ លើមធ្យមភាគពិន្ទុ 4.62 និងសូចនាករទី២ "គ្រូបង្រៀនដឹងពីពេលវេលានៃការចុះអធិការកិច្ចថ្នាក់រៀន″ មានការយល់ស្របទាបជាងគេ កម្រិត "ល្អ″ មានមធ្យមភាគពិន្ទុ 4.23។

| ល.រ | បរិយាយ | ចំនួន | មធ្យម | លទ្ធផល |
|---|---|---|---|---|
| | **C. ការគោរពពេលវេលា** | | | |
| ១ | ក្រុមអធិការកិច្ច បានគោរពពេលវេលាក្នុងការចុះអធិការកិច្ចបានត្រឹមត្រូវ | 13 | 4.62 | ល្អណាស់ |
| ២ | គ្រូបង្រៀនដឹងពីពេលវេលានៃការចុះអធិការកិច្ចថ្នាក់រៀន | 13 | 4.23 | ល្អ |
| ៣ | ក្រុមអធិការចុះសង្កេតថ្នាក់រៀនតាមកម្មវិធីអធិការកិច្ចដែលបានកំណត់ | 13 | 4.77 | ល្អ |
| សរុប | | | 4.54 | ល្អណាស់ |

***តារាង 20៖** ការគោរពពេលវេលារបស់ក្រុមអធិការកិច្ច តាមរយៈកម្រងសំណួរនាយក/នាយិកា*

ជារួមឆ្លងតាមការបកស្រាយលទ្ធផលខាងលើ យើងអាចនិយាយបានថា គ្រូបង្រៀនភាគច្រើនមានឥរិយាបថវិជ្ជមានចំពោះការគោរពពេលវេលារបស់ក្រុមអធិការកិច្ច ព្រោះគ្រូបង្រៀនភាគច្រើនបានឯកភាពថា ក្រុមអធិការកិច្ចបានគោរពពេលវេលាបានល្អ នៅថ្ងៃអធិការកិច្ច។ ទាំងនាយក/នាយិកា ព្រមទាំងគ្រូបង្រៀនភាគច្រើនទទួលស្គាល់ថា ក្រុមអធិការបានចុះសង្កេតថ្នាក់រៀនតាមកម្មវិធីដែលបានកំណត់។

### D. ការត្រៀមលក្ខណៈរបស់គ្រូបង្រៀន

មុនពេលបង្រៀន ក៏ដូចជាមុនពេលការចុះអធិការកិច្ចថ្នាក់រៀន គ្រូបង្រៀនតែងតែត្រៀមលក្ខណៈមួយចំនួនសម្រាប់ការបង្រៀនប្រចាំថ្ងៃ ក៏ដូចសម្រាប់ការចុះអធិការកិច្ចផងដែរ។ តាមតារាង21 គ្រូបង្រៀនបាន

យល់ស្របកម្រិត "ល្អ" ក្នុងមធ្យមភាគពិន្ទុ 3.89 ចំពោះការត្រៀមលក្ខណៈមួយចំនួននៅពេលមានការចុះអធិការកិច្ច។ គ្រូបង្រៀនភាគច្រើនបានយល់ស្របខ្ពស់ជាងគេលើសូចនាករទី៤ "គ្រូបង្រៀនចង់ឱ្យអធិការពិនិត្យមើលលើការបង្រៀនរបស់ខ្លួន" កម្រិត "ល្អ" មានមធ្យមភាពពិន្ទុ 4.13 និងសូចនាករទី៣ "គ្រូបង្រៀនបានត្រៀមលក្ខណៈបានល្អ នៅថ្ងៃធ្វើអធិការកិច្ច" កម្រិត "ល្អ" ក្នុងមធ្យមភាពពិន្ទុ 4.12 ដោយបានសម្អាតបរិស្ថានថ្នាក់រៀន រៀបចំបន្ទប់រៀន គោរពពេលវេលាបង្រៀន រៀបចំក្រុមសិស្ស រៀបចំរដ្ឋបាល កិច្ចតែងការសម្ភារបង្រៀន ដើម្បីឱ្យការបង្រៀន និងរៀនមានលក្ខណៈរស់រវើក។ ចំណែកឯ សូចនាករទី២ "គ្រូបង្រៀនមិនមានការព្រួយបារម្ភ ខ្វល់ខ្វាយនៅពេលមានការចុះអធិការកិច្ចថ្នាក់រៀនទេ" បានទទួលការយល់ស្របទាបជាងគេកម្រិត "មធ្យម" ក្នុងមធ្យមភាពពិន្ទុ 3.50 ។

| **ល.រ** | **បរិយាយ** | **ចំនួន** | **មធ្យម** | **លទ្ធផល** |
|---|---|---|---|---|
| | **D. ការត្រៀមលក្ខណៈ** | | | |
| ១ | គ្រូបង្រៀនតែងមានអារម្មណ៍ធម្មតាចំពោះការចុះធ្វើអធិការកិច្ច | 94 | 3.80 | ល្អ |
| ២ | គ្រូបង្រៀនមិនមានការព្រួយបារម្ភ ខ្វល់ខ្វាយនៅពេលមានការចុះអធិការកិច្ចថ្នាក់រៀនទេ | 94 | 3.50 | មធ្យម |
| ៣ | គ្រូបង្រៀន បានត្រៀមលក្ខណៈបានល្អ នៅថ្ងៃធ្វើអធិការកិច្ច | 94 | 4.12 | ល្អ |
| ៤ | គ្រូបង្រៀន ចង់ឱ្យអធិការ ពិនិត្យមើលលើការបង្រៀន របស់ខ្លួន | 94 | 4.13 | ល្អ |
| សរុប | | | 3.89 | ល្អ |

***តារាង 21៖*** *ការត្រៀមលក្ខណៈរបស់គ្រូចំពោះអធិការកិច្ច ទទួលបានតាមរយៈកម្រងសំណួរគ្រូបង្រៀន*

តាមរយៈសំណួរទី២៨ក្នុងសម្រងសំណួរសម្រាប់គ្រូបង្រៀន "មុនពេលការធ្វើអធិការកិច្ច តើអ្នកគ្រូលោកគ្រូបានត្រៀមលក្ខណៈអ្វីខ្លះ? ឬមិនបានត្រៀម? ហេតុអ្វី?" បានបង្ហាញថាគ្រូបង្រៀនលើសលប់គឺ ៩២នាក់ត្រូវនឹង ៩៧.៩% បានឆ្លើយថាបានត្រៀមលក្ខណៈសម្រាប់ការចុះអធិការកិច្ច ប្រសិនបើពួកគាត់បាន

ដឹងដំណឹងពីការចុះអធិការកិច្ចលើការបង្រៀនរបស់គាត់។ ការត្រៀមលក្ខណៈរបស់គាត់មានការរៀបចំលើបរិស្ថានថ្នាក់រៀនមានដូចជាអនាម័យថ្នាក់រៀន វិន័យសិស្ស ការតុបតែងថ្នាក់ ការស្លៀកពាក់ និងការរៀបចំរដ្ឋបាលគ្រូបង្រៀនដូចជា សម្ភារៈបង្រៀន កិច្ចតែងការ សៀវភៅសិក្សាគោលជាដើម។ ការត្រៀមលក្ខណៈនេះដើម្បីឱ្យការបង្រៀន និងរៀនមានភាពងាយស្រួល និងដំណើរការល្អ ហើយវាជាកិច្ចការដែលគ្រូបង្រៀនត្រូវធ្វើមុនពេលបង្រៀនផងដែរ លើសពីនេះគ្រូបង្រៀនចង់បានការវាយតម្លៃល្អពីការចុះអធិការកិច្ច។ ជាក់ស្តែងគ្រូបង្រៀនទី៤១, ៤២, ៤៣, និងទី៩៣ បានត្រៀមសម្ភារបង្រៀន និងកិច្ចតែងការបង្រៀនបានគ្រប់គ្រាន់ មានសៀវភៅហៅឈ្មោះសិស្ស សៀវភៅដាក់ពិន្ទុ ព្រោះជាភារកិច្ចរបស់គ្រូ និងដើម្បីឱ្យការបង្រៀនទទួលបានលទ្ធផលល្អ (គ្រូបង្រៀនទី១៥, ១៩, ២៩ និងទី៣៤) ទទួលបានការវាយតម្លៃល្អ និងចៀសវាងរាល់កំហុស (គ្រូបង្រៀនទី២៤ និង៨៩)។ ទោះជាបីបែបនេះក្តី គ្រូបង្រៀនមួយចំនួនមានការពិបាកខ្លះដែរក្នុងការត្រៀមលក្ខណៈ ជាក់ស្តែងក្នុងសំណួរទី៧៨ "តើលោកគ្រូ/អ្នកគ្រូមានការលំបាកអ្វីខ្លះ ពេលអធិការកិច្ចថ្នាក់រៀន?" ក្នុងចំណោមគ្រូបង្រៀន ៩៤នាក់ មានគ្រូបង្រៀនចំនួន ៤១នាក់ ស្មើនឹង ៤៣.៦១% បានលើកឡើងថា គាត់មានការលំបាកក្នុងការត្រៀមលក្ខណៈសម្រាប់ការចុះអធិការកិច្ច ដោយត្រូវត្រៀមការងាររដ្ឋបាលរបស់គ្រូរៀបចំថ្នាក់រៀន ត្រៀមសម្ភារបង្រៀន កិច្ចតែងការបង្រៀន ហើយត្រៀមរៀបចំខ្លួនជាដើម។ លើសពីនេះមានគ្រូបង្រៀន ៣១នាក់ស្មើនឹង ៣២.៩៨% បានឆ្លើយថាខ្លួនមានអារម្មណ៍ភ័យព្រួយបារម្ភខ្លាចបង្រៀនខុស និងបង្រៀនមិនបានល្អនៅថ្ងៃចុះអធិការកិច្ច ព្រោះសារគាត់មានការលំបាកគ្រប់គ្រងសិស្ស (សិស្សច្រើន និងសិស្សមានអារម្មណ៍ភ័យខ្លាច) ខ្វះខាតសម្ភារបង្រៀន និងដោយសារចំណេះដឹងសិស្សនៅមានមានកម្រិត។

សម្រាប់នាយក/នាយិកា បានយល់ស្របដូចគ្នាដែលថា គ្រូបង្រៀនបានត្រៀមលក្ខណៈល្អ មុនពេលថ្ងៃចុះអធិការកិច្ចថ្នាក់រៀន ដោយមានការយល់ស្រប កម្រិត "ល្អណាស់" ក្នុងមធ្យមភាពពិន្ទុ 4.54។ ប៉ុន្តែពួកគាត់ក៏យល់ថា គ្រូបង្រៀននៅមានការព្រួយបារម្ភខ្លះដែរចំពោះការងារអធិការកិច្ច ជាក់ស្តែង ក្នុងតារាង 22

សូចនាករទី២ " គ្រូបង្រៀនមិនមានការព្រួយបារម្ភ ឬខ្វល់ខ្វាយ នៅពេលមានការចុះអធិការកិច្ចថ្នាក់រៀនទេ" បានទទួលការយល់ស្របទាបជាងគេកម្រិត "ល្អ" ក្នុងមធ្យមភាគពិន្ទុ 3.85។

| ល.រ | បរិយាយ | ចំនួន | មធ្យម | លទ្ធផល |
|---|---|---|---|---|
| | **D. ការត្រៀមលក្ខណៈ** | | | |
| ១ | គ្រូបង្រៀនតែងមានអារម្មណ៍ធម្មតាចំពោះការចុះធ្វើអធិការកិច្ច | 13 | 3.92 | ល្អ |
| ២ | គ្រូបង្រៀនមិនមានការព្រួយបារម្ភ ឬខ្វល់ខ្វាយ នៅពេលមានការចុះអធិការកិច្ចថ្នាក់រៀនទេ | 13 | 3.85 | ល្អ |
| ៣ | គ្រូបង្រៀន បានត្រៀមលក្ខណៈបានល្អ នៅថ្ងៃធ្វើអធិការកិច្ច | 13 | 4.23 | ល្អ |
| ៤ | គ្រូបង្រៀន ចង់ឱ្យអធិការ ពិនិត្យមើលលើការបង្រៀន របស់គាត់ | 13 | 4.54 | ល្អណាស់ |
| សរុប | | | 4.13 | ល្អ |

***តារាង 22៖*** *ការត្រៀមលក្ខណៈរបស់គ្រូចំពោះអធិការកិច្ច ទទួលតាមរយៈកម្រងសំណួរនាយក/នាយិកា*

ក្នុងផ្នែកនេះដែរ សិស្សដែលបានចូលរួមបំពេញកម្រងសំណួរ មានចំនួន១៧៤នាក់ ក្នុងនោះមាន ១៥០នាក់ ស្មើនឹង ៨៧% បានឆ្លើយថា លោកគ្រូ/អ្នកគ្រូ បានដឹងដំណឹងជាមុនថានឹងមានគេចុះអធិការកិច្ចសាលារៀន។ ក្នុងនោះដែរសិស្សចំនួន១៦៩នាក់ ស្មើនឹង៩៧% បានឆ្លើយថាពួកគេធ្លាប់ទទួលបានការណែនាំពីលោកគ្រូ/អ្នកគ្រូពួកគេពីអ្វីដែលត្រូវធ្វើមុនពេលមានការចុះអធិការកិច្ចថ្នាក់រៀន។ លើសពីនេះមានសិស្ស ១៦៧នាក់ ស្មើនឹង៩៦% ទទួលស្គាល់ថាពួកគេធ្លាប់ត្រូវបានលោកគ្រូ/អ្នកគ្រូ ណែនាំពីអ្វីដែលត្រូវធ្វើក្នុងពេលគេចុះអធិការកិច្ចថ្នាក់រៀនផងដែរ។

ជារួមឆ្លងតាមការបកស្រាយខាងលើ យើងអាចសន្និដ្ឋានបានថាគ្រូបង្រៀនមានឥរិយាបថវិជ្ជមានចំពោះការងារអធិការកិច្ចលើការបង្រៀននិងរៀន ដោយគាត់បានត្រៀមលក្ខណៈបានល្អសម្រាប់ការងារអធិការកិច្ចកម្រិត "ល្អ" លើមធ្យមភាគពិន្ទុ 3.89។ ត្រង់ចំណុចនេះដែរ នាយក/នាយិកាយល់ថាគ្រូបង្រៀនចង់

ឱ្យអធិការពិនិត្យមើលលើការបង្រៀនរបស់គាត់ លើមធ្យមភាពពិន្ទុ 4.54 ប៉ុន្តែគ្រូបង្រៀនផ្ទាល់បានយល់ស្រប កម្រិតទាបជាងនេះ ព្រោះគ្រូបង្រៀនជិតពាក់កណ្ដាលនៃគ្រូបង្រៀនដែលបានបំពេញកម្រងសំណួរ មានការព្រួយបារម្ភ និងខ្វល់ខ្វាយនៅពេលមានការចុះអធិការកិច្ចថ្នាក់រៀន។ ត្រង់ចំណុចនេះបង្ហាញថា ទោះបីគ្រូបង្រៀនភាគច្រើនបានត្រៀមលក្ខណៈគ្រប់គ្រាន់សម្រាប់ការចុះអធិការកិច្ចក៏ដោយ ក៏លោកគ្រូ/អ្នកគ្រូមួយចំនួនមានការព្រួយបារម្ភ ឬខ្វល់ខ្វាយខ្លះដែរ នៅពេលមានការចុះអធិការកិច្ច ដោយគាត់ខ្លាចបង្រៀនមិនបានល្អ បង្កកំហុសនៃពេលបង្រៀន ហើយត្រូវបានវាយតម្លៃមិនល្អនៅថ្ងៃចុះអធិការកិច្ច។

| ល.រ | ផ្នែកទី១៖ ឥរិយាបថរបស់គ្រូបង្រៀន មុនពេលអធិការកិច្ចលើការបង្រៀន និងរៀន | មធ្យមភាគ | | |
|---|---|---|---|---|
| | | គ្រូបង្រៀន | នាយក/នាយិកា | សរុប |
| A | ទំនាក់ទំនងរវាងគ្រូបង្រៀន និងក្រុមអធិការកិច្ច | 4.35 | 4.45 | 4.40 |
| B | ការទទួលព័ត៌មានអំពីការចុះអធិការកិច្ចថ្នាក់រៀន | 3.80 | 4.23 | 4.02 |
| C | ការគោរពពេលវេលារបស់ក្រុមអធិការកិច្ច | 4.23 | 4.54 | 4.39 |
| D | ការត្រៀមលក្ខណៈរបស់គ្រូបង្រៀន | 3.89 | 4.13 | 4.01 |
| សរុប | | 4.07 | 4.34 | 4.21 |

***តារាង 23៖** ឥរិយាបថគ្រូបង្រៀនចំពោះអធិការកិច្ច មុនពេលអធិការកិច្ចលើការបង្រៀន និងរៀន*

សរុបរួម ក្នុងផ្នែកទី១នេះមុនពេលអធិការកិច្ចលើការបង្រៀន និងរៀន លោកគ្រូ/អ្នកគ្រូមានឥរិយាបថវិជ្ជមាន ចំពោះអធិការកិច្ច ទាំងទំនាក់ទំនង ការទទួលព័ត៌មាន ការគោរពពេលវេលា និងការត្រៀមលក្ខណៈសម្រាប់អធិការកិច្ច។ តាមរយៈតារាង 23 បង្ហាញថាមុនពេលអធិការកិច្ចលើការបង្រៀន និងរៀន គ្រូបង្រៀន និងនាយក/នាយិកា បានយល់ថា អធិការកិច្ចជាការងារមានប្រយោជន៍សម្រាប់ការបង្រៀន និងរៀន ដោយទទួលបានការយល់ស្របកម្រិត "ល្អ" លើមធ្យមភាគពិន្ទុ 4.21។ ក្នុងចំណោមផ្នែកទាំងអស់ ផ្នែករងA គ្រូបង្រៀន និងនាយក/នាយិកាបានបង្ហាញទំនាក់ទំនងល្អជាមួយក្រុមអធិការ ដោយទទួលបានការយល់ស្រប

ខ្ពស់ជាងគេ កម្រិត"ល្អ" ក្នុងមធ្យមភាពពិន្ទុ 4.40 ព្រោះគ្រូបង្រៀនភាគច្រើនបានយល់ថាក្រុមអធិការជាអ្នកអប់រំ មានចំណេះដឹង បទពិសោធបង្រៀនគ្រប់គ្រាន់ និងបានសម្តែងអាកប្បកិរិយាស្និទ្ធស្នាល មិនរើសអើងជាមួយគ្រូបង្រៀន។ ផ្នែករងB "ការគោរពពេលវេលារបស់ក្រុមអធិការ ក្នុងការចុះអធិការកិច្ចលើការបង្រៀនរបស់គ្រូ" ទទួលបានការយល់ស្របកម្រិត "ល្អ" លើមធ្យមភាគពិន្ទុ 4.23។ ផ្នែកនេះ គ្រូបង្រៀនភាគច្រើនបានឯកភាពថា ក្រុមអធិការកិច្ចបានគោរពពេលវេលាបានល្អនៅថ្ងៃអធិការកិច្ច ហើយទាំងនាយក/នាយិកា ព្រមទាំងគ្រូបង្រៀនភាគច្រើនទទួលស្គាល់ថាក្រុមអធិការបានចុះសង្កេតថ្នាក់រៀនតាមកម្មវិធីដែលបានកំណត់។ ចំពោះការត្រៀមលក្ខណៈរបស់គ្រូបង្រៀនសម្រាប់ការចុះអធិការកិច្ចវិញ ស្ថិតក្នុងលំដាប់ទី៣លើមធ្យមភាពពិន្ទុ 4.01 កម្រិតយល់ស្រប "ល្អ" ព្រោះមុនពេលអធិការកិច្ចគ្រូបង្រៀនភាគច្រើនបានត្រៀមលក្ខណៈមួយចំនួនដូចជា រៀបចំអនាម័យថ្នាក់រៀន រដ្ឋបាលគ្រូបង្រៀន កិច្ចតែងការបង្រៀន និងសម្ភារឧបទេស សម្រាប់ការបង្រៀនប្រចាំថ្ងៃ ជាពិសេសគ្រូបង្រៀនមិនបានបដិសេធចំពោះអធិការកិច្ចក្នុងការពិនិត្យមើលការបង្រៀនរបស់គាត់ ទោះបីជាគ្រូបង្រៀនទាំងនោះមានការព្រួយបារម្ភ និងខ្វល់ខ្វាយខ្លះៗក្តី។ នេះមានន័យថាអារម្មណ៍ភ័យព្រួយ បារម្ភតែងតែកើតមានចំពោះគ្រូបង្រៀនភាគច្រើនមុនពេលត្រូវបានចុះអធិការកិច្ចលើការបង្រៀនទោះបីជាគាត់បានត្រៀមលក្ខណៈបានច្រើនយ៉ាងណាក្តី។ ចំណែកឯការទទួលព័ត៌មានអំពីការចុះអធិការកិច្ចលើការបង្រៀននិងរៀន នាយក/នាយិកា និងគ្រូបង្រៀនយល់ស្របកម្រិត"ល្អ" លើមធ្យមភាគពិន្ទុ 4.02 ដែលថាគ្រូបង្រៀនបានទទួលព័ត៌មានគ្រប់គ្រាន់អំពីការចុះអធិការកិច្ច។ លទ្ធផលបានបង្ហាញថានាយក/នាយិកាបានផ្តល់ព័ត៌មានអំពីអធិការកិច្ចទៅដល់គ្រូបង្រៀន ហើយគ្រូបង្រៀនខ្លួនឯងភាគច្រើនបានដឹងថានឹងមានការចុះអធិការកិច្ចសាលារៀនរបស់ខ្លួន ប៉ុន្តែមានគ្រូបង្រៀនមួយចំនួនមិនទាន់យល់ច្បាស់ពីគោលបំណងនៃការចុះអធិការកិច្ចនៅឡើយ ហើយមួយចំនួនទៀតមិនបានទទួលបានព័ត៌មានទេ ព្រោះពេលចុះមកអធិការមិនបានផ្តល់ព័ត៌មានឱ្យបានច្បាស់លាស់ និងគ្រូបង្រៀនខ្លះទៀតលើកឡើងថាការចុះអធិការកិច្ចមិនបានផ្តល់ដំណឹងឱ្យដឹងជាមុនឡើយ។

### ៤.១.១.២ ឥរិយាបថគ្រូបង្រៀន អំឡុងពេលអធិការកិច្ចលើការបង្រៀន និងរៀន

នៅពេលដែលក្រុមអធិការបានមកដល់សាលារៀន ក្រុមអធិការបានបែងចែកគ្នាទៅសង្កេតការបង្រៀនតាមថ្នាក់រៀនផ្សេងគ្នា និងតាមការជ្រើសរើសរៀងៗខ្លួន។ សកម្មភាពអធិការកិច្ចលើការបង្រៀន និងរៀន មានការសង្កេតថ្នាក់រៀន ការសង្កេតការបង្រៀន និងការសម្ភាសគ្រូបង្រៀនជាដើម។ ក្នុងផ្នែកនេះ យើងនឹងធ្វើការបកស្រាយពីឥរិយាបថគ្រូបង្រៀន ចំពោះអធិការកិច្ច ក្នុងពេលសង្កេតថ្នាក់ ពេលគ្រូកំពុងបង្រៀន និងពេលសម្ភាស។

#### A. ពេលសង្កេតថ្នាក់

តាមរយៈតារាង 24 បានបង្ហាញថា លោកគ្រូ/អ្នកគ្រូបានយល់ស្របច្រើន លើសកម្មភាពអធិការកិច្ចក្នុងពេលសង្កេតថ្នាក់ ក្នុងកម្រិត "ល្អ" លើមធ្យមភាគពិន្ទុ 4.29។ ក្នុងផ្នែករងនេះ មាន៧សូចនាករ បើយើងពិនិត្យមើលលើសូចនាករទី៦ "ក្រុមអធិការមិនប្រើភាសាគំរោះគំរើយ ឬចំអក និងមិនឡូឡានៅក្នុងថ្នាក់រៀន ឬបង្ហាញទឹកមុខដែលធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍សិស្ស និងគ្រូបង្រៀនឡើយ" ឃើញថាសូចនាករនេះទទួលបានការយល់ស្របខ្ពស់បំផុតពីលោកគ្រូ/អ្នកគ្រូ កម្រិត "ល្អណាស់" ក្នុងមធ្យមភាគពិន្ទុ 4.60 ។ បន្ទាប់មកទៀតគឺសូចនាករទី២ "អធិការបានយកចិត្តទុកដាក់គ្រប់សកម្មភាពទាំងអស់នៅក្នុងថ្នាក់រៀន ពេលលោកគ្រូ/អ្នកគ្រូបង្រៀន" ទទួលបានការយល់ស្រប កម្រិត "ល្អណាស់"ដូចគ្នា ក្នុងមធ្យមភាគពិន្ទុ 4.51។ ផ្ទុយទៅវិញ សូចនាករដែលទទួលបានការយល់ស្របទាបជាងគេក្នុងផ្នែករងនេះគឺ សូចនាករទី៤ "អធិការកិច្ចពិនិត្យមើលចំណុចល្អច្រើនជាងចំណុចដែលត្រូវកែលម្អលើការបង្រៀន និងរៀន" មានការយល់ស្របកម្រិត "ល្អ" មានមធ្យមភាគពិន្ទុ 3.81។

| ល.រ | បរិយាយ | ចំនួន | មធ្យម | លទ្ធផល | លំដាប់ |
|---|---|---|---|---|---|
| | A. ពេលសង្កេតថ្នាក់ | | | | |
| ១ | អធិការបានផ្តោតខ្លាំងទៅលើបរិបទ ឬស្ថានភាពរបស់ថ្នាក់ | 94 | 4.11 | ល្អ | 6 |

| | | | | | |
|---|---|---|---|---|---|
| | រៀននីមួយៗ | | | | |
| ២ | អធិការបានយកចិត្តទុកដាក់គ្រប់សកម្មភាពទាំងអស់នៅក្នុងថ្នាក់រៀន ពេលលោកគ្រូ/អ្នកគ្រូបង្រៀន | 94 | 4.51 | ល្អណាស់ | 2 |
| ៣ | អធិការប្រើប្រាស់ឧបករណ៍គ្រប់គ្រាន់ និងមានប្រសិទ្ធភាពក្នុងពេលធ្វើអធិការកិច្ចលើការបង្រៀនរបស់គ្រូ | 94 | 4.14 | ល្អ | 5 |
| ៤ | អធិការកិច្ចពិនិត្យមើលចំណុចល្អ ច្រើនជាងចំណុចដែលត្រូវកែលម្អលើ ការបង្រៀន និងរៀន | 94 | 3.81 | ល្អ | 7 |
| ៥ | ក្រុមអធិការមិនបានរំខានដល់ការបង្រៀនរបស់គ្រូបង្រៀនឡើយ | 94 | 4.47 | ល្អ | 3 |
| ៦ | ក្រុមអធិការមិនប្រើភាសាគំរោះគំរើយ ឬចំអក និងមិនឡូឡានៅក្នុងថ្នាក់រៀន ឬបង្ហាញទឹកមុខដែលធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍សិស្ស និងគ្រូបង្រៀនឡើយ | 94 | 4.60 | ល្អណាស់ | 1 |
| ៧ | ការចុះធ្វើអធិការកិច្ច មិនបង្កបរិយាកាសស្មុគស្មាញដល់គ្រូក្នុងការបង្រៀន និងរៀនឡើយ | 94 | 4.37 | ល្អ | 4 |
| សរុប | | | 4.29 | ល្អ | |

***តារាង 24៖** ឥរិយាបថគ្រូបង្រៀនចំពោះការចុះសង្កេតថ្នាក់រៀនរបស់ក្រុមអធិការ ទទួលបានកម្រងសំណួរគ្រូបង្រៀន*

បើយើងពិនិត្យមើលការយល់ឃើញរបស់នាយក/នាយិកាសាលា ទៅលើឥរិយាបថគ្រូបង្រៀនពេលអធិការសង្កេតថ្នាក់រៀនឃើញថាលោកគ្រូ/អ្នកគ្រូបានយល់ស្របទៅលើវិធីសាស្ត្រ និងសកម្មភាពរបស់អធិការកិច្ចក្នុងថ្នាក់រៀន ដោយមិនមានការអាក់អន់ចិត្តទៅនឹងការចុះអធិការកិច្ចថ្នាក់រៀនឡើយ។ ជាក់ស្តែងតាមតារាង25 ឃើញថាមធ្យមភាគភាគពិន្ទុសរុបរួមគឺ4.46 មានន័យថាឥរិយាបថគ្រូបង្រៀនមានភាពវិជ្ជមាន

ចំពោះការសង្កេតថ្នាក់រៀនរបស់ក្រុមអធិការ។ ក្នុងនោះផងដែរ នាយក/នាយិកាបានយល់ស្របខ្លាំងបំផុតទៅលើសូចនាករទី៥ "ក្រុមអធិការ មិនប្រើភាសាគំរោះគំរើយ ឬចំអក និងមិនឡូឡានៅក្នុងថ្នាក់រៀន ឬបង្ហាញទឹកមុខដែលធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍សិស្ស និងគ្រូបង្រៀនឡើយ" មានកម្រិតយល់ស្រប "ល្អណាស់" លើមធ្យមភាគពិន្ទុ 4.85 ហើយចំណុចដែលទទួលការយល់ស្របទាបជាងគេ គឺសូចនាករទី៣ "អធិការកិច្ចពិនិត្យមើលចំណុចល្អ ច្រើនជាងចំណុចដែលត្រូវកែលម្អលើ ការបង្រៀន និងរៀន" មានកម្រិតយល់ស្រប "ល្អ" និងមធ្យមភាពពិន្ទុ 3.77 ស្រដៀងនឹងការយល់ឃើញរបស់គ្រូបង្រៀនដែរ។

| ល.រ | បរិយាយ | ចំនួន | មធ្យម | លទ្ធផល | លំដាប់ |
|---|---|---|---|---|---|
| | A. ពេលសង្កេតថ្នាក់ | | | | |
| ១ | អធិការកិច្ច បានធ្វើការសង្កេតថ្នាក់រៀនភាគច្រើនក្នុងសាលា | 13 | 4.15 | ល្អ | 5 |
| ២ | អធិការបានយកចិត្តទុកដាក់គ្រប់សកម្មភាពទាំងអស់នៅក្នុងថ្នាក់រៀន ពេលលោកគ្រូ/អ្នកគ្រូបង្រៀន | 13 | 4.62 | ល្អណាស់ | 4 |
| ៣ | អធិការកិច្ចពិនិត្យមើលចំណុចល្អ ច្រើនជាងចំណុចដែលត្រូវកែលម្អលើ ការបង្រៀន និងរៀន | 13 | 3.77 | ល្អ | 6 |
| ៤ | ក្រុមអធិការមិនបានរំខានដល់ការបង្រៀនរបស់គ្រូបង្រៀនឡើយ | 13 | 4.62 | ល្អណាស់ | 3 |
| ៥ | ក្រុមអធិការ មិនប្រើភាសាគំរោះគំរើយ ឬចំអក និងមិនឡូឡានៅក្នុងថ្នាក់រៀន ឬបង្ហាញទឹកមុខដែលធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍សិស្ស និងគ្រូបង្រៀនឡើយ | 13 | 4.85 | ល្អណាស់ | 1 |
| ៦ | ការចុះធ្វើអធិការកិច្ច មិនបង្កបរិយាកាសស្មុគស្មាញដល់គ្រូ | 13 | 4.77 | ល្អណាស់ | 2 |

| | | | | | |
|---|---|---|---|---|---|
| | ក្នុងការបង្រៀន និងរៀនឡើយ | | | | |
| សរុប | | | 4.46 | ល្អ | |

*តារាង 25៖ ឥរិយាបថគ្រូបង្រៀនចំពោះការចុះសង្កេតថ្នាក់រៀនរបស់អធិការ ទទួលបានកម្រងសំណួរនាយក/នាយិកា*

ជារួមក្នុងផ្នែករង "ការសង្កេតថ្នាក់របស់អធិការកិច្ច" បានបង្ហាញថាលោកគ្រូ/អ្នកគ្រូ មានឥរិយាបថវិជ្ជមាន ចំពោះក្រុមអធិការកិច្ច ក្នុងពេលសង្កេតថ្នាក់រៀន។ នាយក/នាយិកា និងគ្រូភាគច្រើនបានយល់ស្របថា ក្រុមអធិការមិនបានធ្វើសកម្មភាពណាមួយដែលប៉ះពាល់ដល់អារម្មណ៍សិស្ស និងគ្រូបង្រៀនពេលអធិការមានវត្តមានក្នុងថ្នាក់រៀនឡើយ។ លើសពីនេះ គ្រូបង្រៀនបានឯកភាពកម្រិតល្អណាស់ទៅលើភាពហ្មត់ចត់របស់អធិការ ដោយបានពិនិត្យ និងយកចិត្តទុកដាក់គ្រប់សកម្មភាពទាំងអស់នៅក្នុងថ្នាក់រៀន។ ប៉ុន្តែមានគ្រូបង្រៀន និងនាយក/នាយកាមួយចំនួនប៉ុណ្ណោះ បានយល់ថាអធិការកិច្ចបានពិនិត្យមើលចំណុចល្អ ច្រើនជាងចំណុចដែលត្រូវកែលម្អលើការបង្រៀន និងរៀន។ មានន័យថា ទោះបីជាគ្រូបង្រៀន យល់ថាការសង្កេតថ្នាក់របស់អធិការកិច្ចមិនបានបង្កការលំបាកដល់ខ្លួនយ៉ាងណាក្តី តែក្នុងអារម្មណ៍របស់គាត់យល់ថាការធ្វើអធិការថ្នាក់រៀន គឺដើម្បីស្វែងរកចំណុចមិនល្អរបស់គ្រូបង្រៀន។

ផ្នែកបន្តទៀត គឺសកម្មភាពរបស់គ្រូបង្រៀននៅពេលមានវត្តមានអធិការនៅក្នុងបន្ទប់រៀន ហើយកំពុងសង្កេតការបង្រៀនរបស់គាត់។ តើលោកគ្រូ/អ្នកគ្រូមានឥរិយាបថបែបណា?

**B. ពេលសង្កេតការបង្រៀន**

នៅពេលដែលអធិការសង្កេតមើលការបង្រៀន គ្រូបង្រៀនជាច្រើនមានការយល់ស្របនឹងសកម្មភាពរបស់អធិការកិច្ចលើការបង្រៀនរបស់ខ្លួន ដោយមានកម្រិតយល់ស្រប "ល្អ" មានមធ្យមភាគពិន្ទុ 4.29។ ជាមួយគ្នានេះដែរ បើពិនិត្យលើតារាង 26 ឃើញថា សូចនាករទី៧ "ក្រុមអធិការពិនិត្យមើលការអនុវត្តកិច្ចតែងការបង្រៀនរបស់គ្រូ" លោកគ្រូ/អ្នកគ្រូមានការយល់ស្របខ្ពស់ជាងគេ កម្រិត "ល្អណាស់" ជាមួយមធ្យមភាគពិន្ទុ 4.53។ បន្ទាប់មកទៀត សូចនាករទី៨ "ក្រុមអធិការពិនិត្យមើលការចាត់តាំងសកម្មភាពរៀន និងបង្រៀន

នៅក្នុងថ្នាក់រៀន" មានមធ្យមភាគពិន្ទុ 4.38។ អ្វីដែលគួរឱ្យកត់សម្គាល់ សូចនាករទី៣៨ "គ្រូបង្រៀនក្លាហានក្នុងការធ្វើពិសោធន៍គំនិតថ្មី/វិធីសាស្ត្រថ្មីៗ ក្នុងពេលអធិការកិច្ច" បានទទួលការយល់ស្របតិចជាងគេ កម្រិត "ល្អ" លើមធ្យមភាគពិន្ទុ 4.09 ។

| ល.រ | បរិយាយ | ចំនួន | មធ្យម | លទ្ធផល | លំដាប់ |
|---|---|---|---|---|---|
| | B. ការបង្រៀន | | | | |
| ១ | គ្រូបង្រៀនបានព្យាយាមជំរុញឱ្យសិស្សមានសកម្មភាពច្រើនក្នុងថ្នាក់រៀន ពេលមានការចុះអធិការកិច្ច | 94 | 4.20 | ល្អ | 8 |
| ២ | គ្រូបង្រៀនគ្រប់គ្រងថ្នាក់រៀនបានល្អ ពេលមានអធិការចុះសង្កេតថ្នាក់ | 94 | 4.16 | ល្អ | 10 |
| ៣ | គ្រូបង្រៀនក្លាហានក្នុងការធ្វើពិសោធន៍គំនិតថ្មី / វិធីសាស្ត្រថ្មីៗ ក្នុងពេលអធិការកិច្ច | 94 | 4.09 | ល្អ | 11 |
| ៤ | គ្រូបង្រៀនពេញចិត្តចំពោះសកម្មភាពអធិការកិច្ចនៅក្នុងថ្នាក់រៀន | 94 | 4.27 | ល្អ | 7 |
| ៥ | គ្រូបង្រៀនយល់ថាអធិការជាអ្នកមានបទពិសោធន៍ក្នុងការបង្រៀនបានល្អ | 94 | 4.20 | ល្អ | 8 |
| ៦ | អធិការមិនជជែកវែកញែកអំពីកំហុសរបស់គ្រូ នៅចំពោះមុខសិស្សឡើយ | 94 | 4.37 | ល្អ | 3 |
| ៧ | ក្រុមអធិការពិនិត្យមើលការអនុវត្តកិច្ចតែងការបង្រៀនរបស់គ្រូ | 94 | 4.53 | ល្អណាស់ | 1 |
| ៨ | ក្រុមអធិការពិនិត្យមើលការចាត់តាំងសកម្មភាពរៀន និង | 94 | 4.38 | ល្អ | 2 |

| | | | | | |
|---|---|---|---|---|---|
| | បង្រៀននៅក្នុងថ្នាក់រៀន | | | | |
| ៩ | ក្រុមអធិការ បានឱ្យយោបល់ពីការប្រើប្រាស់សម្ភារឧបទេសក្នុងការរៀន និងបង្រៀន | 94 | 4.30 | ល្អ | 5 |
| ១០ | ក្រុមអធិការបានពិនិត្យមើលគ្រប់ជ្រុងជ្រោយក្នុងដំណើរការបង្រៀននៅក្នុងថ្នាក់ | 94 | 4.37 | ល្អ | 3 |
| ១១ | អធិការជាអ្នកជួយកែលម្អគ្រូក្នុងពេលបង្រៀន ជាជាងអ្នកស្វែងរកកំហុសរបស់គ្រូ | 94 | 4.28 | ល្អ | 6 |
| សរុប | | | 4.29 | ល្អ | |

***តារាង 26៖** ឥរិយាបថគ្រូបង្រៀនចំពោះអធិការកិច្ចពេលចុះសង្កេតការបង្រៀន ទទួលបានពីកម្រងសំណួរគ្រូបង្រៀន*

សម្រាប់នាយក/នាយិកាវិញ តារាង 27 បង្ហាញថា នាយក/នាយិកា បានយល់ស្របទៅនឹងវិធីសាស្ត្រ និងសកម្មភាពអធិការកិច្ចក្នុងថ្នាក់រៀនដែរ ដោយមានកម្រិតយល់ស្រប "ល្អ" លើមធ្យមភាគពិន្ទុ 4.35។ បើពិនិត្យមើលលើសូចនាករទី៥ "ក្រុមអធិការបានពិនិត្យមើលគ្រប់ជ្រុងជ្រោយក្នុងដំណើរការបង្រៀននៅក្នុងថ្នាក់" នាយក/នាយិកាបាន យល់ស្របខ្ពស់ជាងគេកម្រិត "ល្អណាស់" លើមធ្យមភាគពិន្ទុ 4.77 និងសូចនាករទី១ "ពេលមានការចុះអធិការកិច្ច គ្រូព្យាយាមជំរុញឱ្យសិស្សមានសកម្មភាពច្រើនក្នុងថ្នាក់រៀន" មានការយល់ស្របទាបជាងគេ កម្រិត "ល្អ" លើមធ្យមភាគពិន្ទុ 3.85 ។

| **ល.រ** | **បរិយាយ** | **ចំនួន** | **មធ្យម** | **លទ្ធផល** | **លំដាប់** |
|---|---|---|---|---|---|
| **B. ការបង្រៀន** | | | | | |
| ១ | ពេលមានការចុះអធិការកិច្ច គ្រូព្យាយាមជំរុញឱ្យសិស្សមានសកម្មភាពច្រើនក្នុងថ្នាក់រៀន | 13 | 3.85 | ល្អ | 6 |
| ២ | ពេលមានអធិការកិច្ចថ្នាក់រៀន គ្រូបង្រៀនគ្រប់គ្រងថ្នាក់រៀន | 13 | 4.23 | ល្អ | 4 |

| | | | | | |
|---|---|---|---|---|---|
| | បានល្អ | | | | |
| ៣ | គ្រូបង្រៀនក្លាហានក្នុងការធ្វើពិសោធន៍គំនិតថ្មី / វិធីសាស្រ្តថ្មីៗ ក្នុងពេលអធិការកិច្ច | 13 | 4.08 | ល្អ | 5 |
| ៤ | គ្រូបង្រៀនពេញចិត្តចំពោះសកម្មភាពអធិការកិច្ចនៅក្នុងថ្នាក់រៀន | 13 | 4.69 | ល្អណាស់ | 2 |
| ៥ | ក្រុមអធិការបានពិនិត្យមើលគ្រប់ជ្រុងជ្រោយក្នុងដំណើរការបង្រៀននៅក្នុងថ្នាក់ | 13 | 4.77 | ល្អណាស់ | 1 |
| ៦ | អធិការជាអ្នកជួយកែលម្អគ្រូក្នុងពេលបង្រៀន ជាជាងអ្នកស្វែងរកកំហុសរបស់គ្រូ | 13 | 4.46 | ល្អ | 3 |
| សរុប | | | 4.35 | ល្អ | |

***តារាង 27៖*** *ឥរិយាបថគ្រូបង្រៀនចំពោះអធិការកិច្ចពេលសង្កេតការបង្រៀន តាមរយៈកម្រងសំណួរនាយក*

ម្យ៉ាងទៀតសំណួរទី១១នៃកម្រងសំណួរសម្រាប់សិស្ស "ក្នុងពេលមានគេចុះអធិការកិច្ចថ្នាក់រៀនរបស់ប្អូន តើការបង្រៀនរបស់លោកគ្រូ/អ្នកគ្រូមានសកម្មភាពខុសប្លែកពីរាល់ថ្ងៃដែរឬទេ?" ចម្លើយសិស្សមានភាពប្រហាក់ប្រហែលគ្នាគឺសិស្ស៩៦នាក់ ត្រូវនឹង៥៥%បានឆ្លើយថា លោកគ្រូ/អ្នកគ្រូរបស់ពួកគេមានសកម្មភាពបង្រៀនមិនខុសប្លែកពីរាល់ដងទេនៅថ្ងៃដែលគេចុះអធិការកិច្ច និងសិស្ស៧៤នាក់ ស្មើនឹង៤៣%ទៀតយល់ថាការបង្រៀនរបស់លោកគ្រូ/អ្នកគ្រូរបស់ពួកគេមានភាពខុសប្លែកពីថ្ងៃធម្មតា ចំណែកឯសិស្ស៤នាក់ទៀតស្មើនឹង២% ឆ្លើយថាមិនបានចាប់អារម្មណ៍លើសកម្មភាពលោកគ្រូ/អ្នកគ្រូ នៅពេលគេចុះមកអធិការកិច្ចថ្នាក់រៀនទេ។

សរុបរួមក្នុងផ្នែករងនេះ គ្រូបង្រៀនមានឥរិយាបថវិជ្ជមានចំពោះការងារអធិការកិច្ច លើសកម្មភាព និងវិធីសាស្រ្តដែលអធិការបានធ្វើក្នុងពេលសង្កេតថ្នាក់រៀន។ ទាំងគ្រូបង្រៀន និងនាយក/នាយិកា បានយល់ថា

អធិការកិច្ចបានពិនិត្យមើលការអនុវត្តកិច្ចតែងការបង្រៀនរបស់គ្រូ ពិនិត្យមើលការចាត់តាំងសកម្មភាពរៀន និងបង្រៀននៅក្នុងថ្នាក់រៀន ជាពិសេសអធិការមិនជជែកវែកញែកអំពីកំហុសរបស់គ្រូ នៅចំពោះមុខសិស្សឡើយ ដែលជាហេតុធ្វើឱ្យការបង្រៀនរបស់គ្រូប្រព្រឹត្តទៅតាមដំណើរដែលបានត្រៀមទុក។ ក្នុងផ្នែកនេះដែរ យើងសង្កេតឃើញថា ទោះបីជាគ្រូបង្រៀនមានឥរិយាបថវិជ្ជមានចំពោះអធិការកិច្ច ក្នុងអំឡុងពេលសង្កេតថ្នាក់រៀនក៏ដោយ ប៉ុន្តែគ្រូបង្រៀនមួយចំនួនតូចហាក់បានប្រឹងប្រែង និងព្យាយាមជំរុញឱ្យសិស្សមានសកម្មភាពច្រើនក្នុងថ្នាក់រៀន ពេលមានការចុះអធិការកិច្ច និងមិនមានភាពក្លាហានក្នុងការធ្វើពិសោធន៍គំនិតថ្មី/វិធីសាស្ត្រថ្មីៗនៅពេលបង្រៀនឡើយ។ ត្រង់ចំណុចនេះបង្ហាញថា គ្រូបង្រៀនមួយចំនួនតូច នៅតែមានភាពខ្លាចរអាក្នុងការបង្កើតកំហុសក្នុងពេលបង្រៀនចំពោះមុខអធិការកិច្ច។

### C. ការសម្ភាសអំពីការបង្រៀន និងរៀន

ការសម្ភាសគ្រូ ជាកិច្ចការមួយដែលអធិការកិច្ចតែងតែធ្វើជាទម្លាប់ក្នុងពេលចុះអធិការកិច្ចសាលារៀននីមួយ។ ការសម្ភាសគ្រូ មានគោលបំណងសាកសួរ ដើម្បីរកព័ត៌មានបន្ថែមក្រៅពីការសង្កេតពីការបង្រៀន ការរៀបចំឯកសាររដ្ឋបាល វឌ្ឍនភាព និងបញ្ហាប្រឈមមួយចំនួនទាក់ទងនឹងការបង្រៀន។ ក្នុងផ្នែករងបន្ទាប់នេះ យើងនឹងបកស្រាយពីឥរិយាបថគ្រូបង្រៀន ក្នុងការចូលរួមសម្ភាសជាមួយក្រុមអធិការលើការបង្រៀន និងរៀនរបស់ខ្លួន។ តាមតារាង 28 លោកគ្រូ/អ្នកគ្រូ បានយល់ស្របកម្រិត "ល្អ" មានមធ្យមភាគពិន្ទុ 4.38 ទៅលើបច្ចេកទេស វិធីសាស្ត្រ និងភាពប៉ិនប្រសប់របស់ក្រុមអធិការ ក្នុងការសម្ភាសគ្រូបង្រៀន និងការចូលរួមរបស់គ្រូបង្រៀននៅពេលសម្ភាសនោះ។ ចំណុចដែលទទួលបានការយល់ស្របខ្ពស់ជាងគេ គឺសូចនាករទី៣ "លោកគ្រូ/អ្នកគ្រូ មិននិយាយកុហក ដើម្បីចៀសផុតពីការវាយតម្លៃមិនល្អឡើយ" កម្រិត "ល្អណាស់" លើមធ្យមភាគពិន្ទុ 4.51 និងសូចនាករទី៤ "ក្នុងពេលអធិការកិច្ច គ្រូបង្រៀនអាចរៀបរាប់ពីបញ្ហាលំបាកលើការបង្រៀន និងរៀន" មានកម្រិតយល់ស្រប "ល្អ" លើមធ្យមភាគពិន្ទុ 4.46។ ទោះបីក្នុងផ្នែកនេះ គ្រប់សូចនាករទាំងអស់ លោកគ្រូ/អ្នកគ្រូបានយល់ស្រប ក្នុងកម្រិតល្អពិតមែន ប៉ុន្តែសូចនាករទី១ "អធិការប្រើប្រាស់កម្រង

សំណួរសម្ភាស មានភាពងាយស្រួលសម្រាប់គ្រូបង្រៀនក្នុងការឆ្លើយ″ ទទួលបានការយល់ស្របទាបជាងគេ កម្រិត″ល្អ″ លើមធ្យមភាគពិន្ទុ 4.23 និងសូចនាករទី២ ″អធិការមានភាពប៉ិនប្រសប់ក្នុងការសម្ភាសន៍គ្រូអំពីការបង្រៀន និងរៀន″ មានមធ្យមភាគពិន្ទុ 4.38។

| ល.រ | បរិយាយ | ចំនួន | មធ្យម | លទ្ធផល | លំដាប់ |
|---|---|---|---|---|---|
| C. ការសម្ភាសអំពីការបង្រៀន និងរៀន | | | | | |
| ១ | អធិការប្រើប្រាស់កម្រងសំណួរសម្ភាស មានភាពងាយស្រួលសម្រាប់គ្រូបង្រៀនក្នុងការឆ្លើយ | 94 | 4.23 | ល្អ | 8 |
| ២ | អធិការមានភាពប៉ិនប្រសប់ក្នុងការសម្ភាសន៍គ្រូអំពីការបង្រៀន និងរៀន | 94 | 4.38 | ល្អ | 7 |
| ៣ | គ្រូបង្រៀន គ្មានការស្ទាក់ស្ទើរក្នុងការចូលរួមឆ្លើយសំណួរសម្ភាសន៍របស់អធិការកិច្ច | 94 | 4.51 | ល្អ | 4 |
| ៤ | លោកគ្រូ/អ្នកគ្រូ មិននិយាយកុហក ដើម្បីចៀសផុតពីការវាយតម្លៃមិនល្អឡើយ | 94 | 4.46 | ល្អណាស់ | 1 |
| ៥ | ក្នុងពេលអធិការកិច្ច គ្រូបង្រៀនអាចរៀបរាប់ពីបញ្ហាលំបាកលើការបង្រៀន និងរៀន | 94 | 4.31 | ល្អ | 2 |
| ៦ | ក្រុមអធិការបានបង្ហាញពីសកម្មភាព និងមូលហេតុដែលលោកគ្រូ/អ្នកគ្រូអនុវត្តបានល្អ លើការបង្រៀននិងរៀន | 94 | 4.40 | ល្អ | 6 |
| ៧ | ក្រុមអធិការបានបង្ហាញពីសកម្មភាពនិងមូលហេតុដែលគ្រូបង្រៀនអនុវត្តមិនបានល្អ លើការបង្រៀន និងរៀន | 94 | 4.35 | ល្អ | 3 |
| ៨ | លោកគ្រូ/អ្នកគ្រូមានឱកាសលើកអំណះអំណាងអំពីមូល | 94 | 4.37 | ល្អ | 5 |

| | | | | | |
|---|---|---|---|---|---|
| | ហេតុនៃការបង្រៀន នៅពេលសម្ភាសន៍ | | | | |
| សរុប | | | 4.38 | ល្អ | |

*តារាង 28៖ ឥរិយាបថគ្រូបង្រៀនចំពោះការសម្ភាស ទទួលបានតាមរយៈកម្រងសំណួរគ្រូបង្រៀន*

សម្រាប់នាយក/នាយិកា ដែលបានសង្កេតឃើញគ្រូបង្រៀន ក្នុងការចូលរួមសម្ភាសនៅពេលការចុះអធិការកិច្ច បានបង្ហាញថាលោកគ្រូ/អ្នកគ្រូ បានសហការ និងចូលរួមឆ្លើយសំណួរសម្ភាសពីក្រុមអធិការកិច្ច នៅពេលមានការស្នើសុំ សម្ភាស ដោយបានលើកឡើងថា គ្រូបង្រៀនបានចូលរួម និងសម្របសម្រួលដល់ក្រុមអធិការកិច្ច ធ្វើយ៉ាងណាឱ្យការធ្វើអធិការកិច្ចមានដំណើរការល្អ។ តាមតារាង 29 លោកនាយក/នាយិកា បានបង្ហាញការយល់ស្របកម្រិត "ល្អ" លើមធ្យមភាគ 4.44 ទៅលើសកម្មភាពសម្ភាសរបស់អធិការកិច្ច និងគ្រូបង្រៀនចំពោះការបង្រៀន និងរៀន។ ក្នុងនោះដែរ សូចនាករទី៥ "ក្រុមអធិការបានបង្ហាញពីសកម្មភាព និងមូលហេតុដែលលោកគ្រូ/អ្នកគ្រូអនុវត្តបានល្អ លើការបង្រៀននិងរៀន" ទទួលបានការយល់ស្របខ្ពស់ជាងគេ កម្រិត "ល្អណាស់" លើមធ្យមភាគពិន្ទុ 4.69។ រីឯសូចនាករទី៦ "ក្រុមអធិការបានបង្ហាញពីសកម្មភាពនិងមូលហេតុដែលគ្រូបង្រៀនអនុវត្តមិនបានល្អ លើការបង្រៀន និងរៀន" ទទួលបានការយល់ស្របទាបជាងគេ កម្រិត "ល្អ" លើមធ្យមភាគពិន្ទុ 4.00។

| ល.រ | បរិយាយ | ចំនួន | មធ្យម | លទ្ធផល | លំដាប់ |
|---|---|---|---|---|---|
| **C. ការសម្ភាសអំពីការបង្រៀន និងរៀន** | | | | | |
| ១ | អធិការមានភាពប៉ិនប្រសប់ក្នុងការសម្ភាសគ្រូអំពីការបង្រៀន និងរៀន | 13 | 4.62 | ល្អណាស់ | 3 |
| ២ | គ្រូបង្រៀន គ្មានការស្ទាក់ស្ទើរក្នុងការចូលរួមឆ្លើយសំណួរសម្ភាសន៍របស់អធិការកិច្ច | 13 | 4.69 | ល្អណាស់ | 1 |
| ៣ | ក្នុងពេលអធិការកិច្ច គ្រូបង្រៀនបានរៀបរាប់ពីបញ្ហា | 13 | 4.31 | ល្អ | 4 |

| | | | | | |
|---|---|---|---|---|---|
| | លំបាកលើការបង្រៀន និងរៀន | | | | |
| ៤ | លោកគ្រូ/អ្នកគ្រូ  មិននិយាយកុហក ដើម្បីចៀសផុតពីការវាយតម្លៃមិនល្អឡើយ | 13 | 4.31 | ល្អ | 5 |
| ៥ | ក្រុមអធិការបានបង្ហាញពីសកម្មភាព និងមូលហេតុដែលលោកគ្រូ/អ្នកគ្រូអនុវត្តបានល្អ លើការបង្រៀននិងរៀន | 13 | 4.69 | ល្អណាស់ | 1 |
| ៦ | ក្រុមអធិការបានបង្ហាញពីសកម្មភាពនិងមូលហេតុដែលគ្រូបង្រៀនអនុវត្តមិនបានល្អ លើការបង្រៀន និងរៀន | 13 | 4.00 | ល្អ | 6 |
| សរុប | | | 4.44 | ល្អ | |

***តារាង 29៖*** *ឥរិយាបថគ្រូបង្រៀនចំពោះការសម្ភាស ទទួលបានតាមរយៈកម្រងសំណួរនាយក/នាយិកា*

សម្រាប់សិស្ស  ក្នុងចំណោមសិស្ស១៧៤នាក់  ដែលមានចូលរួមឆ្លើយសំណួរទាក់ទងនឹងសកម្មភាពរបស់គ្រូបង្រៀន នៅពេលការចុះអធិការកិច្ចលើការបង្រៀន និងរៀន បានបង្ហាញថាលោកគ្រូ/អ្នកគ្រូបានផ្តល់ឱកាសឱ្យក្រុមសិស្សចូលរួមឆ្លើយសំណួរសម្ភាសរបស់អធិការ  និងគ្មានការស្តីបន្ទោសទេ  ជាក់ស្តែងសំណួរ "តើលោកគ្រូ/អ្នកគ្រូរបស់ប្អូន ធ្លាប់បន្ទោសពីការ ផ្តល់ព័ត៌មានដល់អធិការអំពីការបង្រៀនរបស់គ្រូបង្រៀនដែរឬទេ?" សិស្សចំនួន១៤៣នាក់ ស្មើនឹង ៨២% បានឆ្លើយថាទេ គឺលោកគ្រូ/អ្នកគ្រូមិនស្តីបន្ទោសអំពីអ្វីដែលពួកគេបាននិយាយទៅកាន់ក្រុមអធិការកិច្ចទេ។ ម្យ៉ាងទៀតមានសិស្ស២៩នាក់ទៀត ស្មើនឹង១៧%បានគាំទ្រថាលោកគ្រូ/អ្នកគ្រូរបស់ពួកគេធ្លាប់បានស្តីបន្ទោសពីអ្វី  ដែលពួកគេបានរៀបរាប់ប្រាប់ក្រុមអធិការអំពីការបង្រៀនរបស់គ្រូបង្រៀន។ ត្រង់ចំណុចនេះ បង្ហាញថាគ្រូបង្រៀនបានបង្ហាញការសហការ ក្នុងសកម្មភាពអធិការកិច្ច និងមានការបើកទូលាយសម្រាប់ការឆ្លើយសំណួរសម្ភាស។

ជារួមក្នុងផ្នែករង "ការសម្ភាសអំពីការបង្រៀន និងរៀន" គ្រូបង្រៀនបានបង្ហាញឥរិយាបថវិជ្ជមានចំពោះការចូលរួមឆ្លើយសំណួរសម្ភាសជាមួយអធិការកិច្ចដោយគ្មានការស្ទាក់ស្ទើរ  និងបានរៀបរាប់ពីបញ្ហា

លំបាកលើការបង្រៀន និងរៀនទៅដល់ក្រុមអធិការដើម្បីចូលរួមរិះរកវិធីដោះស្រាយ។ លើសពីនេះគ្រូបង្រៀនភាគច្រើនបានបង្ហាញភាពស្មោះត្រង់ និងមិនលាក់លៀមសកម្មភាពមិនល្អរបស់ខ្លួន ចំពោះមុខអធិការកិច្ច និងមានភាពបើកទូលាយដល់សិស្សក្នុងការចូលរួមឆ្លើយសំណួរសម្ភាស ដល់ក្រុមអធិការផងដែរ។ លទ្ធផលក្នុងផ្នែកនេះមានន័យថា គ្រូបង្រៀនបានផ្តល់ទំនុកចិត្តក្នុងការរៀបរាប់ពីបញ្ហានានាក្នុងដំណើរការនៃការបង្រៀនទៅដល់ក្រុមអធិការកិច្ច ប៉ុន្តែគ្រូបង្រៀនមួយចំនួនតូចយល់ថា អធិការមិនទាន់មានភាពប៉ិនប្រសប់ក្នុងការសម្ភាស និងការប្រើប្រាស់កម្រងសំណួរសម្ភាសន៍គ្រូអំពីការបង្រៀន និងរៀននៅឡើយ។

ក្នុងអំឡុងពេលអធិការកិច្ចនេះ បើផ្អែកលើចម្លើយដែលគ្រូបង្រៀនបានបំពេញក្នុងសំណួរទី ៥៥ "ក្នុងអំឡុងពេលអធិការកិច្ច តើអធិការកិច្ចបានប្រមូលព័ត៌មានគ្រប់ជ្រុងជ្រោយឬទេ អំពីការបង្រៀនរបស់លោកគ្រូអ្នកគ្រូ? ហេតុអ្វី?" គ្រូបង្រៀន៧៤នាក់ស្មើនឹង៧៨.៧២% បានទទួលស្គាល់ថា ក្នុងអំឡុងពេលអធិការកិច្ច អធិការបានទទួលព័ត៌មានគ្រប់គ្រាន់អំពីការបង្រៀន និងបង្រៀនរបស់គាត់ ព្រោះអធិការបានចុះសង្កេតសកម្មភាពបង្រៀនក្នុងថ្នាក់រៀនដោយមានឧបករណ៍វាយតម្លៃបានត្រឹមត្រូវ។ អធិការបានសម្ភាសគ្រូបង្រៀន និងដឹងពីចំណុចដែលត្រូវកែលម្អរបស់គ្រូ ជាក់ស្តែងគ្រូបង្រៀនទី៥, ៩, ១០, ៤៤ និងទី៩២ បានលើកឡើងថា "អធិការបានទទួលព័ត៌មានបានគ្រប់ជ្រុងជ្រោយ ព្រោះគាត់បានចុះសង្កេតនៅពេលលោកគ្រូ/អ្នកគ្រូបង្រៀន" និងគ្រូបង្រៀនទី១៦ និងទី៨៧ បានលើកឡើងដែរថា "អធិការបានប្រមូលព័ត៌គ្រប់ជ្រុងជ្រោយអំពីការបង្រៀន ព្រោះគាត់ដើម្បីដឹងនិងកែលម្អចំណុចខ្លះ" លើសពីនេះអធិការបានប្រមូលគ្រប់ជ្រុងជ្រោយ ព្រោះគាត់បានពិនិត្យ និងធ្វើការសម្ភាស ហើយកែតម្រូវរាល់ចំណុចខ្វះខាត (គ្រូបង្រៀនទី១៩)។ ប៉ុន្តែគ្រូបង្រៀន ១៧នាក់ ស្មើនឹង១៨.០៨% បានយល់ថាអធិការកិច្ចមិនបានប្រមូលព័ត៌មានបានគ្រប់ជ្រុងជ្រោយអំពីការបង្រៀនរបស់គាត់នៅឡើយទេ ដោយសារការចុះអធិការកិច្ចមានពេលវេលាខ្លីពេក និងមិនបានចុះសង្កេតការបង្រៀនបានគ្រប់ថ្នាក់។ ជាក់ស្តែងគ្រូបង្រៀនទី១៥ ៣៣, ៣៤ និងទី៣៥បានលើកឡើងថា "អធិការមិនបានទទួលព័ត៌មានគ្រប់ជ្រុងជ្រោយទេ ព្រោះពួកគាត់ចំណាយពេលខ្លីក្នុងការសម្ភាស និងសង្កេត

លើការបង្រៀន និងរៀន"។ ចំពោះនាយក/នាយិកាវិញ បានមើលឃើញថាក្នុងអំឡុងពេលអធិការកិច្ច គ្រូបង្រៀនបានទទួលរាក់ទាក់ ស្វាគមន៍ ចូលរួមសហការក្នុងសកម្មភាពអធិការកិច្ចដោយយកចិត្តទុកដាក់លើការបង្រៀន និងបានត្រៀមលក្ខណៈក្នុងការទទួលយកអនុសាសន៍ពីក្រុមអធិការកិច្ច។

| ល.រ | **ផ្នែកទី២៖ ឥរិយាបថរបស់គ្រូបង្រៀន អំឡុងពេលអធិការកិច្ចលើការបង្រៀន និងរៀន** | **មធ្យមភាគ** | | |
|---|---|---|---|---|
| | | **គ្រូបង្រៀន** | **នាយក/នាយិកា** | **សរុប** |
| A | ការសង្កេតថ្នាក់រៀន | 4.29 | 4.46 | 4.38 |
| B | សង្កេតការបង្រៀន | 4.29 | 4.35 | 4.32 |
| C | ការសម្ភាសអំពីការរៀន និងរៀន | 4.38 | 4.44 | 4.41 |
| សរុប | | 4.32 | 4.42 | 4.37 |

***តារាង 30៖*** *ឥរិយាបថគ្រូបង្រៀន អំឡុងពេលអធិការកិច្ចលើការបង្រៀន និងរៀន*

ការសិក្សាក្នុងផ្នែកទី២ លើឥរិយាបថគ្រូបង្រៀនអំឡុងពេលអធិការកិច្ចលើការបង្រៀន និងរៀនបានបង្ហាញឱ្យឃើញថា លោកគ្រូ/អ្នកគ្រូនៅតាមសាលាបឋមសិក្សាមានឥរិយាបថវិជ្ជមានចំពោះសកម្មភាព និងដំណើរការការងារអធិការកិច្ច ទៅលើការបង្រៀន និងរៀនរបស់ពួកគាត់ លើកម្រិតយល់ស្រប "ល្អ" លើមធ្យមភាគ 4.37។ នាយក/នាយិកា និងគ្រូបង្រៀនភាគច្រើនបានយល់ស្របថាគ្រូបង្រៀនបានចូលរួម និងសហការបានយ៉ាងល្អនៅថ្ងៃចុះអធិការកិច្ចក្នុងសកម្មភាពសង្កេតថ្នាក់រៀន ការសង្កេតលើការបង្រៀន និងការសម្ភាស។ គ្រូបង្រៀនចំនួន៧៨.៧២% យល់ថាអធិការបានប្រមូលព័ត៌មានបានគ្រប់គ្រាន់អំពីការបង្រៀនរបស់គាត់ នៅពេលចុះអធិការកិច្ចថ្នាក់រៀន ព្រោះអធិការបានពិនិត្យគ្រប់សកម្មភាពទាំងអស់នៅក្នុងថ្នាក់រៀន រួមមានការអនុវត្តកិច្ចតែងការបង្រៀនរបស់គ្រូ ពិនិត្យមើលការចាត់តាំងសកម្មភាពបង្រៀន និងរៀនជាដើម ដោយមិនធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍សិស្ស និងគ្រូបង្រៀនឡើយ។ ទោះជាយ៉ាងនេះក្តី គ្រូបង្រៀនភាគច្រើនមានអារម្មណ៍

ថាអធិការសង្កេតថ្នាក់រៀនគឺដើម្បីស្វែងរកចំណុចមិនល្អរបស់គ្រូបង្រៀន ជាហេតុធ្វើឱ្យគ្រូបង្រៀនព្យាយាមជំរុញឱ្យសិស្សមានសកម្មភាពច្រើនក្នុងថ្នាក់រៀន និងមានភាពខ្លាចរអាក្នុងការបង្កើតកំហុសក្នុងពេលបង្រៀនចំពោះមុខអធិការកិច្ច។ ប៉ុន្តែនៅពេលសម្ភាស គ្រូបង្រៀនភាគច្រើនបានចូលរួមឆ្លើយសំណួរដោយគ្មានការស្ទាក់ស្ទើរក្នុងការរៀបរាប់ពីបញ្ហាលំបាកលើការបង្រៀន និងរៀនទៅដល់ក្រុមអធិការ ដើម្បីចូលរួមរិះរកវិធីដោះស្រាយ។ សរុបមកគ្រូបង្រៀនបឋមសិក្សាភាគច្រើនមានឥរិយាបថវិជ្ជមាន ចំពោះការសង្កេតថ្នាក់រៀន និងការសម្ភាសរបស់ក្រុមអធិការកិច្ច។

### ៤.១.១.៣ ឥរិយាបថគ្រូបង្រៀន ក្រោយពេលអធិការកិច្ចលើការបង្រៀន និងរៀន

នៅដំណាក់កាលចុងក្រោយ នៃការធ្វើអធិការកិច្ចលើការបង្រៀន និងរៀន និងក្រោយពេលដែលក្រុមអធិការកិច្ចប្រមូលបានព័ត៌មានអំពីការបង្រៀន និងរៀន ដែលទទួលបានពីការសម្ភាស ការសង្កេតថ្នាក់ និងពិនិត្យមើលការបង្រៀនរបស់គ្រូបង្រៀននៅតាមថ្នាក់រួចមក ក្រុមអធិការកិច្ចនឹងបើកការប្រជុំរយៈពេលខ្លីដើម្បីផ្សព្វផ្សាយពីព័ត៌មានត្រលប់ ឬលទ្ធផលបណ្តោះអាសន្ននៃអធិការកិច្ចទៅលើការបង្រៀន និងរៀនរបស់គ្រូបង្រៀន រួមទាំងការផ្តល់អនុសាសន៍ចំពោះចំណុចដែលត្រូវកែលម្អបន្ថែម។

ផ្នែកខាងក្រោមនេះ យើងនឹងបកស្រាយអំពីឥរិយាបថគ្រូបង្រៀនក្រោយពេលអធិការកិច្ចលើការបង្រៀន និងរៀនរួមទាំងការយល់ឃើញរបស់គ្រូបង្រៀនលើអនុសាសន៍របស់ក្រុមអធិការកិច្ច ក៏ដូចជារបាយ-ការណ៍អធិការកិច្ចផងដែរ។

**A. ការផ្តល់អនុសាសន៍**

| ល.រ | បរិយាយ | ចំនួន | មធ្យម | លទ្ធផល | លំដាប់ |
|---|---|---|---|---|---|
| | **A. ការផ្តល់អនុសាសន៍** | | | | |
| ១ | អធិការតែងតែផ្តល់អនុសាសន៍លើការបង្រៀនរបស់គ្រូ | 94 | 4.54 | ល្អណាស់ | 1 |
| ២ | អនុសាសន៍របស់អធិការកិច្ចលើការបង្រៀននិងរៀន សម | 94 | 4.24 | ល្អ | 10 |

| | | | | | |
|---|---|---|---|---|---|
| | ស្របនឹងបរិបទរបស់សាលារៀនរបស់ពួកយើង | | | | |
| ៣ | អនុសាសន៍របស់អធិការកិច្ច មានលក្ខណៈសមស្របនិងច្បាស់លាស់ | 94 | 4.39 | ល្អ | 6 |
| ៤ | អនុសាសន៍របស់អធិការកិច្ច ធ្វើឱ្យការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាព | 94 | 4.49 | ល្អ | 5 |
| ៥ | អធិការកិច្ចបានផ្តល់អនុសាសន៍ផ្សារភ្ជាប់ស្ថានភាពជាក់ស្តែងតាមតម្រូវការ និងសមត្ថភាពរបស់លោកគ្រូ/អ្នកគ្រូ | 94 | 4.19 | ល្អ | 11 |
| ៦ | អនុសាសន៍របស់អធិការកិច្ច មានសារៈសំខាន់សម្រាប់គ្រូបង្រៀន | 94 | 4.51 | ល្អណាស់ | 3 |
| ៧ | ក្រុមអធិការតែងតែចែករំលែកនូវរាល់បទពិសោធន៍ល្អៗអំពីការបង្រៀន និងរៀន | 94 | 4.54 | ល្អណាស់ | 1 |
| ៨ | អនុសាសន៍របស់អធិការបានជួយឱ្យលោក/អ្នក ក្លាយទៅជាគ្រូបង្រៀនល្អ | 94 | 4.50 | ល្អ | 4 |
| ៩ | អនុសាសន៍របស់អធិការកិច្ច មិនមែនជាការដាក់បន្ទុកបន្ថែមលើការងារបង្រៀន របស់គ្រូបង្រៀនឡើយ | 94 | 4.26 | ល្អ | 9 |
| ១០ | លោកគ្រូ/អ្នកគ្រូ ទទួលស្គាល់បញ្ហាអំពីការបង្រៀន និងរៀនដែលអធិការកិច្ចបានរកឃើញ | 94 | 4.34 | ល្អ | 8 |
| ១១ | លោកគ្រូ/អ្នកគ្រូ នឹងអនុវត្តតាមអនុសាសន៍របស់ក្រុមអធិការកិច្ច លើបង្រៀន និងរៀន | 94 | 4.39 | ល្អ | 6 |
| សរុប | | | 4.40 | ល្អ | |

***តារាង 31៖** ឥរិយាបថគ្រូបង្រៀនចំពោះអនុសាសន៍អធិការកិច្ច ទទួលបានតាមរយៈកម្រងសំណួរគ្រូបង្រៀន*

តាមតារាង 31 គ្រូបង្រៀនភាគច្រើនទទួលយកអនុសាសន៍របស់អធិការកិច្ច លើការបង្រៀនរបស់ខ្លួន និងយល់ថាអនុសាសន៍អធិការកិច្ចលើការបង្រៀន និងរៀនជាការជួយកែលម្អបង្រៀនរបស់ខ្លួន។ ជាក់ស្តែង គ្រូបង្រៀនបានយល់ស្របទៅនឹងអនុសាសន៍អធិការកិច្ចក្នុងកម្រិត "ល្អ" លើមធ្យមភាគពិន្ទុ 4.40។ ក្នុងចំណោមសូចនាករទាំងអស់១១ សូចនាករទី៧ "ក្រុមអធិការតែងតែចែករំលែកនូវរាល់បទពិសោធន៍ល្អៗអំពីការបង្រៀន និងរៀន" និងសូចនាករទី៥ "អធិការតែងតែផ្តល់អនុសាសន៍លើការបង្រៀនរបស់គ្រូ" ទទួលបានការយល់ស្របពីសំណាក់លោកគ្រូ/អ្នកគ្រូច្រើនជាងគេ កម្រិត "ល្អណាស់" ដូចគ្នាលើមធ្យមភាគពិន្ទុ 4.54 ហើយគ្រូបង្រៀនយល់ថាអនុសាសន៍របស់អធិការកិច្ចមានសារៈសំខាន់សម្រាប់គ្រូបង្រៀន កម្រិត "ល្អណាស់" លើមធ្យមភាគពិន្ទុ 4.51។ ចំណែកឯសូចនាករទី២ "អនុសាសន៍របស់អធិការកិច្ចលើការបង្រៀននិងរៀន សមស្របនឹងបរិបទរបស់សាលារៀនរបស់ពួកយើង" និងសូចនាករទី១ "អធិការកិច្ចបានផ្តល់អនុសាសន៍ផ្សារភ្ជាប់ស្ថានភាពជាក់ស្តែងតាមតម្រូវការ និងសមត្ថភាពរបស់លោកគ្រូ/អ្នកគ្រូ" ទទួលបានការយល់ស្របតិចជាងក្នុងកម្រិត "ល្អ" ក្រោមមធ្យមភាគពិន្ទុរៀងគ្នា 4.24 និង4.19។

សម្រាប់នាយក/នាយិកា ជាគណៈគ្រប់គ្រងសាលា និងជាអ្នកបានឃើញសកម្មភាពគ្រូបង្រៀនរាល់ថ្ងៃ ជាពិសេសក្រោយពេលមានការចុះអធិការកិច្ចលើការបង្រៀននិងរៀន បានយល់ស្របថាគ្រូបង្រៀនបានទទួលយកអនុសាសន៍អធិការកិច្ចលើការបង្រៀន និងរៀនកម្រិត "ល្អណាស់" លើមធ្យមភាគពិន្ទុ 4.71។ ក្នុងនោះដែរសូចនាករទី៣ និងទី៥ "អនុសាសន៍របស់អធិការកិច្ច មានលក្ខណៈសមស្របនិងច្បាស់លាស់ចំពោះការបង្រៀន និងរៀន" និង "អនុសាសន៍របស់អធិការកិច្ចមានសារៈសំខាន់សម្រាប់គ្រូបង្រៀន" នាយក/នាយិកាមានការយល់ស្របច្រើនជាងគេកម្រិត "ល្អណាស់" លើមធ្យមភាគពិន្ទុ 4.92 ដូចគ្នា។ ចំណែកឯសូចនាករដែលទទួលបានការយល់ស្របតិចជាងគេ គឺសូចនាករទី៩ និង១០ "លោកគ្រូ/អ្នកគ្រូ បានអនុវត្តតាមអនុសាសន៍របស់ក្រុមអធិការកិច្ចលើកិច្ចការបង្រៀន" ហើយ "គ្រូបង្រៀនបានផ្លាស់ប្តូរវិធីសាស្រ្តបង្រៀនក្នុងការបង្រៀន តាមអនុសាសន៍របស់អធិការកិច្ច" កម្រិត "ល្អ" លើមធ្យមភាគពិន្ទុ 4.38។

| ល.រ | បរិយាយ | ចំនួន | មធ្យម | លទ្ធផល | លំដាប់ |
|---|---|---|---|---|---|
| A. ការផ្តល់អនុសាសន៍ | | | | | |
| ១ | អធិការតែងតែផ្តល់អនុសាសន៍លើការបង្រៀនរបស់គ្រូ | 13 | 4.62 | ល្អណាស់ | 7 |
| ២ | អនុសាសន៍របស់អធិការកិច្ចលើការបង្រៀននិងរៀន សមស្របនឹងបរិបទរបស់សាលារៀននីមួយៗ | 13 | 4.69 | ល្អណាស់ | 6 |
| ៣ | អនុសាសន៍របស់អធិការកិច្ច មានលក្ខណៈសមស្របនិងច្បាស់លាស់ចំពោះ ការបង្រៀន និងរៀន | 13 | 4.92 | ល្អណាស់ | 1 |
| ៤ | អនុសាសន៍របស់អធិការកិច្ច ធ្វើឱ្យការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាព | 13 | 4.92 | ល្អណាស់ | 1 |
| ៥ | អនុសាសន៍របស់អធិការកិច្ច មានសារៈសំខាន់សម្រាប់គ្រូបង្រៀន | 13 | 4.92 | ល្អណាស់ | 1 |
| ៦ | អនុសាសន៍របស់អធិការបានជួយឱ្យគ្រូបង្រៀនក្លាយទៅជាគ្រូបង្រៀនល្អ | 13 | 4.77 | ល្អណាស់ | 5 |
| ៧ | អនុសាសន៍របស់អធិការកិច្ច មិនមែនជាការដាក់បន្ទុកបន្ថែមលើការងារបង្រៀន របស់គ្រូឡើយ | 13 | 4.85 | ល្អណាស់ | 4 |
| ៨ | លោកគ្រូ/អ្នកគ្រូ ទទួលស្គាល់បញ្ហាអំពីការបង្រៀន និងរៀនដែលអធិការកិច្ចបានរកឃើញ | 13 | 4.62 | ល្អណាស់ | 7 |
| ៩ | លោកគ្រូ/អ្នកគ្រូ បានអនុវត្តតាមអនុសាសន៍របស់ក្រុមអធិការកិច្ច លើកិច្ចការបង្រៀន | 13 | 4.38 | ល្អ | 9 |
| ១០ | គ្រូបង្រៀនបានផ្លាស់ប្តូរឥរិយាបថក្នុងការបង្រៀន តាមអនុ | 13 | 4.38 | ល្អ | 9 |

| | | | | | |
|---|---|---|---|---|---|
| | សាសន៍របស់អធិការកិច្ច | | | | |
| សរុប | | | 4.71 | ល្អណាស់ | |

***តារាង 32៖** ឥរិយាបថគ្រូបង្រៀនចំពោះអនុសាសន៍អធិការកិច្ច ទទួលបានតាមរយៈកម្រងសំណួរនាយក/នាយិកា*

ចំណែកឯសិស្សានុសិស្សវិញបានចូលរួមឆ្លើយសំណួរអំពីឥរិយាបថគ្រូបង្រៀន ក្រោយពេលអធិការកិច្ចនេះផងដែរដូចជា៖ គ្រូធ្លាប់បាននិយាយប្រាប់ពីលទ្ធផលអធិការកិច្ច និងការប្រែប្រួលរបៀបបង្រៀនរបស់គ្រូក្រោយពេលអធិការកិច្ច។

| **ល.រ** | **បរិយាយ** | **បាទ/ចាស** | | **ទេ** | | **មិនច្បាស់ទេ** | |
|---|---|---|---|---|---|---|---|
| | | **ចំនួន** | **ភាគរយ** | **ចំនួន** | **ភាគរយ** | **ចំនួន** | **ភាគរយ** |
| ១ | តើលោកគ្រូ/អ្នកគ្រូ ធ្លាប់និយាយក្នុងថ្នាក់អំពីលទ្ធផលអធិការកិច្ចដែរឬទេ? | 101 | 58% | 64 | 37% | 9 | 5% |
| ២ | តើការបង្រៀនរបស់លោកគ្រូ/អ្នកគ្រូ ប្រែប្រួលឬទេ បន្ទាប់ពីមានការចុះអធិការកិច្ច? | 92 | 53% | 79 | 45% | 3 | 2% |
| សិស្សសរុប | | 174 | | | | | |

***តារាង 33៖** សកម្មភាពគ្រូបង្រៀនក្រោយពេលចុះអធិការកិច្ច ទទួលបានតាមរយៈកម្រងសំណួរសិស្ស*

តាមតារាង 33 បង្ហាញថា សិស្សបឋមសិក្សាចំនួន ១០១នាក់ ស្មើនឹង ៥៨% ក្នុងចំណោម១៧៤នាក់ បានយល់ស្របទៅលើសំណួរ "តើលោកគ្រូ/អ្នកគ្រូ ធ្លាប់និយាយក្នុងថ្នាក់អំពីលទ្ធផលអធិការកិច្ចដែរឬទេ?" ហើយសិស្សចំនួន ៦៤នាក់ ស្មើនឹង ៣៧% ឆ្លើយថាលោកគ្រូ/អ្នកគ្រូ មិនធ្លាប់បាននិយាយពីលទ្ធផលនៃការអធិការកិច្ចថ្នាក់រៀនទេ។ ចំណែកឯសំណួរទី២ "តើការបង្រៀនរបស់លោកគ្រូ/អ្នកគ្រូ ប្រែប្រួលឬទេ បន្ទាប់ពីមានការចុះអធិការកិច្ច?" សិស្ស ៩២នាក់ ស្មើនឹង ៥៣% ឆ្លើយថា ការបង្រៀនរបស់លោកគ្រូ/អ្នកគ្រូ មានការប្រែប្រួលបន្ទាប់ពីមានការធ្វើអធិការកិច្ចថ្នាក់រៀនហើយ ហើយសិស្ស ៧៩នាក់ទៀត ស្មើនឹង ៤៥% ឆ្លើយ

ថា ការបង្រៀនរបស់លោកគ្រូ/អ្នកគ្រូមិនមានការប្រែប្រួលទេក្រោយពេលអធិការកិច្ច។

សរុបជារួម ដោយផ្អែកលើមធ្យមភាគពិន្ទុសរុប 4.40 នៃការយល់ស្របរបស់គ្រូបង្រៀន ទៅលើការផ្តល់អនុសាសន៍របស់ក្រុមអធិការកិច្ចលើការបង្រៀន និងរៀន យើងអាចសន្និដ្ឋានថាគ្រូបង្រៀនមានឥរិយាបថវិជ្ជមានចំពោះអនុសាសន៍របស់អធិការកិច្ច ដោយគ្រូបង្រៀនជាច្រើនបានយល់ស្របថាអធិការកិច្ចបានផ្តល់អនុសាសន៍ទៅលើការបង្រៀនរបស់គាត់ ហើយអនុសាសន៍នោះផងដែរ ពិតជាមានសារៈសំខាន់សម្រាប់គ្រូបង្រៀន ដែលអាចជួយឱ្យគាត់ក្លាយទៅជាគ្រូបង្រៀនល្អម្នាក់ ព្រោះក្រុមអធិការបានចែករំលែកបទពិសោធន៍ល្អៗទាក់ទងនឹងការបង្រៀន និងរៀន។ ទាំងនាយក/នាយិកា និងគ្រូបង្រៀនភាគច្រើនបានឯកភាពពីអ្វីដែលអធិការកិច្ចបានរកឃើញ។ ទោះបីជាគ្រូបង្រៀនបានបង្ហាញពីឥរិយាបថវិជ្ជមានជារួមយ៉ាងណាក្តី យើងសង្កេតឃើញថាលោកគ្រូ/អ្នកគ្រូមួយចំនួនតូច បានយល់ថាការផ្តល់អនុសាសន៍មិនសូវបានផ្សារភ្ជាប់ស្ថានភាពជាក់ស្តែងតាមតម្រូវការ និងសមត្ថភាពរបស់លោកគ្រូ/អ្នកគ្រូឡើយ។ លើសពីនេះអនុសាសន៍របស់អធិការកិច្ច មិនទាន់មានលក្ខណៈសមស្រប និងច្បាស់លាស់ ដែលធ្វើឱ្យការបង្រៀនកាន់តែមានប្រសិទ្ធភាពខ្លាំងក្លាទេ ទាំងនេះជាហេតុធ្វើឱ្យលោកគ្រូ/អ្នកគ្រូមួយចំនួនតូចបានអនុវត្តតាមអនុសាសន៍របស់ក្រុមអធិការកិច្ច លើកិច្ចការបង្រៀនបានតិចតួច បើយោងតាមចម្លើយរបស់នាយក/នាយិកា និងសិស្ស។

### B. ការផ្តល់របាយការណ៍

ជាទូទៅក្រោយពេលអធិការកិច្ច ក្រុមអធិការតែងតែបញ្ជូនរបាយការណ៍អធិការកិច្ចត្រលប់ទៅសាលារៀនវិញ ក្នុងរយៈពេលណាមួយ។ ក្នុងផ្នែកនេះ យើងនឹងសិក្សាបន្តទៅលើឥរិយាបថគ្រូបង្រៀន ចំពោះរបាយ-ការណ៍អធិការកិច្ច។ តាមតារាង 34 គ្រូបង្រៀន មានការយល់ស្របទៅនឹងរបាយការណ៍អធិការកិច្ច អំពីការបង្រៀន និងរៀនរបស់ខ្លួនបានកម្រិត ″ល្អ″ និងមធ្យមភាគពិន្ទុ 3.92។ ក្នុងផ្នែករងនេះមានសូចនាករទាំងអស់ ៨ ហើយសូចនាករទី៧ និងទី៨ ″លោកគ្រូ/អ្នកគ្រូទាំងអស់យល់ឃើញថាសកម្មភាពនៃការចុះអធិការកិច្ចមានប្រយោជន៍ដល់ការបង្រៀន និងរៀនរបស់ខ្លួន″ និង ″ការវាយតម្លៃរបស់អធិការកិច្ចលើការបង្រៀនរបស់គ្រូ

ផ្តោតលើបច្ចេកទេស មិនមែនប្រើអារម្មណ៍ផ្ទាល់ខ្លួន″ បានទទួលការយល់ស្របខ្ពស់ជាងគេកម្រិត "ល្អ″ និងមានមធ្យមភាគពិន្ទុ 4.43 ដូចគ្នា។ ចំណែកឯ សូចនាករទី៦ "របាយការណ៍អធិការកិច្ចបានបំពេញការចំណុចខ្វះខាតរបស់គ្រូបង្រៀនក្នុងអាជីពរបស់ពួកគាត់″ និងសូចនាករទី៤ "របាយការណ៍អធិការកិច្ចបង្កលក្ខណៈងាយស្រួលដល់គ្រូបង្រៀនក្នុងការអាន″ បានទទួលការយល់ស្របតិច កម្រិត "ល្អ″ លើមធ្យមភាគពិន្ទុ 3.78 ដូចគ្នា។ លើសពីនេះ សូចនាករទី១ "លោកគ្រូ/អ្នកគ្រូបានដឹងពីខ្លឹមសារក្នុងរបាយការណ៍អធិការកិច្ច″ បានទទួលការយល់ស្របតិចជាងគេបំផុតកម្រិត "មធ្យម″ លើមធ្យមភាគ 3.16 ជាតម្លៃមួយបង្ហាញពីភាពអវិជ្ជមាន។

| ល.រ | បរិយាយ | ចំនួន | មធ្យម | លទ្ធផល | លំដាប់ |
|---|---|---|---|---|---|
| B. ការផ្តល់របាយការណ៍ | | | | | |
| ១ | លោកគ្រូ/អ្នកគ្រូបានដឹងពីខ្លឹមសារក្នុងរបាយការណ៍អធិការកិច្ច | 94 | 3.16 | មធ្យម | 8 |
| ២ | របាយការណ៍អធិការកិច្ច បានបំពេញការចំណុចខ្វះខាតរបស់គ្រូបង្រៀន ក្នុងអាជីពរបស់ពួកគាត់ | 94 | 3.78 | ល្អ | 6 |
| ៣ | របាយការណ៍អធិការកិច្ច បានបង្ហាញពីចំណុចដែលត្រូវកែលម្អលើការបង្រៀន និងរៀន | 94 | 3.95 | ល្អ | 4 |
| ៤ | របាយការណ៍អធិការកិច្ច បង្កលក្ខណៈងាយស្រួលដល់គ្រូបង្រៀនក្នុងការអាន | 94 | 3.78 | ល្អ | 6 |
| ៥ | គ្រូបង្រៀនយល់ស្របនឹងរបាយការណ៍អធិការកិច្ច | 94 | 3.93 | ល្អ | 5 |
| ៦ | គ្រូបង្រៀនប្រើប្រាស់របាយកាណ៍អធិការកិច្ច សម្រាប់កែលម្អការបង្រៀន និងរៀន | 94 | 3.96 | ល្អ | 3 |
| ៧ | លោកគ្រូ/អ្នកគ្រូទាំងអស់យល់ឃើញថាសកម្មភាពនៃការចុះអធិការកិច្ចមានប្រយោជន៍ដល់ការបង្រៀន និងរៀនរបស់ខ្លួន | 94 | 4.43 | ល្អ | 1 |

| | | | | | |
|---|---|---|---|---|---|
| ៨ | ការវាយតម្លៃរបស់អធិការកិច្ចលើការបង្រៀនរបស់គ្រូ ផ្តោតលើបច្ចេកទេស មិនមែនប្រើអារម្មណ៍ផ្ទាល់ខ្លួន | 94 | 4.43 | ល្អ | 1 |
| សរុប | | | 3.92 | ល្អ | |

*តារាង 34៖ ឥរិយាបថគ្រូបង្រៀនចំពោះរបាយការណ៍អធិការកិច្ច ទទួលបានតាមរយៈកម្រងសំណួរគ្រូបង្រៀន*

សម្រាប់នាយក/នាយិកាវិញ ក៏ដូចគ្រូបង្រៀនដែរ បានយល់ស្របច្រើនចំពោះរបាយការណ៍អធិការកិច្ចលើការបង្រៀន និងរៀន។ ជាក់ស្តែង តាមរយៈតារាង 35 កម្រិតយល់ស្របរបស់នាយក/នាយិកាលើរបាយ-ការណ៍អធិការកិច្ចមានកម្រិត "ល្អណាស់" លើមធ្យមភាគពិន្ទុ 4.56។ នាយក/នាយិកា បានយល់ស្របច្រើនជាងគេលើសូចនាករទី៤ "របាយការណ៍អធិការកិច្ច បានបង្ហាញពីចំណុចដែលត្រូវកែលម្អលើការបង្រៀន និងរៀន" កម្រិត "ល្អណាស់" លើមធ្យមភាគពិន្ទុ 4.69។ ប៉ុន្តែនាយក/នាយិកាបានយល់ស្របតិចជាងគេលើសូចនាករទី២ "គ្រូបង្រៀនយកចិត្តទុកដាក់លើខ្លឹមសារក្នុងរបាយការណ៍អធិការកិច្ច" កម្រិត"ល្អ" លើមធ្យមភាគពិន្ទុ 4.38។

| ល.រ | **បរិយាយ** | **ចំនួន** | **មធ្យម** | **លទ្ធផល** | **លំដាប់** |
|---|---|---|---|---|---|
| | **B. ការផ្តល់របាយការណ៍** | | | | |
| ១ | នាយក/នាយិកាបានផ្សព្វផ្សាយអំពីលទ្ធផលក្នុងរបាយការណ៍អធិការកិច្ចទៅដល់គ្រូបង្រៀន | 13 | 4.54 | ល្អណាស់ | 4 |
| ២ | គ្រូបង្រៀន យកចិត្តទុកដាក់លើខ្លឹមសារក្នុងរបាយការណ៍អធិការកិច្ច | 13 | 4.38 | ល្អ | 8 |
| ៣ | គ្រូបង្រៀនចង់ដឹងពីខ្លឹមសារនៃរបាយការណ៍អធិការកិច្ច អំពីការបង្រៀន និងរៀនរបស់ខ្លួន | 13 | 4.54 | ល្អណាស់ | 4 |
| ៤ | របាយការណ៍អធិការកិច្ច បានបង្ហាញពីចំណុចដែលត្រូវកែលម្អ | 13 | 4.69 | ល្អណាស់ | 1 |

| | | | | | |
|---|---|---|---|---|---|
| | លើការបង្រៀន និងរៀន | | | | |
| ៥ | របាយការណ៍អធិការកិច្ច បង្កលក្ខណៈងាយស្រួលដល់គ្រូបង្រៀនក្នុងការអាន | 13 | 4.54 | ល្អណាស់ | 4 |
| ៦ | គ្រូបង្រៀនយល់ស្របនឹងរបាយការណ៍អធិការកិច្ច | 13 | 4.62 | ល្អណាស់ | 2 |
| ៧ | គ្រូបង្រៀនប្រើប្រាស់របាយកាណ៍អធិការកិច្ច សម្រាប់កែលម្អការបង្រៀន និងរៀន | 13 | 4.54 | ល្អណាស់ | 4 |
| ៨ | លោកគ្រូ/អ្នកគ្រូទាំងអស់យល់ឃើញថាសកម្មភាពនៃការចុះអធិការកិច្ចមានប្រយោជន៍ដល់ការបង្រៀន និងរៀនរបស់ខ្លួន | 13 | 4.62 | ល្អណាស់ | 2 |
| សរុប | | | 4.56 | ល្អណាស់ | |

***តារាង 35៖** ឥរិយាបថគ្រូបង្រៀនចំពោះរបាយការណ៍អធិការកិច្ច ទទួលបានតាមរយៈកម្រងសំណួរនាយក/នាយិកា*

ជារួមក្នុងផ្នែករងនេះ យើងអាចសន្និដ្ឋានបានថា គ្រូបង្រៀនបឋមសិក្សាមានឥរិយាបថវិជ្ជមានបន្តិចបន្តួចទៅលើរបាយការណ៍អធិការកិច្ច លើមធ្យមភាគពិន្ទុ 3.92 កម្រិត "ល្អ" ព្រោះគ្រូបង្រៀនយល់ថា របាយ-ការណ៍អធិការកិច្ច បានបង្ហាញពីចំណុចដែលត្រូវកែលម្អលើការបង្រៀន និងរៀន ដែលអាចឱ្យគាត់យកទៅប្រើប្រាស់ដើម្បីសម្រាប់កែលម្អការបង្រៀន និងរៀនទៅថ្ងៃខាងមុខ។ ទន្ទឹមនឹងភាពវិជ្ជមាន គ្រូបង្រៀនមួយចំនួននៅមិនទាន់ដឹងពីខ្លឹមសារក្នុងរបាយការណ៍អធិការកិច្ចលើការបង្រៀន និងរៀនបានល្អនៅឡើយ។ ជាក់ស្តែង នាយក/នាយិកាទាំង១៣សាលាបានយល់ស្របកម្រិតល្អណាស់ក្នុងផ្សព្វផ្សាយអំពីលទ្ធផលក្នុងរបាយការណ៍អធិការកិច្ចទៅដល់គ្រូបង្រៀនក្នុងមធ្យមភាគពិន្ទុ 4.54 ប៉ុន្តែគ្រូបង្រៀនភាគតិចប៉ុណ្ណោះបានដឹងពីខ្លឹមសាររបាយការណ៍អធិការកិច្ចលើការបង្រៀន និងរៀនមានមធ្យមភាគ 3.16 ជាមធ្យមភាគទាបខ្លាំងកម្រិត "មធ្យម"។ លទ្ធផលនេះបង្ហាញថាគ្រូបង្រៀនភាគច្រើនមិនបានយកចិត្តទុកដាក់ចំពោះរបាយការណ៍អធិការកិច្ចទេ ព្រោះគ្រូបង្រៀនភាគច្រើនមិនបានដឹងពីខ្លឹមសារដែលមានក្នុងរបាយការណ៍ ដូចនេះការប្រើ

ប្រាស់របាយកាណ៍អធិការកិច្ច សម្រាប់កែលម្អការបង្រៀន និងរៀនក៏មិនមានដែរ។

បើផ្អែកលើចម្លើយរបស់គ្រូបង្រៀន លើសំណួរទី៧៥ "ជារួម តើលោកគ្រូ អ្នកគ្រូយល់ថាអនុសាសន៍ និងរបាយការណ៍អធិការកិច្ចលើការបង្រៀននិងរៀនមានសារៈសំខាន់ឬទេ? ព្រោះអ្វី? " ឃើញថា គ្រូបង្រៀនស្ទើរទាំងអស់ដែលបានចូលរួមបំពេញកម្រងសំណួរបានយល់ថាទាំងអនុសាសន៍ និងរបាយការណ៍អធិការកិច្ចពិតជាមានសារៈសំខាន់សម្រាប់ការបង្រៀនរបស់ខ្លួន ព្រោះអាចឱ្យគាត់ដឹងពីចំណុចខ្លាំង ចំណុចខ្សោយលើការបង្រៀន និងទទួលបានអនុសាសន៍សម្រាប់កែលម្អ ដើម្បីឱ្យការបង្រៀនកាន់តែមានប្រសិទ្ធភាព។ លើសពីនេះគ្រូបង្រៀនអាចផ្លាស់ប្តូរបទពិសោធន៍លើការបង្រៀនជាមួយក្រុមអធិការបានផងដែរ។ ជាក់ស្តែង គ្រូបង្រៀនទី៦៨ បានលើកឡើងថា "របាយការណ៍បានធ្វើឱ្យគ្រូបង្រៀនដឹងពីចំណុចខ្វះខាត ហើយត្រូវកែលម្អឱ្យការបង្រៀនមានភាពប្រសើរឡើង" និង "នាងខ្ញុំយល់ថាអនុសាសន៍ និងរបាយការណ៍អធិការកិច្ចលើការបង្រៀន និងរៀនសំខាន់ព្រោះអាចជួយឱ្យគ្រូបង្រៀនមានបទពិសោធល្អៗ"(គ្រូទី៥៧)។

| ល.រ | ផ្នែកទី៣៖ ឥរិយាបថរបស់គ្រូបង្រៀន ក្រោយពេលអធិការកិច្ចលើការបង្រៀន និងរៀន | មធ្យមភាគ | | |
|---|---|---|---|---|
| | | គ្រូបង្រៀន | នាយក/នាយិកា | សរុប |
| A | ការផ្តល់អនុសាសន៍ | 4.40 | 4.71 | 4.56 |
| B | ការផ្តល់របាយការណ៍ | 3.92 | 4.56 | 4.24 |
| **សរុប** | | 4.16 | 4.64 | 4.40 |

***តារាង 36៖*** *ឥរិយាបថរបស់គ្រូបង្រៀន ក្រោយពេលចុះអធិការកិច្ចលើការបង្រៀន និងរៀន*

សរុបមកក្នុងផ្នែកទី៣នេះ យើងអាចសន្និដ្ឋានបានថា ក្រោយពេលអធិការកិច្ចលើការបង្រៀន និងរៀន គ្រូបង្រៀនបឋមសិក្សាមានឥរិយាបថវិជ្ជមានចំពោះអនុសាសន៍ និងរបាយការណ៍អធិការកិច្ច។ គ្រូបង្រៀនភាគច្រើនយល់ថាអនុសាសន៍ និងរបាយការណ៍អធិការកិច្ចពិតជាមានសារៈសំខាន់សម្រាប់ការបង្រៀនរបស់ខ្លួន ព្រោះអាចឱ្យគាត់ដឹងពីចំណុចខ្លាំង ចំណុចខ្សោយលើការបង្រៀន និងទទួលបានអនុសាសន៍សម្រាប់កែ

លម្អ ដើម្បីឱ្យការបង្រៀនកាន់តែមានប្រសិទ្ធភាព។ ប៉ុន្តែក្នុងចំណោមគ្រូបង្រៀនទាំងអស់ គ្រូបង្រៀនភាគច្រើនយកចិត្តទុកដាក់ចំពោះអនុសាសន៍អធិការកិច្ចច្រើនជាងរបាយការណ៍អធិការកិច្ច ពីព្រោះគ្រូបង្រៀនភាគច្រើនទទួលយកអនុសាសន៍ភ្លាមៗបន្ទាប់ពីការធ្វើអធិការកិច្ចចប់ ហើយគ្រូបង្រៀនមានលទ្ធភាពក្នុងការបកស្រាយហេតុផលចំពោះមុខអធិការអំពីអ្វីដែលអធិការកិច្ចបានរកឃើញ។ ផ្ទុយទៅវិញលោកគ្រូ/អ្នកគ្រូមិនបានចាប់អារម្មណ៍ពីខ្លឹមសារក្នុងរបាយការណ៍ទេ។ លទ្ធផលទាំងនេះបង្ហាញថា គ្រូបង្រៀននឹងមិនកែប្រែការបង្រៀនរបស់ខ្លួនទៅតាមអនុសាសន៍ និងរបាយការណ៍អធិការកិច្ចនោះទេ។

| **ផ្នែក** | **ផ្នែករង** | **តម្លៃមធ្យម** $(N = 94)$ | **សរុប** |
|---|---|---|---|
| មុនពេលអធិការកិច្ច | ទំនាក់ទំនងរវាងគ្រូ និងអធិការ | 4.35 | 4.07 |
| | ការផ្តល់ព័ត៌មាន | 3.80 | |
| | ការគោរពពេលវេលា | 4.23 | |
| | ការត្រៀមលក្ខណៈរបស់គ្រូ | 3.89 | |
| អំឡុងពេលអធិការកិច្ច | ពេលសង្កេតថ្នាក់រៀន | 4.29 | 4.32 |
| | ការបង្រៀន និងរៀន | 4.29 | |
| | ការសម្ភាស | 4.38 | |
| ក្រោយពេលអធិការកិច្ច | ការផ្តល់អនុសាសន៍ | 4.40 | 4.16 |
| | របាយការណ៍អធិការកិច្ច | 3.92 | |
| **សរុប** | | 4.18 | |

***តារាង 37៖*** *តារាងសង្ខេបស្តីពីឥរិយាបថគ្រូបង្រៀន ចំពោះអធិការកិច្ចលើការបង្រៀន និងរៀន ទាំងបីដំណាក់កាល*

បើពិនិត្យលើទិន្នន័យដែលប្រមូលបានពីគ្រូបង្រៀន៩៤នាក់ ឃើញថាគ្រូបង្រៀនភាគច្រើនមានឥរិយាបថវិជ្ជមានចំពោះដំណើរការអធិការកិច្ចទាំងមូលលើការបង្រៀន និងរៀនមានមធ្យមភាគពិន្ទុ 4.18 តាមតារាង 37។ ក្នុងដំណាក់កាលទាំងបីនៃដំណើរការអធិការកិច្ចលើការបង្រៀន និងរៀន យើងសង្កេតឃើញថាគ្រូបង្រៀនមានការពេញចិត្តលើដំណាក់កាលទី២ "អំឡុងពេលអធិការកិច្ច" ទៅលើសកម្មភាពអធិការក្នុងពេលអធិការកិច្ចថ្នាក់រៀន និងពេលសម្ភាស ច្រើនជាងដំណាក់កាលទី១"មុនពេលអធិការកិច្ច" និងដំណាក់កាលទី២"ក្រោយពេលអធិការកិច្ច"។ លទ្ធផលនេះ មានន័យថាគ្រូបង្រៀនភាគច្រើន បានការចូលរួមសហការជាមួយក្រុមអធិការកិច្ច និងយកចិត្តទុកដាក់លើសកម្មភាពបង្រៀន និងរៀនតែក្នុងពេលក្រុមអធិការមានវត្តមាននៅក្នុងសាលារៀន ប៉ុន្តែក្នុងដំណាក់កាលទី១ "មុនពេលអធិការកិច្ច" និងដំណាក់កាលទី៣ "ក្រោយពេលអធិការកិច្ច" ឥរិយាបថវិជ្ជមានរបស់គ្រូបង្រៀនចំពោះអធិការកិច្ច មានកម្រិតទាបជាងមុន។ នៅមុនពេលអធិការកិច្ច គ្រូបង្រៀនមួយភាគច្រើន មានការព្រួយបារម្ភ និងខ្វល់ខ្វាយខ្លះៗចំពោះការចុះអធិការកិច្ចលើការបង្រៀនរបស់គាត់ ទោះបីជាគាត់បានត្រៀមលក្ខណៈបានច្រើនយ៉ាងណាក្តី។ ម្យ៉ាងទៀតគ្រូបង្រៀនមួយចំនួនមិនទាន់យល់ដឹងពីគោលបំណងនៃការចុះអធិការកិច្ចនៅឡើយ។ នៅក្រោយពេលអធិការកិច្ច គ្រូបង្រៀនភាគច្រើនមិនបានយកចិត្តទុកដាក់លើរបាយការណ៍អធិការកិច្ចដែលបានសរសេររៀបរាប់ពីចំណុចល្អ និងចំណុចត្រូវកែលម្អលើការបង្រៀន និងរៀនឡើយ។ ត្រង់ចំណុចនេះមានន័យថា គ្រូបង្រៀនមិនបានកែលម្អការបង្រៀនតាមអនុសាសន៍ និងរបាយការណ៍អធិការកិច្ចទេ ទោះបីជាគ្រូបង្រៀនទាំងនោះយល់ថាវាពិតជាមានសារៈសំខាន់សម្រាប់ការបង្រៀនរបស់ខ្លួន និងបានទទួលស្គាល់ការរកឃើញរបស់អធិការកិច្ចក្តី។

### ៤.១.២ ឥរិយាបថគ្រូបង្រៀនបឋមសិក្សា ចំពោះអធិការកិច្ច ផ្អែកលើទីតាំងសាលារៀន

ក្នុងចំណុច៤.១.២ យើងបានដឹងពីឥរិយាបថជារួមរបស់គ្រូបង្រៀនថ្នាក់បឋមសិក្សាចំពោះអធិការកិច្ចលើការបង្រៀន និងរៀន។ លើសពីនេះយើងបានដឹងថា ជាមធ្យមគ្រូបង្រៀនមានឥរិយាបថវិជ្ជមានចំពោះអធិការកិច្ច។ ក្នុងផ្នែកបន្តទៅទៀតនេះ អ្នកស្រាវជ្រាវនឹងបន្តប្រៀបធៀបឥរិយាបថគ្រូបង្រៀនបឋមសិក្សា ក្នុង

ករណីដែលគាត់បង្រៀននៅទីតាំងសាលារៀនផ្សេងៗគ្នា។ តំបន់សាលារៀនដែលយើងលើកមកបង្ហាញមានពីរគឺ សាលារៀនក្នុងតំបន់ជនបទ និងសាលារៀនក្នុងតំបន់ទីប្រជុំជន។ ក្នុងការស្រាវជ្រាវនេះ ផ្តោតលើកម្រងសំណួរដែលទទួលបានពីគ្រូបង្រៀន និងនាយក/នាយិកា ក្នុងនោះមានគ្រូបង្រៀនចំនួន៩៤នាក់ មកពីសាលារៀនតំបន់ជនបទ៤៤នាក់ និងគ្រូបង្រៀនមកពីសាលាតំបន់ទីប្រជុំជនមាន៥០នាក់ និងនាយក/នាយិកាចំនួន ១៣នាក់ក្នុងនោះនាយក/នាយិកានៅសាលារៀនតំបន់ជនបទ មានចំនួន៨នាក់ និង៥នាក់ទៀតនៅតំបន់ទីប្រជុំជន។

| ប្រភេទសាលារៀន | លេខរៀងគ្រូបង្រៀនដែលបំពេញកម្រងសំណួរ |
|---|---|
| តំបន់ជនបទ | ១,២,៣,៤,៥,៦,៧,៨,៩,១០,១១,១២,១៣,១៤,១៥,១៦,១៧,១៨,១៩,២០,២១,២២,៣៣,៣៤,៣៥,៣៦,៣៧,៣៨,៣៩,៤០,៤១,៤២,៤៣,៤៤,៤៥,៤៦,៤៧,៤៨,៤៩,៥០,៥១,៥២,៥៣,៥៤ |
| តំបន់ទីប្រជុំជន | ២៣,២៤,២៥,២៦,២៧,២៨,២៩,៣០,៣១,៣២,៥៥,៥៦,៥៧,៥៨,៥៩,៦០,៦១,៦២,៦៣,៦៤,៦៥,៦៦,៦៧,៦៨,៦៩,៧០,៧១,៧២,៧៣,៧៤,៧៥,៧៦,៧៧,៧៨,៧៩,៨០,៨១,៨២,៨៣,៨៤,៨៥,៨៦,៨៧,៨៨,៨៩,៩០,៩១,៩២,៩៣,៩៤ |

| ប្រភេទសាលារៀន | លេខរៀងនាយក/នាយិកាដែលបំពេញកម្រងសំណួរ |
|---|---|
| តំបន់ជនបទ | ១,២,៣,៤,៦,៧,៨,៩ |
| តំបន់ទីប្រជុំជន | ៥,១០,១១,១២,១៣ |

### ៤.១.២.១ ឥរិយាបថគ្រូបង្រៀននៅតំបន់ជនបទ និងតំបន់ទីប្រជុំជន មុនពេលអធិការកិច្ច

#### A. ទំនាក់ទំនងរវាងគ្រូបង្រៀន និងអធិការកិច្ច

តាមតារាង៤.១៦a បានបង្ហាញថាគ្រូបង្រៀននៅជនបទ បានផ្តល់តម្លៃលើអធិការកិច្ច ដែលអាចយល់ពីអាជីពជាគ្រូបង្រៀនបានច្រើនជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជន។ ជាក់ស្តែងសូចនាករទី១ "ក្រុមអធិការបានយល់ច្បាស់ពីតម្រូវការរបស់គ្រូបង្រៀន" តម្លៃមធ្យមនៃការយល់ស្របរបស់គ្រូបង្រៀនជនបទស្មើនឹង 4.11 ហើយតម្លៃមធ្យមនៃការយល់ស្របរបស់គ្រូបង្រៀនទីប្រជុំជន 4.00។ ផ្ទុយទៅវិញគ្រូបង្រៀននៅទីប្រជុំជនយល់ថាអធិការជាអ្នកអប់រំ និងមានអាកប្បកិរិយាជាគំរូច្រើនជាងគ្រូបង្រៀននៅទីជនបទ ជាក់ស្តែងសូចនាករទី២ "ក្រុមអធិការមានអាកប្បកិរិយាសំដែងចេញភាពជាគំរូ និងជាអ្នកអប់រំ" តម្លៃមធ្យមនៃការយល់ស្របរបស់គ្រូបង្រៀនទីប្រជុំជន ស្មើនឹង 4.40 ខ្ពស់ជាងតម្លៃមធ្យមនៃការយល់ស្របរបស់គ្រូបង្រៀននៅតំបន់ជនបទ 4.39។

បើនិយាយពីការប្រាស្រ័យទាក់ទងគ្នា រវាងគ្រូបង្រៀន និងក្រុមអធិការ ក្នុងតារាង 38 បានបង្ហាញថាគ្រូបង្រៀននៅតំបន់ជនបទបានបង្ហាញពីភាពស្និទ្ធស្នាលចំពោះក្រុមអធិការជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជន ដូចក្នុងសូចនាករទី៣ "ក្រុមអធិការបានសម្តែងអាកប្បកិរិយាស្និទ្ធស្នាលជាមួយ លោកគ្រូ/អ្នកគ្រូដោយគ្មានការរើសអើង" តម្លៃមធ្យមនៃការយល់ស្របរបស់គ្រូបង្រៀនជនបទស្មើនឹង 4.59 ហើយតម្លៃមធ្យមនៃការយល់ស្របរបស់គ្រូបង្រៀនទីប្រជុំជនស្មើនឹង4.40។ ជាងនេះទៅទៀត គ្រូបង្រៀននៅតំបន់ជនបទបានគិតថាការងារអធិការកិច្ចលើការបង្រៀន និងរៀនជាការងារមួយដែលអាចផ្តល់ផលប្រយោជន៍ដល់ការបង្រៀនរបស់គាត់ ច្រើនជាងការគិតរបស់គ្រូបង្រៀននៅតំបន់ទីប្រជុំជន ជាក់ស្តែងសូចនាករទី៤ "ការចុះអធិការកិច្ចបានផ្តល់អត្ថប្រយោជន៍ដល់ការបង្រៀន និងរៀនជាច្រើនគឺជួយជំរុញឱ្យការបង្រៀននិងរៀនឱ្យកាន់តែមានប្រសិទ្ធភាព" តម្លៃមធ្យមនៃការយល់ស្របរបស់គ្រូបង្រៀនជនបទស្មើនឹង 4.55 ហើយគ្រូបង្រៀននៅទីប្រជុំជនមានការយល់ស្របមានតម្លៃមធ្យម 4.46។ ដូចគ្នាដែរក្នុងផ្នត់គំនិតគ្រូបង្រៀននៅតាមទីជនបទ យល់ថាអធិការគឺអ្នក

មានចំណេះដឹង និងបទពិសោធន៍គ្រប់គ្រាន់ ចំពោះការបង្រៀន និងរៀន។ ក្នុងសូចនាករទី៥ នៃតារាង 38 ″គ្រូបង្រៀន យល់ថាអធិការមានចំណេះដឹង និងបទពិសោធន៍គ្រប់គ្រាន់លើការបង្រៀន និងរៀន″ តម្លៃមធ្យមនៃការយល់ស្របរបស់គ្រូបង្រៀនជនបទស្មើនឹង 4.36 ហើយតម្លៃមធ្យមនៃការយល់ស្របរបស់គ្រូបង្រៀនទីប្រជុំជន 4.28។

| ល.រ | បរិយាយ | តម្លៃមធ្យម | | |
|---|---|---|---|---|
| | **A. ទំនាក់ទំនងរវាងគ្រូបង្រៀន និងអធិការកិច្ច** | **ជនបទ** $(N = 44)$ | **ទីប្រជុំជន** $(N = 50)$ | **គម្លាត** |
| ១ | ក្រុមអធិការបានយល់ច្បាស់ពីតម្រូវការរបស់គ្រូបង្រៀន | 4.11 | 4.00 | 0.11 |
| ២ | ក្រុមអធិការមានអាកប្បកិរិយាសំដែងចេញភាពជាគំរូ និងជាអ្នកអប់រំ | 4.39 | 4.40 | 0.01 |
| ៣ | ក្រុមអធិការបានសម្តែងអាកប្បកិរិយាស្និទ្ធស្នាលជាមួយលោកគ្រូ/អ្នកគ្រូដោយគ្មានការរើសអើង | 4.59 | 4.40 | 0.19 |
| ៤ | ការចុះអធិការកិច្ចបានផ្តល់អត្ថប្រយោជន៍ដល់ការបង្រៀននិងរៀនជាច្រើនគឺជួយជំរុញឱ្យការបង្រៀននិងរៀនឱ្យកាន់តែមានប្រសិទ្ធភាព | 4.55 | 4.46 | 0.09 |
| ៥ | គ្រូបង្រៀន យល់ថាអធិការមានចំណេះដឹង និងបទពិសោធន៍គ្រប់គ្រាន់លើការបង្រៀន និងរៀន | 4.36 | 4.28 | 0.08 |
| សរុប | | 4.40 | 4.31 | 0.09 |

***តារាង 38៖*** *តរិយាបថគ្រូបង្រៀនតំបន់ជនបទ និងប្រជុំជន លើទំនាក់ទំនងរវាងគ្រូបង្រៀន និងក្រុមអធិការកិច្ច*

ចំពោះនាយក/នាយិកានៅតាមសាលារៀនវិញបានយល់ឃើញថាទំនាក់ទំនងរវាងគ្រូបង្រៀន និងក្រុមអធិការមានកម្រិតល្អប្រហាក់ប្រហែលគ្នាទាំងគ្រូនៅសាលានៅតំបន់ជនបទ និងសាលានៅតំបន់ទីប្រជុំជន។ ប៉ុន្តែនៅតំបន់ទីប្រជុំជន នាយក/នាយិកាយល់ថាគ្រូបង្រៀននៅតំបន់របស់ខ្លួនបានបង្ហាញទំនាក់ទំនងល្អចំពោះអធិការកិច្ច និងបានឱ្យតម្លៃលើការចុះអធិការកិច្ច ដែលអាចផ្តល់អត្ថប្រយោជន៍ដល់ការបង្រៀន និងរៀនរបស់ខ្លួន ច្រើនជាងគ្រូនៅតំបន់ទីជនបទ។ ជាក់ស្តែងសូចនាករទី៤នៃតារាង 39 "គ្រូបង្រៀនយល់ថាការចុះអធិការកិច្ចបានផ្តល់អត្ថប្រយោជន៍ដល់ការបង្រៀន និងរៀនគឺជួយជំរុញឱ្យការបង្រៀននិងរៀនឱ្យកាន់តែមានប្រសិទ្ធភាព" នាយក/នាយិកានៅសាលារៀនទីប្រជុំជនបានយល់ស្របលើមធ្យមភាពពិន្ទុ 4.80 ខ្ពស់ជាងមធ្យមភាគយល់ស្របរបស់នាយក/នាយិកានៅតំបន់ទីជនបទដែលមានតម្លៃត្រឹមតែ 4.50។

| ល.រ | **ផ្នែកទី១ ៖ មុនពេលអធិការកិច្ច** | **តម្លៃមធ្យម** | | |
|---|---|---|---|---|
| | **A. ទំនាក់ទំនងរវាងគ្រូបង្រៀន និងអធិការកិច្ច** | **ជនបទ** $(N=8)$ | **ទីប្រជុំជន** $(N=5)$ | **គម្លាត** |
| ១ | គ្រូបង្រៀនបង្ហាញពីទំនាក់ទំនងល្អចំពោះអធិការកិច្ច លើការបង្រៀន និងរៀន | 4.25 | 4.40 | 0.15 |
| ២ | ក្រុមអធិការមានអាកប្បកិរិយាសំដែងចេញភាពជាគំរូ និងជាអ្នកអប់រំ | 4.50 | 4.40 | 0.10 |
| ៣ | ក្រុមអធិការបានសម្តែងអាកប្បកិរិយាស្និទ្ធស្នាលជាមួយគ្រូបង្រៀនដោយគ្មានការរើសអើង | 4.50 | 4.40 | 0.10 |
| ៤ | គ្រូបង្រៀនយល់ថា ការចុះអធិការកិច្ចបានផ្តល់អត្ថប្រយោជន៍ដល់ការបង្រៀន និងរៀនគឺជួយជំរុញឱ្យការបង្រៀន និងរៀនឱ្យកាន់តែមានប្រសិទ្ធភាព | 4.50 | 4.80 | 0.30 |

| | | | | |
|---|---|---|---|---|
| ៥ | គ្រូបង្រៀន យល់ថាអធិការមានចំណេះដឹង និងបទពិសោធន៍គ្រប់គ្រាន់លើការបង្រៀន និងរៀន | 4.38 | 4.40 | 0.02 |
| សរុប | | 4.43 | 4.48 | 0.05 |

*តារាង 39៖ ឥរិយាបថគ្រូបង្រៀនតំបន់ជនបទ និងប្រជុំជនចំពោះទំនាក់ទំនងរវាងគ្រូបង្រៀន និងក្រុមអធិការកិច្ច តាមរយៈកម្រងសំណួរនាយក/នាយិកា*

ជារួមមក មុនពេលមានអធិការកិច្ចគ្រូបង្រៀននៅតំបន់ជនបទ បានបង្ហាញឥរិយាបថវិជ្ជមានចំពោះការប្រាស្រ័យទាក់ទងរបស់ក្រុមអធិការ ក៏ដូចជាការមើលឃើញអំពីរូបភាពល្អៗនៃអធិការកិច្ចលើការបង្រៀន និងរៀន ខ្ពស់ជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជន។ ប៉ុន្តែនាយក/នាយិកាបានមើលឃើញថាគ្រូបង្រៀននៅតំបន់ទីប្រជុំជនមានទំនាក់ទំនងល្អជាមួយក្រុមអធិការកិច្ច និងយល់ថាការងារអធិការកិច្ចផ្តល់ប្រយោជន៍ដល់ការបង្រៀននិងរៀន ខ្ពស់ជាងគ្រូបង្រៀននៅតំបន់ជនបទវិញ។

**B. ការផ្តល់ព័ត៌មាន**

សម្រាប់ការផ្តល់ព័ត៌មានរបស់ក្រុមអធិការកិច្ច ទៅដល់គ្រូបង្រៀនវិញ ក្នុងតារាង 40 បានបង្ហាញថាគ្រូបង្រៀននៅតំបន់ជនបទមានការយល់ស្របកម្រិត "ល្អ" ខ្ពស់ជាងការយល់ស្របរបស់គ្រូបង្រៀននៅតំបន់ទីប្រជុំជន។ ចំណុចនេះមានន័យថា គ្រូបង្រៀននៅតំបន់ជនបទបានដឹងជាមុនថានឹងមានការចុះអធិការកិច្ចលើការបង្រៀន និងរៀន ដឹងពីគោលបំណងនៃការធ្វើអធិការកិច្ចខ្ពស់ជាងគ្រូនៅតាមតំបន់ទីប្រជុំជន។ បើយើងពិនិត្យមើលលើសូចនាករទី១ "គ្រូបង្រៀនបានដឹងព័ត៌មានពីការចុះអធិការកិច្ចថ្នាក់រៀន" បានបញ្ជាក់ថាគ្រូបង្រៀននៅតំបន់ជនបទបានយល់ស្របកម្រិត "ល្អ" លើមធ្យមភាគពិន្ទុ 3.84 ខ្ពស់ជាងពិន្ទុមធ្យមរបស់គ្រូបង្រៀននៅតាមទីប្រជុំជនមានតម្លៃ 3.70។ លើសពីនេះគ្រូបង្រៀននៅតំបន់ជនបទមានបំណងចង់ដឹងពីព័ត៌មានច្បាស់លាស់អំពីការចុះអធិការកិច្ច ដូចជាពេលវេលា ថ្នាក់រៀនដែលត្រូវធ្វើអធិការកិច្ច និងមុខវិជ្ជាបង្រៀនខ្ពស់ជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជន ជាក់ស្តែងសូចនាករទី២ "គ្រូបង្រៀនចង់ដឹងពីព័ត៌មានអំពីការចុះអធិការកិច្ចថ្នាក់រៀនមុនពេលថ្ងៃចុះអធិការកិច្ច" បានបង្ហាញតម្លៃមធ្យមនៃការយល់ស្របរបស់គ្រូ

បង្រៀនជនបទស្មើនឹង 4.39 ហើយតម្លៃមធ្យមនៃការយល់ស្របរបស់គ្រូបង្រៀនទីប្រជុំជន 4.08។ លើសពីនេះ គ្រូបង្រៀននៅតំបន់ជនបទមានការយល់ដឹងពីគោលបំណងនៃការធ្វើអធិការកិច្ច លើការបង្រៀន និងរៀន ក៏ដូចជាអ្វីដែលក្រុមអធិការកិច្ចត្រូវពិនិត្យពេលចុះអធិការកិច្ច បានខ្ពស់ជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជនផងដែរ (តារាង 40)។

***តារាង 40៖*** *តវិយាបថគ្រូបង្រៀនជនបទ និងប្រជុំជន លើការផ្តល់ព័ត៌មានមុនពេលចុះអធិការកិច្ច*

| ល.រ | **បរិយាយ** | **តម្លៃមធ្យម** | | |
|---|---|---|---|---|
| | **B. ការផ្តល់ព័ត៌មាន** | **ជនបទ** $(N=44)$ | **ទីប្រជុំជន** $(N=50)$ | **គម្លាត** |
| ១ | គ្រូបង្រៀនបានដឹងព័ត៌មាន ពីការចុះអធិការកិច្ចថ្នាក់រៀន | 3.84 | 3.70 | 0.14 |
| ២ | គ្រូបង្រៀនចង់ដឹងពីព័ត៌មានអំពីការចុះអធិការកិច្ចថ្នាក់រៀន មុនពេលថ្ងៃចុះអធិការកិច្ច | 4.39 | 4.08 | 0.31 |
| ៣ | គ្រូបង្រៀនបានយល់ច្បាស់ពីគោលបំណងនៃការចុះអធិការកិច្ច លើការបង្រៀននិងរៀន | 4.05 | 3.78 | 0.27 |
| ៤ | គ្រូបង្រៀនបានដឹងពីកម្មវិធីនៃការចុះអធិការកិច្ចថ្នាក់រៀន | 3.64 | 3.20 | 0.44 |
| ៥ | លោកគ្រូ/អ្នកគ្រូ ដឹងពីអ្វីដែលអធិការកិច្ចត្រូវពិនិត្យនៅក្នុងថ្នាក់រៀន | 3.98 | 3.42 | 0.56 |
| សរុប | | 3.98 | 3.64 | 0.34 |

ចំពោះនាយក/នាយិកាវិញ បានយល់ឃើញថាគ្រូបង្រៀននៅតំបន់ទីប្រជុំជន បានទទួលព័ត៌មានបានច្រើនពីការចុះអធិការកិច្ច ជាងគ្រូនៅតំបន់ជនបទ ព្រោះនាយកទាំងអស់បានផ្តល់ដំណឹងទៅដល់គ្រូបង្រៀនពីការចុះអធិការកិច្ច។

| ល.រ | បរិយាយ | តម្លៃមធ្យម | | |
|---|---|---|---|---|
| | B. ការផ្តល់ព័ត៌មាន | ជនបទ $(N=8)$ | ទីប្រជុំជន $(N=5)$ | គម្លាត |
| ១ | នាយក/នាយិកាបានផ្តល់ព័ត៌មានពីការចុះអធិការកិច្ចថ្នាក់រៀនទៅដល់គ្រូបង្រៀន | 4.25 | 5.00 | 0.75 |
| ២ | គ្រូបង្រៀនបានយល់ច្បាស់ពីគោលបំណងនៃការចុះអធិការកិច្ចលើការបង្រៀននិងរៀន | 4.13 | 4.20 | 0.07 |
| ៣ | គ្រូបង្រៀន ដឹងពីអ្វីដែលអធិការត្រូវពិនិត្យនៅពេលបង្រៀននៅក្នុងថ្នាក់ | 4.00 | 4.00 | 0.00 |
| សរុប | | 4.13 | 4.40 | 0.27 |

***តារាង 41៖** តរិយាបថគ្រូបង្រៀន ចំពោះការផ្តល់ព័ត៌មានមុនពេលចុះអធិការកិច្ចតាមរយៈកម្រងសំណួរនាយក/នាយិកា*

សរុបមក ទោះបីនាយក/នាយិកាបានជូនដំណឹងពីការចុះអធិការកិច្ចទៅដល់គ្រូបង្រៀនក៏ដោយ ហើយបានយល់ស្របថា គ្រូបង្រៀននៅតំបន់ទីប្រជុំជនបានទទួលព័ត៌មានគ្រប់គ្រាន់ពីក្រុមអធិការកិច្ចល្អជាងគ្រូបង្រៀននៅតំបន់ជនបទក្តី ប៉ុន្តែតាមរយៈកម្រងសំណួរគ្រូបង្រៀនបានបង្ហាញថាគ្រូនៅតំបន់ជនបទ បានទទួលព័ត៌មានអំពីការចុះអធិការកិច្ចបានល្អជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជនទៅវិញ។ លទ្ធផលនេះកើតឡើងដោយសារសាលារៀននៅតំបន់ទីប្រជុំជនមានគ្រូបង្រៀនច្រើន និងជាសាលារៀនពីរវេន ដូចនេះគ្រូបង្រៀននៅតំបន់ប្រជុំជនមិនអាចដឹងព័ត៌មានបានច្បាស់លាស់ពីការចុះអធិការកិច្ចនោះទេ ទោះបីនាយក/នាយិកាបានផ្សព្វផ្សាយទៅដល់គ្រូក៏ដោយ។ ជាក់ស្តែងគ្រូបង្រៀននៅតំបន់ជនបទ ៣៨នាក់ ក្នុងចំណោម ៤៤នាក់បានសរសេរថាបានទទួលព័ត៌មានគ្រប់ជ្រុងជ្រោយ ជាក់ស្តែងគ្រូបង្រៀនទី១៣, ១៥ និងទី៤៤ បានលើកឡើងថា *គ្រូបង្រៀនបានទទួលព័ត៌មានគ្រប់គ្រាន់ពីការចុះអធិការកិច្ច ព្រោះក្រុមអធិការបានជូនដំណឹង*

*ជាមុន* និងគ្រូបង្រៀនទី៣០ បានសរសេរចម្លើយថា *គ្រូទទួលព័ត៌មានបានគ្រប់គ្រាន់ ព្រោះក្រុមអធិការបានណែនាំពីការចុះអធិការកិច្ច និងត្រួតពិនិត្យគ្រូបង្រៀន*។ ចំណែកនៅតំបន់ទីប្រជុំជនវិញ គ្រូបង្រៀន១៥នាក់បានឆ្លើយថា មិនបានដឹងព័ត៌មានពីការចុះអធិការកិច្ចទេ ព្រោះពេលខ្លះការចុះអធិការកិច្ចមិនបានផ្តល់ដំណឹងឱ្យដឹងមុន ហើយពេលអធិការមកដល់សាលា ក្រុមអធិការកិច្ចមិនប្រាប់ពីគោលបំណងមុនដល់គ្រូ ហើយគ្រូផ្ទាល់មិនដឹងថាអធិការចូលសង្កេតថ្នាក់រៀនណាមួយឱ្យប្រាកដ។

**C. ការគោរពពេលវេលា**

ចំពោះការគោរពពេលវេលារបស់ក្រុមអធិការកិច្ចវិញ តាមតារាង 42 បង្ហាញថាគ្រូបង្រៀននៅតំបន់ជនបទមានឥរិយាបថវិជ្ជមានខ្ពស់ជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជនលើមធ្យមភាគពិន្ទុ 4.41 កម្រិត ៉ល្អ៉ ធៀបនឹង 4.10។ គ្រូបង្រៀននៅតំបន់ជនបទបានយល់ស្របកម្រិត ៉ល្អណាស់៉ ថាក្រុមអធិការជាអ្នកគោរពពេលវេលាដែលបានកំណត់សម្រាប់ការចុះអធិការកិច្ចខ្ពស់ជាងគ្រូបង្រៀននៅទីប្រជុំជន។ ជាក់ស្តែងសូចនាករទី១ ៉ក្រុមអធិការកិច្ច បានគោរពពេលវេលាក្នុងការចុះអធិការកិច្ចបានត្រឹមត្រូវ៉ មធ្យមភាគពិន្ទុនៃកម្រិតយល់ស្របរបស់គ្រូនៅតំបន់ជនបទស្មើនឹង 3.91 និងមធ្យមភាគនៃកម្រិតយល់ស្របរបស់គ្រូនៅតំបន់ទីប្រជុំជនស្មើនឹង 3.70។ ក្នុងតារាង 42 គ្រូបង្រៀននៅទីប្រជុំជន បានដឹងពីពេលវេលានៃការចុះធ្វើអធិការកិច្ចនៃការបង្រៀន និងរៀនតិចតួចណាស់ បើធៀបនឹងពីអ្វីដែលគ្រូបង្រៀននៅតំបន់ជនបទបានដឹង ដូចបានបង្ហាញក្នុងសូចនាករទី២ ៉គ្រូបង្រៀនដឹងពីពេលវេលានៃការចុះអធិការកិច្ចថ្នាក់រៀន៉ មធ្យមភាគកម្រិតយល់ស្របរបស់គ្រូបង្រៀននៅតំបន់ទីប្រជុំជនស្មើនឹង 3.74 តូចជាងឆ្ងាយ មធ្យមភាគយល់ស្រប 4.25 របស់គ្រូបង្រៀននៅតំបន់ជនបទ។

| ល.រ | បរិយាយ | តម្លៃមធ្យម | | |
|---|---|---|---|---|
| | **C. ការគោរពពេលវេលា** | **ជនបទ** $(N = 44)$ | **ទីប្រជុំជន** $(N = 50)$ | **គម្លាត** |

| | | | | |
|---|---|---|---|---|
| ១ | ក្រុមអធិការកិច្ច បានគោរពពេលវេលាក្នុងការចុះអធិការកិច្ចបានត្រឹមត្រូវ | 4.64 | 4.38 | 0.26 |
| ២ | គ្រូបង្រៀនដឹងពីពេលវេលានៃការចុះអធិការកិច្ចថ្នាក់រៀន | 4.25 | 3.74 | 0.51 |
| ៣ | ក្រុមអធិការចុះសង្កេតថ្នាក់រៀនតាមកម្មវិធីអធិការកិច្ចដែលបានកំណត់ | 4.34 | 4.18 | 0.16 |
| **សរុប** | | 4.41 | 4.10 | 0.31 |

***តារាង 42៖** តវិយាបថគ្រូបង្រៀនតំបន់ជនបទ និងប្រជុំជន លើការគោរពពេលវេលារបស់ក្រុមអធិការកិច្ច*

ចំណែកឯនាយក/នាយិកាវិញ ក្នុងតារាង 43បានបង្ហាញគ្រូបង្រៀននៅតំបន់ជនបទ បានផ្តល់ការជឿជាក់លើការគោរពពេលវេលារបស់ក្រុមអធិការកិច្ចខ្ពស់ជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជន។ បើយើងពិនិត្យលើសូចនាករទី២ "គ្រូបង្រៀនដឹងពីពេលវេលានៃការចុះអធិការកិច្ចថ្នាក់រៀន" នាយក/នាយិកានៅសាលារៀនតំបន់ទីប្រជុំជនបានយល់ថាគ្រូបង្រៀននៅសាលាខ្លួនបានដឹងពីពេលវេលាច្បាស់លាស់នៃការចុះអធិការកិច្ចថ្នាក់រៀន ទាបជាងគ្រូបង្រៀននៅសាលារៀនតំបន់ជនបទ។

| **ល.រ** | **បរិយាយ** | **តម្លៃមធ្យម** | | |
|---|---|---|---|---|
| | **C. ការគោរពពេលវេលា** | **ជនបទ** $(N=8)$ | **ទីប្រជុំជន** $(N=5)$ | **គម្លាត** |
| ១ | ក្រុមអធិការកិច្ច បានគោរពពេលវេលាក្នុងការចុះអធិការកិច្ចបានត្រឹមត្រូវ | 4.63 | 4.60 | 0.03 |
| ២ | គ្រូបង្រៀនដឹងពីពេលវេលានៃការចុះអធិការកិច្ចថ្នាក់រៀន | 4.38 | 4.00 | 0.38 |
| ៣ | ក្រុមអធិការចុះសង្កេតថ្នាក់រៀនតាមកម្មវិធីអធិការកិច្ចដែលបានកំណត់ | 4.75 | 4.80 | 0.05 |

| | | | |
|---|---|---|---|
| សរុប | 4.58 | 4.47 | 0.11 |

***តារាង 43៖*** *ឥរិយាបថគ្រូបង្រៀនជនបទ និងប្រជុំជន លើការគោរពពេលវេលារបស់ក្រុមអធិការកិច្ច ទទួលបានពីកម្រង សំណួរនាយក/នាយិកា*

សរុបមកគ្រូបង្រៀនជនបទ មានការយល់ស្របទៅលើការគោរពពេលវេលារបស់ក្រុមអធិការកិច្ច ខ្ពស់ជាងគ្រូបង្រៀននៅទីប្រជុំជន។ ការយល់ស្របនេះ ស្របនឹងការយល់ឃើញដោយនាយក/នាយិកាសាលារៀនផងដែរ ដោយហេតុថាសាលារៀននៅតំបន់ជនបទភាគច្រើនជាសាលាតូច បើធៀបធៀបទៅនឹងសាលាតំបន់ទីប្រជុំជន ដូចនេះលោកគ្រូ/អ្នកគ្រូអាចដឹង ឬឃើញសកម្មភាពអធិការក្នុងសាលារៀនរបស់ខ្លួន ទោះបីជាអធិការមិនចូលសង្កេតប៉ះចំថ្នាក់ដែលគាត់កំពុងបង្រៀនក៏ដោយ។

**D. ការត្រៀមលក្ខណៈ**

ចំណុចបន្ទាប់នេះ យើងនឹងបកស្រាយពីការត្រៀមលក្ខណៈរបស់គ្រូបង្រៀន ចំពោះការចុះអធិការកិច្ចលើការបង្រៀនដោយផ្អែកលើប្រភេទសាលារៀនដដែល។ សម្រាប់ការចុះអធិការកិច្ច គ្រូបង្រៀននៅតំបន់ជនបទបានត្រៀមលក្ខណៈសម្រាប់បង្រៀនក្នុងពេលអធិការកិច្ចលើការបង្រៀន និងរៀន បានល្អជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជនដោយមធ្យមភាគពិន្ទុ 4.06 ធៀបនឹង 3.74។ ដូចបង្ហាញក្នុងតារាង 44 យើងឃើញថា គ្រូបង្រៀននៅជនបទភាគច្រើនមានអារម្មណ៍ធម្មតាចំពោះការចុះអធិការកិច្ចដោយគាត់មិនមានការភ័យខ្លាច ឬមានការមិនពេញចិត្តណាមួយឡើយ។ អារម្មណ៍បែបនេះ មានកម្រិតខ្ពស់ជាងគ្រូបង្រៀននៅទីប្រជុំជន។ ជាក់ស្តែងសូចនាករទី១ "គ្រូបង្រៀនតែងមានអារម្មណ៍ធម្មតាចំពោះការចុះធ្វើអធិការកិច្ច" កម្រិតយល់ស្របរបស់គ្រូបង្រៀននៅតំបន់ជនបទស្មើនឹង 3.91 ខ្ពស់ជាងកម្រិតយល់ស្របរបស់គ្រូបង្រៀននៅតំបន់ទីប្រជុំជនដែលមានតម្លៃមធ្យម 3.30។ លើសពីនេះការយល់ស្របរបស់គ្រូបង្រៀននៅតំបន់ជនបទ នៅតែមានកម្រិតខ្ពស់ជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជន លើការត្រៀមលក្ខណៈបានល្អនៅថ្ងៃអធិការកិច្ចលើមធ្យមភាគពិន្ទុ 4.27 ធៀបនឹង 3.98។ ត្រង់ផ្នែកនេះ អាចមកពីគ្រូបង្រៀននៅតំបន់ជនបទ បានទទួលព័ត៌មានបានល្អទាក់ទងនឹងការចុះអធិការកិច្ចជាងគ្រូតាមតំបន់ទីប្រជុំជន។ ម្យ៉ាងទៀតគ្រូនៅតំបន់ទីជនបទបានបង្ហាញ

អារម្មណ៍ស្វាគមន៍ ចំពោះការចុះធ្វើអធិការកិច្ចក្នុងថ្នាក់រៀនរបស់ខ្លួន ខ្ពស់ជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជនផងដែរ តួយ៉ាងសូចនាករទី៤ "គ្រូបង្រៀនចង់ឱ្យអធិការពិនិត្យមើលលើការបង្រៀន របស់ខ្លួន" កម្រិតយល់ស្របរបស់គ្រូបង្រៀនទាំងពីរតំបន់ មានតម្លៃមធ្យមរៀងគ្នា 4.32 និង 3.96។ ចំណុចនេះ បានបង្ហាញថា គ្រូបង្រៀននៅតំបន់ជនបទ បានត្រៀមលក្ខណៈបានល្អសម្រាប់ការចុះអធិការកិច្ច និងរីករាយទទួលការចុះអធិការកិច្ចលើការបង្រៀនរបស់ខ្លួន ល្អជាងគ្រូនៅតំបន់ទីប្រជុំជន។

| ល.រ | បរិយាយ | តម្លៃមធ្យម | | |
|---|---|---|---|---|
| | D. ការត្រៀមលក្ខណៈ | ជនបទ $(N=44)$ | ទីប្រជុំជន $(N=50)$ | គម្លាត |
| ១ | គ្រូបង្រៀនតែងមានអារម្មណ៍ធម្មតាចំពោះការចុះធ្វើអធិការកិច្ច | 3.91 | 3.70 | 0.21 |
| ២ | គ្រូបង្រៀនមិនមានការព្រួយបារម្ភ ខ្វល់ខ្វាយនៅពេលមានការចុះអធិការកិច្ចថ្នាក់រៀនទេ | 3.73 | 3.30 | 0.43 |
| ៣ | គ្រូបង្រៀន ត្រៀមលក្ខណៈបានល្អ នៅថ្ងៃធ្វើអធិការកិច្ច | 4.27 | 3.98 | 0.29 |
| ៤ | គ្រូបង្រៀន ចង់ឱ្យអធិការ ពិនិត្យមើលលើការបង្រៀន របស់ខ្លួន | 4.32 | 3.96 | 0.36 |
| សរុប | | 4.06 | 3.74 | 0.32 |

***តារាង 44៖** តរិយាបថគ្រូបង្រៀនតំបន់ជនបទ និងប្រជុំជន ចំពោះការត្រៀមលក្ខណៈសម្រាប់ការចុះអធិការកិច្ច*

ចំពោះនាយក/នាយិកានៅតាមសាលារៀនប្រភេទផ្សេងគ្នា បានយល់ឃើញថា គ្រូបង្រៀននៅតាមសាលារៀនជនបទ បានត្រៀមលក្ខណៈជារួម ល្អជាងគ្រូបង្រៀននៅតាមទីប្រជុំជនលើមធ្យមភាពពិន្ទុ 4.25 និង 3.95។ លើសូចនាករទី២, ៣ និងទី៤ ក្នុងតារាង 45 នាយក/នាយិកាបានយល់ស្របថា គ្រូបង្រៀននៅតំបន់ទីប្រជុំជនមានការព្រួយបារម្ភ ឬខ្វល់ខ្វាយនៅពេលមានការចុះអធិការកិច្ច និងហាក់ដូចជាមិនចង់

ឱ្យអធិការ ពិនិត្យមើលលើការបង្រៀន របស់គាត់នោះទេ ទោះជាគាត់បានត្រៀមលក្ខណៈសម្រាប់ការបង្រៀន នៅថ្ងៃធ្វើអធិការកិច្ចរួចរាល់ក្តី។

| ល.រ | បរិយាយ | តម្លៃមធ្យម | | |
|---|---|---|---|---|
| | D. ការត្រៀមលក្ខណៈរបស់គ្រូ | ជនបទ $(N=8)$ | ទីប្រជុំជន $(N=5)$ | គម្លាត |
| ១ | គ្រូបង្រៀនតែងមានអារម្មណ៍ធម្មតាចំពោះការចុះធ្វើអធិការកិច្ច | 4.00 | 3.80 | 0.20 |
| ២ | គ្រូបង្រៀនមិនមានការព្រួយបារម្ភ ឬខ្វល់ខ្វាយ នៅពេលមានការចុះអធិការកិច្ចថ្នាក់រៀនទេ | 4.13 | 3.40 | 0.73 |
| ៣ | គ្រូបង្រៀនត្រៀមលក្ខណៈបានល្អ នៅថ្ងៃធ្វើអធិការកិច្ច | 4.13 | 4.40 | 0.27 |
| ៤ | គ្រូបង្រៀនចង់ឱ្យអធិការពិនិត្យមើលលើការបង្រៀនរបស់គាត់ | 4.75 | 4.20 | 0.55 |
| សរុប | | 4.25 | 3.95 | 0.70 |

***តារាង 45៖*** *ឥរិយាបថគ្រូបង្រៀននៅតំបន់ជនបទ និងប្រជុំជន ចំពោះការត្រៀមលក្ខណៈសម្រាប់ការចុះអធិការកិច្ច ទទួលបានពីកម្រងសំណួរនាយក/នាយិកា*

សរុបមក គ្រូបង្រៀននៅតំបន់ជនបទបានបង្ហាញពីសកម្មភាពវិជ្ជមានចំពោះអធិការកិច្ចល្អជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជន ទៅលើការត្រៀមលក្ខណៈមួយចំនួនសម្រាប់ការចុះសង្កេតថ្នាក់រៀន ដូចជា ត្រៀមកិច្ចតែងការ សៀវភៅរដ្ឋបាល សម្ភារឧបទេស ការរៀបចំអនាម័យថ្នាក់រៀន ការគ្រប់គ្រងសិស្សជាដើម។ បើយោងតាមចម្លើយរបស់លោកគ្រូ/អ្នកគ្រូ និងនាយក/នាយិកាឃើញថាគ្រូបង្រៀននៅតាមតំបន់ទីប្រជុំជនមានការព្រួយបារម្ភច្រើនជាងគ្រូបង្រៀននៅតាមសាលាតំបន់ជនបទមុនពេលការចុះអធិការកិច្ច។ ផ្ទុយទៅវិញ នាយក/នាយិកា បែរជាយល់ថាគ្រូបង្រៀននៅតំបន់ទីប្រជុំជនបានត្រៀមលក្ខណៈបានល្អនៅថ្ងៃអធិការកិច្ចច្រើនជាងគ្រូបង្រៀននៅតំបន់ជនបទ ព្រោះគាត់បានបញ្ជូនដំណឹងអំពីការចុះអធិការកិច្ច ១០០% ទៅដល់គ្រូបង្រៀន( តារាង 41 )។ ដូចនេះនាយក/នាយិកា យល់ថាគ្រូបង្រៀនបានត្រៀមលក្ខណៈជាមុនរួចរាល់ ប៉ុន្តែ

ចំពោះលោកគ្រូ/អ្នកគ្រូផ្ទាល់ មិនបានយល់ឃើញបែបនេះទេ។

លទ្ធផលជារួម ដូចបង្ហាញក្នុងតារាង 46 អាចឱ្យយើងដឹងថាទាំងគ្រូបង្រៀននៅសាលារៀនតំបន់ជនបទ និងសាលារៀនតំបន់ទីប្រជុំជនសុទ្ធតែមានឥរិយាបថវិជ្ជមានដូចគ្នា ទៅលើរូបភាពនៃសកម្មភាពរបស់អធិការមុនពេលអធិការកិច្ច ប៉ុន្តែគ្រូបង្រៀននៅតំបន់ជនបទ មានការយល់ស្របខ្ពស់ជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជន។ បើយើងពិនិត្យលើផ្នែករងនីមួយៗ យើងឃើញថាគ្រប់ផ្នែករងទាំងអស់គឺគ្រូបង្រៀននៅតំបន់ជនបទតែតែងមានការយល់ស្របក្នុងមធ្យមភាគខ្ពស់ជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជនជានិច្ច ទាំងការប្រាស្រ័យទាក់ទងជាមួយក្រុមអធិការកិច្ច ការទទួលបានព័ត៌មានអំពីអធិការកិច្ច ការយល់ពីគោលបំណងនៃការធ្វើអធិការកិច្ចលើការបង្រៀន និងរៀន ការដឹងពីពេលវេលានៃអធិការកិច្ច ជាពិសេសបានត្រៀមលក្ខណៈសម្រាប់ការបង្រៀនបានល្អក្នុងពេលអធិការកិច្ច និងរីករាយស្វាគមន៍ចំពោះការចុះសង្កេតការបង្រៀនរបស់ក្រុមអធិការ។

| **បរិយាយ** | | **តម្លៃមធ្យម** | | |
|---|---|---|---|---|
| **ផ្នែកទី១** | **មុនពេលអធិការកិច្ច** | **តំបន់ជនបទ** $(N = 44)$ | **តំបន់ទីប្រជុំជន** $(N = 50)$ | **គម្លាត** |
| A | ទំនាក់ទំនងរវាងគ្រូបង្រៀន និងក្រុមអធិការកិច្ច | 4.40 | 4.31 | 0.09 |
| B | ការទទួលព័ត៌មានអំពីការចុះអធិការកិច្ចថ្នាក់រៀន | 3.98 | 3.64 | 0.34 |
| C | ការគោរពពេលវេលារបស់ក្រុមអធិការកិច្ច | 4.41 | 4.10 | 0.31 |
| D | ការត្រៀមលក្ខណៈរបស់គ្រូបង្រៀន | 4.06 | 3.74 | 0.32 |
| សរុប | | 4.21 | 3.94 | 0.27 |

***តារាង 46៖*** *ឥរិយាបថគ្រូបង្រៀនតំបន់ជនបទ និងតំបន់ប្រជុំជន មុនពេលអធិការកិច្ចលើការបង្រៀន និងរៀន*

### ៤.១.២.២ឥរិយាបថគ្រូបង្រៀននៅតំបន់ជនបទ និងតំបន់ទីប្រជុំជន អំឡុងពេលអធិការកិច្ច

ដូចបានបង្ហាញរួចម្តងហើយនៅចំណុច ៤.២.២ អំពីឥរិយាបថគ្រូបង្រៀន អំឡុងពេលអធិការកិច្ចលើការបង្រៀន និងរៀន គឺលោកគ្រូ/អ្នកគ្រូនៅតាមសាលាបឋមសិក្សាមានឥរិយាបថវិជ្ជមានចំពោះសកម្មភាព និងដំណើរការការងារអធិការកិច្ចទៅលើការបង្រៀន និងរៀនរបស់ពួកគាត់លើកម្រិតយល់ស្រប "ល្អ" លើមធ្យមភាគ 4.32។ ដូចគ្នាដែរសកម្មភាពមួយចំនួនរបស់អធិការកិច្ចរួមមាន ការសង្កេតថ្នាក់រៀន ការសង្កេតលើការបង្រៀនរបស់គ្រូបង្រៀន ការសម្ភាសគ្រូអំពីការបង្រៀន និងរៀន សុទ្ធតែទទួលបានការយល់ស្របកម្រិត "ល្អ" ពីសំណាក់គ្រូបង្រៀនផងដែរ។

**A. ការសង្កេតថ្នាក់រៀន**

ផ្នែកនេះ យើងនឹងបន្តបកស្រាយនូវសំណួរស្រាវជ្រាវទី២ តើឥរិយាបថរបស់គ្រូបង្រៀនបឋមសិក្សាក្នុងអំឡុងពេលអធិការកិច្ចលើការបង្រៀន និងរៀនមានភាពខុសគ្នាឬទេដោយផ្អែកលើទីតាំងសាលារៀន?

តាមតារាង 47 (សូចនាករទី១ និង២) បានបង្ហាញថាគ្រូបង្រៀននៅតំបន់ជនបទ មានការយល់ស្របខ្ពស់ជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជនទៅលើការយល់ឃើញថា អធិការបានយកចិត្តទុកដាក់ទៅបរិបទសាលារៀន និងស្ថានភាពថ្នាក់រៀននីមួយៗពេលចុះសង្កេតថ្នាក់ និងការយកចិត្តទុកដាក់របស់អធិការចំពោះគ្រប់សកម្មភាពក្នុងថ្នាក់រៀនពេលអ្នកគ្រូ/អ្នកគ្រូបង្រៀន។ ខុសប្លែកពីខាងលើបន្តិច គ្រូបង្រៀននៅតំបន់ទីប្រជុំជនបានយល់ស្របខ្ពស់ជាងគ្រូបង្រៀននៅតំបន់ជនបទវិញ ទៅលើការប្រើប្រាស់ឧបករណ៍អធិការកិច្ចប្រកបដោយប្រសិទ្ធភាព។ ជាក់ស្តែងសូចនាករទី៣ "អធិការប្រើប្រាស់ឧបករណ៍គ្រប់គ្រាន់ និងមានប្រសិទ្ធភាពក្នុងពេលធ្វើអធិការកិច្ចលើការបង្រៀនរបស់គ្រូ" មធ្យមភាគយល់ស្របរបស់គ្រូបង្រៀនតំបន់ទីប្រជុំជនគឺ 4.16 លើ 4.11 នៃមធ្យមភាគរបស់គ្រូបង្រៀនតំបន់ជនបទ។ ម្យ៉ាងទៀត គ្រូនៅតំបន់ទីប្រជុំជនបានយល់ស្របខ្ពស់ជាងគ្រូនៅតំបន់ជនបទផងដែរទៅលើ "ការអធិការកិច្ចថ្នាក់រៀនបានពិនិត្យមើលចំណុចល្អច្រើនជាងចំណុចមិនល្អរបស់គ្រូ"។ ផ្ទុយទៅវិញ គ្រូបង្រៀននៅតំបន់ជនបទបានបង្ហាញពីឥរិយាបថវិជ្ជមានផងដែរចំពោះ

សកម្មភាពអធិការពេលសង្កេតការបង្រៀន ជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជន ដូចជាក្រុមអធិការមិនបានរំខានដល់ការបង្រៀន ឬបង្កបរិយាកាសស្អុតស្អាញដល់គ្រូក្នុងការបង្រៀន និងរៀនឡើយ(តារាង 47)។ ជារួមអំឡុងពេលអធិការចុះសង្កេតថ្នាក់រៀន គ្រូបង្រៀនតំបន់ជនបទមានការយល់ស្របល្អចំពោះសកម្មភាពអធិការកិច្ចខ្ពស់ជាងការយល់ស្របរបស់គ្រូបង្រៀននៅតំបន់ទីប្រជុំជន លើមធ្យមភាពពិន្ទុ 4.33 ធៀបនឹង 4.24។

| ល.រ | ផ្នែកទី២៖ អំឡុងពេលអធិការកិច្ច | តម្លៃមធ្យម | | |
|---|---|---|---|---|
| | A. ការសង្កេតថ្នាក់រៀន | ជនបទ $(N=44)$ | ទីប្រជុំជន $(N=50)$ | គម្លាត |
| ១ | អធិការបានផ្តោតខ្លាំងទៅលើបរិបទ ឬស្ថានភាពរបស់ថ្នាក់រៀននីមួយៗ | 4.27 | 3.96 | 0.31 |
| ២ | អធិការបានយកចិត្តទុកដាក់គ្រប់សកម្មភាពទាំងអស់នៅក្នុងថ្នាក់រៀន ពេលលោកគ្រូ/អ្នកគ្រូបង្រៀន | 4.55 | 4.48 | 0.07 |
| ៣ | អធិការប្រើប្រាស់ឧបករណ៍គ្រប់គ្រាន់ និងមានប្រសិទ្ធភាព ក្នុងពេលធ្វើអធិការកិច្ចលើការបង្រៀនរបស់គ្រូ | 4.11 | 4.16 | 0.05 |
| ៤ | អធិការកិច្ចពិនិត្យមើលចំណុចល្អ ច្រើនជាងចំណុចដែលត្រូវកែលម្អលើ ការបង្រៀន និងរៀន | 3.73 | 3.88 | 0.15 |
| ៥ | ក្រុមអធិការមិនបានរំខានដល់ការបង្រៀនរបស់គ្រូបង្រៀនឡើយ | 4.57 | 4.38 | 0.19 |
| ៦ | ក្រុមអធិការមិនប្រើភាសាគំរោះគំរើយ ឬចំអក និងមិនឡូឡានៅក្នុងថ្នាក់រៀន ឬបង្ហាញទឹកមុខដែលធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍សិស្ស និងគ្រូបង្រៀនឡើយ | 4.59 | 4.60 | 0.01 |
| ៧ | ការចុះធ្វើអធិការកិច្ច មិនបង្កបរិយាកាសស្អុតស្អាញដល់គ្រូក្នុង | 4.52 | 4.24 | 0.28 |

| | | | | |
|---|---|---|---|---|
| | ការបង្រៀន និងរៀនឡើយ | | | |
| សរុប | | 4.33 | 4.24 | 0.09 |

*តារាង 47៖ ឥរិយាបថគ្រូបង្រៀនតំបន់ជនបទ និងតំបន់ប្រជុំជនចំពោះការសង្កេតថ្នាក់រៀនរបស់អធិការកិច្ច*

ចំពោះនាយក/នាយិកា បានយល់ស្របស្រដៀងនឹងគ្រូបង្រៀនដែរទៅលើភាពរួមនៃឥរិយាបថគ្រូបង្រៀននៅពេលអធិការកិច្ចចុះសង្កេតថ្នាក់រៀន គឺថាគ្រូបង្រៀននៅតំបន់ជនបទបានបង្ហាញការពេញចិត្តចំពោះអធិការនៅពេលសង្កេតថ្នាក់រៀនខ្ពស់ជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជន។ នៅសូចនាករទី៣ "អធិការកិច្ចពិនិត្យមើលចំណុចល្អ ច្រើនជាងចំណុចដែលត្រូវកែលម្អលើការបង្រៀន និងរៀន" នាយក/នាយិកាបានយល់ស្របថា គ្រូបង្រៀននៅតំបន់ជនបទបានគិតថាអធិការផ្តោតលើចំណុចល្អច្រើនជាងចំណុចខ្សោយរបស់គ្រូខ្ពស់ជាងគ្រូបង្រៀននៅតាមតំបន់ប្រជុំជន ប៉ុន្តែមានមធ្យមភាគទាបជាងគេក្នុងចំណោមសូចនាករទាំងអស់។ មានន័យថានាយក/នាយិកាបានយល់ថា គ្រូបង្រៀននៅគិតថាអធិការកិច្ចបានពិនិត្យមើលចំណុចដែលត្រូវកែលម្អរបស់ខ្លួន ច្រើនជាងចំណុចល្អ។

| ល.រ | **ផ្នែកទី២ ៖ អំឡុងពេលអធិការកិច្ច** | **តម្លៃមធ្យម** | | |
|---|---|---|---|---|
| | **A. ការសង្កេតថ្នាក់រៀន** | **ជនបទ** $(N = 8)$ | **ទីប្រជុំជន** $(N = 5)$ | **គម្លាត** |
| ១ | អធិការកិច្ច បានធ្វើការសង្កេតថ្នាក់រៀនភាគច្រើនក្នុងសាលា | 4.13 | 4.20 | 0.07 |
| ២ | អធិការបានយកចិត្តទុកដាក់គ្រប់សកម្មភាពទាំងអស់នៅក្នុងថ្នាក់រៀន ពេលលោកគ្រូ/អ្នកគ្រូបង្រៀន | 4.50 | 4.80 | 0.30 |
| ៣ | អធិការកិច្ចពិនិត្យមើលចំណុចល្អ ច្រើនជាងចំណុចដែលត្រូវកែលម្អលើការបង្រៀន និងរៀន | 3.88 | 3.60 | 0.28 |
| ៤ | ក្រុមអធិការមិនបានរំខានដល់ការបង្រៀនរបស់គ្រូបង្រៀន | 4.88 | 4.20 | 0.68 |

| | | | | |
|---|---|---|---|---|
| | ឡើយ | | | |
| ៥ | ក្រុមអធិការ មិនប្រើភាសាគំរោះគំរើយ ឬចំអក និងមិនឡូឡា នៅក្នុងថ្នាក់រៀន ឬបង្ហាញទឹកមុខដែលធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍សិស្ស និងគ្រូបង្រៀនឡើយ | 4.75 | 5.00 | 0.25 |
| ៦ | ការចុះធ្វើអធិការកិច្ច មិនបង្កបរិយាកាសស្មុគស្មាញដល់គ្រូក្នុងការបង្រៀន និងរៀនឡើយ | 4.75 | 4.80 | 0.05 |
| សរុប | | 4.48 | 4.43 | 0.05 |

***តារាង 48៖*** *ឥរិយាបថគ្រូបង្រៀនតំបន់ជនបទ និងទីប្រជុំជន ចំពោះការសង្កេតថ្នាក់រៀនរបស់អធិការកិច្ច ទទួលបានពីកម្រងសំណួរនាយក/នាយិកា*

សរុបមួយមក នៅពេលដែលអធិការបានចុះសង្កេតនៅក្នុងថ្នាក់រៀន លោកគ្រូ/អ្នកគ្រូមានការពេញចិត្តចំពោះសកម្មភាពសង្កេតថ្នាក់រៀនរបស់ក្រុមអធិការ ប៉ុន្តែគ្រូបង្រៀននៅតំបន់ជនហាក់បានផ្តល់តម្លៃទៅអធិការដែលបានយកចិត្តទុកដាក់លើគ្រប់សកម្មភាពក្នុងថ្នាក់រៀន ខ្ពស់ជាងបន្តិចបន្តួចទៅលើគ្រូបង្រៀននៅតំបន់ទីប្រជុំជន។

**B. ការបង្រៀន**

ចំពោះការបង្រៀនវិញ តើគ្រូបង្រៀននៅតំបន់ផ្សេងគ្នាមានឥរិយាបថបែបណា នៅពេលអធិការចុះសង្កេតការបង្រៀនរបស់គាត់? តាមតារាង 49 ខាងក្រោមបង្ហាញថាគ្រូបង្រៀនបឋមសិក្សាមានឥរិយាបថវិជ្ជមានប្រហាក់ប្រហែលគ្នា។ បើយើងពិនិត្យលើសូចនាករនីមួយៗ យើងឃើញថាគ្រូបង្រៀននៅតំបន់ទីប្រជុំជនបានព្យាយាមឱ្យសិស្សមានសកម្មភាពក្នុងថ្នាក់ខ្លាំងជាងគ្រូបង្រៀននៅតំបន់ជនបទ។ ជាក់ស្តែងសូចនាករទី១ "គ្រូបង្រៀនបានព្យាយាមជំរុញឱ្យសិស្សមានសកម្មភាពច្រើនក្នុងថ្នាក់រៀនពេលមានការចុះអធិការកិច្ច" កម្រិតយល់ស្របរបស់គ្រូបង្រៀននៅតំបន់ទីប្រជុំជនមានតម្លៃមធ្យម 4.42។ ចំណែកឯគ្រូបង្រៀននៅតំបន់ជនបទវិញបានយល់ស្របក្នុងតម្លៃមធ្យម 3.95។ ផ្ទុយទៅវិញគ្រូបង្រៀននៅតំបន់ជនបទ អាចគ្រប់គ្រងថ្នាក់រៀនបាន

ល្អជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជន។ ត្រង់ចំណុចនេះ ដោយសារចំនួនសិស្សនៅតាមថ្នាក់ក្នុងសាលាតំបន់ទីប្រជុំជនមានសិស្សច្រើនធ្វើឱ្យគ្រូបង្រៀនត្រូវប្រឹងប្រែងធ្វើឱ្យសិស្សមានសកម្មភាពច្រើនជាងមុន និងពិបាកគ្រប់គ្រងសិស្សជាងគ្រូបង្រៀននៅតាមសាលាជនបទ។ លើសពីនេះ គ្រូបង្រៀននៅតំបន់ជនបទមានការពេញចិត្តចំពោះសកម្មភាពរបស់អធិការកិច្ចនៅក្នុងថ្នាក់រៀន ច្រើនជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជន។ ការពេញចិត្តនេះ ដោយសារគ្រូបង្រៀននៅតំបន់ជនបទបានយល់ស្របខ្ពស់ថាអធិការជាអ្នកមានបទពិសោធន៍ច្រើនលើការបង្រៀន។ ជាឧទាហរណ៍ សូចនាករទី៥ "គ្រូបង្រៀនយល់ថាអធិការជាអ្នកមានបទពិសោធន៍ក្នុងការបង្រៀនបានល្អ" មធ្យមភាគយល់ស្របរបស់គ្រូបង្រៀននៅតំបន់ជនបទ ស្មើនឹង 4.36 ចំណែកឯ មធ្យមភាគយល់ស្របរបស់គ្រូបង្រៀននៅតំបន់ទីប្រជុំជនវិញ ស្មើនឹង 4.06។

| ល.រ | **បរិយាយ** | **តម្លៃមធ្យម** | | |
|---|---|---|---|---|
| | **B. ការបង្រៀន** | **ជនបទ** $(N = 44)$ | **ទីប្រជុំជន** $(N = 50)$ | **គម្លាត** |
| ១ | គ្រូបង្រៀនបានព្យាយាមជំរុញឱ្យសិស្សមានសកម្មភាពច្រើនក្នុងថ្នាក់រៀន ពេលមានការចុះអធិការកិច្ច | 3.95 | 4.42 | 0.47 |
| ២ | គ្រូបង្រៀនគ្រប់គ្រងថ្នាក់រៀនបានល្អ ពេលមានអធិការចុះសង្កេតថ្នាក់ | 4.18 | 4.14 | 0.04 |
| ៣ | គ្រូបង្រៀនក្លាហានក្នុងការធ្វើពិសោធន៍គំនិតថ្មី / វិធីសាស្ត្រថ្មីៗក្នុងពេលអធិការកិច្ច | 4.09 | 4.08 | 0.01 |
| ៤ | គ្រូបង្រៀនពេញចិត្តចំពោះសកម្មភាពអធិការកិច្ចនៅក្នុងថ្នាក់រៀន | 4.48 | 4.08 | 0.40 |
| ៥ | គ្រូបង្រៀនយល់ថាអធិការជាអ្នកមានបទពិសោធន៍ក្នុងការ | 4.36 | 4.06 | 0.30 |

| | | | | |
|---|---|---|---|---|
| | បង្រៀនបានល្អ | | | |
| ៦ | អធិការមិនដដែករែកញែកអំពីកំហុសរបស់គ្រូ នៅចំពោះមុខសិស្សឡើយ | 4.34 | 4.40 | 0.06 |
| ៧ | ក្រុមអធិការពិនិត្យមើលការអនុវត្តកិច្ចតែងការបង្រៀនរបស់គ្រូ | 4.59 | 4.48 | 0.11 |
| ៨ | ក្រុមអធិការពិនិត្យមើលការចាត់តាំងសកម្មភាពរៀន និងបង្រៀននៅក្នុងថ្នាក់រៀន | 4.39 | 4.38 | 0.01 |
| ៩ | ក្រុមអធិការ បានឱ្យយោបល់ពីការប្រើប្រាស់សម្ភារឧបទេសក្នុងការរៀន និងបង្រៀន | 4.36 | 4.24 | 0.12 |
| ១០ | ក្រុមអធិការបានពិនិត្យមើលគ្រប់ជ្រុងជ្រោយក្នុងដំណើរការបង្រៀននៅក្នុងថ្នាក់ | 4.30 | 4.44 | 0.14 |
| ១១ | អធិការជាអ្នកជួយកែលម្អគ្រូក្នុងពេលបង្រៀន ជាជាងអ្នកស្វែងរកកំហុសរបស់គ្រូ | 4.18 | 4.36 | 0.18 |
| សរុប | | 4.29 | 4.28 | 0.01 |

***តារាង 49៖** ឥរិយាបថគ្រូបង្រៀនតំបន់ជនបទ និងតំបន់ប្រជុំជនចំពោះការចុះអធិការកិច្ចលើការបង្រៀន*

ចំពោះនាយក/នាយិកា បានយល់ថាគ្រូបង្រៀននៅតំបន់ជនបទ មានឥរិយាបថវិជ្ជមានក្នុងពេលបង្រៀន អំឡុងពេលអធិការកិច្ច ខ្ពស់ជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជន លើមធ្យមភាគពិន្ទុ 4.48 លើ 4.13។ ការយល់ឃើញនេះ ស្របនឹងការយល់ឃើញរបស់គ្រូបង្រៀនដែរ ប៉ុន្តែ លើសូចនាករទី ៦ "អធិការជាអ្នកជួយកែលម្អគ្រូក្នុងពេលបង្រៀន ជាជាងអ្នកស្វែងរកកំហុសរបស់គ្រូ" នាយក/នាយិកា នៅសាលាជនបទបានយល់ស្របកម្រិត "ល្អណាស់" លើមធ្យមភាគពិន្ទុ 4.75 ធៀបនឹង 4.00 នៃការយល់ស្របរបស់នាយក/នាយិកាសាលារៀនតំបន់ទីប្រជុំជន ដែលមានការខុសគ្នាខ្លាំងនឹងការយល់ឃើញរបស់លោកគ្រូ/អ្នកគ្រូ។

| ល.រ | បរិយាយ | តម្លៃមធ្យម | | |
|---|---|---|---|---|
| | B. ការសង្កេតការបង្រៀន | ជនបទ $(N=8)$ | ទីប្រជុំជន $(N=5)$ | គម្លាត |
| ១ | ពេលមានការចុះអធិការកិច្ច គ្រូព្យាយាមជំរុញឱ្យសិស្សមានសកម្មភាពច្រើនក្នុងថ្នាក់រៀន | 4.13 | 3.40 | 0.07 |
| ២ | ពេលមានអធិការកិច្ចថ្នាក់រៀន គ្រូបង្រៀនគ្រប់គ្រងថ្នាក់រៀនបានល្អ | 4.38 | 4.00 | 0.38 |
| ៣ | គ្រូបង្រៀនក្លាហានក្នុងការធ្វើពិសោធន៍គំនិតថ្មី / វិធីសាស្ត្រថ្មីៗក្នុងពេលអធិការកិច្ច | 4.13 | 4.00 | 0.13 |
| ៤ | គ្រូបង្រៀនពេញចិត្តចំពោះសកម្មភាពអធិការកិច្ចនៅក្នុងថ្នាក់រៀន | 4.75 | 4.60 | 0.15 |
| ៥ | ក្រុមអធិការបានពិនិត្យមើលគ្រប់ជ្រុងជ្រោយក្នុងដំណើរការបង្រៀននៅក្នុងថ្នាក់ | 4.75 | 4.80 | 0.05 |
| ៦ | អធិការជាអ្នកជួយកែលម្អគ្រូក្នុងពេលបង្រៀន ជាជាងអ្នកស្វែងរកកំហុសរបស់គ្រូ | 4.75 | 4.00 | 0.75 |
| សរុប | | 4.48 | 4.13 | 0.35 |

***តារាង 50៖** ឥរិយាបថគ្រូបង្រៀននៅតំបន់ទីជនបទ និងទីប្រជុំជនចំពោះការចុះអធិការកិច្ចលើការបង្រៀន ទទួលបានពីកម្រងសំណួរនាយក/នាយិកា*

សរុបមក ទោះបីនៅតំបន់ផ្សេងគ្នា គ្រូបង្រៀនមានឥរិយាបថមិនសូវខុសគ្នាទេចំពោះសកម្មភាពអធិការចុះសង្កេតការបង្រៀនរបស់គាត់ គឺគ្រូបានព្យាយាមឱ្យសិស្សមានសកម្មភាពក្នុងថ្នាក់រៀនដូចគ្នា និង

មានការពេញចិត្តចំពោះសកម្មភាពរបស់អធិការកិច្ចនៅក្នុងថ្នាក់រៀនផងដែរ។

### C. ការសម្ភាសអំពីការបង្រៀន និងរៀន

ចំពោះការសម្ភាសអំពីការបង្រៀន និងរៀន គ្រូបង្រៀននៅតំបន់ជនបទបានបង្ហាញភាពវិជ្ជមានខ្ពស់ជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជនទៅលើការប្រើប្រាស់កម្រងសំណួរសម្ភាសន៍ ការប៉ិនប្រសប់នៃការសួរសំណួរ និងភាពស្មោះត្រង់នៃការឆ្លើយជាដើម។ តាមតារាង 51 បានបង្ហាញថា អធិការកិច្ចបានប្រើប្រាស់កម្រងសំណួរសម្ភាសន៍ងាយស្រួលសម្រាប់គ្រូ កម្រិតយល់ស្រប "ល្អ" ប៉ុន្តែគ្រូបង្រៀននៅតំបន់ជនបទ មានការយល់ស្របខ្ពស់ជាង គ្រូនៅតំបន់ទីប្រជុំជន។ ចំណែកបច្ចេកទេសនៃការសម្ភាសគ្រូបង្រៀនវិញ គ្រូនៅតំបន់ជនបទបានយល់ស្របទៅលើភាពប៉ិនប្រសប់របស់អធិការ ខ្ពស់ជាងគ្រូនៅតំបន់ទីប្រជុំជន។ ជាក់ស្តែងសូចនាករទី២ "អធិការមានភាពប៉ិនប្រសប់ក្នុងការសម្ភាសន៍គ្រូអំពីការបង្រៀន និងរៀន "មធ្យមភាគយល់ស្របរបស់គ្រូបង្រៀននៅតំបន់ជនបទស្មើនឹង 4.50 ចំណែកឯមធ្យមភាគយល់ស្របរបស់គ្រូបង្រៀននៅតំបន់ទីប្រជុំជនវិញស្មើនឹង 4.28។ ដូចគ្នាដែរគ្រូបង្រៀននៅតំបន់ជនបទគ្មានភាពស្ទាក់ស្ទើរក្នុងការចូលរួមឆ្លើយសំណួរសម្ភាស និងមិននិយាយកុហកដើម្បីចៀសផុតពីការវាយតម្លៃមិនល្អឡើយ លើសពីនេះគាត់មានលទ្ធភាពរៀបរាប់ពីបញ្ហាលំបាកលើការបង្រៀន និងរៀនរបស់ខ្លួនទៅដល់អធិការ ហើយសកម្មភាពនេះមានកម្រិតយល់ស្របខ្ពស់ បើធៀបទៅនឹងការយល់ឃើញរបស់គ្រូបង្រៀននៅតំបន់ទីប្រជុំជន។

| ល.រ | **បរិយាយ** | **តម្លៃមធ្យម** | | |
|---|---|---|---|---|
| | **C. ការសម្ភាសអំពីការបង្រៀន និងរៀន** | **ជនបទ** $(N=44)$ | **ទីប្រជុំជន** $(N=50)$ | **គម្លាត** |
| ១ | អធិការប្រើប្រាស់កម្រងសំណួរសម្ភាសន៍ មានភាពងាយស្រួលសម្រាប់គ្រូបង្រៀនក្នុងការឆ្លើយ | 4.27 | 4.18 | 0.09 |
| ២ | អធិការមានភាពប៉ិនប្រសប់ក្នុងការសម្ភាសគ្រូអំពីការបង្រៀន | 4.50 | 4.28 | 0.22 |

| | | | | |
|---|---|---|---|---|
| | និងរៀន | | | |
| ៣ | គ្រូបង្រៀន គ្មានការស្ទាក់ស្ទើរក្នុងការចូលរួមឆ្លើយសំណួរសម្ភាសន៍របស់អធិការកិច្ច | 4.61 | 4.42 | 0.19 |
| ៤ | លោកគ្រូ/អ្នកគ្រូ មិននិយាយកុហក ដើម្បីចៀសផុតពីការវាយតម្លៃមិនល្អឡើយ | 4.59 | 4.34 | 0.25 |
| ៥ | ក្នុងពេលអធិការកិច្ច គ្រូបង្រៀនអាចរៀបរាប់ពីបញ្ហាលំបាកលើការបង្រៀន និងរៀន | 4.41 | 4.22 | 0.19 |
| ៦ | ក្រុមអធិការបានបង្ហាញពីសកម្មភាព និងមូលហេតុដែលលោកគ្រូ/អ្នកគ្រូអនុវត្តបានល្អ លើការបង្រៀននិងរៀន | 4.45 | 4.36 | 0.09 |
| ៧ | ក្រុមអធិការបានបង្ហាញពីសកម្មភាពនិងមូលហេតុដែលគ្រូបង្រៀនអនុវត្តមិនបានល្អ លើការបង្រៀន និងរៀន | 4.43 | 4.28 | 0.15 |
| ៨ | លោកគ្រូ/អ្នកគ្រូមានឱកាសលើកអំណះអំណាងអំពីមូលហេតុនៃការបង្រៀន នៅពេលសម្ភាស | 4.48 | 4.28 | 0.2 |
| សរុប | | 4.47 | 4.30 | 0.17 |

***តារាង 51៖ តំរិយាបថគ្រូបង្រៀនតំបន់ជនបទ និងតំបន់ប្រជុំជនចំពោះការសម្ភាសរបស់ក្រុមអធិការកិច្ច***

ចំណែកឯ នាយក/ នាយិកាបានសម្គាល់ថាគ្រូបង្រៀននៅតំបន់ជនបទបានបង្ហាញភាពវិជ្ជមានខ្ពស់ជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជនទៅលើការប្រើប្រាស់កម្រងសំណួរសម្ភាសន៍ ការប៉ិនប្រសប់នៃការសួរសំណួរ និងការសហការនៃការធ្វើសម្ភាសដូចគ្នានឹងការយល់ឃើញរបស់គ្រូបង្រៀនដែរ។ ប៉ុន្តែនាយក/នាយិកានៅតំបន់ទីក្រុងបាន យល់ស្របទាបជាងគេលើសូចនាករទី៦ "ក្រុមអធិការបានបង្ហាញពីសកម្មភាពនិងមូលហេតុដែលគ្រូបង្រៀនអនុវត្តមិនបានល្អលើការបង្រៀន និងរៀន" បានសេចក្តីថានាយក/នាយិកាយល់ថា

អធិការកិច្ចមិនទាន់បង្ហាញបានគ្រប់គ្រាន់ អំពីអ្វីដែលគ្រូបង្រៀនអនុវត្តមិនទាន់បានល្អក្នុងការបង្រៀន និងរៀននៅឡើយទេ។ នេះបង្ហាញថានាយក/នាយិកានៅតំបន់ទីក្រុងចង់ឱ្យអធិការកិច្ចជួយកែលម្អ ឬផ្តល់ពិសោធន៍ល្អៗបន្ថែមទៅដល់គ្រូបង្រៀន ដើម្បីឱ្យគាត់អនុវត្តការងារបង្រៀនប្រកបដោយប្រសិទ្ធភាព។

| ល.រ | បរិយាយ | តម្លៃមធ្យម | | |
|---|---|---|---|---|
| | C. ការសម្ភាស | តំបន់ជនបទ $(N=8)$ | ទីប្រជុំជន $(N=5)$ | គម្លាត |
| ១ | អធិការមានភាពប៉ិនប្រសប់ក្នុងការសម្ភាសគ្រូអំពីការរៀន និងរៀន | 4.50 | 4.80 | 0.30 |
| ២ | គ្រូបង្រៀន គ្មានការស្ទាក់ស្ទើរក្នុងការចូលរួមឆ្លើយសំណួរសម្ភាសន៍របស់អធិការកិច្ច | 4.88 | 4.40 | 0.48 |
| ៣ | ក្នុងពេលអធិការកិច្ច គ្រូបង្រៀនបានរៀបរាប់ពីបញ្ហាលំបាកលើការបង្រៀន និងរៀន | 4.38 | 4.20 | 0.18 |
| ៤ | លោកគ្រូ/អ្នកគ្រូ មិននិយាយកុហក ដើម្បីចៀសផុតពីការវាយតម្លៃមិនល្អឡើយ | 4.38 | 4.20 | 4.18 |
| ៥ | ក្រុមអធិការបានបង្ហាញពីសកម្មភាព និងមូលហេតុដែលលោកគ្រូ/អ្នកគ្រូអនុវត្តបានល្អ លើការបង្រៀននិងរៀន | 4.75 | 4.60 | 0.15 |
| ៦ | ក្រុមអធិការបានបង្ហាញពីសកម្មភាពនិងមូលហេតុដែលគ្រូបង្រៀនអនុវត្តមិនបានល្អ លើការបង្រៀន និងរៀន | 4.13 | 3.80 | 0.67 |
| សរុប | | 4.50 | 4.33 | 0.17 |

***តារាង 52៖** តារាងបរិយាយថគ្រូបង្រៀននៅតំបន់ផ្សេងគ្នាចំពោះការសម្ភាសរបស់ក្រុមអធិការកិច្ច ទទួលបានពីកម្រងសំណួរនាយក/នាយិកា*

ជារួម ក្នុងផ្នែកទី២នេះតាមតារាង 53 យើងបានសង្កេតឃើញថា គ្រូបង្រៀនមានឥរិយាបថវិជ្ជមានចំពោះសកម្មភាពរបស់អធិការអំឡុងពេលអធិការកិច្ច ដោយមានកម្រិតយល់ស្រប "ល្អ"។ ប៉ុន្តែបើយើងធ្វើការប្រៀបធៀបឥរិយាបថគ្រូបង្រៀននៅតំបន់ជនបទ និងគ្រូនៅតំបន់ទីប្រជុំជនវិញ ឃើញថាគ្រូបង្រៀននៅតំបន់ជនមានឥរិយាបថវិជ្ជមានលើសកម្មភាពសង្កេតថ្នាក់រៀនរបស់ក្រុមអធិការ ក៏ដូចសង្កេតការបង្រៀន និងការសម្ភាសគ្រូអំពីការបង្រៀន និងរៀនខ្ពស់ជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជន ទោះបីជាការយល់ស្របគ្រូបង្រៀនទាំងពីរប្រភេទមានកម្រិត "ល្អ" ដូចគ្នាក៏ដោយ។

| **បរិយាយ** | | **តម្លៃមធ្យម** | | |
|---|---|---|---|---|
| ផ្នែកទី២៖ | អំឡុងពេលអធិការកិច្ច | **ជនបទ** $(N = 44)$ | **ទីប្រជុំជន** $(N = 50)$ | **គម្លាត** |
| A | ការសង្កេតថ្នាក់រៀន | 4.33 | 4.24 | 0.09 |
| B | សង្កេតការបង្រៀន | 4.29 | 4.28 | 0.01 |
| C | ការសម្ភាសអំពីការបង្រៀន និងរៀន | 4.47 | 4.30 | 0.17 |
| សរុប | | 4.37 | 4.27 | 0.10 |

***តារាង 53៖*** *ឥរិយាបថគ្រូបង្រៀនតំបន់ជនបទ និងតំបន់ប្រជុំជន អំឡុងពេលអធិការកិច្ច*

### ៤.១.២.៣ ឥរិយាបថគ្រូបង្រៀននៅតំបន់ជនបទ និងតំបន់ទីប្រជុំជន ក្រោយពេលអធិការកិច្ច

#### A. ការផ្តល់អនុសាសន៍

ដោយផ្អែកលើលទ្ធផល ត្រង់ចំណុច៤.២.៣ បង្ហាញថាគ្រូបង្រៀនមានឥរិយាបថវិជ្ជមានចំពោះអនុសាសន៍របស់អធិការកិច្ច ដោយពួកគាត់បានយល់ស្របថា អធិការកិច្ចតែងតែផ្តល់ជាអនុសាសន៍ទៅលើការបង្រៀនរបស់គាត់ ហើយអនុសាសន៍នោះផងដែរ មានសារៈសំខាន់សម្រាប់គ្រូបង្រៀន ដែលអាចជួយឱ្យគាត់ក្លាយទៅជាគ្រូបង្រៀនល្អ និងអាចទទួលបាននូវរាល់បទពិសោធន៍ល្អៗអំពីការបង្រៀន និងរៀនផងដែរ។ ផ្នែក

បន្តនេះ យើងនឹងបន្តបកស្រាយនូវសំណួរស្រាវជ្រាវទី២ តើឥរិយាបថរបស់គ្រូបង្រៀនបឋមសិក្សា ក្រោយពេលអធិការកិច្ច លើការបង្រៀន និងរៀន មានភាពខុសគ្នាឬទេ ដោយផ្អែកលើទីតាំងសាលារៀន?

តាមតារាង 54 បង្ហាញថាគ្រូបង្រៀននៅតំបន់ជនបទ មានការយល់ស្របខ្ពស់ជាង ការយល់ស្របរបស់គ្រូបង្រៀននៅតំបន់ទីប្រជុំជនលើគ្រប់សូចនាករ។ ជាក់ស្តែងសូចនាករទី៦ "អនុសាសន៍របស់អធិការកិច្ចមានសារៈសំខាន់សម្រាប់គ្រូបង្រៀន" ការយល់ស្របរបស់គ្រូនៅតំបន់ជនបទ មានតម្លៃមធ្យម 4.64 ធៀបនឹងតម្លៃមធ្យម 4.40 របស់គ្រូនៅតំបន់ទីប្រជុំជន។ ដូចគ្នាដែរសូចនាករទី៥ "អធិការកិច្ចបានផ្តល់អនុសាសន៍ផ្សារភ្ជាប់ស្ថានភាពជាក់ស្តែង តាមតម្រូវការ និងសមត្ថភាពរបស់លោកគ្រូ/អ្នកគ្រូ" គ្រូបង្រៀននៅតំបន់ជនបទមានមធ្យមភាគពិន្ទុ 4.34 លើ 4.06 នៃមធ្យមភាគពិន្ទុរបស់គ្រូបង្រៀននៅទីប្រជុំជន។ ម្យ៉ាងទៀត ទោះជាលោកគ្រូ/អ្នកគ្រូបានទទួលស្គាល់បញ្ហាអំពីការបង្រៀន និងរៀនដែលអធិការកិច្ចបានរកឃើញក្តី ក៏ការទទួលយកអនុសាសន៍របស់អធិការកិច្ចទៅអនុវត្តមានកម្រិតមិនដូចគ្នាទេ។ ជាក់ស្តែងសូចនាករទី១១ "គ្រូនឹងអនុវត្តតាមអនុសាសន៍របស់ក្រុមអធិការកិច្ច លើការបង្រៀន និងរៀន" គ្រូបង្រៀននៅតំបន់ជនបទ បានយល់ស្របលើមធ្យមភាគពិន្ទុ 4.59 ខ្ពស់ជាងការយល់ស្របរបស់គ្រូបង្រៀននៅតំបន់ទីប្រជុំជន ដែលមានមធ្យមភាគពិន្ទុ 4.22 ។

| ល.រ | **ផ្នែកទី២៖ ក្រោយពេលអធិការកិច្ច** | **តម្លៃមធ្យម** | | |
|---|---|---|---|---|
| | **A. ការផ្តល់អនុសាសន៍** | **ជនបទ** $(N = 44)$ | **ទីប្រជុំជន** $(N = 50)$ | **គម្លាត** |
| ១ | អធិការតែងតែផ្តល់អនុសាសន៍លើការបង្រៀនរបស់គ្រូ | 4.59 | 4.50 | 0.09 |
| ២ | អនុសាសន៍របស់អធិការកិច្ចលើការបង្រៀននិងរៀន សមស្របនឹងបរិបទរបស់សាលារៀនរបស់ពួកយើង | 4.25 | 4.24 | 0.01 |
| ៣ | អនុសាសន៍របស់អធិការកិច្ច មានលក្ខណៈសមស្របនិង | 4.50 | 4.30 | 0.20 |

| | | | | |
|---|---|---|---|---|
| | ច្បាស់លាស់ | | | |
| ៤ | អនុសាសន៍របស់អធិការកិច្ច ធ្វើឱ្យការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាព | 4.59 | 4.40 | 0.19 |
| ៥ | អធិការកិច្ចបានផ្តល់អនុសាសន៍ផ្សារភ្ជាប់ស្ថានភាពជាក់ស្តែងតាមតម្រូវការ និងសមត្ថភាពរបស់លោកគ្រូ/អ្នកគ្រូ | 4.34 | 4.06 | 0.28 |
| ៦ | អនុសាសន៍របស់អធិការកិច្ច មានសារៈសំខាន់សម្រាប់គ្រូបង្រៀន | 4.64 | 4.40 | 0.24 |
| ៧ | ក្រុមអធិការតែងតែចែករំលែកនូវរាល់បទពិសោធន៍ល្អៗអំពីការបង្រៀន និងរៀន | 4.59 | 4.50 | 0.09 |
| ៨ | អនុសាសន៍របស់អធិការបានជួយឱ្យលោក/អ្នក ក្លាយទៅជាគ្រូបង្រៀនល្អ | 4.55 | 4.46 | 0.09 |
| ៩ | អនុសាសន៍របស់អធិការកិច្ច មិនមែនជាការដាក់បន្ទុកបន្ថែមលើការងារបង្រៀន របស់គ្រូបង្រៀនឡើយ | 4.45 | 4.08 | 0.37 |
| ១០ | លោកគ្រូ/អ្នកគ្រូ ទទួលស្គាល់បញ្ហាអំពីការបង្រៀន និងរៀនដែលអធិការកិច្ចបានរកឃើញ | 4.55 | 4.16 | 0.39 |
| ១១ | លោកគ្រូ/អ្នកគ្រូ នឹងអនុវត្តតាមអនុសាសន៍របស់ក្រុមអធិការកិច្ចលើការបង្រៀន និងរៀន | 4.59 | 4.22 | 0.37 |
| សរុប | | 4.51 | 4.30 | 0.21 |

***តារាង 54៖ ឥរិយាបថគ្រូបង្រៀនតំបន់ជនបទ និងតំបន់ប្រជុំជន ចំពោះអនុសាសន៍អធិការកិច្ច***

ចំពោះនាយក/នាយិកាបានយល់ស្របថា គ្រូបង្រៀននៅតំបន់ជនបទបានបង្ហាញភាពរីជ្ឈមាន ខ្ពស់ជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជន ដូចគ្នានឹងការយល់ឃើញរបស់គ្រូបង្រៀនដែរចំពោះអនុសាសន៍របស់អធិការកិច្ច។ បើពិនិត្យលើសូចនាករនីមួយៗ យើងឃើញថាគ្រូបង្រៀនជនបទមានមធ្យមភាគពិន្ទុខ្ពស់ជាងគ្រូបង្រៀននៅតំបន់ទីក្រុងទៅលើសារៈសំខាន់របស់អនុសាសន៍អធិការកិច្ច ដែលមានភាពសមស្របតាមសមត្ថភាពរបស់គ្រូបង្រៀន ជាពិសេសគ្រូបង្រៀនបានឯកភាពថាគាត់នឹងអនុវត្តតាមអនុសាសន៍របស់ក្រុមអធិការកិច្ចដើម្បីកែលម្អលើការបង្រៀន និងរៀន។ ប៉ុន្តែ បើយើងពិនិត្យលើសូចនាករទី១ "អធិការតែងតែផ្តល់អនុសាសន៍លើការបង្រៀនរបស់គ្រូ" នាយក/នាយិកានៅតំបន់ជនបទបានយល់ស្របកម្រិត "ល្អណាស់" លើមធ្យមភាពពិន្ទុ 4.88 ធៀបនឹង4.20 នៃការយល់ស្របរបស់នាយក/នាយិកា នៅតំបន់ទីប្រជុំជន។ នេះមានន័យថា នាយក/នាយិកា បានយល់ថាគ្រូបង្រៀននៅតំបន់ទីប្រជុំជន មិនទាន់បានទទួលអនុសាសន៍ពីអធិការកិច្ចបានពេញលេញនៅឡើយទេ ដែលជាហេតុធ្វើឱ្យគ្រូកែប្រែការបង្រៀនរបស់ខ្លួនផ្អែកលើអនុសាសន៍អធិការកិច្ចបានតិចតួច និងចំណែកឯការផ្លាស់ប្តូរឥរិយាបថក្នុងការបង្រៀនក៏បានតិចទៅតាមនោះដែរ ដូចបង្ហាញក្នុងតារាង 55។

***តារាង 55៖*** *ឥរិយាបថគ្រូបង្រៀននៅតំបន់ជនបទ និងទីប្រជុំជនចំពោះអនុសាសន៍អធិការកិច្ច ទទួលបានពីកម្រងសំណួរនាយក/នាយិកា*

| ល.រ | ផ្នែកទី៣ ៖ ក្រោយពេលអធិការកិច្ច | តម្លៃមធ្យម | | |
|---|---|---|---|---|
| | A. ការផ្តល់អនុសាសន៍ | ជនបទ $(N=8)$ | ទីប្រជុំជន $(N=5)$ | គម្លាត |
| ១ | អធិការតែងតែផ្តល់អនុសាសន៍លើការបង្រៀនរបស់គ្រូ | 4.88 | 4.20 | 0.68 |
| ២ | អនុសាសន៍របស់អធិការកិច្ចលើការបង្រៀននិងរៀន សមស្របនឹងបរិបទរបស់សាលារៀននីមួយៗ | 4.75 | 4.60 | 0.15 |

| | | | | |
|---|---|---|---|---|
| ៣ | អនុសាសន៍របស់អធិការកិច្ច មានលក្ខណៈសមស្របនិង ច្បាស់លាស់ចំពោះ ការបង្រៀន និងរៀន | 5.00 | 4.80 | 0.20 |
| ៤ | អនុសាសន៍របស់អធិការកិច្ច ធ្វើឱ្យការបង្រៀន និងរៀនកាន់តែ មានប្រសិទ្ធភាព | 5.00 | 4.80 | 0.20 |
| ៥ | អនុសាសន៍របស់អធិការកិច្ច មានសារៈសំខាន់សម្រាប់គ្រូ បង្រៀន | 5.00 | 4.80 | 0.20 |
| ៦ | អនុសាសន៍របស់អធិការបានជួយឱ្យគ្រូបង្រៀនក្លាយទៅជាគ្រូ បង្រៀនល្អ | 4.88 | 4.60 | 0.22 |
| ៧ | អនុសាសន៍របស់អធិការកិច្ច មិនមែនជាការដាក់បន្ទុកបន្ថែមលើ ការងារបង្រៀន របស់គ្រូឡើយ | 4.88 | 4.80 | 0.02 |
| ៨ | លោកគ្រូ/អ្នកគ្រូ ទទួលស្គាល់បញ្ហាអំពីការបង្រៀន និងរៀន ដែលអធិការកិច្ចបានរកឃើញ | 4.63 | 4.60 | 0.03 |
| ៩ | លោកគ្រូ/អ្នកគ្រូ បានអនុវត្តតាមអនុសាសន៍របស់ក្រុមអធិការ កិច្ច លើកិច្ចការបង្រៀន | 4.50 | 4.20 | 0.30 |
| ១០ | គ្រូបង្រៀនបានផ្លាស់ប្តូរវិធីសាស្ត្របង្រៀនក្នុងការបង្រៀន តាមអនុ សាសន៍របស់អធិការកិច្ច | 4.50 | 4.20 | 0.30 |
| សរុប | | 4.80 | 4.56 | 0.24 |

សរុបរួមមក អនុសាសន៍អធិការកិច្ចជាផ្នែកមួយដែលគ្រូបង្រៀនយល់ថាមានសារៈសំខាន់ជាងគេ នៅពេលមានការចុះអធិការកិច្ចថ្នាក់រៀន ដោយគ្រូបង្រៀនយល់ថាអធិការកិច្ចបានផ្តល់អនុសាសន៍ដោយផ្ទាល់

ទៅឱ្យគ្រូ និងបានជួយកែលម្អនូវចំណុចខ្វះខាតលើការបង្រៀន និងរៀន ជាពិសេសវាមានលក្ខណៈសមស្រប ច្បាស់លាស់តាមស្ថានភាពជាក់ស្តែង នៃតម្រូវការ និងសមត្ថភាពរបស់លោកគ្រូ/អ្នកគ្រូ។ ត្រង់ចំណុចនេះ យើងបានសង្កេតឃើញថា គ្រូបង្រៀនបានយល់ស្របទៅនឹងការអនុវត្តតាមអនុសាសន៍របស់ក្រុមអធិការកិច្ច ផងដែរ។ បើផ្អែកទៅលើទីតាំងសាលារៀនវិញ លទ្ធផលបង្ហាញថាគ្រូបង្រៀននៅសាលារៀនតំបន់ជនបទ មានឥរិយាបថវិជ្ជមានខ្ពស់ជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជននៅគ្រប់សូចនាករ ដែលមានន័យថាគ្រូបង្រៀន នៅតំបន់ទីប្រជុំជន មានការទទួលស្គាល់អំពីអ្វីដែលអធិការកិច្ចបានរកឃើញលើការបង្រៀន និងរៀនរបស់ គាត់ នៅមានកម្រិតនៅឡើយ បើធៀបនឹងគ្រូបង្រៀននៅសាលារៀនតំបន់ទីជនបទ ហើយទំនោរនៃការអនុវត្ត តាមអនុសាសន៍របស់អធិការកិច្ច ដើម្បីកែលម្អការបង្រៀន សម្រាប់គ្រូបង្រៀននៅតំបន់ទីប្រជុំជន អាចមាន ការប្រែប្រួលតិចតួច។

**B. របាយការណ៍អធិការកិច្ច**

ចំពោះរបាយការណ៍អធិការកិច្ច គ្រូបង្រៀនសម្តែងឥរិយាបថវិជ្ជមានដោយបានយល់ស្របកម្រិត "ល្អ" លើមធ្យមភាគពិន្ទុ 3.92។ ប្រសិនបើយើងពិនិត្យលើសូចនាករនីមួយៗ ក្នុងតារាងទី 56 យើងឃើញថាគ្រូ បង្រៀននៅតំបន់ទីប្រជុំជន បានដឹងពីខ្លឹមសារអធិការកិច្ចបានតិចតួចណាស់ធៀបនឹងគ្រូបង្រៀននៅតំបន់ជន បទ។ ជាក់ស្តែង សូចនាករទី១ "លោកគ្រូ/អ្នកគ្រូបានដឹងពីខ្លឹមសារក្នុងរបាយការណ៍អធិការកិច្ច" កម្រិតយល់ ស្របរបស់គ្រូបង្រៀនតំបន់ទីប្រជុំជន ស្មើនឹង 2.86 ធៀបនឹងតម្លៃមធ្យមនៃការយល់ស្របរបស់គ្រូបង្រៀននៅ តំបន់ជនបទគឺ 3.50។ ដូចគ្នាដែរ គ្រូនៅតំបន់ជនបទបានយល់ស្របកម្រិត"ល្អ" លើរបាយការណ៍អធិការកិច្ច ដែលបានបំពេញការចំណុចខ្វះខាតរបស់ខ្លួន និងបង្ហាញពីចំណុចដែលត្រូវកែលម្អលើការបង្រៀន និងរៀន ខ្ពស់ជាងការយល់ស្របរបស់គ្រូនៅតំបន់ទីប្រជុំជន ដូចបានបង្ហាញក្នុងសូចនាករទី២ និងទី៣។ លើសពីនេះ គ្រូនៅតំបន់ជនបទបានយល់ស្របទៅលើរបាយការណ៍អធិការកិច្ច ហើយបានប្រើប្រាស់របាយកាណ៍អធិការ កិច្ចសម្រាប់កែលម្អការបង្រៀន និងរៀនល្អជាងគ្រូនៅតំបន់ទីប្រជុំជន។

| ល.រ | បរិយាយ | តម្លៃមធ្យម | | |
|---|---|---|---|---|
| | B. របាយការណ៍អធិការកិច្ច | ជនបទ $(N=44)$ | ទីប្រជុំជន $(N=50)$ | គម្លាត |
| ១ | លោកគ្រូ/អ្នកគ្រូបានដឹងពីខ្លឹមសារក្នុងរបាយការណ៍អធិការកិច្ច | 3.50 | 2.86 | 0.64 |
| ២ | របាយការណ៍អធិការកិច្ច បានបំពេញចំណុចខ្វះខាតរបស់គ្រូបង្រៀន ក្នុងអាជីពរបស់ពួកគាត់ | 4.11 | 3.48 | 0.63 |
| ៣ | របាយការណ៍អធិការកិច្ច បានបង្ហាញពីចំណុចដែលត្រូវកែលម្អលើការបង្រៀន និងរៀន | 4.25 | 3.68 | 0.57 |
| ៤ | របាយការណ៍អធិការកិច្ច បង្កលក្ខណៈងាយស្រួលដល់គ្រូបង្រៀនក្នុងការអាន | 3.98 | 3.58 | 0.40 |
| ៥ | គ្រូបង្រៀនយល់ស្របនឹងរបាយការណ៍អធិការកិច្ច | 4.27 | 3.62 | 0.65 |
| ៦ | គ្រូបង្រៀនប្រើប្រាស់របាយកាណ៍អធិការកិច្ច សម្រាប់កែលម្អការបង្រៀន និងរៀន | 4.25 | 3.70 | 0.55 |
| ៧ | លោកគ្រូ/អ្នកគ្រូទាំងអស់យល់ឃើញថាសកម្មភាពនៃការចុះអធិការកិច្ចមានប្រយោជន៍ដល់ការបង្រៀន និងរៀនរបស់ខ្លួន | 4.70 | 4.18 | 0.52 |
| ៨ | ការវាយតម្លៃរបស់អធិការកិច្ចលើការបង្រៀនរបស់គ្រូ ផ្តោតលើបច្ចេកទេស មិនមែនប្រើអារម្មណ៍ផ្ទាល់ខ្លួន | 4.75 | 4.14 | 0.61 |
| សរុប | | 4.23 | 3.66 | 0.57 |

***តារាង 56៖*** *តវិយាបថគ្រូបង្រៀនតំបន់ជនបទ និងតំបន់ប្រជុំជន ចំពោះរបាយការណ៍អធិការកិច្ច*

សម្រាប់នាយក/នាយិកាសាលារៀនទាំងពីរប្រភេទ បានយល់ឃើញប្រហាក់ប្រហែលគ្នាទៅលើឥរិយាបថគ្រូបង្រៀនទៅលើរបាយការណ៍អធិការកិច្ច។ តាមតារាង 57 នាយក/នាយិកានៅសាលាតំបន់ទីប្រជុំជនបានយល់ស្របខ្ពស់ជាងនាយក/នាយិកានៅសាលាតំបន់ជនបទ ចំពោះការផ្សព្វផ្សាយពីលទ្ធផលនៃរបាយការណ៍អធិការកិច្ចទៅដល់គ្រូបង្រៀន ប៉ុន្តែគ្រូបង្រៀននៅតំបន់ទីប្រជុំជន បានបង្ហាញការយល់ស្របទាបបន្តិចបន្តួចជាងគ្រូបង្រៀននៅតំបន់ជនបទ ទៅលើការយល់ស្របនឹងរបាយការណ៍អធិការកិច្ចដែលបានសរសេររៀបរាប់ពីការបង្រៀនរបស់គ្រូ ដែលវាមិនបានបង្កលក្ខណៈងាយស្រួលដល់គ្រូបង្រៀនក្នុងការអាន ជាពិសេសគ្រូមិនសូវចាប់អារម្មណ៍ចង់ដឹងពីខ្លឹមសារនៃរបាយការណ៍អធិការកិច្ចអំពីការបង្រៀន និងរៀនរបស់ខ្លួនឡើយ។

| ល.រ | បរិយាយ | តម្លៃមធ្យម | | |
|---|---|---|---|---|
| | B. ការផ្តល់របាយការណ៍អធិការកិច្ច | ជនបទ $(N=8)$ | ទីប្រជុំជន $(N=5)$ | គម្លាត |
| ១ | នាយក/នាយិកាបានផ្សព្វផ្សាយអំពីលទ្ធផលក្នុងរបាយការណ៍អធិការកិច្ចទៅដល់គ្រូបង្រៀន | 4.50 | 4.60 | 0.10 |
| ២ | គ្រូបង្រៀន យកចិត្តទុកដាក់លើខ្លឹមសារក្នុងរបាយការណ៍អធិការកិច្ច | 4.38 | 4.40 | 0.02 |
| ៣ | គ្រូបង្រៀនចង់ដឹងពីខ្លឹមសារនៃរបាយការណ៍អធិការកិច្ច អំពីការបង្រៀន និងរៀនរបស់ខ្លួន | 4.63 | 4.40 | 0.23 |
| ៤ | របាយការណ៍អធិការកិច្ច បានបង្ហាញពីចំណុចដែលត្រូវកែលម្អលើការបង្រៀន និងរៀន | 4.63 | 4.80 | 0.17 |
| ៥ | របាយការណ៍អធិការកិច្ច បង្កលក្ខណៈងាយស្រួលដល់គ្រូ | 4.63 | 4.40 | 0.23 |

| | | | | |
|---|---|---|---|---|
| | បង្រៀនក្នុងការអាន | | | |
| ៦ | គ្រូបង្រៀនយល់ស្របនឹងរបាយការណ៍អធិការកិច្ច | 4.63 | 4.60 | 0.03 |
| ៧ | គ្រូបង្រៀនប្រើប្រាស់របាយកាណ៍អធិការកិច្ច សម្រាប់កែលម្អការបង្រៀន និងរៀន | 4.63 | 4.40 | 0.23 |
| ៨ | លោកគ្រូ/អ្នកគ្រូទាំងអស់យល់ឃើញថាសកម្មភាពនៃការចុះអធិការកិច្ចមានប្រយោជន៍ដល់ការបង្រៀន និងរៀនរបស់ខ្លួន | 4.63 | 4.60 | 0.03 |
| សរុប | | 4.58 | 4.53 | 0.05 |

***តារាង 57៖ ឥរិយាបថគ្រូបង្រៀនតំបន់ជនបទ និងតំបន់ប្រជុំជន ចំពោះរបាយការណ៍អធិការកិច្ច តាមរយៈកម្រងសំណួរនាយក***

ជារួមក្នុងផ្នែករបាយការណ៍អធិការកិច្ចនេះ បានបង្ហាញថានៅតាមសាលារៀននីមួយៗដែលបានធ្វើអធិការកិច្ចរួចហើយ នាយក/នាយិកា បានផ្សព្វផ្សាយអំពីលទ្ធផលតាមរបាយការណ៍អធិការកិច្ចទៅដល់គ្រូបង្រៀន ប៉ុន្តែគ្រូបង្រៀនតិចតួចណាស់ដែលបានដឹងពីខ្លឹមសារដែលមាននៅក្នុងរបាយការណ៍អធិការកិច្ច ជាពិសេសគ្រូបង្រៀននៅតំបន់ទីប្រជុំជន។ លទ្ធផលនេះបង្ហាញថាគ្រូបង្រៀននៅតំបន់ទីប្រជុំជន គាត់មិនសូវបានចាប់អារម្មណ៍ និងស្វែងយល់ពីអ្វីដែលក្រុមអធិការកិច្ចបានរកឃើញ និងសរសេររៀបរាប់ក្នុងរបាយការណ៍ទេ ព្រោះនាយក/នាយិកាផ្សព្វផ្សាយមិនបានទូលំទូលាយទៅដល់គ្រូបង្រៀន បានជាគាត់មិនបានដឹង ឬមកពីរបាយការណ៍អធិការកិច្ចមានភាពស្មុគ្រស្មាញសម្រាប់គ្រូអាន និងមិនអាចយល់ពីអ្វីដែលបានសរសេរ។ មូលហេតុផ្សេងទៀត អាចមកពីគ្រូបង្រៀនមិនបានយល់ថារបាយការណ៍អធិការកិច្ចមានសារៈសំខាន់សម្រាប់គាត់ផ្ទាល់ ឬមកពីរបាយការណ៍អធិការកិច្ចបានបញ្ជូនមិនទៅដល់សាលារៀន និងប្រើរយៈពេលយូរ ធ្វើឱ្យគ្រូបង្រៀនភ្លេច ឬលែងចង់ដឹង។

ជារួមក្នុងផ្នែកទី៣នេះ តារាង 58 បានបង្ហាញថាគ្រូបង្រៀននៅតំបន់ជនបទ មានការយល់ស្របលើគ្រប់សូចនាករ ខ្ពស់ជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជន លើមធ្យមភាពពិន្ទុ 4.37 ទល់នឹង 3.98 ចំពោះ

សកម្មភាពអធិការ ក្រោយពេលចុះអធិការកិច្ចលើការបង្រៀន និងរៀន ដែលរួមមានការផ្តល់អនុសាសន៍លើការបង្រៀន និងរៀនការផ្តល់របាយការណ៍អធិការកិច្ចជាដើម។ ប៉ុន្តែបើយើងពិនិត្យលើផ្នែករង"A" ឃើញថាគ្រូបង្រៀននៅតំបន់ទាំងពីរមានឥរិយាបថវិជ្ជមានប្រហាក់ប្រហែលគ្នាចំពោះអនុសាសន៍អធិការកិច្ច និងការទទួលយកអនុសាសន៍យកទៅអនុវត្ត។ ប៉ុន្តែនៅផ្នែក"B" ឥរិយាបថគ្រូបង្រៀនចំពោះរបាយការណ៍អធិការកិច្ចឃើញថាគ្រូបង្រៀននៅតំបន់ទីប្រជុំជនមានការយល់ស្របទាបឆ្ងាយពីគ្រូបង្រៀននៅតំបន់ជនបទ លើមធ្យមភាពពិន្ទុ 3.66 ទល់នឹង 4.23។ ត្រង់ចំណុចនេះយើងអាចសន្និដ្ឋានបានថា គ្រូបង្រៀននៅតំបន់ទីប្រជុំជនបានចាប់អារម្មណ៍តិចតួចណាស់ចំពោះរបាយការណ៍អធិការកិច្ច បើធៀបនឹងការអនុសាសន៍ មានន័យថា គ្រូបង្រៀនចូលចិត្តទទួលយកការណែនាំដោយផ្ទាល់មាត់ ជាជាងការណែនាំដោយការសរសេរក្នុងរបាយការណ៍។

| **បរិយាយ** | | **តម្លៃមធ្យម** | | |
|---|---|---|---|---|
| ផ្នែកទី៣៖ | ក្រោយពេលអធិការកិច្ច | **តំបន់ជនបទ** $(N=44)$ | **តំបន់ទីប្រជុំជន** $(N=50)$ | គម្លាត |
| A | ការផ្តល់អនុសាសន៍ | 4.51 | 4.30 | 0.21 |
| B | ការផ្តល់របាយការណ៍ | 4.23 | 3.66 | 0.57 |
| សរុប | | 4.37 | 3.98 | 0.39 |

***តារាង 58៖*** *ឥរិយាបថគ្រូបង្រៀនតំបន់ជនបទ និងតំបន់ប្រជុំជន ក្រោយពេលអធិការកិច្ច*

លទ្ធផលជារួម ដូចបង្ហាញក្នុងតារាង 58 អាចឱ្យយើងដឹងថា ទាំងគ្រូបង្រៀននៅសាលារៀនតំបន់ជនបទ និងសាលារៀនតំបន់ទីប្រជុំជន សុទ្ធតែមានឥរិយាបថវិជ្ជមានដូចគ្នា ទៅលើរូបភាពនៃសកម្មភាពរបស់អធិការមុនពេលអធិការកិច្ច ប៉ុន្តែគ្រូបង្រៀននៅតំបន់ជនបទ មានការយល់ស្របខ្ពស់ជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជន។ បើយើងពិនិត្យ លើផ្នែករងនីមួយៗ យើងឃើញថាគ្រប់ផ្នែករងទាំងអស់ គឺគ្រូបង្រៀននៅតំបន់ជនបទ តែតែងមានការយល់ស្របក្នុងមធ្យមភាគខ្ពស់ជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជនជានិច្ច ទាំងការ

ប្រាស្រ័យទាក់ទងជាមួយក្រុមអធិការកិច្ច ការទទួលបានព័ត៌មានអំពីអធិការកិច្ច ការយល់ពីគោលបំណងនៃការអធិការកិច្ចលើការបង្រៀន និងរៀន ការដឹងពីពេលវេលានៃអធិការកិច្ច ជាពិសេសបានត្រៀមលក្ខណៈសម្រាប់ការបង្រៀនបានល្អ ក្នុងពេលអធិការកិច្ច និងរីករាយស្វាគមន៍ ការចុះសង្កេតការបង្រៀន របស់ក្រុមអធិការ។

តារាង 59 បានបង្ហាញលទ្ធផលជារួមនៃឥរិយាបថគ្រូបង្រៀន ចំពោះអធិការកិច្ចលើការបង្រៀន និងរៀនដោយផ្អែកលើទីតាំងសាលារៀន។ លទ្ធផលបង្ហាញថា គ្រូបង្រៀននៅតំបន់ជនបទ មានឥរិយាបថវិជ្ជមានកម្រិតខ្ពស់ជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជន គ្រប់ដំណាក់កាលនៃអធិការកិច្ច(មុន,អំឡុងពេល,ក្រោយ) លើមធ្យមភាគពិន្ទុ 4.32 ធៀបនឹង 4.06។ ដូចបានរៀបរាប់ក្នុងចំណុច ៤.១.២ដែរ គ្រូបង្រៀនភាគច្រើនបង្ហាញឥរិយាបថវិជ្ជមានខ្ពស់ជាងគេនៅពេលមានវត្តមានអធិការកិច្ចនៅក្នុងសាលារៀន ហើយឥរិយាបថវិជ្ជមាននោះថយចុះមកវិញនៅក្រោយពេលអធិការកិច្ច។ ទិន្នន័យដដែលបានបង្ហាញថា មធ្យមភាគពិន្ទុគ្រូបង្រៀននៅតំបន់ជនបទមានតម្លៃស្មើគ្នា 4.37 ទាំងអំឡុងពេលអធិការកិច្ច និងក្រោយពេលអធិការកិច្ច ខុសប្លែកពីគ្រូបង្រៀននៅតំបន់ទីប្រជុំជន ដែលតម្លៃមធ្យមបានថយចុះពី 4.27 ក្នុងអំឡុងពេលអធិការកិច្ច មកត្រឹម 3.98 ក្រោយពេលអធិការកិច្ច។ លទ្ធផលនេះបញ្ជាក់ថាគ្រូបង្រៀននៅតំបន់ជនបទភាគច្រើនបានផ្តល់តម្លៃដល់ការងារអធិការកិច្ច និងទទួលយកការកែលម្អតាមរយៈអនុសាសន៍ និងរបាយការណ៍ពីក្រុមអធិការកិច្ច ប៉ុន្តែគ្រូបង្រៀននៅតំបន់ទីប្រជុំជនមួយចំនួនមានបម្រុងប្រយ័ត្នលើការងារបង្រៀន និងរៀនតែក្នុងពេលថ្ងៃចុះអធិការកិច្ច ប៉ុន្តែបានចាប់អារម្មណ៍តិចតួចណាស់ចំពោះកែលម្អរបស់ក្រុមអធិការកិច្ចតាមរយៈការផ្តល់អនុសាសន៍ និងរបាយការណ៍អធិការកិច្ច ហើយភាគច្រើននៃគ្រូបង្រៀនទាំងនោះ ហាក់ទទួលយកការណែនាំដោយផ្ទាល់មាត់ ជាជាងការណែនាំដោយការសរសេរក្នុងរបាយការណ៍។

| ផ្នែក | ផ្នែករង | ជនបទ $(N = 44)$ | ប្រជុំជន $(N = 50)$ | គម្លាត |
|---|---|---|---|---|
| មុនពេលអធិការកិច្ច | ទំនាក់ទំនងរវាងគ្រូ និងអធិការ | 4.40 | 4.31 | 0.09 |
| | ការផ្តល់ព័ត៌មាន | 3.98 | 3.64 | 0.34 |
| | ការគោរពពេលវេលា | 4.41 | 4.10 | 0.31 |
| | ការត្រៀមលក្ខណៈរបស់គ្រូ | 4.06 | 3.74 | 0.32 |
| | ***សរុប*** | ***4.21*** | ***3.94*** | ***0.27*** |
| អំឡុងពេលអធិការកិច្ច | ពេលសង្កេតថ្នាក់រៀន | 4.33 | 4.24 | 0.09 |
| | ការបង្រៀន និងរៀន | 4.29 | 4.28 | 0.01 |
| | ការសម្ភាស | 4.47 | 4.30 | 0.17 |
| | ***សរុប*** | ***4.37*** | ***4.27*** | ***0.1*** |
| ក្រោយពេលអធិការកិច្ច | ការផ្តល់អនុសាសន៍ | 4.51 | 4.30 | 0.21 |
| | របាយការណ៍អធិការកិច្ច | 4.23 | 3.66 | 0.57 |
| | ***សរុប*** | ***4.37*** | ***3.98*** | ***0.39*** |
| សរុបរួម | | **4.32** | **4.06** | **0.26** |

***តារាង 59៖*** *តារាងសង្ខេបស្តីពី ឥរិយាបថគ្រូបង្រៀនចំពោះអធិការកិច្ច ផ្អែកតាមទីតាំងសាលារៀន*

*រូបភាព 5៖ ភាពខុសគ្នានៃឥរិយាបថគ្រូបង្រៀននៅតំបន់ជនបទ និងតំបន់ទីប្រជុំជន*




### ៤.១.៣ ឥរិយាបថគ្រូបង្រៀនបឋមសិក្សា ចំពោះអធិការកិច្ច ផ្អែកលើបទពិសោធន៍ការងារ

ចំពោះការសិក្សាលើប្រធានបទ ឥរិយាបថគ្រូបង្រៀនបឋមសិក្សាចំពោះអធិការកិច្ចលើការបង្រៀននេះដែរ អ្នកស្រាវជ្រាវធ្វើការប្រៀបធៀបឥរិយាបថគ្រូបង្រៀនដោយផ្អែកលើបទពិសោធន៍ការងារដែលបានបែងចែកជា៥ផ្នែកគឺ៖ តិចជាងមួយឆ្នាំ , ពី១ដល់៣ឆ្នាំ , ពី៤ដល់៦ឆ្នាំ , ពី៧ដល់៩ឆ្នាំ និងលើស១០ឆ្នាំ។ ការសិក្សាលើផ្នែកនេះ អ្នកស្រាវជ្រាវផ្ដោតតែលើកម្រងសំណួរគ្រូបង្រៀនតែមួយគត់ ចំពោះកម្រងសំណួរសម្រាប់នាយក/នាយិកា និងសិស្ស មិនត្រូវបានយកមកវិភាគទេ ព្រោះបទពិសោធន៍នាយក/នាយិកា លើការបង្រៀនមិនអាចឆ្លុះបញ្ចាំងអំពីឥរិយាបថគ្រូបង្រៀន ដោយផ្អែកលើបទពិសោធន៍ការងារបង្រៀនបានទេ។

| **បទពិសោធន៍ជាគ្រូបង្រៀន** | **ចំនួន** | **លេខរៀងគ្រូបង្រៀនបំពេញកម្រងសំណួរ** |
|---|---|---|
| តិចជាង១ឆ្នាំ | ៦នាក់ | ៥,៨,១៦,២១,២២ និង ៤៩ |
| ១ឆ្នាំ ដល់៣ឆ្នាំ | ១០នាក់ | ១,៣,៦,៧,១០,១២,១៥,២០,៤៨ និង ៧៣ |
| ៤ឆ្នាំ ដល់៦ឆ្នាំ | ៨នាក់ | ៤,៩,១១,១៤,១៨,៤៥,៤៦ និង ៤៧ |

| | | |
|---|---|---|
| ៧ឆ្នាំ ដល់៩ឆ្នាំ | ៨នាក់ | ២,១៩,៤០,៤៣,៤៤,៥១, ៥៦,៥៨ |
| ច្រើនជាង១០ឆ្នាំ | ៦២នាក់ | ១៣,១៧,២៣,២៤,២៥,២៦,២៧,២៨,២៩,៣០,៣១,៣២ ៣៣,៣៤,៣៥,៣៦,៣៧,៣៨,៣៩,៤១,៤២,៥០,៥២,៥៣ ៥៤,៥៥,៥៧, និងពី៥៩ ដល់ ៩៤ |

### ៤.១.៣.១ ឥរិយាបថគ្រូបង្រៀន មុនពេលអធិការកិច្ច ផ្អែកលើបទពិសោធន៍ការងារ

ក្នុងផ្នែកនេះ អ្នកសិក្សាស្រាវជ្រាវនឹងធ្វើការបកស្រាយលទ្ធផល ដែលបង្ហាញពីឥរិយាបថគ្រូបង្រៀនមុនពេលអធិការកិច្ចផ្អែកលើរយៈពេលបម្រើការងារ ដែលរួមមានទំនាក់ទំនងរវាងគ្រូបង្រៀន និងក្រុមអធិការកិច្ច ការទទួលព័ត៌មាន ការគោរពពេលវេលារបស់ក្រុមអធិការកិច្ច និងការត្រៀមលក្ខណៈសម្រាប់ការចុះអធិការកិច្ច។

**A. ទំនាក់ទំនងរវាងគ្រូបង្រៀន និងអធិការកិច្ច**

ចំពោះទំនាក់ទំនងរវាងគ្រូបង្រៀន និងក្រុមអធិការកិច្ច តាមតារាង 60 បានបង្ហាញថាគ្រូបង្រៀនដែលទើបចេញបង្រៀនឆ្នាំទី១បានយល់សបស្របខ្ពស់ជាងគេលើមធ្យមភាព 4.60 ហើយគ្រូបង្រៀនដែលមានបទពិសោធន៍ការងារពី៤ឆ្នាំទៅ៦ឆ្នាំ មានការយល់ស្របទាបជាងគេលើមធ្យមភាពពិន្ទុ 4.08។ លទ្ធផលនេះបង្ហាញថាគ្រូបង្រៀនថ្មីថ្មោងឱ្យតម្លៃខ្លាំងទៅលើក្រុមអធិការកិច្ច ដោយគាត់យល់ថាក្រុមអធិការកិច្ចជាអ្នកមានចំណេះដឹង មានបទពិសោធន៍លើការបង្រៀនគ្រប់គ្រាន់ ជាអ្នកអប់រំ និងជាគំរូទៅដល់គ្រូបង្រៀន។ ជាក់ស្តែង គ្រូបង្រៀនទី១៦ បានលើកឡើងថា "*ក្រុមអធិការចេះគោរព ចេះគួរសមចំពោះគ្រូ និងសិស្ស*" និងគ្រូបង្រៀនទី២២ បានបញ្ចេញយោបល់ថា "*ក្រុមអធិការកិច្ចចេះគោរព និងផ្តល់តម្លៃឱ្យគ្នាទៅវិញទៅមក*" ផ្ទុយទៅវិញគ្រូបង្រៀនដែលមានបទពិសោធន៍មធ្យម ពោលចន្លោះពី៤ឆ្នាំទៅ៦ឆ្នាំ មានការយល់ស្របឃើញទាបជាងគេ ដោយសារគាត់ធ្លាប់មានបទពិសោធន៍លើការបង្រៀន បានការឆ្លងកាត់ការវាយតម្លៃពីនាយក/ នាយិការួចរាល់ និងតាមបទពិសោធន៍របស់គាត់ឃើញថា អធិការកិច្ចលើការបង្រៀនធ្វើយូរៗម្តង ធ្វើឱ្យគាត់មានការចាប់អារម្មណ៍តិចតួចចំពោះការធ្វើអធិការកិច្ចលើការបង្រៀននិងរៀននេះ ជាក់ស្តែង គ្រូបង្រៀនទី១១ បាន

ឆ្លើយថា " *ទំនាក់ទំនងរវាងគ្រូ និងក្រុមអធិការ មិនល្អព្រោះ មិនសូវបានជួបទេគឺមួយឆ្នាំអធិការកិច្ចចុះមកតែមួយដង*"។ ម្យ៉ាងទៀត ក្នុងសូចនាករទី៤ "ការចុះអធិការកិច្ចបានផ្តល់អត្ថប្រយោជន៍ដល់ការបង្រៀន និងរៀនជាច្រើនគឺជួយជំរុញឱ្យការបង្រៀននិងរៀនឱ្យកាន់តែមានប្រសិទ្ធភាព" គ្រូបង្រៀនមានបទពិសោធន៍តិចជាងមួយឆ្នាំបានយល់ស្របខ្ពស់ជាងគេ លើមធ្យមភាពពិន្ទុ 4.83 ធៀបនឹងគ្រូបង្រៀនមានបទពិសោធន៍លើការបង្រៀនពី៤ ទៅ៦ឆ្នាំមានកម្រិតយល់ស្របទាបជាងគេ មានមធ្យមភាគពិន្ទុ 4.00។

សរុបមកគ្រូបង្រៀនបឋមសិក្សាមានឥរិយាបថវិជ្ជមានលើទំនាក់ទំនងរវាងក្រុមអធិការ និងគ្រូបង្រៀនដូចគ្នាទោះបីជាពួកគាត់មានបទពិសោធន៍លើការបង្រៀនខុសគ្នាក៏ដោយ ប៉ុន្តែគ្រូបង្រៀនដែលមានបទពិសោធន៍បង្រៀនតិចជាងមួយឆ្នាំមានការយល់ស្របខ្ពស់ជាងគេ ហើយគ្រូបង្រៀនមានបទពិសោធន៍បង្រៀនពី៤ឆ្នាំទៅ៦ឆ្នាំ មានការយល់ស្របទាបជាងគេ។

| ល.រ | **បរិយាយ** | **តម្លៃមធ្យម** | | | | |
|---|---|---|---|---|---|---|
| | **A. ទំនាក់ទំនងរវាងគ្រូបង្រៀន និងអធិការកិច្ច** | **< ១ឆ្នាំ** $(N=6)$ | **១-៣ឆ្នាំ** $(N=10)$ | **៤-៦ឆ្នាំ** $(N=8)$ | **៧-៩ឆ្នាំ** $(N=8)$ | **>១០ឆ្នាំ** $(N=62)$ |
| ១ | ក្រុមអធិការបានយល់ច្បាស់ពីតម្រូវការរបស់គ្រូបង្រៀន | 4.33 | 4.00 | 3.63 | 4.25 | 4.06 |
| ២ | ក្រុមអធិការមានអាកប្បកិរិយាសំដែងចេញភាពជាគំរូ និងជាអ្នកអប់រំ | 4.50 | 4.20 | 4.00 | 4.63 | 4.44 |
| ៣ | ក្រុមអធិការបានសម្តែងអាកប្បកិរិយាស្និទ្ធស្នាលជាមួយ លោកគ្រូ/អ្នកគ្រូដោយគ្មានការរើសអើង | 4.67 | 4.40 | 4.50 | 4.63 | 4.47 |
| ៤ | ការចុះអធិការកិច្ចបានផ្តល់អត្ថប្រយោជន៍ | 4.83 | 4.60 | 4.00 | 4.63 | 4.50 |

| | | | | | | |
|---|---|---|---|---|---|---|
| | ដល់ការបង្រៀន និងរៀនជាច្រើនគឺជួយជំរុញឱ្យការបង្រៀននិងរៀនឱ្យកាន់តែមានប្រសិទ្ធភាព | | | | | |
| ៥ | គ្រូបង្រៀន យល់ថាអធិការមានចំណេះដឹង និងបទពិសោធន៍គ្រប់គ្រាន់លើការបង្រៀន និងរៀន | 4.67 | 4.20 | 4.25 | 4.25 | 4.32 |
| សរុប | | 4.60 | 4.28 | 4.08 | 4.48 | 4.36 |

***តារាង 60៖** ទំនាក់ទំនងរវាងគ្រូបង្រៀន និងក្រុមអធិការកិច្ច ផ្អែកលើបទពិសោធន៍នៃការបង្រៀន*

**B. ការផ្តល់ព័ត៌មាន**

ចំពោះការផ្តល់ព័ត៌មានរបស់ក្រុមអធិការកិច្ចទៅដល់គ្រូបង្រៀនវិញ តាមតារាង 61 បានបង្ហាញថាគ្រូបង្រៀនមានបទពិសោធន៍លើការបង្រៀនខុសគ្នា មានការយល់ស្របកម្រិតខុសគ្នាមានតម្លៃមធ្យមចន្លោះពី 3.58 ដល់ 4.13 ហើយយើងបានសង្កេតឃើញផងដែរ ថាគ្រូបង្រៀនមានបទពិសោធន៍តិចជាងមួយឆ្នាំមានការយល់ស្របខ្ពស់ជាងគេ និងគ្រូបង្រៀនមានបទពិសោធន៍ពី៤ឆ្នាំទៅ៦ឆ្នាំ មានការយល់ស្របទាបជាងគេ។ គ្រូបង្រៀនមានបទពិសោធន៍តិចជាងមួយឆ្នាំ បានដឹងព័ត៌មានពីការចុះអធិការកិច្ចខ្ពស់ជាងគេ ហើយគាត់ពិតជាចង់ដឹងពីព័ត៌មានអំពីការចុះអធិការកិច្ចថ្នាក់រៀន មុនពេលថ្ងៃចុះអធិការកិច្ចមកដល់ ជាក់ស្តែងគ្រូបង្រៀនទី៥បានលើកឡើងថា"*គាត់បានទទួលព័ត៌មានគ្រប់គ្រាន់អំពីអធិការកិច្ច ព្រោះក្រុមអធិការកិច្ចបានផ្តល់ព័ត៌មានជាមុន*" និងគ្រូបង្រៀនទី២១បានលើកឡើងថា "*គាត់ទទួលបានព័ត៌មានគ្រប់គ្រាន់ ព្រោះក្រុមអធិការបានណែនាំពីការចុះអធិការកិច្ច និងត្រួតពិនិត្យ*"។ ចំណែកគ្រូបង្រៀនមានបទពិសោធន៍ពី៤ឆ្នាំ ទៅ៦ឆ្នាំបានដឹងពីព័ត៌មានការចុះអធិការកិច្ចថ្នាក់រៀនតិចជាងគេ មិនទាន់យល់ច្បាស់ពីគោលបំណងនៃការចុះអធិការកិច្ចនៅឡើយ ជាពិសេសគាត់មិនទាន់ដឹងច្បាស់ពីអ្វីដែលអធិការត្រូវពិនិត្យនៅអធិការកិច្ចថ្នាក់រៀននៅឡើយទេ

ដាក់ស្តែងគ្រូបង្រៀនទី៤៥ "*គាត់ទទួលព័ត៌មានពុំបានគ្រប់គ្រាន់នៅឡើយ ទាំងគោលបំណង និងកម្មវិធីនៃការចុះអធិការកិច្ច*" ។

| ល.រ | បរិយាយ | តម្លៃមធ្យម | | | | |
|---|---|---|---|---|---|---|
| | B. ការផ្តល់ព័ត៌មាន | < ១ឆ្នាំ $(N=6)$ | ១-៣ឆ្នាំ $(N=10)$ | ៤-៦ឆ្នាំ $(N=8)$ | ៧-៩ឆ្នាំ $(N=8)$ | >១០ឆ្នាំ $(N=62)$ |
| ១ | គ្រូបង្រៀនបានដឹងព័ត៌មាន ពីការចុះអធិការកិច្ចថ្នាក់រៀន | 4.00 | 3.80 | 3.38 | 3.63 | 3.81 |
| ២ | គ្រូបង្រៀនចង់ដឹងពីព័ត៌មានអំពីការចុះអធិការកិច្ចថ្នាក់រៀន មុនពេលថ្ងៃចុះអធិការកិច្ច | 4.67 | 4.40 | 4.63 | 4.25 | 4.10 |
| ៣ | គ្រូបង្រៀនបានយល់ច្បាស់ពីគោលបំណងនៃការចុះអធិការកិច្ច លើការបង្រៀននិងរៀន | 4.00 | 3.90 | 3.63 | 4.25 | 3.89 |
| ៤ | គ្រូបង្រៀនបានដឹងពីកម្មវិធីនៃការចុះអធិការកិច្ចថ្នាក់រៀន | 3.83 | 3.60 | 3.00 | 3.38 | 3.39 |
| ៥ | លោកគ្រូ/អ្នកគ្រូ ដឹងពីអ្វីដែលអធិការត្រូវពិនិត្យនៅអធិការកិច្ចថ្នាក់រៀន | 4.17 | 3.90 | 3.25 | 4.00 | 3.61 |
| សរុប | | 4.13 | 3.92 | 3.58 | 3.90 | 3.76 |

***តារាង 61៖*** *តរិយាបថគ្រូបង្រៀន លើការផ្តល់ព័ត៌មានរបស់ក្រុមអធិការកិច្ច ផ្អែកលើបទពិសោធន៍នៃការបង្រៀន*

### C. ការគោរពពេលវេលា

ចំពោះការគោរពពេលវេលាអធិការកិច្ច របស់ក្រុមអធិការ ឃើញថាកម្រិតយល់ស្របរបស់គ្រូបង្រៀនមានមធ្យមភាគពិន្ទុចន្លោះពី4.17 ដល់4.26 (តារាង 62)។ គ្រូបង្រៀនមានបទពិសោធន៍តិចជាងមួយឆ្នាំមានយល់ស្របខ្ពស់ជាងគេ ដោយបានឯកភាពថាក្រុមអធិការកិច្ចបានគោរពពេលវេលាក្នុងការចុះអធិការកិច្ច និងបានចុះសង្កេតថ្នាក់រៀនតាមកម្មវិធីដែលបានកំណត់។ ផ្ទុយពីគ្រូបង្រៀនមានបទពិសោធន៍ចន្លោះឆ្នាំ៤ឆ្នាំ ទៅ៦ឆ្នាំ ដែលមានការយល់ស្របទាបជាងគេ ដោយគាត់យល់ថាក្រុមអធិការចុះសង្កេតថ្នាក់រៀនតាមកម្មវិធីអធិការកិច្ចដែលបានកំណត់នៅមានកម្រិត។ លទ្ធផលនេះបង្ហាញថា នៅពេលដែលគ្រូបង្រៀនមិនបានទទួលព័ត៌មានគ្រប់គ្រាន់ពីការចុះអធិការកិច្ច គាត់នឹងមិនដឹងច្បាស់ពីពេលវេលាច្បាស់លាស់នៃការធ្វើអធិការកិច្ចក៏ដូចកម្មវិធីនៃការចុះអធិការកិច្ចដែរ។

| ល.រ | បរិយាយ | តម្លៃមធ្យម | | | | |
|---|---|---|---|---|---|---|
| | C. ការគោរពពេលវេលា | < ១ឆ្នាំ $(N=6)$ | ១-៣ឆ្នាំ $(N=10)$ | ៤-៦ឆ្នាំ $(N=8)$ | ៧-៩ឆ្នាំ $(N=8)$ | >១០ឆ្នាំ $(N=62)$ |
| ១ | ក្រុមអធិការកិច្ច បានគោរពពេលវេលាក្នុងការចុះអធិការកិច្ចបានត្រឹមត្រូវ | 4.67 | 4.60 | 4.38 | 4.38 | 4.50 |
| ២ | គ្រូបង្រៀនដឹងពីពេលវេលានៃការចុះអធិការកិច្ចថ្នាក់រៀន | 4.50 | 4.10 | 4.13 | 4.13 | 3.87 |
| ៣ | ក្រុមអធិការចុះសង្កេតថ្នាក់រៀនតាមកម្មវិធីអធិការកិច្ចដែលបានកំណត់ | 4.50 | 4.10 | 4.00 | 4.13 | 4.31 |
| សរុប | | 4.56 | 4.27 | 4.17 | 4.21 | 4.23 |

***តារាង 62៖*** *តរិយាបថគ្រូបង្រៀន លើការគោរពពេលវេលារបស់ក្រុមអធិការកិច្ច ផ្អែកលើបទពិសោធន៍នៃការបង្រៀន*

### D. ការត្រៀមលក្ខណៈ

ចំពោះការត្រៀមលក្ខណៈរបស់គ្រូបង្រៀន មុនពេលថ្ងៃអធិការកិច្ច តាម តារាង 63 បង្ហាញថា កម្រិតយល់ស្របរបស់គ្រូបង្រៀនផ្អែកលើបទពិសោធន៍នៃការបង្រៀន មានមធ្យមភាគពិន្ទុចន្លោះ3.75 ដល់4.13។ គ្រូបង្រៀនមានបទពិសោធន៍តិចជាងមួយឆ្នាំ មានការយល់ស្របខ្ពស់ជាងគេ ដោយគាត់មានបំណងចង់ឱ្យអធិការកិច្ចពិនិត្យមើលលើការបង្រៀនរបស់ខ្លួន ដោយមិនមានការព្រួយបារម្ភ ខ្វល់ខ្វាយនៅពេលមានការចុះអធិការកិច្ចថ្នាក់រៀនទេ។ ចំណុចនេះបង្ហាញថា គ្រូបង្រៀនមានបទពិសោធន៍បង្រៀនតិចឆ្នាំ មានឆន្ទៈខ្ពស់ក្នុងការអភិវឌ្ឍសមត្ថភាពរបស់ខ្លួនតាមរយៈការអធិការកិច្ច ហើយគាត់បានត្រៀមលក្ខណៈបានល្អសម្រាប់អធិការកិច្ច ជាក់ស្តែងគ្រូបង្រៀនទី ២១ បានឆ្លើយថា "*មុនពេលអធិការកិច្ច គាត់បានត្រៀមលក្ខណៈដូចជា ត្រៀមកិច្ចតែងការ សម្ភារបង្រៀន ការបង្រៀនក្នុងថ្នាក់រៀន រួមទាំង បញ្ជីហៅឈ្មោះ បញ្ជីស្រង់ពិន្ទុ* " ហើយគ្រូបង្រៀនទី៥ បានបង្ហាញថា "*គាត់បានត្រៀមរួចជាស្រេចមុនពេលការចុះអធិការកិច្ច ព្រោះដើម្បីទទួលបានលទ្ធផលល្អ*"។ ចំណែកឯគ្រូបង្រៀន មានបទពិសោធន៍ពី១ឆ្នាំ ដល់៣ឆ្នាំ មានការយល់ស្របតិចជាងគេ ចំពោះការត្រៀមលក្ខណៈសម្រាប់ការចុះអធិការកិច្ចលើការបង្រៀន និងរៀន ដោយគាត់មានអារម្មណ៍ព្រួយបារម្ភ ខ្វល់ខ្វាយតិចតួចនៅពេលបង្រៀន និងមិនបានសម្តែងការចង់បានឱ្យមានការសង្កេតការបង្រៀនគាត់ទេ ទោះបីគាត់បានត្រៀមឯកសារ សម្ភារបង្រៀន និងរៀបចំថ្នាក់រៀនហើយក្តី ដូចការលើកឡើងរបស់គ្រូបង្រៀនទី៦ថា "*គាត់បានត្រៀមឯកសារ ដែលពាក់ព័ន្ធទុកសម្រាប់ការត្រួតពិនិត្យរបស់ក្រុមអធិការ ព្រោះមិនចង់ឱ្យមានបញ្ហា*" និងគ្រូបង្រៀនទី៧ បានឆ្លើយថា "*គាត់បានត្រៀមសម្រាប់ការចុះអធិការកិច្ច ព្រោះមិនចង់ឱ្យមានចំនុចខ្វះខាតលើការបង្រៀន និងមិនចង់ឱ្យមានការរិះគន់អាក្រក់*" ។

សរុបមកមុនពេលអធិការកិច្ច គ្រូបង្រៀនភាគច្រើនបានត្រៀមលក្ខណៈរួចរាល់សម្រាប់ការធ្វើអធិការកិច្ច រួមមានការរៀបចំកិច្ចតែងការ ការរៀបចំសម្ភារបង្រៀន ការរៀបចំអនាម័យថ្នាក់រៀន និងឯកសារនានាសម្រាប់អធិការកិច្ច។ ប៉ុន្តែការត្រៀមលក្ខណៈនេះមានកម្រិតខុសគ្នាទៅតាមបទពិសោធន៍នៃការបង្រៀនគឺ គ្រូ

បង្រៀនមានបទពិសោធន៍តិចជាងមួយឆ្នាំមានឥរិយាបថវិជ្ជមានខ្ពស់ជាងគេ និងគ្រូបង្រៀនមានបទពិសោធន៍ពី១ឆ្នាំដល់៣ឆ្នាំមានឥរិយាបថវិជ្ជមានកម្រិតទាបជាងគេ។

***តារាង 63៖** ឥរិយាបថគ្រូបង្រៀនលើការត្រៀមលក្ខណៈសម្រាប់ការចុះអធិការកិច្ច ផ្អែកលើបទពិសោធន៍នៃការបង្រៀន*

| ល.រ | **បរិយាយ** | **តម្លៃមធ្យម** | | | | |
|---|---|---|---|---|---|---|
| | **D. ការត្រៀមលក្ខណៈ** | **< ១ឆ្នាំ** $(N=6)$ | **១-៣ឆ្នាំ** $(N=10)$ | **៤-៦ឆ្នាំ** $(N=8)$ | **៧-៩ឆ្នាំ** $(N=8)$ | **>១០ឆ្នាំ** $(N=62)$ |
| ១ | គ្រូបង្រៀនតែងមានអារម្មណ៍ធម្មតាចំពោះការចុះធ្វើអធិការកិច្ច | 3.67 | 3.50 | 3.75 | 3.88 | 3.85 |
| ២ | គ្រូបង្រៀនមិនមានការព្រួយបារម្ភ ខ្វល់ខ្វាយនៅពេលមានការចុះអធិការកិច្ចថ្នាក់រៀនទេ | 4.00 | 3.30 | 3.88 | 3.63 | 3.42 |
| ៣ | គ្រូបង្រៀន បានត្រៀមលក្ខណៈបានល្អ នៅថ្ងៃធ្វើអធិការកិច្ច | 4.17 | 4.10 | 3.88 | 4.25 | 4.13 |
| ៤ | គ្រូបង្រៀនចង់ឱ្យអធិការ ពិនិត្យមើលលើការបង្រៀនរបស់ខ្លួន | 4.67 | 4.10 | 4.25 | 4.13 | 4.06 |
| សរុប | | 4.13 | 3.75 | 3.94 | 3.97 | 3.87 |

ក្នុងផ្នែកទី១ ឥរិយាបថគ្រូបង្រៀនមុនពេលអធិការកិច្ចលើការបង្រៀន និងរៀន ក្នុងតារាង 64 បង្ហាញថាគ្រូបង្រៀនគ្រូបង្រៀនទាំងអស់មានឥរិយាបថវិជ្ជមាន មុនពេលអធិការកិច្ចលើការបង្រៀននិងរៀន។ គ្រូបង្រៀនមានបទពិសោធន៍តិចជាង១ឆ្នាំ មានឥរិយាបថវិជ្ជមានខ្ពស់ជាងគេ ដោយសារគាត់ជាគ្រូបង្រៀនថ្មី គាត់មានការប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់ចំពោះការបង្រៀនរបស់ខ្លួន ជាពិសេសគាត់បានឱ្យតម្លៃខ្ពស់

ចំពោះការងារអធិការកិច្ច ដោយយល់ថាក្រុមអធិការជាអ្នកអប់រំ ជាអ្នកមានបទពិសោធន៍ច្រើនលើការបង្រៀន ជាអ្នកផ្តល់គំរូដល់គ្រូបង្រៀនដទៃ និងបានត្រៀមអ្វីៗដែលពាក់ព័ន្ធនឹងការបង្រៀនសម្រាប់ការចុះអធិការកិច្ចលើការបង្រៀន និងរៀន។ ទោះបីយ៉ាងនេះក្តី គ្រូបង្រៀនមានបទពិសោធន៍ពី៤ឆ្នាំទៅ៦ឆ្នាំមានឥរិយាបថវិជ្ជមានកម្រិតទាបជាងគេមុនពេលអធិការកិច្ចលើការបង្រៀន និងរៀន ដោយមូលហេតុថាស្ថានភាពនេះ គាត់មានបទពិសោធន៍ល្មមគ្រប់គ្រាន់លើការបង្រៀន គាត់បានយកចិត្តទុកដាក់តិចតួចលើផលប្រយោជន៍ចំពោះការធ្វើអធិការកិច្ច ឬអាចមកពីក្រុមអធិការមិនបានបញ្ជូនព័ត៌មានទៅដល់សាលារៀនក៏ដូចជាគ្រូបង្រៀន និងមិនបានពន្យល់ពីគោលបំណងនៃអធិការកិច្ចឱ្យបានច្បាស់លាស់ទៅដល់គ្រូបង្រៀនមុនពេលអធិការកិច្ច។

| **បរិយាយ** | | **តម្លៃមធ្យម** | | | | |
|---|---|---|---|---|---|---|
| **ផ្នែកទី១៖មុនពេលអធិការកិច្ច** | | **< ១ឆ្នាំ** $(N=6)$ | **១-៣ឆ្នាំ** $(N=10)$ | **៤-៦ឆ្នាំ** $(N=8)$ | **៧-៩ឆ្នាំ** $(N=8)$ | **>១០ឆ្នាំ** $(N=62)$ |
| A | ទំនាក់ទំនងរវាងគ្រូបង្រៀន និងក្រុមអធិការកិច្ច | 4.60 | 4.28 | 4.08 | 4.48 | 4.36 |
| B | ការទទួលព័ត៌មានអំពីការចុះអធិការកិច្ចថ្នាក់រៀន | 4.13 | 3.92 | 3.58 | 3.90 | 3.76 |
| C | ការគោរពពេលវេលារបស់ក្រុមអធិការកិច្ច | 4.13 | 3.75 | 3.94 | 3.97 | 3.87 |
| D | ការត្រៀមលក្ខណៈរបស់គ្រូបង្រៀន | 4.13 | 3.75 | 3.94 | 3.97 | 3.87 |
| សរុប | | 4.35 | 4.05 | 3.94 | 4.14 | 4.05 |

***តារាង 64៖*** *ឥរិយាបថគ្រូបង្រៀន មុនពេលអធិការកិច្ច ផ្អែកលើបទពិសោធន៍នៃការបង្រៀន*

### ៤.១.៣.២ ឥរិយាបថគ្រូបង្រៀន អំឡុងពេលអធិការកិច្ចផ្អែកលើបទពិសោធន៍ការងារ

#### A. ការសង្កេតថ្នាក់រៀន

ក្នុងផ្នែកនេះអ្នកស្រាវជ្រាវនឹងធ្វើការប្រៀបធៀបបន្តទៅទៅលើឥរិយាបថគ្រូបង្រៀនផ្អែកលើរយៈពេលបំពេញការងារ ក្នុងអំឡុងពេលអធិការកិច្ច ពោលគឺពេលអធិការកិច្ចសង្កេតថ្នាក់រៀន សង្កេតលើការបង្រៀន

និងពេលអធិការសម្ភាសគ្រូ។

តាមតារាង 65 បង្ហាញពីមធ្យមភាពនៃការយល់ស្របរបស់គ្រូបង្រៀនតាមបទពិសោធន៍លើការបង្រៀនខុសគ្នា ចំពោះការសង្កេតថ្នាក់របស់អធិការកិច្ច។ ជាលទ្ធផលយើងឃើញកម្រិតយល់ស្របមានមធ្យមភាគពិន្ទុចន្លោះ 3.67 ដល់ 3.81។ គ្រូបង្រៀនមានបទពិសោធន៍បង្រៀនពី១ឆ្នាំទៅ៣ឆ្នាំ បានយល់ស្របខ្ពស់ជាងគេចំពោះសកម្មភាពអធិការកិច្ចនៅក្នុងថ្នាក់រៀន ដោយគាត់បានយល់ថាអធិការបានយកចិត្តទុកដាក់លើស្ថានភាពថ្នាក់រៀន និងសកម្មភាពនានាក្នុងថ្នាក់រៀនផងដែរ។ ចំណែកឯគ្រូបង្រៀនមានបទពិសោធន៍ចន្លោះពី៤ឆ្នាំទៅ៩ឆ្នាំ មានការយល់ស្របកម្រិតទាបជាងគេ ដែលមានតម្លៃមធ្យមងាកទៅរកកម្រិត "មធ្យម" ដោយគាត់យល់ថាអធិការកិច្ចបានផ្តោតទៅលើគ្រូបង្រៀនច្រើនជាងស្ថានភាពថ្នាក់រៀនទាំងមូល ជាពិសេសគឺមើលចំណុចដែលត្រូវកែលម្អរបស់គ្រូលើការបង្រៀន និងរៀន ច្រើនជាងចំណុចល្អដែលគ្រូមានស្រាប់។ ជាក់ស្តែងសូចនាករទី៤ "អធិការកិច្ចពិនិត្យមើលចំណុចល្អ ច្រើនជាងចំណុចដែលត្រូវកែលម្អលើ ការបង្រៀន និងរៀន" គ្រូមានបទពិសោធន៍ពី១ឆ្នាំទៅ៦ឆ្នាំ មានការយល់ស្របទាបជាងគេកម្រិត "មធ្យម" លើមធ្យមភាគពិន្ទុ 3.50 និង 3.25។ ចំណែកឯសូចនាករទី៣ "អធិការប្រើប្រាស់ឧបករណ៍គ្រប់គ្រាន់ និងមានប្រសិទ្ធភាព ក្នុងពេលធ្វើអធិការកិច្ចលើការបង្រៀនរបស់គ្រូ" គ្រូមានបទពិសោធន៍ពី៤ឆ្នាំទៅ៦ឆ្នាំ មានការយល់ស្របទាបជាងគេ ងាកទៅរកកម្រិតមធ្យម 3.75។ ចំណុចនេះបង្ហាញថាគ្រូបង្រៀនដែលមានបទពិសោធន៍មធ្យម ចន្លោះពី៤ឆ្នាំទៅ៩ឆ្នាំ បានយល់ថាអធិការកិច្ចក្នុងថ្នាក់រៀនទោះតិចឬច្រើនបានស្វែងរកកំហុសរបស់គ្រូបង្រៀន ច្រើនជាងការស្វែងរកចំណុចល្អរបស់គ្រូបង្រៀន ហើយគ្រូបង្រៀននៅមិនទាន់ឯកភាពទាំងស្រុងចំពោះប្រសិទ្ធភាពនៃការប្រើប្រាស់ឧបករណ៍អធិការកិច្ច ក្នុងការសង្កេតថ្នាក់នៅឡើយទេ។

| ល.រ | បរិយាយ | តម្លៃមធ្យម | | | | |
|---|---|---|---|---|---|---|
| | A. ការសង្កេតថ្នាក់រៀន | < ១ឆ្នាំ $(N=6)$ | ១-៣ឆ្នាំ $(N=10)$ | ៤-៦ឆ្នាំ $(N=8)$ | ៧-៩ឆ្នាំ $(N=8)$ | >១០ឆ្នាំ $(N=62)$ |

| | | | | | | |
|---|---|---|---|---|---|---|
| ១ | អធិការបានផ្តោតខ្លាំងទៅលើបរិបទ ឬស្ថានភាពរបស់ថ្នាក់រៀននីមួយៗ | 3.83 | 4.60 | 4.25 | 4.13 | 4.03 |
| ២ | អធិការបានយកចិត្តទុកដាក់គ្រប់សកម្មភាពទាំងអស់នៅក្នុងថ្នាក់រៀន ពេលលោកគ្រូ/អ្នកគ្រូបង្រៀន | 4.67 | 4.70 | 4.25 | 4.50 | 4.50 |
| ៣ | អធិការប្រើប្រាស់ឧបករណ៍គ្រប់គ្រាន់ និងមានប្រសិទ្ធភាព ក្នុងពេលធ្វើអធិការកិច្ចលើការបង្រៀនរបស់គ្រូ | 4.17 | 4.00 | 3.75 | 4.00 | 4.23 |
| ៤ | អធិការកិច្ចពិនិត្យមើលចំណុចល្អ ច្រើនជាងចំណុចដែលត្រូវកែលម្អលើ ការបង្រៀន និងរៀន | 3.83 | 3.50 | 3.25 | 3.75 | 3.94 |
| ៥ | ក្រុមអធិការមិនបានរំខានដល់ការបង្រៀនរបស់គ្រូបង្រៀនឡើយ | 4.67 | 4.70 | 4.75 | 4.50 | 4.37 |
| ៦ | ក្រុមអធិការមិនប្រើភាសាគំរោះគំរើយ ឬចំអក និងមិនឡូឡានៅក្នុងថ្នាក់រៀន ឬបង្ហាញទឹកមុខដែលធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍សិស្ស និងគ្រូបង្រៀនឡើយ | 4.67 | 4.60 | 4.75 | 4.38 | 4.60 |
| ៧ | ការចុះធ្វើអធិការកិច្ច មិនបង្កបរិយាកាសស្មុគស្មាញដល់គ្រូក្នុងការបង្រៀន និងរៀនឡើយ | 4.33 | 4.40 | 4.50 | 4.13 | 4.39 |
| សរុប | | 3.77 | 3.81 | 3.69 | 3.67 | 3.76 |

***តារាង 65៖*** *ឥរិយាបថគ្រូបង្រៀន ពេលក្រុមអធិការកិច្ចសង្កេតថ្នាក់រៀន ផ្អែកលើបទពិសោធន៍នៃការបង្រៀន*

### B. ការបង្រៀន

ចំពោះសកម្មភាពបង្រៀនរបស់គ្រូ នៅពេលអធិការសង្កេតថ្នាក់រៀនតាមតារាង 66 បានបង្ហាញថា គ្រូបង្រៀនមានកម្រិតយល់ស្របមានមធ្យមភាពពិន្ទុចន្លោះពី 4.08 ទៅ 4.39។ គ្រូបង្រៀនមានបទពិសោធន៍បង្រៀនតិចជាង1ឆ្នាំបានយល់ស្របខ្ពស់ជាងគេ ដោយគាត់មានការពេញចិត្តចំពោះការងារអធិការកិច្ច ដែលបានសង្កេតលើការបង្រៀនរបស់គាត់ ដោយយល់ថាអធិការជាអ្នកមានបទពិសោធន៍ក្នុងការបង្រៀន និងបានពិនិត្យមើលគ្រប់ជ្រុងជ្រោយក្នុងដំណើរការបង្រៀននៅក្នុងថ្នាក់ ដោយអធិការបានពិនិត្យនិងផ្តល់យោបល់ទៅលើការប្រើប្រាស់កិច្ចតែងការ ការប្រើប្រើសម្ភារឧបទេស និងសកម្មភាពនៃដំណើរការបង្រៀនរបស់ខ្លួន។ ផ្ទុយទៅវិញ គ្រូបង្រៀនមានបទពិសោធន៍បង្រៀនពី១ឆ្នាំ ទៅ៣ឆ្នាំ បានយល់ស្របទាបជាងគេ ចំពោះសកម្មភាពអធិការកិច្ច នៅពេលដែលពួកគាត់បង្រៀន។ ទោះបីជាគាត់ធ្លាប់បង្រៀន តែពួកគាត់មានការស្ទាក់ស្ទើរក្នុងការធ្វើពិសោធន៍វិធីសាស្ត្រថ្មីៗ និងភ័យខ្លាចបង្កកំហុស ហើយគាត់មានអារម្មណ៍ថាខ្លួនមិនទាន់អាចគ្រប់គ្រងថ្នាក់បានល្អនៅឡើយនៅពេលមានការធ្វើការអធិការកិច្ចថ្នាក់រៀន។ ជាក់ស្តែងសូចនាករទី១ ″គ្រូបង្រៀនបានព្យាយាមជំរុញឱ្យសិស្សមានសកម្មភាពច្រើនក្នុងថ្នាក់រៀនពេលមានការចុះអធិការកិច្ច ″ ពួកគាត់មានការយល់ស្របទាបជាងគេលើមធ្យមភាពពិន្ទុ 3.80, សូចនាករទី២ ″គ្រូបង្រៀនគ្រប់គ្រងថ្នាក់រៀនបានល្អពេលមានអធិការចុះសង្កេតថ្នាក់″ មានមធ្យមភាគពិន្ទុ 3.60, សូចនាករទី៣ ″គ្រូបង្រៀនក្លាហានក្នុងការធ្វើពិសោធន៍គំនិតថ្មី / វិធីសាស្ត្រថ្មីៗក្នុងពេលអធិការកិច្ច″ មធ្យមភាពពិន្ទុ 3.90 និងសូចនាករទី៤ ″គ្រូបង្រៀនពេញចិត្តចំពោះសកម្មភាពអធិការកិច្ចនៅក្នុងថ្នាក់រៀន″ មធ្យមភាគពិន្ទុ ៤.១០ និងសូចនាករទី១១ ″អធិការជាអ្នកជួយកែលម្អគ្រូក្នុងពេលបង្រៀន ជាជាងអ្នកស្វែងរកកំហុសរបស់គ្រូ″ មានមធ្យមភាពពិន្ទុ 3.90។

សរុបមកទោះបីជាគ្រូបង្រៀនទាំងអស់បានបង្ហាញឥរិយាបថវិជ្ជមានដូចគ្នា ចំពោះសកម្មភាពអធិការកិច្ចក្នុងថ្នាក់រៀន លើមធ្យមភាពកម្រិត ″ល្អ″ យ៉ាងណាក្តីយើងឃើញថាកម្រិតយល់ស្របទាំងនោះមានភាពខុសគ្នា ដោយគ្រូបង្រៀនមានបទពិសោធន៍តិចជាង១ឆ្នាំបានសម្តែងការពេញចិត្តច្រើនជាងគេចំពោះអធិការកិច្ច

ដោយគាត់បានឱ្យតម្លៃទៅលើចំណេះដឹង បទពិសោធន៍របស់អធិការលើការបង្រៀន ដែលផ្ទុយពីគ្រូបង្រៀនមានបទពិសោធន៍ពី១ឆ្នាំទៅ៣ឆ្នាំ មានការបារម្ភលើសកម្មភាពបង្រៀនខ្លួនឯង ខ្លាចមានកំហុសក្នុងពេលបង្រៀន មិនក្លាហានក្នុងការប្រើវិធីសាស្ត្រថ្មីៗ ជាពិសេសពិបាកក្នុងការគ្រប់គ្រងថ្នាក់ឱ្យបានល្អ ដោយសារគាត់មានគំនិតខ្លះថា អធិការជាអ្នកចាប់កំហុសរបស់គ្រូពេលបង្រៀន ជាជាងអ្នកកែលម្អ។

| ល.រ | បរិយាយ | តម្លៃមធ្យម | | | | |
|---|---|---|---|---|---|---|
| | B. ការបង្រៀន | < ១ឆ្នាំ $(N=6)$ | ១-៣ឆ្នាំ $(N=10)$ | ៤-៦ឆ្នាំ $(N=8)$ | ៧-៩ឆ្នាំ $(N=8)$ | >១០ឆ្នាំ $(N=62)$ |
| ១ | គ្រូបង្រៀនបានព្យាយាមជំរុញឱ្យសិស្សមានសកម្មភាពច្រើនក្នុងថ្នាក់រៀន ពេលមានការចុះអធិការកិច្ច | 3.83 | 3.80 | 3.88 | 4.38 | 4.32 |
| ២ | គ្រូបង្រៀនគ្រប់គ្រងថ្នាក់រៀនបានល្អ ពេលមានអធិការចុះសង្កេតថ្នាក់ | 4.17 | 3.60 | 4.38 | 4.38 | 4.19 |
| ៣ | គ្រូបង្រៀនក្លាហានក្នុងការធ្វើពិសោធន៍គំនិតថ្មី / វិធីសាស្ត្រថ្មីៗ ក្នុងពេលអធិការកិច្ច | 4.33 | 3.90 | 4.38 | 4.25 | 4.03 |
| ៤ | គ្រូបង្រៀនពេញចិត្តចំពោះសកម្មភាពអធិការកិច្ចនៅក្នុងថ្នាក់រៀន | 4.67 | 4.10 | 4.63 | 4.13 | 4.23 |
| ៥ | គ្រូបង្រៀនយល់ថាអធិការជាអ្នកមានបទពិសោធន៍ក្នុងការបង្រៀនបានល្អ | 4.67 | 4.10 | 4.38 | 4.13 | 4.16 |
| ៦ | អធិការមិនជជែកវែកញែកអំពីកំហុសរបស់គ្រូ នៅចំពោះមុខសិស្សឡើយ | 4.00 | 4.10 | 4.50 | 4.50 | 4.42 |

| | | | | | | |
|---|---|---|---|---|---|---|
| ៧ | ក្រុមអធិការពិនិត្យមើលការអនុវត្តកិច្ចតែងការបង្រៀនរបស់គ្រូ | 4.83 | 4.50 | 4.63 | 4.25 | 4.53 |
| ៨ | ក្រុមអធិការពិនិត្យមើលការចាត់តាំងសកម្មភាពរៀន និងបង្រៀននៅក្នុងថ្នាក់រៀន | 4.33 | 4.40 | 4.38 | 4.13 | 4.42 |
| ៩ | ក្រុមអធិការ បានឱ្យយោបល់ពីការប្រើប្រាស់សម្ភារឧបទេសក្នុងការរៀន និងបង្រៀន | 4.67 | 4.30 | 4.38 | 4.13 | 4.27 |
| ១០ | ក្រុមអធិការបានពិនិត្យមើលគ្រប់ជ្រុងជ្រោយក្នុងដំណើរការបង្រៀននៅក្នុងថ្នាក់ | 4.83 | 4.20 | 4.13 | 4.13 | 4.42 |
| ១១ | អធិការជាអ្នកជួយកែលម្អគ្រូក្នុងពេលបង្រៀន ជាជាងអ្នកស្វែងរកកំហុសរបស់គ្រូ | 4.00 | 3.90 | 4.50 | 4.13 | 4.35 |
| សរុប | | 4.39 | 4.08 | 4.38 | 4.23 | 4.30 |

***តារាង 66៖*** *ឥរិយាបថគ្រូបង្រៀនពេលអធិការសង្កេតការបង្រៀន ផ្អែកលើបទពិសោធន៍នៃការបង្រៀន*

### C. ការសម្ភាសអំពីការបង្រៀន និងរៀន

ក្នុងពេលអធិការកិច្ច ជានិច្ចជាកាលក្រុមអធិការតែងសម្ភាសជាមួយគ្រូបង្រៀនទាក់ទងនឹងការបងៀន និងរៀនរបស់គាត់។ តាមតារាង 67 បង្ហាញថាគ្រូបង្រៀនបានបង្ហាញការយល់ស្របកម្រិតផ្សេងគ្នា ដែលមានតម្លៃមធ្យមចាប់ពី 4.34 ដល់ 4.63។ គ្រូបង្រៀនមានបទពិសោធន៍បង្រៀនតិចជាងមួយឆ្នាំ បានបង្ហាញការយល់ស្របខ្ពស់ជាងគេកម្រិត "ល្អណាស់" លើសកម្មភាពចូលរួមឆ្លើយសំណួរសម្ភាសរបស់ក្រុមអធិការកិច្ច ដូចជាគាត់បានឯកភាពថាក្រុមអធិការមានភាពប៉ិនប្រសប់ក្នុងការធ្វើសម្ភាសជាមួយគ្រូបង្រៀន ហើយគ្រូបង្រៀនចូលរួមឆ្លើយសំណួរដោយគ្មានការស្ទាក់ស្ទើរ ឬភូតភរដើម្បីគេចវេសពីការវាយតម្លៃមិនល្អឡើយ។ ជាងនេះទៅទៀតគ្រូបង្រៀនឆ្នាំដំបូងមានភាពក្លាហានក្នុងការរៀបរាប់ពីបញ្ហា ឬលើកអំណះអំណាងផ្សេង

អំពីការបង្រៀនទៅដល់ក្រុមអធិការកិច្ច ហើយពួកគាត់បានដឹងពីសកម្មភាព និងមូលហេតុមួយចំនួន ដែលគាត់អនុវត្តមិនបានល្អ លើការបង្រៀនពីក្រុមអធិការកិច្ច។ ផ្ទុយពីគ្រូបង្រៀនចេញបង្រៀនឆ្នាំដំបូង គ្រូបង្រៀនដែលមានបទពិសោធន៍ចាប់ពី១០ឆ្នាំឡើងទៅបានយល់ស្របក្នុងកម្រិតទាបជាងគេ លើការចូលរួមឆ្លើយសំណួរសម្ភាសជាមួយក្រុមអធិការកិច្ច។ ដោយសារគាត់អាយុច្រើន និងមានបទពិសោធន៍យូរឆ្នាំលើការបង្រៀន គ្រូបង្រៀនអាចបង្ហាញសកម្មភាពមិនសូវស្វាហាប់ក្នុងការឆ្លើយតបនឹងការសម្ភាសរបស់ក្រុមអធិការកិច្ចឡើយ។ ជាក់ស្តែងសូចនាករទី២ "អធិការមានភាពប៉ិនប្រសប់ក្នុងការសម្ភាសគ្រូអំពីការបង្រៀន និងរៀន" គាត់បានស្របតិចជាងគេ បន្ទាប់ពីគ្រូបង្រៀនមានបទពិសោធន៍បង្រៀន ពី៤ ទៅ៦ឆ្នាំ។ ម្យ៉ាងទៀតសូចនាករទី៤ "លោកគ្រូ/អ្នកគ្រូ មិននិយាយកុហក ដើម្បីចៀសផុតពីការវាយតម្លៃមិនល្អឡើយ" ក៏ទទួលបានការយល់ស្របទាបជាងគេដែរ លើមធ្យមភាពពិន្ទុ 4.37។ លើសពីនេះគាត់យល់ថានៅពេលសម្ភាស គាត់មិនមានឱកាសច្រើនសម្រាប់បកស្រាយនូវមូលហេតុដែលក្រុមអធិការកិច្ចបានរកឃើញនៅឡើយទេ ជាក់ស្តែងសូចនាករទី៨ "លោកគ្រូ/អ្នកគ្រូមានឱកាសលើកអំណះអំណាងអំពីមូលហេតុនៃការបង្រៀន នៅពេលសម្ភាស" ទទួលបានការយល់ស្របទាបជាងគេលើមធ្យមភាពពិន្ទុ 4.29។

សរុបមក ដោយផ្អែកលើបទពិសោធន៍ការងារ យើងឃើញថាគ្រូបង្រៀនបានបង្ហាញឥរិយាបថផ្សេងគ្នាចំពោះការចូលរួមសម្ភាសន៍អធិការកិច្ច។ ជាលទ្ធផលគ្រូចេញបង្រៀនឆ្នាំដំបូងមានការចូលរួមខ្ពស់ ក្នុងការឆ្លើយសំណួរសម្ភាស ទាំងការផ្តល់តម្លៃលើវិធីសាស្ត្រសម្ភាស របស់ក្រុមអធិការ និងគ្មានការលាក់បាំងព័ត៌មានផ្សេងៗ ដើម្បីចៀសវាងការវាយតម្លៃមិនល្អឡើយ ជាពិសេសគាត់អាចដឹងពីសកម្មភាព និងមូលហេតុដែលគាត់អនុវត្តមិនបានល្អ តាមរយៈការចូលរួមសម្ភាសនេះ។ ចំណែកឯគ្រូបង្រៀន មានបទពិសោធន៍បង្រៀនយូរជាងគេវិញ គាត់មិនមានការយល់ឃើញដូចគ្រូបង្រៀនខាងលើទាំងអស់ទេ ដោយសារគាត់មានបទពិសោធន៍លើការបង្រៀនច្រើន និងប្រហែលជាធ្លាប់ជួបការធ្វើអធិការកិច្ចច្រើនដង ជាហេតុធ្វើឱ្យគាត់សម្តែងអារម្មណ៍ធម្មតា មិនសូវសហការ លើការឆ្លើយសំណួររបស់ក្រុមអធិការកិច្ច។

| ល.រ | បរិយាយ | តម្លៃមធ្យម | | | | |
|---|---|---|---|---|---|---|
| | C. ការសម្ភាសអំពីការបង្រៀន និងរៀន | < ១ឆ្នាំ $(N=6)$ | ១-៣ឆ្នាំ $(N=10)$ | ៤-៦ឆ្នាំ $(N=8)$ | ៧-៩ឆ្នាំ $(N=8)$ | >១០ឆ្នាំ $(N=62)$ |
| ១ | អធិការប្រើប្រាស់កម្រងសំណួរសម្ភាស មានភាពងាយស្រួលសម្រាប់គ្រូបង្រៀនក្នុងការឆ្លើយ | 4.33 | 4.00 | 4.00 | 4.50 | 4.24 |
| ២ | អធិការមានភាពប៉ិនប្រសប់ក្នុងការសម្ភាសគ្រូអំពីការបង្រៀន និងរៀន | 4.83 | 4.40 | 4.25 | 4.50 | 4.34 |
| ៣ | គ្រូបង្រៀន គ្មានការស្ទាក់ស្ទើរក្នុងការចូលរួមឆ្លើយសំណួរសម្ភាសន៍របស់អធិការកិច្ច | 4.83 | 4.60 | 4.88 | 4.25 | 4.45 |
| ៤ | លោកគ្រូ/អ្នកគ្រូ  មិននិយាយកុហក ដើម្បីចៀសផុតពីការវាយតម្លៃមិនល្អទ្បើយ | 4.83 | 4.70 | 4.50 | 4.50 | 4.37 |
| ៥ | ក្នុងពេលអធិការកិច្ច គ្រូបង្រៀនអាចរៀបរាប់ពីបញ្ហាលំបាកលើការបង្រៀន និងរៀន | 4.50 | 4.20 | 4.13 | 4.63 | 4.29 |
| ៦ | ក្រុមអធិការបានបង្ហាញពីសកម្មភាព និងមូលហេតុដែលលោកគ្រូ/អ្នកគ្រូអនុវត្តបានល្អលើការបង្រៀន និងរៀន | 4.33 | 4.30 | 4.50 | 4.50 | 4.40 |
| ៧ | ក្រុមអធិការបានបង្ហាញពីសកម្មភាព និងមូលហេតុដែលគ្រូបង្រៀនអនុវត្តមិនបានល្អលើការបង្រៀន និងរៀន | 4.67 | 4.50 | 4.50 | 4.13 | 4.31 |

| | | | | | | |
|---|---|---|---|---|---|---|
| ៨ | លោកគ្រូ/អ្នកគ្រូមានឱកាសលើកអំណះអំណាងអំពីមូលហេតុនៃការបង្រៀន នៅពេលសម្ភាស | 4.67 | 4.40 | 4.63 | 4.50 | 4.29 |
| សរុប | | 4.63 | 4.39 | 4.42 | 4.44 | 4.34 |

***តារាង 67៖** ឥរិយាបថគ្រូបង្រៀនចំពោះការសម្ភាសរបស់ក្រុមអធិការកិច្ច ផ្អែកលើបទពិសោធន៍នៃការបង្រៀន*

សរុបរួមមក ក្នុងផ្នែកទី២ ឥរិយាបថគ្រូបង្រៀន អំឡុងពេលអធិការកិច្ចលើការបង្រៀន ដូចបង្ហាញក្នុងតារាង 68 យើងឃើញថា គ្រូបង្រៀនមានបទពិសោធន៍បង្រៀនតិចជាង១ឆ្នាំ បានយល់ស្របកម្រិតខ្ពស់ លើសកម្មភាពសង្កេតថ្នាក់រៀនរបស់ក្រុមអធិការកិច្ច ដោយគាត់បានយល់ថាអធិការបានយកចិត្តទុកដាក់លើស្ថានភាពថ្នាក់រៀន និងសកម្មភាពនានាក្នុងថ្នាក់រៀន។ ជាងនេះទៅទៀត គ្រូបង្រៀនថ្មីៗបានបង្ហាញការគោរព និងឱ្យតម្លៃទៅលើចំណេះដឹង និងបទពិសោធន៍របស់អធិការលើការបង្រៀន និងរៀន។ នៅពេលសម្ភាសពួកគាត់បានទទួលស្គាល់ភាពប៉ិនប្រសប់សម្ភាសរបស់ក្រុមអធិការ ហើយបានបង្ហាញប្រាប់ពីព័ត៌មានដោយស្មោះត្រង់ មិនលាក់លៀម និងបានទទួលយកពីមូលហេតុនានា ដែលគាត់អនុវត្តមិនបានល្អក្នុងពេលបង្រៀនតាមរយៈការចូលរួមសម្ភាស។ ត្រង់នេះបង្ហាញថា គ្រូចេញបង្រៀនឆ្នាំដំបូងៗមានសកម្មភាពវិជ្ជមានច្រើនអំឡុងពេលអធិការកិច្ចលើការបង្រៀន និងរៀន។ តារាង ៤.៣៥ បានបង្ហាញផងដែរនូវមធ្យមភាគពិន្ទុ 4.09 របស់គ្រូបង្រៀនមានបទពិសោធន៍បង្រៀនពី១ឆ្នាំទៅ៣ឆ្នាំមានពិន្ទុទាបជាងគេ។ លទ្ធផលនេះបង្ហាញថាគ្រូបង្រៀនបានយល់ថាការធ្វើអធិការកិច្ចច្រើនផ្តោតទៅលើចំណុចដែលត្រូវកែលម្អរបស់គ្រូ លើការបង្រៀន និងរៀនច្រើនជាងចំណុចល្អរបស់គ្រូ ជាហេតុធ្វើឱ្យគាត់មានការព្រួយបារម្ភលើសកម្មភាពបង្រៀនខ្លួនឯង ខ្លាចបង្កកំហុសលើការបង្រៀន គាត់មិនមានភាពក្លាហានក្នុងការប្រើវិធីសាស្ត្រថ្មីៗ ជាពិសេសពិបាកក្នុងការគ្រប់គ្រងថ្នាក់ឱ្យបានល្អឡើយ។ ចំណែកឯគ្រូបង្រៀនមានបទពិសោធន៍បង្រៀនលើសពី១០ឆ្នាំ គាត់បានបង្ហាញពីការចូលរួមមិនពេញលេញចំពោះការឆ្លើយសំណួររបស់ក្រុមអធិការកិច្ច ដោយសារប្រហែលជាគាត់

ធ្លាប់ជួបស្ថានភាពអធិការកិច្ចថ្នាក់រៀនច្រើនដង និងធ្លាប់ជាគ្រូបង្រៀនយូរឆ្នាំមកហើយ ធ្វើឱ្យគាត់យល់ថា អធិការមិនមានភាពប៉ិនប្រសប់ក្នុងការសម្ភាសជាមួយគាត់។

| បរិយាយ | | តម្លៃមធ្យម | | | | |
|---|---|---|---|---|---|---|
| ផ្នែកទី២៖អំឡុងពេលអធិការកិច្ច | | < ១ឆ្នាំ $(N=6)$ | ១-៣ឆ្នាំ $(N=10)$ | ៤-៦ឆ្នាំ $(N=8)$ | ៧-៩ឆ្នាំ $(N=8)$ | >១០ឆ្នាំ $(N=62)$ |
| A | ការសង្កេតថ្នាក់រៀន | 3.77 | 3.81 | 3.69 | 3.67 | 3.76 |
| B | សង្កេតការបង្រៀន | 4.39 | 4.08 | 4.38 | 4.23 | 4.30 |
| C | ការសម្ភាសអំពីការបង្រៀន និងរៀន | 4.63 | 4.39 | 4.42 | 4.44 | 4.34 |
| សរុប | | 4.26 | 4.09 | 4.16 | 4.11 | 4.13 |

***តារាង 68៖*** *ឥរិយាបថគ្រូបង្រៀនអំឡុងពេលអធិការកិច្ច ផ្អែកលើបទពិសោធន៍នៃការបង្រៀន*

### ៤.១.៣.៣ ឥរិយាបថគ្រូបង្រៀន ក្រោយពេលអធិការកិច្ចផ្អែកលើបទពិសោធន៍ការងារ

ដូចបានរៀបរាប់ម្តងរួចមកហើយ ក្រោយពីបានអធិការកិច្ចថ្នាក់រៀន សម្ភាសជាមួយគ្រូលើការបង្រៀន និងរៀន អធិការកិច្ចបានប្រជុំជាមួយគ្រូបង្រៀន ដើម្បីបូកសរុបលទ្ធផលនៃអធិការកិច្ច និងផ្តល់ជាអនុសាសន៍ លើចំណុចដែលគ្រូបង្រៀន គួរតែកែលម្អ។ ខាងក្រោមនេះ អ្នកស្រាវជ្រាវនឹងបង្ហាញលទ្ធផលនៃឥរិយាបថ គ្រូបង្រៀនចំពោះអនុសាសន៍អធិការកិច្ចទៅលើការបង្រៀន និងរៀន ដោយផ្អែកលើរយៈពេលនៃការបំពេញ ការងារជាគ្រូបង្រៀន។

#### A. ការផ្តល់អនុសាសន៍

តាមតារាង 69 យើងឃើញថា កម្រិតយល់ស្របរបស់គ្រូបង្រៀនទៅលើអនុសាសន៍អធិការកិច្ច ស្ថិតក្នុងកម្រិត"ល្អ" និងមានមធ្យមភាពពិន្ទុចាប់ពី 4.34 ដល់ 4.59។ ជាលទ្ធផលបង្ហាញថាគ្រូបង្រៀនថ្មីថ្មោង ដែលមានបទពិសោធន៍ចាប់ពីឆ្នាំដំបូងរហូតដល់៣ឆ្នាំមានការយល់ស្របខ្ពស់ជាងគ្រូបង្រៀនមានបទពិសោធន៍

យូរឆ្នាំ ដោយសារគាត់បានឯកភាពថាអនុសាសន៍របស់អធិការកិច្ចមានលក្ខណៈច្បាស់លាស់ សមស្របតាមបរិបទសាលារៀន និងសមត្ថភាពគ្រូបង្រៀន ដែលនឹងធ្វើឱ្យការបង្រៀនកាន់ប្រសើរឡើង។ លើសពីនេះគ្រូបង្រៀនមានបទពិសោធន៍ចាប់ពីឆ្នាំដំបូងរហូតដល់៣ឆ្នាំ បានបង្ហាញការយល់ស្រប និងអនុវត្តតាមអនុសាសន៍របស់ក្រុមអធិការកិច្ច ព្រោះគាត់យល់ថាវាមានសារៈសំខាន់សម្រាប់កែលម្អការបង្រៀន និងទទួលបាននូវ បទពិសោធន៍ល្អៗ។ ចំណែកឯគ្រូបង្រៀនមានបទពិសោធន៍ចាប់ពី៤ឆ្នាំឡើងទៅ មានមធ្យមភាគពិន្ទុនៃការយល់ស្របទាប ដោយគាត់យល់ថាអនុសាសន៍របស់អធិការកិច្ច មិនទាន់សមស្របទៅតាមបរិបទសាលារៀន និងសមត្ថភាពគ្រូបង្រៀននៅឡើយ ទោះបីគាត់យល់ថាអនុសាសន៍របស់អធិការកិច្ចមានប្រយោជន៍ក៏ដោយ។ លទ្ធផលនេះបង្ហាញថា គ្រូដែលមានបទពិសោធន៍យូរឆ្នាំមានអារម្មណ៍ថា គាត់មិនអាចក្លាយជាគ្រូបង្រៀនល្អដោយគ្រាន់តែអនុវត្តតាមអនុសាសន៍របស់អធិការបានទេ។ ដូចនេះគាត់នឹងមិនអនុវត្តតាមអនុសាសន៍របស់ក្រុមអធិការកិច្ច លើការបង្រៀននិងរៀនឡើយ ហើយពួកគាត់បានយល់ថា អនុសាសន៍របស់អធិការកិច្ច ជាការដាក់បន្ទុកបន្ថែមទៀតលើការងារបង្រៀនរបស់គាត់ទៀតផង។

សរុបមក ឥរិយាបថគ្រូបង្រៀនក្នុងការទទួលអនុសាសន៍ពីក្រុមអធិការកិច្ច មានភាពមិនដូចគ្នាទេ។ គ្រូបង្រៀនដែលមានចេញបង្រៀនថ្មីថ្មោង(ពីឆ្នាំទី១ដល់ឆ្នាំទី៣) បានផ្តល់តម្លៃខ្លាំងចំពោះអនុសាសន៍អធិការកិច្ច ដោយយល់ថាវាមានសារៈប្រយោជន៍ធ្វើឱ្យការបង្រៀនមានប្រសិទ្ធភាពជាងមុន។ ជាងនេះទៅទៀត គាត់បានសម្តែងការយល់ស្របទៅលើការអនុវត្តតាមអនុសាសន៍អធិការកិច្ចដែលបានផ្តល់ជូន។ ប៉ុន្តែគ្រូបង្រៀនដែលមានបទពិសោធន៍ច្រើនឆ្នាំ បានផ្តល់តម្លៃតិចតួចចំពោះអនុសាសន៍អធិការកិច្ច បើធៀបនឹងគ្រូបង្រៀនចេញថ្មី។ ការយល់ឃើញបែបនេះ ដោយសារគាត់ធ្លាប់មានបទពិសោធន៍ច្រើនក្នុងការបង្រៀន និងអាចធ្លាប់ជួបការចុះអធិការកិច្ចច្រើនដង ធ្វើឱ្យគាត់យល់ថាអនុសាសន៍អធិការកិច្ចមិនមានលក្ខណៈសមស្របតាមបរិបទសាលារៀន និងសមត្ថភាពរបស់គាត់ទេ ហើយវានឹងមិនធ្វើឱ្យការបង្រៀនមានភាពប្រសើរឡើងទេ និងអាចជាការបន្ថែមកិច្ចការផ្សេងទៀតសម្រាប់គាត់ផងដែរ។

| ល.រ | ផ្នែកទី២៖ ក្រោយពេលអធិការកិច្ច | តម្លៃមធ្យម | | | | |
|---|---|---|---|---|---|---|
| | A. ការផ្តល់អនុសាសន៍ | < ១ឆ្នាំ ($N=6$) | ១-៣ឆ្នាំ ($N=10$) | ៤-៦ឆ្នាំ ($N=8$) | ៧-៩ឆ្នាំ ($N=8$) | >១០ឆ្នាំ ($N=62$) |
| ១ | អធិការតែងតែផ្តល់អនុសាសន៍លើការបង្រៀនរបស់គ្រូ | 4.17 | 4.10 | 4.00 | 4.38 | 4.29 |
| ២ | អនុសាសន៍របស់អធិការកិច្ចលើការបង្រៀន និងរៀន សមស្របនឹងបរិបទរបស់សាលារៀនរបស់ពួកយើង | 4.17 | 4.10 | 4.00 | 4.38 | 4.29 |
| ៣ | អនុសាសន៍របស់អធិការកិច្ច មានលក្ខណៈសមស្របនិងច្បាស់លាស់ | 4.83 | 4.30 | 4.38 | 4.38 | 4.37 |
| ៤ | អនុសាសន៍របស់អធិការកិច្ច ធ្វើឱ្យការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាព | 5.00 | 4.50 | 4.63 | 4.50 | 4.42 |
| ៥ | អធិការកិច្ចបានផ្តល់អនុសាសន៍ផ្សារភ្ជាប់ស្ថានភាពជាក់ស្តែង តាមតម្រូវការ និងសមត្ថភាពរបស់លោកគ្រូ/អ្នកគ្រូ | 4.67 | 4.30 | 4.13 | 4.13 | 4.15 |
| ៦ | អនុសាសន៍របស់អធិការកិច្ច មានសារៈសំខាន់សម្រាប់គ្រូបង្រៀន | 4.83 | 4.50 | 4.63 | 4.38 | 4.48 |
| ៧ | ក្រុមអធិការតែងតែចែករំលែកនូវរាល់បទពិសោធន៍ល្អៗអំពីការបង្រៀន និងរៀន | 4.67 | 4.60 | 4.38 | 4.38 | 4.56 |
| ៨ | អនុសាសន៍របស់អធិការបានជួយឱ្យលោក/ | 4.50 | 4.70 | 4.38 | 4.38 | 4.50 |

| | | | | | | |
|---|---|---|---|---|---|---|
| | អ្នក ក្លាយទៅជាគ្រូបង្រៀនល្អ | | | | | |
| ៩ | អនុសាសន៍របស់អធិការកិច្ច មិនមែនជាការដាក់បន្ទុកបន្ថែមលើការងារបង្រៀន របស់គ្រូបង្រៀនឡើយ | 4.50 | 4.40 | 4.13 | 4.38 | 4.21 |
| ១០ | លោកគ្រូ/អ្នកគ្រូ ទទួលស្គាល់បញ្ហាអំពីការបង្រៀន និងរៀនដែលអធិការកិច្ចបានរកឃើញ | 4.50 | 4.70 | 4.63 | 4.38 | 4.23 |
| ១១ | លោកគ្រូ/អ្នកគ្រូ នឹងអនុវត្តតាមអនុសាសន៍របស់ក្រុមអធិការកិច្ច លើការបង្រៀន និងរៀន | 4.67 | 4.70 | 4.63 | 4.38 | 4.29 |
| សរុប | | 4.59 | 4.45 | 4.35 | 4.36 | 4.34 |

***តារាង 69៖** ឥរិយាបថគ្រូបង្រៀនចំពោះអនុសាសន៍អធិការកិច្ច ផ្អែកលើបទពិសោធន៍នៃការបង្រៀន*

### B. របាយការណ៍អធិការកិច្ច

ផ្នែកនេះ យើងនឹងបន្តបកស្រាយឥរិយាបថគ្រូបង្រៀនចំពោះរបាយការណ៍អធិការកិច្ច។ ជាធម្មតា របាយការណ៍នេះត្រូវបានបញ្ជូនទៅកាន់សាលារៀនរយៈពេលពីរសប្តាហ៍ក្រោយពីអធិការកិច្ច។ តើគ្រូបង្រៀនដែលមានបទពិសោធន៍បង្រៀនខុសៗគ្នា យល់ឃើញដូចគ្នាឬទេ ចំពោះរបាយការណ៍អធិការកិច្ច?

តាមតារាង 70 បានបង្ហាញថាមធ្យមភាគពិន្ទុនៃការយល់ស្របរបស់គ្រូបង្រៀនមានបទពិសោធន៍បង្រៀនខុសគ្នា ទៅលើរបាយការណ៍អធិការកិច្ចមានតម្លៃចន្លោះពី 3.62 ទៅដល់ 4.15។ គ្រូបង្រៀនមានបទពិសោធន៍បង្រៀនចាប់ពី៧ឆ្នាំទៅ៩ឆ្នាំមានការយល់ស្របខ្ពស់ជាងគេ ហើយគ្រូបង្រៀនមានបទពិសោធន៍បង្រៀនច្រើនជាង១០ឆ្នាំមានកម្រិតយល់ស្របទាបជាងគេ។ បើយើងពិនិត្យលើសូចនាករទី១ "លោកគ្រូ/អ្នកគ្រូបានដឹងពីខ្លឹមសារក្នុងរបាយការណ៍អធិការកិច្ច" បានបង្ហាញថាគ្រូភាគច្រើនមិនបានដឹងពីខ្លឹមសារនៃរបាយការណ៍អធិការកិច្ចឡើយដោយមានមធ្យមភាគពី 2.67 ដល់ 3.75។ មានតែគ្រូបង្រៀនមានបទពិសោធន៍

ពី៤ឆ្នាំដល់៩ឆ្នាំប៉ុណ្ណោះ ដែលមានមធ្យមភាគពិន្ទុខ្ពស់ជាងពិន្ទុមធ្យមបន្តិចបន្តួច។ គ្រូបង្រៀនភាគច្រើនមិនបានដឹងពីខ្លឹមសារនៃរបាយការណ៍អធិការកិច្ចឡើយ ជាហេតុធ្វើឱ្យគាត់មិនបានដឹងថាខ្លឹមសាររបស់វាអាចជួយបំពេញនូវចំណុចខ្វះខាតនៃការបង្រៀនរបស់គាត់បានដែរទេ។ ជាក់ស្តែងសូចនាករទី២ ″របាយការណ៍អធិការកិច្ចបានបំពេញការចំណុចខ្វះខាតរបស់គ្រូបង្រៀនក្នុងអាជីពរបស់ពួកគាត់″ កម្រិតយល់ស្របរបស់គ្រូមានបទពិសោធន៍ពី១ឆ្នាំទៅ៣ឆ្នាំ និងគ្រូបង្រៀនមានបទពិសោធន៍ច្រើនជាង១០ឆ្នាំមានមធ្យមភាគពិន្ទុ 3.60 និង 3.66 ដែលជាតម្លៃងាកទៅរកកម្រិតមធ្យម (អវិជ្ជមាន)។ ទោះបីមិនបានដឹងពីខ្លឹមសារនៃរបាយការណ៍អធិការកិច្ច គ្រូបង្រៀនមានបទពិសោធន៍តិចជាង១ឆ្នាំនៅតែមានការយល់ស្របពីអ្វីដែលរៀបរាប់ក្នុងរបាយកាណ៍អធិការកិច្ច ដូចបានបង្ហាញក្នុងសូចនាករទី៣ ″របាយការណ៍អធិការកិច្ច បានបង្ហាញពីចំណុចដែលត្រូវកែលម្អលើការបង្រៀន និងរៀន″ បានទទួលការយល់ស្របខ្ពស់ជាងគេ។ ផ្ទុយទៅវិញ គ្រូដែលមានបទពិសោធន៍បង្រៀនច្រើនជាង១០ឆ្នាំ មិនបានយល់ស្របខ្លាំងនូវអ្វីដែលបានសរសេរក្នុងរបាយការណ៍នោះទេ។ ជាក់ស្តែងសូចនាករទី២ ″របាយការណ៍អធិការកិច្ចបានបំពេញចំណុចខ្វះខាតរបស់គ្រូបង្រៀនក្នុងអាជីពរបស់ពួកគាត់″ បានទទួលការយល់ស្របទាបលើមធ្យមភាពពិន្ទុ 3.66 ជាពិន្ទុមួយងាកទៅរកឥរិយាបថអវិជ្ជមាន។ លើសពីនេះគាត់បានឯកភាពតិចតួចលើរបាយការណ៍អធិការកិច្ចបានបង្កលក្ខណៈងាយស្រួលក្នុងការអាន និងបានបង្ហាញពីចំណុចដែលគាត់ត្រូវបានកែលម្អលើការបង្រៀន។

សរុបមក ឥរិយាបថគ្រូបង្រៀនចំពោះរបាយការណ៍អធិការកិច្ច មិនដូចគ្នាទេបើផ្អែកលើបទពិសោធន៍ការងារ។ តាមតារាង 70 បានបង្ហាញថា នៅពេលគ្រូមិនបានដឹងពីខ្លឹមសារអធិការកិច្ច ធ្វើឱ្យគាត់បង្ហាញពីឥរិយាបថអវិជ្ជមានចំពោះសារៈសំខាន់របស់វា(លើកលែងតែគ្រូចេញបង្រៀនដំបូង) ហើយលទ្ធភាពនៃការប្រើប្រាស់របាយការណ៍អធិការកិច្ចសម្រាប់កែលម្អទៅលើការបង្រៀន និងរៀន ក៏បានតិចទៅតាមហ្នឹងដែរ។

| ល.រ | ផ្នែកទី២៖ ក្រោយពេលអធិការកិច្ច | តម្លៃមធ្យម | | | | |
|---|---|---|---|---|---|---|
| | B. របាយការណ៍អធិការកិច្ច | < ១ឆ្នាំ ($N=6$) | ១-៣ឆ្នាំ ($N=10$) | ៤-៦ឆ្នាំ ($N=8$) | ៧-៩ឆ្នាំ ($N=8$) | >១០ឆ្នាំ ($N=62$) |
| ១ | លោកគ្រូ/អ្នកគ្រូបានដឹងពីខ្លឹមសារក្នុងរបាយការណ៍អធិការកិច្ច | 2.67 | 3.20 | 3.63 | 3.75 | 3.06 |
| ២ | របាយការណ៍អធិការកិច្ច បានបំពេញការចំណុចខ្វះខាតរបស់គ្រូបង្រៀន ក្នុងអាជីពរបស់ពួកគាត់ | 4.17 | 3.60 | 4.13 | 4.25 | 3.66 |
| ៣ | របាយការណ៍អធិការកិច្ច បានបង្ហាញពីចំណុចដែលត្រូវកែលម្អលើការបង្រៀន និងរៀន | 4.67 | 4.10 | 4.25 | 4.13 | 3.79 |
| ៤ | របាយការណ៍អធិការកិច្ច បង្កលក្ខណៈងាយស្រួលដល់គ្រូបង្រៀនក្នុងការអាន | 3.83 | 4.00 | 3.88 | 4.00 | 3.68 |
| ៥ | គ្រូបង្រៀនយល់ស្របនឹងរបាយការណ៍អធិការកិច្ច | 4.50 | 4.10 | 4.13 | 4.63 | 3.73 |
| ៦ | គ្រូបង្រៀនប្រើប្រាស់របាយកាណ៍អធិការកិច្ចសម្រាប់កែលម្អការបង្រៀន និងរៀន | 4.17 | 4.20 | 4.38 | 4.13 | 3.82 |
| សរុប | | 4.00 | 3.87 | 4.06 | 4.15 | 3.62 |

***តារាង 70៖*** *ឥរិយាបថគ្រូបង្រៀនចំពោះរបាយការណ៍អធិការកិច្ច ផ្អែកលើបទពិសោធន៍នៃការបង្រៀន*

ឆ្លងតាមការបកស្រាយលទ្ធផលខាងលើក្នុងផ្នែកនេះ យើងអាចធ្វើការបូកសរុបជារួមបានថាឥរិយាបថគ្រូបង្រៀនក្រោយពេលអធិការកិច្ច ចំពោះអនុសាសន៍ និងរបាយការណ៍អធិការកិច្ចមានភាពខុសគ្នាបើប្រៀបធៀបទៅលើបទពិសោធន៍ការងារបង្រៀន។ គ្រូបង្រៀនថ្មី(ឆ្នាំទី១)បានផ្តល់តម្លៃខ្លាំងចំពោះអនុសាសន៍អធិការកិច្ច និងរបាយការណ៍អធិការកិច្ច ដោយគាត់បានយល់ថាវាមានសារៈប្រយោជន៍សម្រាប់កែលម្អលើការបង្រៀនកាន់តែមានប្រសិទ្ធភាពជាងមុន។ ប៉ុន្តែគ្រូបង្រៀនមានពិសោធន៍លើសពី១០ឆ្នាំ មិនបានយល់ស្របថាអនុសាសន៍អធិការកិច្ចនឹងធ្វើឱ្យការបង្រៀនមានភាពប្រសើរឡើងនោះទេ ដោយគាត់បានយល់ឃើញថា វាជាការដាក់កិច្ចការបន្ថែមទៀតសម្រាប់គាត់ទៅវិញ ហើយគាត់មិនបានអាន ឬមិនបានដឹងពីខ្លឹមសារនៃរបាយ-ការណ៍បានពេញលេញនោះទេ។ រីឯការបង្រៀន និងរៀនរបស់គាត់នឹងត្រូវអនុវត្តបែបដដែលៗធម្មតាដូចពីមុនបន្តទៅទៀត។

| **បរិយាយ** | | **តម្លៃមធ្យម** | | | | |
|---|---|---|---|---|---|---|
| **ផ្នែកទី៣៖ក្រោយពេលអធិការកិច្ច** | | **< ១ឆ្នាំ** $(N=6)$ | **១-៣ឆ្នាំ** $(N=10)$ | **៤-៦ឆ្នាំ** $(N=8)$ | **៧-៩ឆ្នាំ** $(N=8)$ | **>១០ឆ្នាំ** $(N=62)$ |
| A | ការផ្តល់អនុសាសន៍ | 4.59 | 4.45 | 4.35 | 4.36 | 4.34 |
| B | ការផ្តល់របាយការណ៍ | 4.00 | 3.87 | 4.06 | 4.15 | 3.62 |
| សរុប | | 4.30 | 4.16 | 4.21 | 4.25 | 3.98 |

***តារាង 71៖*** *ឥរិយាបថគ្រូបង្រៀនក្រោយពេលអធិការកិច្ច ផ្អែកលើបទពិសោធន៍ការងារ*

លទ្ធផលជារួម ក្នុងផ្នែក៤.១.៤ គ្រូបង្រៀនមានឥរិយាបថវិជ្ជមានកម្រិតខុសគ្នា បើធៀបទៅនឹងរយៈពេលបំពេញការងារជាគ្រូបង្រៀន។ តាមតារាង 72 ឃើញថាគ្រូបង្រៀនមានបទពិសោធន៍តិចជាងមួយឆ្នាំមានឥរិយាបថវិជ្ជមានខ្ពស់ជាងគេនៅគ្រប់ដំណាក់កាលនៃការធ្វើអធិការកិច្ច និងមានតម្លៃមធ្យមជារួម 4.30។ ចំណែកឯ គ្រូបង្រៀនមានបទពិសោធន៍បង្រៀនលើសពី១០ឆ្នាំមានឥរិយាបថវិជ្ជមានកម្រិតទាបជាងគេ លើ

មធ្យមភាពរួម 4.05។ លើសពីនេះទិន្នន័យបានបង្ហាញថា គ្រូបង្រៀនមានបទពិសោធន៍ពី១ដល់៣ឆ្នាំ, ពី៤ដល់៦ឆ្នាំ និងពី៧ដល់៩ឆ្នាំ មានមធ្យមភាគពិន្ទុនៃការយល់ស្របកើនឡើងជាលំដាប់តាំងពីមុនពេលអធិការកិច្ច រហូតដល់ក្រោយពេលអធិការកិច្ច ខុសប្លែកពីគ្រូបង្រៀនមានបទពិសោធន៍ច្រើនជាង១០ឆ្នាំ ដែលមធ្យមភាគពិន្ទុក្រោយពេលអធិការកិច្ចទាបជាងមធ្យមភាគទាំងមុនពេល និងអំឡុងពេលអធិការកិច្ច។ លទ្ធផលនេះអាចធ្វើការសន្និដ្ឋានបានថា គ្រូបង្រៀនទើបចេញថ្មីមានឥរិយាបថវិជ្ជមានកម្រិតខ្ពស់ចំពោះអធិការកិច្ចលើការបង្រៀន និងរៀន ព្រោះជារយៈពេលនៃកម្មសិក្សាអនុវត្ត និងមិនទាន់ទទួលបានការតែងតាំងស៊ប់នៅឡើយ ខុសគ្នាបើធៀបនឹងគ្រូបង្រៀនដែលមានបទពិសោធន៍យូរឆ្នាំ ដែលបានទទួលការតាំងស៊ប់រួចរាល់មានឥរិយាបថវិជ្ជមានកម្រិតទាបជាងគេ និងបានផ្តល់តម្លៃតិចតួចចំពោះអធិការកិច្ច ទាំងការចូលរួមសម្ភាសជាមួយអធិការ និងការទទួលអនុសាសន៍ចំពោះអធិការកិច្ច។

| ផ្នែក | ផ្នែករង | < ១ឆ្នាំ $(N=6)$ | ១-៣ឆ្នាំ $(N=10)$ | ៤-៦ឆ្នាំ $(N=8)$ | ៧-៩ឆ្នាំ $(N=8)$ | >១០ឆ្នាំ $(N=62)$ |
|---|---|---|---|---|---|---|
| មុនពេលអធិការកិច្ច | ទំនាក់ទំនង | 4.60 | 4.28 | 4.08 | 4.48 | 4.36 |
| | ការផ្តល់ព័ត៌មាន | 4.13 | 3.92 | 3.58 | 3.90 | 3.76 |
| | ការគោរពពេលវេលា | 4.13 | 3.75 | 3.94 | 3.97 | 3.87 |
| | ការត្រៀមលក្ខណៈ | 4.13 | 3.75 | 3.94 | 3.97 | 3.87 |
| | ***សរុប*** | ***4.35*** | ***4.05*** | ***3.94*** | ***4.14*** | ***4.05*** |
| អំឡុងពេលអធិការកិច្ច | ពេលសង្កេតថ្នាក់រៀន | 3.77 | 3.81 | 3.69 | 3.67 | 3.76 |
| | ការបង្រៀន និងរៀន | 4.39 | 4.08 | 4.38 | 4.23 | 4.30 |
| | ការសម្ភាស | 4.63 | 4.39 | 4.42 | 4.44 | 4.34 |

| | | | | | | |
|---|---|---|---|---|---|---|
| | <u>**សរុប**</u> | <u>4.26</u> | <u>4.09</u> | <u>4.16</u> | <u>4.11</u> | <u>4.13</u> |
| ក្រោយពេលអធិការកិច្ច | ការផ្តល់អនុសាសន៍ | 4.59 | 4.45 | 4.35 | 4.36 | 4.34 |
| | របាយការណ៍អធិការកិច្ច | 4.00 | 3.87 | 4.06 | 4.15 | 3.62 |
| | <u>**សរុប**</u> | <u>4.30</u> | <u>4.16</u> | <u>4.21</u> | <u>4.25</u> | <u>3.98</u> |
| សរុបរួម | | 4.30 | 4.10 | 4.10 | 4.17 | 4.05 |

***តារាង 72៖*** *ឥរិយាបថគ្រូបង្រៀនចំពោះអធិការកិច្ចលើការបង្រៀន និងរៀន ផ្អែកលើបទពិសោធន៍ការងារ*

***រូបភាព 6៖*** *ការប្រៀបធៀបឥរិយាបថគ្រូបង្រៀនចំពោះអធិការកិច្ច ផ្អែកលើបទពិសោធន៍ការងារ*



## ៤.២ ការពិភាក្សា

### ៤.២.១ ការពិភាក្សា

#### ៤.២.១.១ ឥរិយាបថគ្រូបង្រៀន មុនពេលអធិការកិច្ច លើការបង្រៀន និងរៀន

ក្នុងផ្នែកទី១នេះ មុនពេលអធិការកិច្ចលើការបង្រៀន និងរៀន លោកគ្រូ/អ្នកគ្រូមានឥរិយាបថវិជ្ជមានចំពោះអធិការកិច្ច លើទំនាក់ទំនងរវាងគ្រូបង្រៀននិងក្រុមអធិការ ការគោរពពេលវេលានៃអធិការកិច្ច និងការត្រៀមលក្ខណៈសម្រាប់អធិការកិច្ច។ មុនពេលអធិការកិច្ចលើការបង្រៀន និងរៀន លោកគ្រូ/អ្នកគ្រូ បានយល់ថាក្រុមអធិការជាអ្នកអប់រំ បានសម្តែងអាកប្បកិរិយាស្និទ្ធស្នាល រួសរាយ មិនរើសអើងចំពោះគ្រូបង្រៀន និងជាអ្នកមានចំណេះដឹង និងបទពិសោធន៍គ្រប់គ្រាន់លើការបង្រៀនផងដែរ។ លទ្ធផលនេះស្រដៀងនឹង លោក សុភា (២០១២) ដែលបានរកឃើញថា នៅពេលចុះអធិការកិច្ចម្តងៗក្រុមអធិការកិច្ចពិតជាមានទំនាក់ទំនងល្អជាមួយគ្រូបង្រៀនបង្កនូវភាពស្និទ្ធស្នាលជាអ្នកពិគ្រោះយោបល់/ផ្តល់ប្រឹក្សាទៅតាមស្ថានភាព និងតម្រូវការរបស់លោកគ្រូ/អ្នកគ្រូ។ ម្យ៉ាងទៀត គ្រូបង្រៀនបានយល់ថាក្រុមអធិការជាអ្នកគោរពពេលវេលានៅពេលចុះមកអធិការកិច្ចសាលារៀន ហើយគ្រូបង្រៀនភាគច្រើននឹងត្រៀមលក្ខណៈសម្រាប់ការបង្រៀនជាមុន ដូចជារៀបចំអនាម័យថ្នាក់រៀន រដ្ឋបាលគ្រូបង្រៀន កិច្ចតែងការបង្រៀន និងសម្ភារឧបទេសសម្រាប់ការបង្រៀន នៅពេលដឹងដំណឹងជាមុនថាមានការចុះអធិការកិច្ច ជាពិសេសគ្រូបង្រៀនមិនបានបដិសេធ ចំពោះការធ្វើអធិការកិច្ចលើការបង្រៀនរបស់គាត់ឡើយ ទោះបីជាគ្រូបង្រៀនខ្លះទៀតមានការព្រួយបារម្ភ ខ្វល់ខ្វាយ ខ្លាចបង្រៀនមិនបានល្អនៅថ្ងៃចុះអធិការកិច្ចក្តី។ លទ្ធផលនេះស្រដៀងនឹង Brimblecombe, Ormston, and Shaw (2006) ដែលបានលើកឡើងថាគ្រូបង្រៀនធ្លាប់មានអារម្មណ៍តានតឹងចំពោះអធិការកិច្ច ដែលមានមូលហេតុមកពីកម្រិតនៃទំនាក់ទំនងរវាងគ្រូបង្រៀនជាមួយអធិការ និងការមិនដឹងច្បាស់ពីពេលវេលាច្បាស់លាស់របស់អធិការនៅក្នុងថ្នាក់រៀន។ ដូចគ្នានេះដែរ បើតាមរយៈការស្រាវជ្រាវរបស់លោក Machumu (2012) បានរកឃើញថាគ្រូបង្រៀនមានឥរិយាបថវិជ្ជមានចំពោះអធិការកិច្ចសាលារៀន គ្រូបង្រៀនមានជំនឿថាអធិការកិច្ច

សាលារៀនមានសារៈសំខាន់ក្នុងការជួយពង្រឹងការរៀនសូត្ររបស់សិស្ស និងបង្កើនវិធីសាស្ត្របង្រៀនរបស់គ្រូ ប៉ុន្តែគ្រូបង្រៀនបានយល់ថា អធិការកិច្ចបានធ្វើឱ្យពួកគាត់មានភាពរវល់ច្រើនលើការរៀបចំបែបបទការងារកិច្ចតែងការបង្រៀន រៀបចំសៀវភៅកំណត់ហេតុ និងឯកសាររដ្ឋបាលផ្សេងៗទៀត។ ម្យ៉ាងទៀតគ្រូបង្រៀនមានការបារម្ភផងដែរទៅលើភាពខ្សោយរបស់ពួកគាត់នឹងត្រូវបានបើកបង្ហាញទៅដល់នាយកសាលា នៅពេលមានអធិការកិច្ច។ បើផ្អែកលើទីតាំងសាលារៀន ឃើញឥរិយាបថគ្រូបង្រៀនមុនពេលអធិការកិច្ច មានភាពខុសប្លែកគ្នា ដោយគ្រូបង្រៀននៅសាលារៀនតំបន់ជនបទបានផ្តល់តម្លៃវិជ្ជមានទៅលើរូបភាពនៃសកម្មភាពរបស់អធិការមុនពេលអធិការកិច្ចខ្ពស់ជាងគ្រូបង្រៀននៅសាលារៀនតំបន់ទីប្រជុំជន។ លទ្ធផលនេះដូចគ្នានឹងការរកឃើញរបស់ លោក សុភា (២០១២) ដែលបានបង្ហាញថា គ្រូបង្រៀននៅតំបន់ទីប្រជុំជនពុំសូវចាប់អារម្មណ៍ទៅលើការងារអធិការកិច្ចប៉ុន្មានឡើយ ខុសពីគ្រូបង្រៀននៅតំបន់ជនបទ ដែលបានឱ្យតម្លៃទៅលើការងារអធិការកិច្ច។ គ្រូបង្រៀននៅតំបន់ទីប្រជុំជនមិនបានទទួលព័ត៌មានអំពីការចុះអធិការកិច្ចលើការបង្រៀន និងរៀនបានគ្រប់គ្រាន់នៅឡើយ ព្រោះគាត់មិនបានដឹងថានឹងមានការចុះអធិការកិច្ចសាលារៀនរបស់ខ្លួន និងមិនបានដឹងច្បាស់ពីគោលបំណង ឬកម្មវិធីច្បាស់លាស់នៃការចុះអធិការកិច្ចលើការបង្រៀនរបស់ខ្លួនឡើយ ធ្វើឱ្យគាត់មានការព្រួយបារម្ភខ្វល់ខ្វាយខ្លាំងនៅថ្ងៃចុះអធិការកិច្ច។ លើសពីនេះបើយើងគិតពីរយៈពេលនៃការបំពេញការងារជាគ្រូបង្រៀនវិញយើងឃើញថា គ្រូបង្រៀនមានបទពិសោធន៍តិចជាង១ឆ្នាំមានឥរិយាបថវិជ្ជមានខ្ពស់ជាងគេ ដោយសារគាត់ជាគ្រូបង្រៀនថ្មី គាត់មានការប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់ចំពោះការបង្រៀនរបស់ខ្លួន ជាពិសេសគាត់បានឱ្យតម្លៃខ្ពស់ចំពោះការងារអធិការកិច្ច ដោយយល់ថាក្រុមអធិការជាអ្នកអប់រំ ជាអ្នកមានបទពិសោធន៍ច្រើនលើការបង្រៀន ជាអ្នកផ្តល់គំរូដល់គ្រូបង្រៀនដទៃ និងបានត្រៀមអ្វីៗដែលពាក់ព័ន្ធនឹងការបង្រៀនសម្រាប់ការចុះអធិការកិច្ចលើការបង្រៀន និងរៀន។ ទោះបីយ៉ាងនេះក្តី គ្រូបង្រៀនមានបទពិសោធន៍ពី៤ឆ្នាំទៅ៦ឆ្នាំ មានឥរិយាបថវិជ្ជមានកម្រិតទាបជាងគេ មុនពេលអធិការកិច្ចលើការបង្រៀន និងរៀន ដោយមូលហេតុថាគាត់មានបទពិសោធន៍ល្មមគ្រប់គ្រាន់លើការបង្រៀន គាត់បានយក

ចិត្តទុកដាក់តិចតួចលើសារៈសំខាន់នៃការធ្វើអធិការកិច្ចលើការបង្រៀន និងរៀន។ ម្យ៉ាងទៀតការទទួលព័ត៌មានរបស់គ្រូបង្រៀនមានបទពិសោធន៍ពី៤ឆ្នាំទៅ៦ឆ្នាំ មានមធ្យមភាគ 3.58 (តារាង៤.៣១) ជាតម្លៃមួយងាកទៅរកឥរិយាបថអវិជ្ជមាន។ លទ្ធផលនេះអាចមកពីក្រុមអធិការមិនបានបញ្ជូនព័ត៌មានច្បាស់លាស់ទៅដល់សាលារៀន និងគ្រូបង្រៀន ហើយក្រុមការងារអធិការកិច្ចមិនបានពន្យល់ឱ្យបានច្បាស់លាស់ ពីគោលបំណងនៃការចុះអធិការកិច្ចទៅដល់គ្រូបង្រៀនមុនពេលចុះសង្កេតថ្នាក់ ឬមកពីគ្រូបង្រៀនខ្លួនឯងមិនបានយកចិត្តទុកដាក់ខ្លាំងលើការងារអធិការកិច្ចលើការបង្រៀន និងរៀន។

### ៤.២.១.២ ឥរិយាបថគ្រូបង្រៀន អំឡុងពេលអធិការកិច្ចលើការបង្រៀន និងរៀន

អំឡុងពេលអធិការកិច្ចលើការបង្រៀន និងរៀន ការសិក្សាបានបង្ហាញថា គ្រូបង្រៀនមានឥរិយាបថវិជ្ជមានចំពោះសកម្មភាព និងដំណើរការការងារអធិការកិច្ច ទៅលើការបង្រៀន និងរៀនរបស់ពួកគាត់ ព្រោះអធិការបានពិនិត្យយ៉ាងហ្មត់ចត់ និងយកចិត្តទុកដាក់គ្រប់សកម្មភាពទាំងអស់នៅក្នុងថ្នាក់រៀន ហើយមិនបានធ្វើសកម្មភាពណាមួយដែលប៉ះពាល់ដល់អារម្មណ៍សិស្ស និងគ្រូបង្រៀនឡើយ ជាហេតុធ្វើឱ្យការបង្រៀនរបស់គ្រូប្រព្រឹត្តទៅតាមដំណើរដែលបានត្រៀមទុក ប៉ុន្តែគ្រូបង្រៀនហាក់បានប្រឹងប្រែង និងព្យាយាមជំរុញឱ្យសិស្សមានសកម្មភាពច្រើនក្នុងថ្នាក់រៀន ពេលមានការចុះអធិការកិច្ច និងមិនក្លាហានក្នុងការធ្វើពិសោធន៍គំនិតថ្មី/វិធីសាស្ត្រថ្មីៗ សម្រាប់បង្រៀនឡើយ ព្រោះដោយសារគ្រូបង្រៀនចៀសវាងបង្កើតកំហុស។ គ្រូបង្រៀន ចំនួន៤១នាក់ ក្នុងចំណោម៩៤នាក់ មានគំនិតថា អធិការកិច្ចថ្នាក់រៀន គឺដើម្បីពិនិត្យមើលចំណុចដែលត្រូវកែលម្អច្រើនជាងចំណុចល្អរបស់គ្រូ និយាយរួមគឺស្វែងរកកំហុសរបស់គ្រូលើការបង្រៀន និងរៀន។ លទ្ធផលនេះដូចគ្នានឹង (វិទ្យាស្ថានជាតិអប់រំ, ២០១៧) ដែលបង្ហាញថា គ្រូបង្រៀនមិនបានបដិសេធគំនិតនៃការត្រួតពិនិត្យឡើយ ប៉ុន្តែអ្វីដែលគ្រូបង្រៀនមិនចូលចិត្តគឺឥរិយាបថរបស់អ្នកត្រួតពិនិត្យ ដែលថាអ្នកពិនិត្យកែលម្អមួយចំនួនមានឥរិយាបថជាអាជ្ញាធរ ឬអ្នករកកំហុស និងមានភាពលម្អៀង ប្រកាន់តែគំនិតខ្លួនឯង។ នៅពេលសម្ភាសគ្រូបង្រៀនបានចូលរួមសហការជាមួយអធិការ ដោយគ្មានការស្ទាក់ស្ទើរ បានរៀបរាប់ពីបញ្ហាផ្សេងលើ

ការបង្រៀន និងរៀនដោយភាពស្មោះត្រង់ មានន័យថាគ្រូបង្រៀនបានផ្តល់ទំនុកចិត្តក្នុងការរៀបរាប់ពីដំណើរការនៃការបង្រៀនទៅដល់ក្រុមអធិការកិច្ច។ បើផ្អែកលើទីតាំងសាលារៀនវិញ យើងឃើញថា មិនមានភាពខុសគ្នាខ្លាំង រវាងឥរិយាបថគ្រូបង្រៀននៅតំបន់ជន និងគ្រូបង្រៀននៅតំបន់ទីប្រជុំជន លើសកម្មភាពសង្កេតថ្នាក់រៀនរបស់ក្រុមអធិការ ក៏ដូចសង្កេតការបង្រៀន និងការសម្ភាសគ្រូអំពីការបង្រៀន និងរៀនឡើយ។ បើផ្អែកលើបទពិសោធន៍នៃការបំពេញការងារជាគ្រូបង្រៀនវិញ យើងឃើញថាគ្រូបង្រៀនមានឥរិយាបថវិជ្ជមានប្រហាក់ប្រហែលគ្នា ដោយគ្រាន់តែគ្រូបង្រៀនដែលមានបទពិសោធន៍តិចជាងមួយឆ្នាំបានបង្ហាញការពេញចិត្តចំពោះសកម្មភាពអធិការកិច្ចលើការបង្រៀនរបស់ខ្លួនច្រើនជាងគេផ្ទុយពីគ្រូបង្រៀនដែលមានបទពិសោធន៍បង្រៀនលើសពីមួយឆ្នាំ។ ម្យ៉ាងទៀតគ្រូបង្រៀនមានបទពិសោធន៍ពី១ឆ្នាំទៅ៣ឆ្នាំ និងពី៤ឆ្នាំទៅ៦ឆ្នាំ បានបង្ហាញការយល់ឃើញទាបជាងគេលើសកម្មភាពនៃអធិការកិច្ចលើការបង្រៀន និងរៀន ជាការងារមួយដើម្បីស្វែងរកកំហុសរបស់គ្រូបង្រៀន ច្រើនជាងចំណុចល្អៗដែលគ្រូបង្រៀនអនុវត្តបាន។ លទ្ធផលនេះបង្ហាញថាគ្រូដែលទើបចេញបង្រៀនឆ្នាំដំបូង ត្រូវការអធិការកិច្ចលើការបង្រៀនរបស់ខ្លួនច្រើនជាងគេ ព្រោះវាជាឱកាសមួយដែលធ្វើឱ្យគាត់អាចដឹងពីចំណុចដែលត្រូវកែលម្អ ក៏ដូចជាចំណុចខ្លាំងរបស់ខ្លួន ដើម្បីធ្វើឱ្យការបង្រៀនកាន់តែមានប្រសិទ្ធភាពជាងមុន ខុសពីគ្រូបង្រៀនដែលមានបទពិសោធន៍បង្រៀនយូររួចហើយ បានយល់ថាក្រុមអធិការការចុះមកសង្កេតការបង្រៀន គឺដើម្បីស្វែងរកកំហុសរបស់គ្រូបង្រៀន ទោះបីជាគាត់មានការពេញចិត្តចំពោះសកម្មភាពអធិការកិច្ចនៅក្នុងថ្នាក់រៀនខ្លះដែរ ដែលមិនបានបង្កបរិយាកាសស្មុគស្មាញ ឬរំខានដល់ការបង្រៀនក្តី។

### ៤.២.១.៣ ឥរិយាបថគ្រូបង្រៀន ក្រោយពេលអធិការកិច្ចលើការបង្រៀន និងរៀន

ក្រោយពេលអធិការកិច្ចលើការបង្រៀន និងរៀន គ្រូបង្រៀនបឋមសិក្សាបានសំដែង ឥរិយាបថវិជ្ជមានចំពោះអធិការកិច្ច លើការទទួលយកអនុសាសន៍ និងរបាយការណ៍អធិការកិច្ច ដោយមានមធ្យមភាពពិន្ទុ 4.16 កម្រិត"ល្អ"។ លទ្ធផលនេះបង្ហាញថា លោកគ្រូ/អ្នកគ្រូ មានការឯកភាព និងទទួលយកទាំងអនុសាសន៍ និង

របាយការណ៍អធិការកិច្ច អំពីការបង្រៀន និងរៀន ព្រោះគ្រូបង្រៀនបានយល់ថាអនុសាសន៍ និងរបាយ-ការណ៍អធិការកិច្ចមានសារៈសំខាន់សម្រាប់គ្រូបង្រៀន ធ្វើឱ្យការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាព។ ប៉ុន្តែលទ្ធផលដដែលបានបង្ហាញថា គ្រូបង្រៀនតែងតែទទួលបានអនុសាសន៍ក្រោយពីអធិការកិច្ចចប់ច្រើនជាងអ្វីដែលសរសេររៀបរាប់ក្នុងរបាយការណ៍អធិការកិច្ច ព្រោះគ្រូបង្រៀនភាគច្រើនមិនបានដឹងពីខ្លឹមសារក្នុងរបាយការណ៍អធិការកិច្ចពាក់ព័ន្ធនឹងការបង្រៀន និងរៀនរបស់ខ្លួនឡើយ។ ត្រង់ចំណុចនេះយើងអាចសន្និដ្ឋានបានថា គ្រូបង្រៀនចូលចិត្តទទួលយកការណែនាំដោយផ្ទាល់មាត់ ជាជាងការណែនាំដោយការសរសេរក្នុងរបាយការណ៍។ តាមលោក (Quintelier, De Maeyer, & Vanhoof, 2020) បានរកឃើញថាគ្រូបង្រៀនដែលទទួលបានយុត្តិធម៌ត្រឹមត្រូវ ទំនងទទួលយកអនុសាសន៍អធិការកិច្ចច្រើនជាងគ្រូបង្រៀនដែលត្រូវវាយការណ៍កម្រិតទាបនៃយុត្តិធម៌ មានន័យថាគ្រូបង្រៀនទទួលយកអនុសាសន៍របស់អធិការកិច្ច នៅពេលដែលពួកគាត់ទទួលបានអនុសាសន៍ត្រឹមត្រូវ។ បើផ្អែកលើទីតាំងសាលារៀន យើងឃើញថាក្រោយពេលអធិការកិច្ច គ្រូបង្រៀនបានបង្ហាញឥរិយាបថវិជ្ជមានប្រហាក់ប្រហែលគ្នា ដោយគ្រាន់តែគ្រូបង្រៀននៅតំបន់ជនបទបានបង្ហាញការគាំទ្រជារួម ខ្ពស់ជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជន ទាំងការផ្តល់អនុសាសន៍ និងការផ្តល់របាយការណ៍អធិការកិច្ច។ លទ្ធផលបានបង្ហាញថាឥរិយាបថគ្រូបង្រៀនចំពោះរបាយការណ៍អធិការកិច្ចមានភាពខុសគ្នាខ្លាំង គឺកម្រិតយល់ស្របរបស់គ្រូបង្រៀននៅតំបន់ទីប្រជុំជនទាបខ្លាំងជាងគ្រូបង្រៀននៅតំបន់ជនបទលើមធ្យមភាពពិន្ទុ3.66 ទល់នឹង 4.23។ លទ្ធផលនេះបង្ហាញថា គ្រូបង្រៀននៅតំបន់ទីប្រជុំជនគាត់មិនសូវបានចាប់អារម្មណ៍ និងស្វែងយល់ពីអ្វីដែលក្រុមអធិការកិច្ចបានរកឃើញ និងសរសេររៀបរាប់ក្នុងរបាយការណ៍ទេ ដែលអាចបណ្តាលមកពីការផ្សព្វផ្សាយមិនបានទូលំទូលាយទៅដល់គ្រូបង្រៀន បានជាគាត់មិនបានដឹង ឬមកពីរបាយការណ៍អធិការកិច្ចមានភាពស្មុគស្មាញសម្រាប់គ្រូអាន និងអាចយល់ពីអ្វីដែលបានសរសេរ ឬអាចមកពីគ្រូបង្រៀនមិនបានយល់ថារបាយការណ៍អធិការកិច្ចមានសារៈសំខាន់សម្រាប់គាត់ផ្ទាល់ ឬមកពីរបាយការណ៍អធិការកិច្ចបានបញ្ជូនមិនទៅដល់សាលារៀន និងប្រើរយៈពេលយូរ ធ្វើឱ្យគ្រូបង្រៀនភ្លេច

ឬលែងចង់ដឹង។ ចំណែកឯឥរិយាបថគ្រូបង្រៀន ក្រោយពេលអធិការកិច្ចចំពោះអនុសាសន៍ និងរបាយ-ការណ៍អធិការកិច្ច មានភាពខុសគ្នាបើប្រៀបធៀបទៅលើបទពិសោធន៍ការងារបង្រៀនបានបង្ហាញថាគ្រូបង្រៀនថ្មី(ឆ្នាំទី១) បានផ្តល់តម្លៃខ្លាំងចំពោះអនុសាសន៍អធិការកិច្ច និងរបាយការណ៍អធិការកិច្ច ដោយគាត់បានយល់ថា វាមានសារៈប្រយោជន៍កែលម្អលើការបង្រៀនកាន់ប្រសិទ្ធភាពជាងមុន។ ប៉ុន្តែគ្រូបង្រៀនបានពិសោធន៍លើសពី១០ឆ្នាំ មិនបានយល់ស្របថាអនុសាសន៍អធិការកិច្ច នឹងធ្វើឱ្យការបង្រៀនមានភាពប្រសើរឡើងទេ ហើយបែរជាយល់ឃើញថាវាជាការដាក់កិច្ចការបន្ថែមទៀតសម្រាប់គាត់ ដោយគាត់មិនបានអាន ឬមិនបានដឹងពីខ្លឹមសារនៃរបាយការណ៍បានពេញលេញនោះទេ។ ដូចនេះការផ្លាស់ប្តូរជាវិជ្ជមានទៅតាមអនុសាសន៍នៃរបាយការណ៍អធិការកិច្ចលើការបង្រៀន និងរៀននឹងមិនអាចកើតមានឡើងទេ។ លទ្ធផលនេះដូចទៅនឹងការស្រាវជ្រាវរបស់លោក Machumu (2012) បានរកឃើញថា គ្រូបង្រៀនដែលមានអតីតភាពបង្រៀនច្រើនជាង១០ឆ្នាំមិនពេញចិត្តនឹងអធិការកិច្ចឡើយ គាត់មានមោទនភាពថាគាត់យល់ដឹងពីសាលារៀនច្រើនជាងមន្ត្រីអធិការ ហើយគាត់មិនអើពើចំពោះអធិការកិច្ចឡើយ និងមិនមានការផ្លាស់ប្តូរឡើយ។ ផ្ទុយទៅវិញ គ្រូបង្រៀនដែលសកម្មនឹងការងារ មានការគាំទ្រចំពោះការងារអធិការកិច្ច ព្រោះវាផ្នែកមួយដើម្បីឱ្យពួកគាត់អាចធ្វើការវាយតម្លៃខ្លួនឯងលើការងារបង្រៀនផ្ទាល់ខ្លួន និងបានចែករំលែកបទពិសោធន៍ជាមួយមន្ត្រីអធិការផងដែរ។ ជាងនេះទៅទៀតលទ្ធផលនេះ បានបង្ហាញពីភាពខុសគ្នាទៅនឹង លោក សុភា (២០១២) ដែលថាគ្រូបង្រៀនមានបទពិសោធន៍ និងបម្រើការងារបានយូរឆ្នាំកាន់តែយល់ឃើញពីសារៈសំខាន់នៃការងារចុះអធិការកិច្ច។ ការទទួលយក ឬមិនទទួលយកអនុសាសន៍របស់អធិការកិច្ចមកអនុវត្តដើម្បីកែលម្អការបង្រៀនរបស់ខ្លួន គឺមកពីភាពមិនស៊ីចង្វាក់គ្នារវាងអនុសាសន៍ដែលបានផ្តល់ពេលអធិការកិច្ចសាលារៀន និងអនុសាសន៍ក្នុងរបាយការណ៍អធិការកិច្ច (Alkutich & Abukari, 2018)។ ចំណុចនេះវាមានសារៈសំខាន់ណាស់សម្រាប់ការិយាល័យអធិការកិច្ច ដែលត្រូវផ្តល់របាយការណ៍អធិការកិច្ចមួយមានលក្ខណៈសមស្របច្បាស់លាស់ពីចំណុចខ្លាំង និងចំណុចដែលត្រូវកែលម្អ ដែលវានឹងជួយបង្កើនផលប្រយោជន៍នៃដំណើរការ

អធិការកិច្ចទៅលើការរៀន និងបង្រៀន។ ប្រសិនបើអនុសាសន៍ និងរបាយការណ៍អធិការកិច្ច មិនមានដំណើរការនោះទេ មានន័យថាការចុះអធិការកិច្ចលើការបង្រៀន និងរៀនគឺគ្មានប្រយោជន៍ បន្ទាប់មកទៀត អធិការនឹងមិនទទួលបានការជឿទុកចិត្ត និងការគោរពពីគ្រូបង្រៀន ជាចុងក្រោយការកែប្រែជាវិជ្ជមានលើការបង្រៀន និងរៀនតាមការផ្តល់អនុសាសន៍ និងរបាយការណ៍អធិកិច្ច ក៏មិនមានទៀតដែរ( Matete, 2009 ) ។

### ៤.២.២ ការផ្ទៀតផ្ទាត់សម្មតិកម្ម

យោងតាមលទ្ធផលខាងលើ យើងអាចធ្វើការផ្ទៀតផ្ទាត់សម្មតិកម្មបានដូចខាងក្រោមៈ

- គ្រូបង្រៀនបឋមសិក្សា មានឥរិយាបថវិជ្ជមានចំពោះអធិការកិច្ចលើការបង្រៀន និងរៀន
- គ្រូបង្រៀននៅតំបន់ជនបទ មានឥរិយាបថវិជ្ជមានចំពោះអធិការកិច្ចលើការបង្រៀន និងរៀន ខ្ពស់ជាងគ្រូបង្រៀន នៅតំបន់ទីប្រជុំជន
- គ្រូបង្រៀនមានបទពិសោធន៍លើការបង្រៀនតិចជាងមួយ មានឥរិយាបថវិជ្ជមានចំពោះអធិការកិច្ចលើការបង្រៀន និងរៀន ខ្ពស់ជាងគ្រូបង្រៀនមានបទពិសោធន៍យូរឆ្នាំ

### ៤.២.៣ ដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទ **ឥរិយាបថគ្រូបង្រៀនបឋមសិក្សាចំពោះអធិការកិច្ចលើការបង្រៀន នៅក្នុងខេត្តកំពង់ធំ** បានធ្វើឡើងនៅតាមសាលាបឋមសិក្សាចំនួន១៣ នៅក្នុងក្រុងស្ទឹងសែន ស្រុកកំពង់ស្វាយ និងស្រុកប្រាសាទសំបូរ។ នៅក្នុងដំណាក់កាល នៃការស្រាវជ្រាវ អ្នកស្រាវជ្រាវមានការលំបាកក្នុងការប្រមូលទិន្នន័យនៅតាមសាលារៀនគោលដៅ ក្នុងបរិបទការរីករាលដាលនៃជំងឺកូវីដ-១៩ ជាហេតុធ្វើឱ្យការប្រមូលទិន្នន័យពីអ្នកពាក់ព័ន្ធបានតិច ជាពិសេសសិស្សមិនបានមកសាលា។ នៅក្នុងដំណាក់កាលបកស្រាយនិងវិភាគទិន្នន័យ អ្នកស្រាវជ្រាវសិក្សាពីឥរិយាបថគ្រូបង្រៀន ដោយផ្តោតច្រើននៅឥរិយាបថបែបចំណេះដឹង និងឥរិយាបថបែបអារម្មណ៍ប៉ុណ្ណោះ ចំពោះឥរិយាបថបែបអាកប្បកិរិយាមិនត្រូវបានបង្ហាញច្រើនទេ ព្រោះពេលចុះទៅប្រមូលទិន្នន័យអ្នកស្រាវជ្រាវមិនអាចសង្កេតឃើញពីសកម្មភាពរបស់គ្រូបង្រៀនចំពោះអធិការកិច្ចបាន

ទេព្រោះសកម្មភាពចុះអធិការកិច្ចបានកន្លងផុតទៅហើយ។

# ជំពូកទី៥

# សន្និដ្ឋាន និងសំណូមពរ

# ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

គោលបំណងនៃការសិក្សាស្រាវជ្រាវគឺដើម្បីសិក្សាស្វែងយល់ពី **ឥរិយាបថគ្រូបង្រៀនបឋមសិក្សាចំពោះអធិការកិច្ចលើការបង្រៀន និងរៀននៅក្នុងខេត្តកំពង់ធំ**។ តើគ្រូបង្រៀនមានឥរិយាបថវិជ្ជមាន ឬឥរិយាបថអវិជ្ជមានចំពោះការងារអធិការកិច្ច ហើយឥរិយាបថគ្រូបង្រៀនមានភាពខុសគ្នាដែរឬទេ បើប្រៀបធៀបទៅតាមតំបន់ និងបទពិសោធន៍ការងារ។ ការស្រាវជ្រាវនេះបានធ្វើឡើងនៅសាលាបឋមសិក្សាចំនួន១៣ផ្សេងគ្នានៅស្រុកប្រាសាទសំបូរ ស្រុកកំពង់ស្វាយ និងក្រុងស្ទឹងសែន ក្នុងខេត្តកំពង់ធំ។ អ្នកស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរបែបបរិមាណវិស័យបីប្រភេទគឺ សម្រាប់គ្រូបង្រៀន នាយក/នាយិកា និងសិស្ស។ អ្នកស្រាវជ្រាវបានទៅប្រមូលទិន្នន័យដោយផ្ទាល់នៅសាលាគោលដៅទាំងអស់ ហើយទទួលបានកម្រងសំណួរមកវិញចំនួន ២០១ ក្នុងនោះគ្រូបង្រៀនចំនួន៩៤នាក់ នាយក/នាយិកាចំនួន១៣នាក់ និងសិស្សចាប់ពីថ្នាក់ទី៤ដល់ទី៦ ចំនួន១៧៤នាក់។ ការវិភាគទិន្នន័យអ្នកស្រាវជ្រាវប្រើប្រាស់ការគណនាប្រេកង់ ភាគរយ និងតម្លៃមធ្យមដើម្បីបកស្រាយពីឥរិយាបថគ្រូបង្រៀនដោយធ្វើការប្រៀបធៀប និងសំយោគពីកម្រងសំណួរទាំងបីប្រភេទរួមគ្នា។

លទ្ធផលដែលទទួលបាន អ្នកស្រាវជ្រាវបានរកឃើញថាគ្រូបង្រៀនបឋមសិក្សា មានឥរិយាបថវិជ្ជមានចំពោះអធិការកិច្ច ទាំងមុនពេលអធិការកិច្ច អំឡុងពេលអធិការកិច្ច និងក្រោយពេលអធិការកិច្ច។ គ្រូបង្រៀនបានបង្ហាញពីសារៈសំខាន់នៃអធិការកិច្ច ដែលអាចជួយកែលម្អការបង្រៀនកាន់តែមានប្រសិទ្ធភាព។ មុនពេលអធិការកិច្ច គ្រូបង្រៀនយល់ថាអធិការជាអ្នកអប់រំ មានបទពិសោធន៍គ្រប់គ្រាន់ មានអាកប្បកិរិយាស្និទ្ធស្នាល រួសរាយ មិនរើសអើងចំពោះគ្រូបង្រៀន និងជាអ្នកគោរពពេលវេលាបានល្អ ហើយបានត្រៀមលក្ខណៈសម្រាប់ការចុះធ្វើអធិការកិច្ច។ អំឡុងពេលអធិការកិច្ច គ្រូបង្រៀនភាគច្រើនមានការពេញចិត្តចំពោះសកម្មភាព និងដំណើរការអធិការកិច្ចទៅលើការបង្រៀន និងរៀន ដែលបានពិនិត្យយ៉ាងហ្មត់ចត់ និងយកចិត្ត

ទុកដាក់គ្រប់សកម្មភាពទាំងអស់នៅក្នុងថ្នាក់រៀន ហើយមិនបានធ្វើសកម្មភាពប៉ះពាល់ដល់អារម្មណ៍សិស្ស និងគ្រូបង្រៀនឡើយ។ ក្រោយពេលអធិការកិច្ច គ្រូបង្រៀនបានឯកភាព និងទទួលយកទាំងអនុសាសន៍ និងរបាយការណ៍អធិការកិច្ចលើការបង្រៀន និងរៀន ព្រោះគ្រូបង្រៀនបានយល់ថាអនុសាសន៍ និងរបាយការណ៍អធិការកិច្ចបានកែលម្អចំណុចខ្វះខាតរបស់គ្រូបង្រៀន និងជួយធ្វើឱ្យការបង្រៀនកាន់តែមានប្រសិទ្ធភាព។ ការសិក្សានេះ បានរកឃើញផងដែរថា ជាទូទៅគ្រូបង្រៀននៅសាលារៀនតំបន់ជនបទ តែងតែមានឥរិយាបថវិជ្ជមានចំពោះអធិការកិច្ច ខ្ពស់ជាងគ្រូបង្រៀននៅតំបន់ទីប្រជុំជន ហើយគ្រូបង្រៀនទើបចេញបង្រៀនថ្មី មានបទពិសោធន៍តិចជាងមួយឆ្នាំបានផ្តល់តម្លៃដល់ការងារអធិការកិច្ចខ្ពស់ជាងគ្រូបង្រៀនដែលមានបទពិសោធន៍បង្រៀនច្រើនឆ្នាំ។

ទោះបីជាគ្រូបង្រៀនបឋមសិក្សាភាគច្រើន មានឥរិយាបថវិជ្ជមានចំពោះអធិការកិច្ចទៅលើការបង្រៀន និងរៀនយ៉ាងណាក្តី ការស្រាវជ្រាវនេះបានរកឃើញនូវសកម្មភាពអវិជ្ជមានមួយចំនួនរបស់គ្រូបង្រៀនចំពោះអធិការកិច្ចផងដែររួមមាន៖ គ្រូបង្រៀនមួយចំនួនមានការព្រួយបារម្ភ និងអារម្មណ៍តានតឹងនៅពេលដឹងថាមានការចុះធ្វើអធិការកិច្ចនៅសាលារៀនរបស់ពួកគាត់។ គាត់មានការលំបាកក្នុងការត្រៀមការងាររដ្ឋបាល រៀបចំថ្នាក់ ត្រៀមសម្ភារបង្រៀន កិច្ចតែងការបង្រៀន ហើយគ្រូបង្រៀនមានអារម្មណ៍ភ័យព្រួយ បារម្ភខ្លាចបង្រៀនមិនបានល្អ បង្រៀនខុស និងគ្រប់គ្រងសិស្សមិនបានល្អនៅពេលដែលក្រុមអធិការកិច្ចចុះសង្កេតថ្នាក់របស់ពួកគាត់។ ការព្រួយបារម្ភនេះមកពីគ្រូបង្រៀននៅមានគំនិតថា អធិការកិច្ចមកដើម្បីស្វែងរកកំហុសលើការបង្រៀនរបស់គ្រូ មិនមែនជាកែលម្អការបង្រៀនទេ។ លើសពីនេះគ្រូបង្រៀនភាគច្រើនមិនបានដឹងព័ត៌មានច្បាស់លាស់ពីពេលវេលាសង្កេតថ្នាក់ មុខវិជ្ជា និងថ្នាក់រៀនដែលត្រូវចុះអធិការកិច្ចនោះទេ ហើយគ្រូមួយចំនួនទៀតមិនទាន់បានយល់ពីគោលបំណងនៃការចុះអធិការកិច្ចបានច្បាស់លាស់នៅឡើយ ដោយហេតុថាក្រុមអធិការមិនបានបញ្ជូនព័ត៌មានទៅដល់សាលារៀន និងគ្រូបង្រៀនជាមុន។ ម្យ៉ាងទៀតពេលទៅដល់សាលារៀន ក្រុមអធិការមិនបានពន្យល់ឱ្យបានច្បាស់លាស់ពីគោលបំណងនៃការចុះអធិការកិច្ចទៅដល់គ្រូបង្រៀន

មុនពេលធ្វើអធិការកិច្ចឡើយ ឬមកពីគ្រូបង្រៀនខ្លួនឯងមិនបានយកចិត្តទុកដាក់ខ្លាំងលើការងារអធិការកិច្ចលើការបង្រៀននិងរៀន។ លើសពីនេះ គ្រូបង្រៀនភាគច្រើនមានទំនោរទទួលយកអនុសាសន៍ដោយផ្ទាល់ជាងអនុសាសន៍ដែលត្រូវបានសរសេរក្នុងរបាយការណ៍អធិការកិច្ច ព្រោះគាត់មិនសូវបានចាប់អារម្មណ៍ និងស្វែងយល់ពីអ្វីដែលក្រុមអធិការកិច្ចបានរកឃើញ និងសរសេររៀបរាប់ក្នុងរបាយការណ៍អធិការកិច្ចទេ។ កត្តានេះបណ្តាលមកពីការផ្សព្វផ្សាយមិនបានទូលំទូលាយទៅដល់គ្រូបង្រៀន បានជាគាត់មិនបានដឹង ឬអាចមកពីរបាយការណ៍អធិការកិច្ចមានលក្ខណៈស្មុគស្មាញសម្រាប់គ្រូអាន និងអាចយល់ពីអ្វីដែលបានបានសរសេររៀបរាប់។ ម្យ៉ាងទៀត កត្តានេះអាចបណ្តាលមកពីគ្រូបង្រៀនបានយល់ថារបាយការណ៍អធិការកិច្ចមិនមានសារៈសំខាន់សម្រាប់ការងារគាត់ ឬមកពីរបាយការណ៍អធិការកិច្ចមិនត្រូវបានបញ្ជូនទៅដល់សាលារៀន និងប្រើរយៈពេលយូរធ្វើឱ្យគ្រូបង្រៀនភ្លេច ឬលែងចង់ដឹង។ ចំណុចនេះបង្ហាញថា ការកែប្រែការបង្រៀនទៅតាមការកែលម្អនៃអនុសាសន៍របស់អធិការកិច្ច អាចកើតមានឡើងតិចតួចណាស់ ក្រោយពីការចុះអធិការកិច្ចរួច។

សន្និដ្ឋានជារួម គ្រូបង្រៀនបឋមសិក្សានៅតំបន់គោលដៅបានបង្ហាញឥរិយាបថវិជ្ជមាន ចំពោះការងារអធិការកិច្ចលើការបង្រៀន និងរៀន ទោះបីជាមានសកម្មភាពខ្លះៗដែលបង្ហាញពីភាពខ្វះចន្លោះក្នុងការចុះអធិការកិច្ចកន្លងមកក្តី។ អ្នកស្រាវជ្រាវបានរកឃើញថា គ្រូបង្រៀនភាគច្រើនមានឥរិយាបថវិជ្ជមានកម្រិតខ្ពស់នៅអំឡុងពេលអធិការកិច្ចលើការបង្រៀន និងរៀនច្រើនជាងមុនពេលអធិការកិច្ច និងក្រោយពេលអធិការកិច្ច។ ម្យ៉ាងទៀតបើប្រៀបធៀបឥរិយាបថគ្រូបង្រៀនមុនពេលអធិការកិច្ច និងក្រោយពេលអធិការកិច្ច ឃើញថាក្រោយពេលអធិការកិច្ច គ្រូបង្រៀនមានឥរិយាបថវិជ្ជមានកម្រិតខ្ពស់ជាង។ លទ្ធផលបង្ហាញ គ្រូបង្រៀនភាគច្រើនចូលរួមក្នុងសកម្មភាពអធិការកិច្ច និងបង្ហាញការសហការល្អតែក្នុងពេលដែលអធិការមានវត្តមាននៅក្នុងសាលារៀន ចំណែកមុនពេលដែលអធិការកិច្ចមកដល់ និងក្រោយពេលអធិការកិច្ចត្រលប់ទៅវិញ ឥរិយាបថវិជ្ជមានរបស់គ្រូបង្រៀនមានការថយចុះ។ បើសិក្សាលើទីតាំងសាលារៀន និងបទពិសោធន៍ ឃើញថាគ្រូបង្រៀននៅសាលារៀនតំបន់ជនបទមានឥរិយាបថវិជ្ជមានចំពោះអធិការកិច្ច ខ្ពស់ជាងគ្រូបង្រៀននៅតំបន់ទី

ប្រជុំជន និងគ្រូដែលទើបចេញបង្រៀនថ្មីមានបទពិសោធន៍តិចជាងមួយឆ្នាំ បានផ្តល់តម្លៃដល់ការងារអធិការកិច្ចខ្ពស់ជាងគ្រូបង្រៀនដែលមានបទពិសោធន៍បង្រៀនច្រើនឆ្នាំ។

ខាងក្រោមនេះ ជាសំណូមពរមួយចំនួន ដែលទទួលបានពីនាយក/នាយិកា លោកគ្រូ/អ្នកគ្រូដែលបានបំពេញកម្រងសំណួរ និងអ្នកស្រាវជ្រាវ ដើម្បីឆ្លើយតបនឹងបញ្ហាដែលបានរកឃើញ ជូនចំពោះភាគីពាក់ព័ន្ធដូចជា មន្ទីរអប់រំយុវជន និងកីឡា ខេត្តកំពង់ធំ ,ការិយាល័យអធិការកិច្ច, ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក និងនាយក/នាយិកា ដើម្បីរួមគ្នាធ្វើឱ្យការងារអធិការកិច្ចលើការបង្រៀន និងរៀន កាន់តែមានប្រសិទ្ធភាព ទទួលបានការទទួលស្គាល់ជាធានាគុណភាពអប់រំ ក្នុងគោលបំណងអភិវឌ្ឍវិស័យអប់រំនៅកម្ពុជាឱ្យសម្រេចបានតាមគោលដៅអប់រំជាតិ។

## ៥.២ សំណូមពរ

ដើម្បីឱ្យការធ្វើអធិការកិច្ចលើការបង្រៀន និងរៀនអនុវត្តទៅបានប្រកបប្រសិទ្ធភាពជាងមុន ភាគីពាក់ព័ន្ធគួរតែគិតគូរឡើងវិញលើចំណុចដូចខាងក្រោម៖

### ៥.២.១ មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ធំ

- ថ្នាក់ដឹកនាំមន្ទីរដែលទទួលបន្ទុកលើការងារអធិការកិច្ច គួរតែពិនិត្យ និងជួយដោះស្រាយបញ្ហាប្រឈម ដែលក្រុមអធិការកិច្ចបានរកឃើញ ដើម្បីធានាថាការអធិការកិច្ចសាលារៀនបានប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពខ្ពស់។

### ៥.២.២ ការិយាល័យអធិការកិច្ច

- ដោយផ្អែកលើលទ្ធផលនៃការស្រាវជ្រាវដែលរកឃើញថា គ្រូបង្រៀនភាគច្រើនមិនទាន់បានទទួលព័ត៌មានគ្រប់គ្រាន់ពីការចុះអធិការកិច្ច និងតាមរយៈសំណូមពររបស់គ្រូបង្រៀន និងនាយក/នាយិកា ក្រុមអធិការកិច្ចត្រូវធានាថារាល់ព័ត៌មានអំពីការចុះអធិការកិច្ច ត្រូវផ្តល់ដំណឹងដល់គ្រូបង្រៀនជាមុន ដើម្បីឱ្យគាត់អាចមានពេលគ្រប់គ្រាន់ក្នុងត្រៀមលក្ខណៈនានាសម្រាប់ពេលមានអធិការកិច្ច។ លើស

ពីនេះក្រុមអធិការគួរចំណាយពេលខ្លះដើម្បីប្រជុំជាមួយគ្រូបង្រៀន មុនពេលចុះអធិការកិច្ចថ្នាក់រៀន ដើម្បីពន្យល់គ្រូបង្រៀនពីគោលបំណងនៃការចុះអធិការកិច្ច និងអាចបង្កើតទំនាក់ទំនងរវាងគ្រូបង្រៀន និងក្រុមអធិការ។

- គ្រូបង្រៀនលើសពី៥០%មិនបានដឹងពីខ្លឹមសារនៃរបាយការណ៍អធិការកិច្ច ទោះបីជានាយក/នាយិកាបានផ្សព្វផ្សាយក្តី ដូចនេះការបញ្ជូនរបាយការណ៍អធិការកិច្ចទៅតាមសាលារៀន គួរតែបន្ថែមវិធីបញ្ជូនតាមប្រព័ន្ធអេឡិចត្រូនិច ឬTelegram ដើម្បីឱ្យនាយក/នាយិកាឆាប់ទទួលបាន និងផ្សព្វផ្សាយទាន់ពេលវេលា ចៀសវាងការទទួលបានយូរ រួចទុកចោលមិនបានប្រើប្រាស់។
- គ្រូបង្រៀនភាគច្រើនចាប់អារម្មណ៍លើអនុសាសន៍ផ្ទាល់មាត់ ជាងអនុសាសន៍ក្នុងរបាយការណ៍ ដូចនេះ ក្រោយពេលអធិការកិច្ចលើការបង្រៀន និងរៀន អធិការគួរតែមានពេលវេលាគ្រប់គ្រប់គ្រាន់សម្រាប់ផ្តល់អនុសាសន៍ និងពិភាក្សាចំណុចដែលត្រូវកែលម្អទៅដល់គ្រូបង្រៀនជារួម និងជាបុគ្គល ព្រោះប្រសិនបើមិនបានឱ្យអនុសាសន៍ លោកគ្រូ/អ្នកគ្រូនឹងមិនដឹងពីចំណុចខ្លាំង និងចំណុចកែលម្អរបស់ខ្លួនឡើយ ម្យ៉ាងទៀតការផ្តល់អនុសាសន៍ជារួម ធ្វើឱ្យគ្រូបង្រៀនមិនអាចកំណត់បានពីចំណុចសំខាន់របស់ខ្លួនដែលត្រូវកែលម្អ។
- ដោយផ្អែកលើសំណូមពរគ្រូបង្រៀន អធិការគួរចែករំលែកបទពិសោធន៍លើវិធីសាស្ត្របង្រៀនថ្មីៗ ការផលិតនិងប្រើប្រាស់សម្ភារឧបទេស និងវិធីសាស្ត្រជួយសិស្សរៀនយឺត។
- តាមរយៈសំណូមពរនាយក/នាយិកា អធិការកិច្ចលើការបង្រៀន និងរៀន គួរតែធ្វើឡើងឱ្យបានគ្រប់ថ្នាក់រៀន និងចប់ម៉ោងសិក្សានីមួយៗ ដើម្បីអាចធ្វើការវាយតម្លៃបានត្រឹមត្រូវ តំណាងឱ្យសាលារៀនទាំងមូលបាន។

### ៥.២.៣ ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង/ស្រុក

- របាយការណ៍អធិការកិច្ចសាលារៀនជាញឹកញាប់ ត្រូវបានបញ្ជូនទៅសាលាតាមរយៈការិយាល័យអប់រំ យុវជន និងកីឡា ក្រុង/ស្រុក ដូចនេះការិយាល័យអប់រំ យុវជន និងកីឡា ក្រុង/ស្រុក នីមួយៗ ត្រូវធានាបញ្ជូនរបាយការណ៍អធិការកិច្ច ឱ្យបានលឿនជាងមុន និងជួយផ្សព្វផ្សាយរបាយការណ៍ទៅដល់គ្រូបង្រៀននៅតាមសាលារៀនគោលដៅ។
- ចុះពិនិត្យតាមដានការអនុវត្តតាមអនុសាសន៍នៃរបាយការណ៍អធិការកិច្ច លើការបង្រៀន និងរៀន។

### ៥.២.៤ នាយក/នាយិកា

- បញ្ជូនដំណឹងពីការចុះអធិការកិច្ចលើការបង្រៀននិងរៀន ទៅដល់គ្រូបង្រៀនឱ្យបានគ្រប់ៗគ្នា។
- ផ្សព្វផ្សាយរបាយការណ៍អធិការកិច្ចលើការបង្រៀន និងរៀនឱ្យបានទូលំទូលាយទៅដល់គ្រូបង្រៀន។

## ៥.៣ អនុសាសន៍សម្រាប់ការសិក្សាស្រាវជ្រាវបន្ត

ការសិក្សាស្រាវជ្រាវនេះផ្តោតទៅលើឥរិយាបថគ្រូបង្រៀនបឋមសិក្សា ចំពោះអធិការកិច្ចលើការបង្រៀន និងរៀន នៅខេត្តកំពង់ធំ ហើយសម្រាប់ការសិក្សាបន្ត អ្នកស្រាវជ្រាវដទៃទៀតអាចធ្វើការពិចារណាដូចតទៅ៖

- សិក្សាតាមគុណវិស័យ លើប្រធានបទដដែលនេះ ដើម្បីស្វែងយល់កាន់តែស៊ីជម្រៅទៅលើឥរិយាបថគ្រូបង្រៀនចំពោះអធិការកិច្ចលើការបង្រៀន និងរៀន។
- គួរតែសិក្សាបន្ថែមពីទស្សនៈរបស់អធិការចំពោះឥរិយាបថគ្រូបង្រៀនបឋមសិក្សាលើការបង្រៀន និងរៀន
- គួរតែពង្រីកវិសាលភាពនៃការស្រាវជ្រាវ និងធ្វើការស្រាវជ្រាវលើឥរិយាបថគ្រូបង្រៀននៅកម្រិតមធ្យមសិក្សា និងធ្វើការប្រៀបធៀប។
- គួរតែសិក្សាលម្អិតពីការប្រៀបធៀបឥរិយាបថគ្រូបង្រៀន មុនពេលអធិការកិច្ច អំឡុងពេលអធិការកិច្ច និងក្រោយពេលអធិការកិច្ច ។

# ឯកសារយោង


រាជរដ្ឋាភិបាលកម្ពុជា (២០១៨) យុទ្ធសាស្ត្រចតុកោណ។

រាជរដ្ឋាភិបាលកម្ពុជា (២០១៩) គោលនយោបាយជាតិ ស្តីពី ការសិក្សាពេញមួយជីវិត។

ក្រសួងអប់រំយុវជន និងកីឡា (២០១៥) បញ្ញត្តិនៃការធានាគុណភាពអប់រំ កម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជា។

ក្រសួងអប់រំយុវជន និងកីឡា (២០១៩) ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣។

ក្រសួងអប់រំយុវជននិងកីឡា (២០១៩) សន្និបាតអប់រំ។

ក្រសួងអប់រំយុវជននិងកីឡា (២០១៧ក) ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃ។

ក្រសួងអប់រំយុវជននិងកីឡា (២០១៧ខ) ប្រកាស ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់តំបន់អធិការកិច្ចអប់រំ លេខ ៦៤៩ អយក.ប្រក.។

វិទ្យាស្ថានជាតិអប់រំ (២០១៧) ឯកសារបំប៉ននាយក នាយិកាសាលារៀន ស្តីពី អធិការកិច្ចអប់រំជាប្រព័ន្ធ។

នាយកដ្ឋានធានាគុណភាពអប់រំ (២០២០ក) បទបង្ហាញ លទ្ធផលអធិការកិច្ចតាមប្រធានបទ "ការគ្រប់គ្រងនិងប្រើប្រាស់សៀវភៅសិក្សាគោលនៅបឋមសិក្សា២០១៩"។

នាយកដ្ឋានធានាគុណភាពអប់រំ (២០២០ខ) វឌ្ឍនភាពការងារអធិការកិច្ច។

របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ២០១៩ ការិយាល័យអធិការកិច្ច មន្ទីរ អយក កំពង់ធំ។

សំ សុភា (២០១២) ទស្សនៈគ្រូបង្រៀនចំពោះការធ្វើអធិការកិច្ចការបង្រៀននៅកម្រិតបឋមសិក្សា។

ឈីញ នីដា (២០១៨) ស្ថាទីស្និកអនុវត្ត។

ប៉ែនឆោម ឆារ៉ែត (២០១៨) ឥរិយាបថគ្រូរបស់គ្រូមធ្យមសិក្សាបឋមភូមិចំពោះការអានករណីសិក្សា៖ ខេត្តត្បូងឃ្មុំ។

សែម ម៉ាក់ (២០១៨) ឥរិយាបថរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេសនៅមធ្យមសិក្សាបឋមភូមិ

ករណីសិក្សា៖ ខេត្តកំពង់ចាម។

Alkutich, M., & Abukari, A. (2018). Examining the Benefit of School Inspection on Teaching and Learning: A Case Study of Dubai Private Schools. Journal of Education and Practice.

Aydın, İ. (2005). Inspection in Education. Ankara: Pegem Publishing.

Başar, H. (1998). Education Inspector. 4th Edition. Ankara: Pegem Publishing.

Başaran, İ.E.(1988). Educational Administration. Ankara: Sevinç Printing House.

Blair, G., Jones R. & Simpson, H. (1954). Educational psychology, (pp. 192, 195). Toronto: Macmillan.

Brimblecombe, N., Ormston, M., & Shaw, M. (2006). Teachers' Perceptions of School Inspection: a stressful experience. Cambridge Journal of Education, 25(1), 53-61. doi:10.1080/0305764950250106

Bursalıoğlu, Z .(2002). New Structures and Behaviours in School Administration. Ankara: Pegem Academy.

Cole, G.A. (1995). Organisational behaviour: Theory and Practice. (pp 112,113). London: DP Publications Ltd.

Corsini, J. (1987). Concise encyclopaedia of psychology, (pp. 96-98). Canada: A Wiley–Interscience Press.

Cowie, A. P. (1994 ed.). Oxford advanced learners encyclopaedic dictionary. (pp. 220 & 284). Hong Kong: Oxford University Press.

Day, C. (1991). In Anna C. (Ed.). (1996). Continuing Professional Development, (p. 163)

Dennis, R.M. (1988). Organisational behaviour: Managerial Strategies for Performance. (p. 103). New York: West Publishing Company.

Dodd, W.A. (1968). Principal school inspection in New Countries. London: Oxford University Press.

Grauwe, A. (2007). Transforming School Supervision into a Tool for Quality Improvement. In International Review of Education, 709-714.

Harcourt, N.-A. (2018). Attitudes of Senior Secondary School Teachers Towards Secondary School Inspection in Obio/Akpor Local Government Area of Rivers State.

Hornby, A.S (1995). Oxford Advanced Learners Dictionary of Current English, London: Oxford University press.

Machumu, H. J. (2012). Secondary_school_teachers_attitude_toward school inspection A case of Bunda District Council in Tanzania. International Research Journal of Musicology and Drama, 1(1)(October 2012), 1-7.

Maina, P. W. (2003). Public secondary school students‟ attitudes towards guidance and counselling in Ol-joro-rok division, (p. 11). Unpublished Post graduate Diploma in Education Thesis, Njoro, Kenya: Egerton University.

Matete, R. (2009). The impact of primary school inspection on teaching and learning in Tanzania : a study of Mbeya city district.

Matthew, I. A. (2012). The Challenges Facing Schools' Inspection Amid Universal Basic Education (UBE) Implementation In Nigeria. International Journal of Learning and Development, 2(5). doi:10.5296/ijld.v2i5.1986

McLeod, S. (2008). Liket Scale.

Memişoğlu, S.P.; Ekinci, Z. (2013). Views of Inspectors and Principals concerning the Problems Encountered in General Inspections of Primary Schools. Journal of Research in Education and Teaching. Volume 2, Number 1.

Murray, M. (2017). The calculation of percentages and means from data in a Blackboard Enterprise Surveys.

Mwangi, J. G. (2002). Education, culture and attitudes to work: Their contributions to One‟s professional success, (pp. 1-5). OSSREA Newsletter available at http://www.ossrea. Org/newsfeb02/article11.htm. printed on 4/12/2002.

Neave, Guy (1987). Accountability in Education. In Psacharopouls George (1987) (ed). Economics of Education- Research and Studies pg 70-79. Oxford: Pergamon press

Nzuve, N.M. (1999). Elements of Organisational behaviour. (p.41). Nairobi: Nairobi University Press.

Ofsted Inspections (2009): a framework for school inspection. Royal Exchange Building, St Ann's Square, Manchester M2 7LA; www.ofsted.gov.uk; enquiries@ofsted.gov.uk

OFSTED. (1995). Guidance on the inspection of secondary schools. London:HMSO (similar handbooks are available for the inspection of primary and special schools).

Ogelabi, A. (1981). A Guide to School Management, Ibadan: Valuta Educational Publishers.

Quintelier, A., De Maeyer, S., & Vanhoof, J. (2020). Determinants of teachers' feedback acceptance during a school inspection visit. School Effectiveness and School Improvement, 1-19. doi:10.1080/09243453.2020.1750432

Sarah aguti (2015) School inspection and its influence in the quality development of inclusive education pratices in Uganda. Page 1

SPIEGEL, M. R., & J.STEPHENS, L. (2008). Theory and Problem of STATISTICS, Fourth Edition. doi:DOI: 10.1036/0071485848

Su, K. (1974). Importance of Inspections in the Turkish Education. İstanbul: Milli Eğitim Printing House.

Wanjohi, S. M. (2007). Teachers' and principals' attitudes towards school inspection in selected public secondary schools in Kenya's Nyandarua District. Egerton University,

Wannatawee, K.; Worakham, P.; & Panya, P. (2017). Development of an Assessment Model on Parallel Educational Management in the Academy Schools under Office of the Basic Education Commission. European Journal of Education Studies, (3)2, 313. doi:10.5281/zenodo.260133

teacher-inspection; www.ualberta.ca

Wenden A. (1991). Learner Strategies for Learner Autonomy. London: Prentice Hall.

www.iedunote.com/components-of-attitudes 10-March-2020

Wilcox, B. (2000). Making school inspection visits more effective: The English experience: Unesco, International Institute for Educational Planning.

Zachariah Wanzare, Kenneth L.Ward,(2000).School Inspection: Rethinking School Inspection in the Third World: The case of Kenya

# បញ្ជីតារាង

**ល.រ** **បរិយាយ** **ទំព័រ**

**តារាង 1៖** ការប្រៀបធៀបរវាងអធិការកិច្ចតាមមុខវិជ្ជា និងអធិការកិច្ចជាប្រព័ន្ធ.................................14

**តារាង 2៖** ការប្រៀបធៀបរវាងអធិការកិច្ចផ្ទៃក្នុង និងអធិការកិច្ចផ្ទៃក្រៅ.............................................15

**តារាង 3៖** គុណសម្បត្តិ និងគុណវិបត្តិនៃអធិការកិច្ចផ្ទៃក្នុង/ផ្ទៃក្រៅ..................................................16

**តារាង 4៖** ភាពខុសគ្នារវាងការពិនិត្យតាមដាន និងវាយតម្លៃ...........................................................22

**តារាង 5៖** បណ្ណសង្កេតថ្នាក់សម្រាប់អធិការកិច្ចថ្នាក់រៀន .............................................................32

**តារាង 6៖** ដំណាក់កាលទាំងបីនៃការធ្វើអធិការកិច្ចថ្នាក់រៀន...........................................................36

**តារាង 7៖** សាលាបឋមសិក្សា ដែលត្រូវបានចុះអធិការកិច្ចតាមកាលកំណត់ ពីឆ្នាំ២០១៨ ដល់ ២០២០...48

**តារាង 8៖** ស្ថិតិសិស្ស-គ្រូ សាលាបឋមសិក្សាគោលដៅនៅឆ្នាំសិក្សា ២០១៩-២០២០ ..........................49

**តារាង 9៖** ចំនួនសំណាក នាយក/នាយិកា - គ្រូបង្រៀន - សិស្ស នៅតាមសាលាគោលដៅ.....................51

**តារាង 10៖** កម្រងសំណួរសម្រាប់គ្រូបង្រៀន...................................................................................53

**តារាង 11៖** កម្រងសំណួរសម្រាប់នាយក/នាយិកា ............................................................................56

**តារាង 12៖** ព័ត៌មានទូទៅអំពីគ្រូបង្រៀន ដែលបានចូលរួមបំពេញកម្រងសំណួរ ...................................62

**តារាង 13៖** ព័ត៌មានទូទៅអំពីនាយក/នាយិកា ដែលបានចូលរួមបំពេញកម្រងសំណួរ ...........................63

**តារាង 14៖** ព័ត៌មានទូទៅអំពីសិស្សានុសិស្ស ដែលបានចូលរួមបំពេញកម្រងសំណួរ.............................66

**តារាង 15៖** ទំនាក់ទំនងរវាងគ្រូបង្រៀន និងក្រុមអធិការកិច្ច ទទួលបានតាមរយៈកម្រងសំណួរគ្រូបង្រៀន .74

**តារាង 16៖** ទំនាក់ទំនងរវាងគ្រូបង្រៀន និងក្រុមអធិការកិច្ច ទទួលបានតាមរយៈកម្រងសំណួរនាយក ......75

**តារាង 17៖** ការផ្តល់ព័ត៌មានអំពីការចុះអធិការកិច្ច ទទួលបានតាមរយៈកម្រងសំណួរគ្រូបង្រៀន .............77

**តារាង 18៖** ការផ្តល់ព័ត៌មានអំពីការចុះអធិការកិច្ច ទទួលបានតាមរយៈកម្រងសំណួរនាយក/នាយិកា .......78

**តារាង 19៖** ការគោរពពេលវេលារបស់ក្រុមអធិការកិច្ច ទទួលបានពីកម្រងសំណួរគ្រូបង្រៀន ..................80
**តារាង 20៖** ការគោរពពេលវេលារបស់ក្រុមអធិការកិច្ច តាមរយៈកម្រងសំណួរនាយក/នាយិកា ................81
**តារាង 21៖** ការត្រៀមលក្ខណៈរបស់គ្រូចំពោះអធិការកិច្ច ទទួលបានតាមរយៈកម្រងសំណួរគ្រូបង្រៀន.....82
**តារាង 22៖** ការត្រៀមលក្ខណៈរបស់គ្រូចំពោះអធិការកិច្ច ទទួលតាមរយៈកម្រងសំណួរនាយក/នាយិកា ...84
**តារាង 23៖** ឥរិយាបថគ្រូបង្រៀនចំពោះអធិការកិច្ច មុនពេលអធិការកិច្ចលើការបង្រៀន និងរៀន .............85
**តារាង 24៖** ឥរិយាបថគ្រូបង្រៀនចំពោះការចុះសង្កេតថ្នាក់រៀនរបស់ក្រុមអធិការ ទទួលបានកម្រងសំណួរគ្រូបង្រៀន..........................................................................................................................88
**តារាង 25៖** ឥរិយាបថគ្រូបង្រៀនចំពោះការចុះសង្កេតថ្នាក់រៀនរបស់អធិការ ទទួលបានកម្រងសំណួរនាយក/នាយិកា..........................................................................................................................90
**តារាង 26៖** ឥរិយាបថគ្រូបង្រៀនចំពោះអធិការកិច្ចពេលចុះសង្កេតការបង្រៀន ទទួលបានពីកម្រងសំណួរគ្រូបង្រៀន..........................................................................................................................92
**តារាង 27៖** ឥរិយាបថគ្រូបង្រៀនចំពោះអធិការកិច្ចពេលសង្កេតការបង្រៀន តាមរយៈកម្រងសំណួរនាយក93
**តារាង 28៖** ឥរិយាបថគ្រូបង្រៀនចំពោះការសម្ភាស ទទួលបានតាមរយៈកម្រងសំណួរគ្រូបង្រៀន ............96
**តារាង 29៖** ឥរិយាបថគ្រូបង្រៀនចំពោះការសម្ភាស ទទួលបានតាមរយៈកម្រងសំណួរនាយក/នាយិកា .....97
**តារាង 30៖** ឥរិយាបថគ្រូបង្រៀន អំឡុងពេលអធិការកិច្ចលើការបង្រៀន និងរៀន.................................99
**តារាង 31៖** ឥរិយាបថគ្រូបង្រៀនចំពោះអនុសាសន៍អធិការកិច្ច ទទួលបានតាមរយៈកម្រងសំណួរគ្រូបង្រៀន .........101
**តារាង 32៖** ឥរិយាបថគ្រូបង្រៀនចំពោះអនុសាសន៍អធិការកិច្ច ទទួលបានតាមរយៈកម្រងសំណួរនាយក/នាយិកា 104
**តារាង 33៖** សកម្មភាពគ្រូបង្រៀនក្រោយពេលចុះអធិការកិច្ច ទទួលបានតាមរយៈកម្រងសំណួរសិស្ស.... 104
**តារាង 34៖** ឥរិយាបថគ្រូបង្រៀនចំពោះរបាយការណ៍អធិការកិច្ច ទទួលបានតាមរយៈកម្រងសំណួរគ្រូបង្រៀន.107

**តារាង 35៖** ឥរិយាបថគ្រូបង្រៀនចំពោះរបាយការណ៍អធិការកិច្ច ទទួលបានតាមរយៈកម្រងសំណួរនាយក/នាយិកា.....108

**តារាង 36៖** ឥរិយាបថរបស់គ្រូបង្រៀន ក្រោយពេលចុះអធិការកិច្ចលើការបង្រៀន និងរៀន.....109

**តារាង 37៖** តារាងសង្ខេបស្ដីពីឥរិយាបថគ្រូបង្រៀនចំពោះអធិការកិច្ចលើការបង្រៀន និងរៀន ទាំង៣ដំណាក់កាល.....110

**តារាង 38៖** ឥរិយាបថគ្រូបង្រៀនតំបន់ជនបទ និងប្រជុំជន លើទំនាក់ទំនងរវាងគ្រូបង្រៀន និងក្រុមអធិការកិច្ច..114

**តារាង 39៖** ឥរិយាបថគ្រូបង្រៀនតំបន់ជនបទ និងប្រជុំជនចំពោះទំនាក់ទំនងរវាងគ្រូបង្រៀន និងក្រុមអធិការកិច្ច តាមរយៈកម្រងសំណួរនាយក/នាយិកា.....116

**តារាង 40៖** ឥរិយាបថគ្រូបង្រៀនជនបទ និងប្រជុំជន លើការផ្ដល់ព័ត៌មានមុនពេលចុះអធិការកិច្ច.....117

**តារាង 41៖** ឥរិយាបថគ្រូបង្រៀន ចំពោះការផ្ដល់ព័ត៌មានមុនពេលចុះអធិការកិច្ចតាមរយៈកម្រងសំណួរនាយក/នាយិកា.....118

**តារាង 42៖** ឥរិយាបថគ្រូបង្រៀនតំបន់ជនបទ និងប្រជុំជន លើការគោរពពេលវេលារបស់ក្រុមអធិការកិច្ច 120

**តារាង 43៖** ឥរិយាបថគ្រូបង្រៀនជនបទ និងប្រជុំជន លើការគោរពពេលវេលារបស់ក្រុមអធិការកិច្ច ទទួលបានពីកម្រងសំណួរនាយក/នាយិកា.....121

តារាង 44៖ ឥរិយាបថគ្រូបង្រៀនតំបន់ជនបទ និងប្រជុំជន ចំពោះការត្រៀមលក្ខណៈសម្រាប់ការចុះអធិការកិច្ច.....122

**តារាង 45៖** ឥរិយាបថគ្រូបង្រៀននៅតំបន់ជនបទ និងប្រជុំជន ចំពោះការត្រៀមលក្ខណៈសម្រាប់ការចុះអធិការកិច្ច ទទួលបានពីកម្រងសំណួរនាយក/នាយិកា.....123

**តារាង 46៖** ឥរិយាបថគ្រូបង្រៀនតំបន់ជនបទ និងតំបន់ប្រជុំជន មុនពេលអធិការកិច្ចលើការបង្រៀន និងរៀន.....124

**តារាង 47៖** ឥរិយាបថគ្រូបង្រៀនតំបន់ជនបទ និងតំបន់ប្រជុំជនចំពោះការសង្កេតថ្នាក់រៀនរបស់អធិការកិច្ច..127

**តារាង 48៖** ឥរិយាបថគ្រូបង្រៀនតំបន់ជនបទ និងទីប្រជុំជន ចំពោះការសង្កេតថ្នាក់រៀនរបស់អធិការកិច្ច ទទួលបានពីកម្រងសំណួរនាយក/នាយិកា ........ 128

**តារាង 49៖** ឥរិយាបថគ្រូបង្រៀនតំបន់ជនបទ និងតំបន់ប្រជុំជនចំពោះការចុះអធិការកិច្ចលើការបង្រៀន 130

**តារាង 50៖** ឥរិយាបថគ្រូបង្រៀននៅតំបន់ទីជនបទ និងទីប្រជុំជនចំពោះការចុះអធិការកិច្ចលើការបង្រៀន ទទួលបានពីកម្រងសំណួរនាយក/នាយិកា ........ 131

**តារាង 51៖** ឥរិយាបថគ្រូបង្រៀនតំបន់ជនបទ និងតំបន់ប្រជុំជនចំពោះការសម្ភាសរបស់ក្រុមអធិការកិច្ច . 133

**តារាង 52៖** ឥរិយាបថគ្រូបង្រៀននៅតំបន់ផ្សេងគ្នាចំពោះការសម្ភាសរបស់ក្រុមអធិការកិច្ច ទទួលបានពីកម្រងសំណួរនាយក/នាយិកា ........ 134

**តារាង 53៖** ឥរិយាបថគ្រូបង្រៀនតំបន់ជនបទ និងតំបន់ប្រជុំជន អំឡុងពេលអធិការកិច្ច ........ 135

**តារាង 54៖** ឥរិយាបថគ្រូបង្រៀនតំបន់ជនបទ និងតំបន់ប្រជុំជន ចំពោះអនុសាសន៍អធិការកិច្ច ........ 137

**តារាង 55៖** ឥរិយាបថគ្រូបង្រៀននៅតំបន់ជនបទ និងទីប្រជុំជនចំពោះអនុសាសន៍អធិការកិច្ច ទទួលបានពីកម្រងសំណួរនាយក/នាយិកា ........ 138

**តារាង 56៖** ឥរិយាបថគ្រូបង្រៀនតំបន់ជនបទ និងតំបន់ប្រជុំជន ចំពោះរបាយការណ៍អធិការកិច្ច ........ 141

**តារាង 57៖** ឥរិយាបថគ្រូបង្រៀនតំបន់ជនបទ និងតំបន់ប្រជុំជន ចំពោះរបាយការណ៍អធិកាកិច្ច តាមរយៈកម្រងសំណួរនាយក ........ 143

**តារាង 58៖** ឥរិយាបថគ្រូបង្រៀនតំបន់ជនបទ និងតំបន់ប្រជុំជន ក្រោយពេលអធិការកិច្ច ........ 144

**តារាង 59៖** តារាងសង្ខេបស្តីពី ឥរិយាបថគ្រូបង្រៀនចំពោះអធិការកិច្ច ផ្អែកតាមទីតាំងសាលារៀន ........ 146

**តារាង 60៖** ទំនាក់ទំនងរវាងគ្រូបង្រៀន និងក្រុមអធិការកិច្ច ផ្អែកលើបទពិសោធន៍នៃការបង្រៀន ........ 150

**តារាង 61៖** ឥរិយាបថគ្រូបង្រៀន លើការផ្តល់ព័ត៌មានរបស់ក្រុមអធិការកិច្ច ផ្អែកលើបទពិសោធន៍នៃការបង្រៀន ........ 151

**តារាង 62៖** ឥរិយាបថគ្រូបង្រៀន លើការគោរពពេលវេលារបស់ក្រុមអធិការកិច្ច ផ្អែកលើបទពិសោធន៍នៃការបង្រៀន....152

**តារាង 63៖** ឥរិយាបថគ្រូបង្រៀនលើការត្រៀមលក្ខណៈសម្រាប់ការចុះអធិការកិច្ច ផ្អែកលើបទពិសោធន៍នៃការបង្រៀន....154

**តារាង 64៖** ឥរិយាបថគ្រូបង្រៀន មុនពេលអធិការកិច្ច ផ្អែកលើបទពិសោធន៍នៃការបង្រៀន....155

**តារាង 65៖** ឥរិយាបថគ្រូបង្រៀន ពេលក្រុមអធិការកិច្ចសង្កេតថ្នាក់រៀន ផ្អែកលើបទពិសោធន៍នៃការបង្រៀន...157

**តារាង 66៖** ឥរិយាបថគ្រូបង្រៀនពេលអធិការសង្កេតការបង្រៀន ផ្អែកលើបទពិសោធន៍នៃការបង្រៀន....160

**តារាង 67៖** ឥរិយាបថគ្រូបង្រៀនចំពោះការសម្ភាសរបស់ក្រុមអធិការកិច្ច ផ្អែកលើបទពិសោធន៍នៃការបង្រៀន163

**តារាង 68៖** ឥរិយាបថគ្រូបង្រៀនអំឡុងពេលអធិការកិច្ច ផ្អែកលើបទពិសោធន៍នៃការបង្រៀន....164

**តារាង 69៖** ឥរិយាបថគ្រូបង្រៀនចំពោះអនុសាសន៍អធិការកិច្ច ផ្អែកលើបទពិសោធន៍នៃការបង្រៀន......167

**តារាង 70៖** ឥរិយាបថគ្រូបង្រៀនចំពោះរបាយការណ៍អធិការកិច្ច ផ្អែកលើបទពិសោធន៍នៃការបង្រៀន....169

**តារាង 71៖** ឥរិយាបថគ្រូបង្រៀនក្រោយពេលអធិការកិច្ច ផ្អែកលើបទពិសោធន៍ការងារ....170

**តារាង 72៖** ឥរិយាបថគ្រូបង្រៀនចំពោះអធិការកិច្ចលើការបង្រៀន និងរៀន ផ្អែកលើបទពិសោធន៍ការងារ 172

# បញ្ជីរូបភាព

| ល.រ | បរិយាយ | ទំព័រ |
|---|---|---|


**រូបភាព 1៖** រចនាសម្ព័ន្ធអធិការកិច្ចជាប្រព័ន្ធ ........................................ 18

**រូបភាព 2៖** គោលបំណងនៃអធិការកិច្ច ........................................ 23

**រូបភាព 3៖** វិធីសាស្ត្រអធិការកិច្ច ........................................ 33

**រូបភាព 4៖** ផែនទីស្រុកគោលដៅ នៃការប្រមូលទិន្នន័យ ........................................ 47

**រូបភាព 5៖** ភាពខុសគ្នានៃឥរិយាបថគ្រូបង្រៀននៅតំបន់ជនបទ និងតំបន់ទីប្រជុំជន ........................ 147

**រូបភាព 6៖** ការប្រៀបធៀបឥរិយាបថគ្រូបង្រៀនចំពោះអធិការកិច្ច ផ្អែកលើបទពិសោធន៍ការងារ ........... 172

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១ ( លិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងការសិក្សាស្រាវជ្រាវ )

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
**លេខ** :..........**វជអ.** ៤៨

មន្ទីរអប់រំខេត្តកំពង់ធំ
ចូល
លេខ: 695
ថ្ងៃទី 17/07/20 ម៉ោង..........
បញ្ជូន..........

**គោរពជូន**
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ធំ**

**កម្មវត្ថុ៖** សម្រួលដល់ការស្រាវជ្រាវរបស់និស្សិតឈ្មោះ **នៅ ចាន់មករា** នៅតាមសាលាបឋមសិក្សានានាក្នុងខេត្តកំពង់ធំ។
**យោង៖** ផែនការបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើខ្ញុំសូមជម្រាបជូន**លោកប្រធាន**ជ្រាបថា៖ លោក **នៅ ចាន់មករា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំពុងទទួលការបណ្តុះបណ្តាល នៅវិទ្យាស្ថានជាតិអប់រំមានគម្រោងចុះស្រាវជ្រាវលើប្រធានបទស្តីពី «**ឥរិយាបទរបស់គ្រូបង្រៀនបឋមសិក្សាចំពោះការងារអធិការកិច្ចលើការបង្រៀន និងរៀន**» ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ។ លោក **នៅ ចាន់មករា** នឹងចែកកម្រងសំណួរបំពេញតាមរយៈ Google Form និងសម្ភាសន៍តាមប្រព័ន្ធ ONLINE ដល់គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ និងសិស្ស នៅសាលាបឋមសិក្សានានានៅខេត្តកំពង់ធំដែលប្រព្រឹត្តទៅចាប់**ពីថ្ងៃទី១៧ ខែកក្កដា ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០**។

អាស្រ័យហេតុនេះសូម**លោកប្រធាន**មេត្តាជួយសម្រួលដោយក្តីអនុគ្រោះ។
សូម**លោកប្រធាន**ទទួលនូវការគោរពរាប់អានដ៏ស្មោះពីខ្ញុំ

ថ្ងៃព្រហស្បតិ៍ ១១រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០
**នាយកវិទ្យាស្ថានជាតិអប់រំ**

**បណ្ឌិត.សៀង សុវណ្ណា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**វិទ្យាស្ថានជាតិអប់រំ**
លេខ : ០៩០ វជអ.

## លិខិតបង្គាប់ការ

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០

បុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំ ដូចមានរាយនាមខាងក្រោមត្រូវបានចាត់តាំងជាគ្រូដឹកនាំបង្គោល និងគ្រូដឹកនាំរងរបស់និស្សិត **នៅ ចាន់មករា** ក្នុងការសរសេរនិក្ខេបបទបញ្ចប់វគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំ៖

១-គ្រូដឹកនាំបង្គោល

លោកបណ្ឌិត អាន វ៉ូប្រាវ

២-គ្រូដឹកនាំរង

លោក លឹម វ៉ាន់

ឯកឧត្តម និងលោកដូចមានរាយនាមខាងលើត្រូវអនុវត្តភារកិច្ចតាមការចាត់តាំង ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ៨រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិនា ឆ្នាំ២០២០
**ជ.នាយកវិទ្យាស្ថានជាតិអប់រំ**
**នាយករង**

បណ្ឌិត. **នួន_រិទ្ធី**

**កន្លែងទទួល៖**
-ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ
-ឯកសារវិទ្យាស្ថានជាតិអប់រំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
**លេខ :..............ចជអ.**

# លិខិតអញ្ជើញ

សូមគោរពអញ្ជើញ ៖ **និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧**

**ដើម្បីចូលរួម** ៖ ការពារនិក្ខេបបទ

**កាលបរិច្ឆេទ** ៖ ពីថ្ងៃសៅរ៍-អាទិត្យ ៨-៩កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ០៧:៣០នាទីព្រឹកដល់១៧:៣០រសៀល (មានភ្ជាប់ជូនកម្មវិធី)។

**ទីកន្លែង** ៖ វិទ្យាស្ថានជាតិអប់រំនៅអគារ H បន្ទប់ជាន់ទី១។

ថ្ងៃពុធ ៥កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

*ព័ត៌មានបន្ថែម ៖*

- ✓ *សម្លៀកបំពាក់សម្រាប់និស្សិត៖ បុរសអាវស៊ំខ្មៅឬខៀវចាស់ និងខោខ្មៅ និងនិស្សិតនារីអាវប៉ាកស សំពត់ខ្មៅ ឬខៀវ។*
- ✓ *និស្សិតមានសិទ្ធិឡើងការពារនិក្ខេបបទបញ្ចប់ការសិក្សាលុះណាមានការឯកភាពពីលោកគ្រូដឹកនាំ និងដឹកនាំរង។*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**វិទ្យាស្ថានជាតិអប់រំ**
**លេខ......✓......វជអ**

## បណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧
## កាលបរិច្ឆេទទទួលនិក្ខេបបទស្រាវជ្រាវ

| ជំពូក | ចំណងជើង | កាលបរិច្ឆេទ | ថ្ងៃកំណត់ |
|---|---|---|---|
| ១ | សេចក្តីផ្តើម | ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២០ | ថ្ងៃអាទិត្យ |
| ២ | រំលឹកទ្រឹស្តី | ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២០ | ថ្ងៃអាទិត្យ |
| ៣ | វិធិសាស្ត្រស្រាវជ្រាវ | ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២០ | ថ្ងៃអាទិត្យ |
| ៤ | វិភាគស៊ីជម្រៅលើលទ្ធផលរបកគំហើញ និងការ ពិភាក្សា | ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២០ | ថ្ងៃអាទិត្យ |
| ៥ | សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ | ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២០ | ថ្ងៃអាទិត្យ |

កំណត់សម្គាល់:

- ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២០ ទទួលនិក្ខេបបទ នៅគណៈកម្មការប្រតិបត្តិនៃការបណ្តុះបណ្តាល ថ្នាក់ក្រោយឧត្តម នៅវិទ្យាស្ថានជាតិអប់រំ។
- ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ **បទបង្ហាញសាកល្បង**ការពារការសរសេរនិក្ខេបបទ។
- ថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ ពិធីការពារការនិក្ខេបបទរៀបចំដោយ គណៈកម្មការប្រតិបត្តិនៃការបណ្តុះបណ្តាលថ្នាក់ក្រោយឧត្តមនៅវិទ្យាស្ថានជាតិអប់រំ។

រាល់ចម្ងល់ពីការសរសេរនិក្ខេបបទស្រាវជ្រាវសូមទាក់ទងគណៈកម្មការប្រតិបត្តិនៃការបណ្តុះបណ្តាលថ្នាក់ក្រោយឧត្តម សម្រាប់កម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ផ្នែក គ្រប់គ្រងអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា។ លោក បណ្ឌិត នូវ វ៉ា នាយករង វិទ្យាស្ថានជាតិអប់រំ និងលោក ចាប រតនា អនុប្រធានដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការនៃវិទ្យាស្ថានជាតិអប់រំ ។

ថ្ងៃសុក្រ ០៤ រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមិនា ឆ្នាំ២០២០
**នាយកវិទ្យាស្ថានជាតិអប់រំ**

**បណ្ឌិត.សៀង សុវណ្ណា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
វិទ្យាស្ថានជាតិអប់រំ

## ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ ឆ្នាំសិក្សា២០១៩-២០២០
## សម័យប្រឡង៖ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២០ នៅវិទ្យាស្ថានជាតិអប់រំ

| ល.រ | គោត្តនាម-នាម | | ភេទ | ថ្ងៃខែឆ្នាំកំណើត | លទ្ធផល | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១ | ជាង | ចាន់ណាក់ | ប | ១៥ មេសា ១៩៨៧ | ជាប់ | |
| ២ | ទិព្វ | សារី | ស | ០២ មីនា ១៩៨៩ | ជាប់ | |
| ៣ | រ៉ុត | សោភ័ណ្ឌ | ប | ០៧ កុម្ភៈ ១៩៨៨ | ជាប់ | |
| ៤ | នៅ | ចាន់មករា | ប | ១១ មករា ១៩៨៨ | ជាប់ | |
| ៥ | ហង្ស | សំអុល | ប | ២៦ កុម្ភៈ ១៩៨៨ | ជាប់ | |
| ៦ | កែម | ម្លិះក្រង | ស | ០៣ មីនា ១៩៨៥ | ជាប់ | |
| ៧ | ឡាច | ភាស់ | ប | ០២ ឧសភា ១៩៨៨ | ជាប់ | |
| ៨ | គង់ | ច័ន្ទបុប្ផាពេជ្រ | ស | ២៦ មីនា ១៩៨២ | ជាប់ | |
| ៩ | ម៉េត | សិរី | ប | ១៨ មករា ១៩៨១ | ជាប់ | |
| ១០ | ទៀង | ចាន់សុភាព | ស | ០៤ មករា ១៩៨៤ | ជាប់ | |
| ១១ | នួន | គីមស្រ៊ាវ | ប | ០១ កុម្ភៈ ១៩៨៥ | ជាប់ | |
| ១២ | ទេព | គង្គា | ប | ១៤ មេសា ១៩៨៨ | ជាប់ | |
| ១៣ | ដាំ | វ៉ាន់នី | ប | ២៧ ឧសភា ១៩៨៦ | ជាប់ | |
| ១៤ | ថៃ | ណាត្រី | ប | ០៧ មេសា ១៩៨០ | ជាប់ | |
| ១៥ | ខនរិទ្ធ | ស៊ីណែត | ស | ០៦ មិថុនា១៩៨៩ | ជាប់ | |
| ១៦ | ឈន | បូរ៉ា | ស | ១០ តុលា ១៩៨២ | ជាប់ | |
| ១៧ | ចែម | ចិន្តា | ប | ១៥ មករា ១៩៨៦ | ជាប់ | |
| ១៨ | ញ៉ែម | ពៅ | ប | ០៦ មករា ១៩៨០ | ជាប់ | |
| ១៩ | សុខ | មករា | ប | ០៥ វិច្ឆិកា ១៩៨៧ | ជាប់ | |
| ២០ | នូ | សុខលៀប | ប | ២០ មករា ១៩៩០ | ជាប់ | |
| ២១ | ឡុង | ឌីណា | ប | ១២ សីហា ១៩៨៩ | ជាប់ | |
| ២២ | យឿន | វន្ថា | ស | ១៦ មេសា ១៩៨៨ | ជាប់ | |
| ២៣ | មួន | មន | ប | ១០ មេសា ១៩៨៤ | ជាប់ | |
| ២៤ | ស៊ិន | ផុន | ប | ១២ តុលា ១៩៨៦ | ជាប់ | |
| ២៥ | ហៃ | សុខអេង | ស | ០១ កុម្ភៈ ១៩៩០ | ជាប់ | |
| ២៦ | ចែម | នី | ប | ១៨ មីនា ១៩៨៨ | ជាប់ | |
| ២៧ | ទៀប | ឆវិន | ស | ២៤ កញ្ញា ១៩៨១ | ជាប់ | |
| ២៨ | ផ្លុង | គិមហួន | ស | ០៨ កុម្ភៈ ១៩៧១ | ជាប់ | |

| | | | | | | |
|---|---|---|---|---|---|---|
| ២៩ | ឌិន | ដួង | ប | ០៣ តុលា ១៩៩១ | ជាប់ | |
| ៣០ | សុន | ឌីណា | ស | ២៨ វិច្ឆិកា ១៩៨៩ | ជាប់ | |
| ៣១ | អ៊ុយ | វណ្ណៈ | ស | ១០ មិថុនា ១៩៨៦ | ជាប់ | |
| ៣២ | យិន | សម្បត្តិ | ប | ១៧ មិថុនា ១៩៨៣ | ជាប់ | |
| ៣៣ | យ៉ា | ច័ន្ទសុធា | ស | ១២ ឧសភា ១៩៨៦ | ជាប់ | |
| ៣៤ | សឿន | សុខណាង | ប | ២៨ តុលា ១៩៨៦ | ជាប់ | |
| ៣៥ | គង់ | ពេញ | ប | ០៦ មករា ១៩៨១ | ជាប់ | |
| ៣៦ | ហ៊ន់ | ហ៊ឹម | ប | ២០សីហា ១៩៩០ | ជាប់ | |
| ៣៧ | សុខ | តុលា | ប | ១២ មេសា ១៩៨៤ | ជាប់ | |
| ៣៨ | ភិន | ភ័ន់ណា | ប | ០៥ ធ្នូ ១៩៧៥ | ជាប់ | |
| ៣៩ | នី | និមល | ប | ០២ មេសា ១៩៨៤ | ជាប់ | |

បញ្ឈប់បញ្ជីត្រឹមចំនួន៖...៣៩.....នាក់ស្រី..១៣..នាក់

ជាប់ជាស្ថាពរ...៣៩..........នាក់ក្នុងនោះស្រី..១៣..នាក់

ធ្លាក់..............០០..............នាក់ក្នុងនោះស្រី..០០...នាក់

ចុះជាប់ធ្លាក់ដោយ...[illegible]...

ផ្ទៀងផ្ទាត់ដោយ.....[illegible].....

ថ្ងៃសុក្រ ១៣រោច ខែ កត្តិក ឆ្នាំជូត ទោស័កព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី..១៣..ខែ..វិច្ឆិកា....ឆ្នាំ២០២០

**ប្រធានគណ:កម្មការខោយតម្លៃ**

**បណ្ឌិត.សឿន សុវណ្ណា**

បានឃើញនិងឯកភាព

ថ្ងៃសុក្រ ១៣រោច ខែ កត្តិក ឆ្នាំជូត ទោស័កព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី..១៣...ខែ..វិច្ឆិកា.....ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**